# ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១៨

## ផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទដល់ម្ចាស់អាជីវកម្ម

http://cambodiapolice.com/ 10:33 am 1 កុម្ភៈ 2018

កំពង់ចាម ៖ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ កម្លាំងការិយា ល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដឹកនាំដោយ លោកស្រីវរសេនីយ៍ទោ ហេង ដាឡែន នាយការិយាល័យ សហការ ជាមួយកម្លាំងអធិការដ្ឋាននគរបាលក្រុងកំពង់ចាម បានចុះធ្វើបច្ចុប្បន្ន ភាពស្ថិតិ និងកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម ព្រមទាំងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើ ធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងសណ្ឋាគារ ផ្ទះសំណាក់ ចំនួន០៦ គោលដៅ មានមនុស្សចូលរួមចំនួន៩១ នាក់ (ស្រី ៤៥នាក់)៖

១-សណ្ឋាគារ ឃីហោ មនោរម្យ VIP មានមនុស្សចូលរួមចំនួន ២១នាក់ (ស្រី១១នាក់)

២-សណ្ឋាគារ ឃីហោ ម៉ារីយ៉ា មានមនុស្សចូលរួមចំនួន០២ នាក់

៣-សណ្ឋាគារ ឃីហោ LBN អាស៊ាន មានមនុស្សចូលរួមចំនួន ៤៩នាក់ (ស្រី២០នាក់)

៤-ផ្ទះសំណាក់ ឃីហោ មេគង្គ-ក្រូសស៊ីង មានមនុស្សចូលរួមចំនួន ០៩នាក់ (ស្រី០៧នាក់)

៥-ផ្ទះសំណាក់ ឃីហោ មូន វីរ៉ៃ មានមនុស្សចូលរួមចំនួន០៥ នាក់ (ស្រី០៤នាក់)

៦-ផ្ទះសំណាក់ ឃីហោ ថ្មដា មានមនុស្សចូលរួមចំនួន ០៥នាក់ (ស្រី០៣នាក់) ៕

## តំលៃសេវាកម្មប័ត្រស៊ីជម្ពូថ្មី និងច្បាប់ធ្វើការ 2ឆ្នាំរបស់ពលករខ្មែរ

http://www.prakpheaktra.com January 30, 2018

នេះជាតួយ៉ាងប័ត្រស៊ីជម្ពូថ្មី និងតំលៃសេវាកម្មវីសារការងារច្បាប់អនុញ្ញាតធ្វើការ និង workpermit ព្រមទាំងប្រកាន់សុខភាព។

1.អ្នកមានប័ត្រស៊ីជម្ពូទៅ(ត)ធ្វើថ្មី+វីសារ+ច្បាប់ការងារ+ប្រកាន់សុខភាព=6180បាត ធ្វើការបាន2ឆ្នាំ

2.អ្នកកាន់លិខិតលុងបៀនទៅធ្វើប័ត្រស៊ីជម្ពូ+វីសារ+ច្បាប់ការងារ+ប្រកាន់សុខភាព=6505បាត ធ្វើការបាន2ឆ្នាំ

3.អ្នកកាន់ប័ត្រស៊ីជម្ពូធ្វើការនេសាទ និងផ្នែកសមុទ្រទៅ(ត)ធ្វើថ្មី+វីសារ+ច្បាប់អនុញ្ញាតធ្វើការ+ប្រកាន់សុខភាព=5980បាត ធ្វើការបាន2ឆ្នាំ។

***តំលៃសេវាកម្មរបស់កូនពលករ**

1.ឪពុកម្តាយកាន់ប័ត្រស៊ីជម្ពូនេសាទតំលៃ4080បាត

2.ឪពុកម្តាយកាន់ប័ត្រស៊ីជម្ពូធម្មតាតំលៃ4280បាត

ចំពោះក្មេងអាយុក្រោម7ឆ្នាំ មិនចាំបាច់ពិនិត្យសុខភាព។

## ស្ថានទូតកម្ពុជា បានបន្តជួយពលរដ្ឋខ្មែរ១៣នាក់ទៀតហើយ ក្រោយចាញ់បោកមេខ្យល់ទៅធ្វើការខុសច្បាប់នៅប្រទេសម៉ាឡេស៊ី វៀតណាម និងចិន

http://www.freshnewsasia.com/ 2018-02-01

**(ភ្នំពេញ)៖** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រកាសថា ស្ថានទូតកម្ពុជា បានពីជួយពលរដ្ឋខ្មែរ១៣នាក់ទៀតហើយពីប្រទេសម៉ាឡេស៊ី ប្រទេសវៀតណាម និងប្រទេសចិន ក្រោយចាញ់បោកមេខ្យល់ទៅធ្វើការដោយខុសច្បាប់។ នេះបើតាមសេចក្តីជូនដំណឹង ដែលអង្គភាព Fresh News ទទួលបាននៅរសៀលថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨នេះ។

បើតាមក្រសួងការបរទេស ពលករ-ពលការិនីខ្មែរ៧នាក់ ត្រូវបានជួយសង្គ្រោះពីប្រទេសម៉ាឡេស៊ី, ពីប្រទេសវៀតណាម ៥នាក់ និងពីប្រទេសចិនម្នាក់។ ក្រសួងបញ្ជាក់ថា ពលករ-ពលការិនីមួយចំនួន ត្រូវបានបញ្ជូនមកដល់ប្រទេសកម្ពុជាហើយ ហើយមួយចំនួនទៀត នឹងបញ្ជូនមកដល់ជាបន្តបន្ទាប់។

**សូមអានខ្លឹមសារលម្អិត នៃសេចក្ដីជូនដំណឹងដែលមាននៅខាងក្រោមនេះ៖**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

## ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរចំនួន១៣នាក់

------------

**១.** ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**៧នាក់** (បុរស៥នាក់ និងនារី ២នាក់) ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង៧នាក់នោះ បានមកដល់កម្ពុជាជាបន្តបន្ទាប់ នៅថ្ងៃទី**២១** ទី**២៥** ទី**២៦** និងទី**២៨** ខែ**មករា** ឆ្នាំ**២០១៨**។

**២.** ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**វៀតណាម** បានសហការជាមួយអាជ្ញាធរវៀតណាម ជួយសង្គ្រោះស្ត្រីខ្មែរ**២នាក់** ដែលត្រូវបានមេខ្យល់បោកបញ្ឆោតបម្រុងនាំទៅរៀបការជាមួយបុរសជនជាតិចិន។ ស្ត្រីទាំង ២នាក់ មកពីខេត្តកណ្ដាល បានធ្វើដំណើរចេញពីភ្នំពេញ តាមយន្តហោះទៅដល់ទីក្រុងហាណូយ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ រួចបន្តដំណើរដោយម៉ូតូឆ្លងកាត់ទីក្រុងហាណូយ ឆ្ពោះទៅព្រំដែនឡាំងសឺនវៀតណាម-ចិន ប៉ុន្តែបានលោតចេញពីម៉ូតូ និងរត់សំដៅទៅការិយាល័យនគរបាលវៀតណាម ដើម្បីសុំកិច្ចអន្តរាគមន៍។

ស្ថានទូត បានសហការជាមួយការិយាល័យអន្តោប្រវេសន៍ទីក្រុងហាណូយ នាំស្ត្រីរងគ្រោះទាំង២នាក់ទៅស្នាក់នៅបណ្ដោះអាសន្នក្នុងមជ្ឈមណ្ឌលគាំពារសង្គម និងបានបញ្ជូនពួកគេតាមយន្តហោះ មកដល់កម្ពុជាវិញ នៅថ្ងៃ**ទី០១ ខែកុម្ភៈ ឆ្នាំ២០១៨** វេលាម៉ោង**១០:៤០** នាទីព្រឹក។

**៣.** ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ ប្រទេស**វៀតណាម** បានទទួលពលរដ្ឋខ្មែរ**៣នាក់** (បុរស ២នាក់និងនារី១នាក់) ដែលបានអនុវត្តទោសជាប់ពន្ធនាគាររយៈពេល២ឆ្នាំ (១៧ មករា ២០១៦ ដល់១៧ មករា ២០១៨) ពីបទ"រៀបចំលេងល្បែងស៊ីសង" និងបានចេញលិខិតធ្វើដំណើរជូនពួកគេត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៨ ដោយមានសាច់ញាតិរង់ចាំទទួលយកពីស្ថានអគ្គកុងស៊ុល។

**៤.** តាមការណែនាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយយោងតាមពាក្យបណ្ដឹងពីសាច់ញាតិជនរងគ្រោះ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ ប្រទេស**ចិន** បានជួយសង្គ្រោះស្ត្រីខ្មែរ**១នាក់** ដែលត្រូវបានមេខ្យល់បញ្ឆោះបញ្ឆូលនាំទៅរៀបការជាមួយបុរសជនជាតិចិនអំឡុងឆ្នាំ២០១២។ ស្ថានអគ្គកុងស៊ុល បានរកឃើញស្ត្រីរងគ្រោះនៅទីក្រុងវ៉េនស៊ូ(Wenzhou) ខេត្តជឺជាំង និងបានជូននាងមកដល់ស្ថានអគ្គកុងស៊ុល នៅថ្ងៃទី២២ ខែមករា ឆ្នាំ ២០១៨ ដោយមានកិច្ចសហការពីនគរបាលទីក្រុងសៀងហៃ។

ស្ត្រីរងគ្រោះនឹងត្រឡប់មកកម្ពុជាវិញក្នុងពេលឆាប់ៗនេះ ក្រោយទទួលបានលិខិតធ្វើដំណើរពីស្ថានអគ្គ-កុងស៊ុល និងទិដ្ឋាការពីអាជ្ញាធរចិន។

ថ្ងៃ ព្រហស្បតិ៍ ១ រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៨
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## មន្ទីរការងារថៃ ប្រកាសបើកចែកលេខរៀង នៅ(ត)ប័ត្រស៊ីជម្ពូថ្មី

http://www.prakpheaktra.com January 31, 2018

មន្ទីរការងារថៃប្រកាសបើកអោយថៅកែថៃទៅដាក់ពាក្យចុះឈ្មោះយកលេខរៀងនាំពលករទៅ(ត)ប័ត្រស៊ីជម្ពូថ្មីនៅសូន្យ OSS (OneStopService)។ នៅថ្ងៃពុធទី៣១ ខែមករា ឆ្នាំ២០១៨នេះ មន្ទីរការងារថៃនៅតាមបណ្តាខេត្តមួយចំនួនក្នុងប្រទេសថៃ ចាប់ផ្តើមចេញសេចក្តីប្រកាសជូនដំណឹងដល់ថៅកែថៃ អោយទៅដាក់ពាក្យចុះឈ្មោះដើម្បីយកលេខរៀងនាំពលករទៅ(ត)ប័ត្រស៊ីជម្ពូនិងធ្វើឯកសារផ្សេងៗនៅក្នុងសូន្យOSS (OneStopService) នៅក្នុងខេត្តដែលពលករធ្វើការរស់នៅ ដូច្នេះហើយសូមបងប្អូនពលករខ្មែរទាំងអស់ មេត្តាផ្តល់ដំណឹងជូនដល់ថៅកែរបស់ខ្លួនដើម្បីទៅទំនាក់ទំនងមន្ទីរការងារថៃ នៅក្នុងខេត្តក្រុងដើម្បីដាក់ពាក្យសុំលេខរៀងនៅ(ត)ប័ត្រស៊ីជម្ពូអោយបានទាន់ពេលវេលា។

## លោកសង្ឃមុខលុយ ចាក់ចង្ហាន់ចោល ទុកតែបច្ច័យ ត្រូវបានអាជ្ញាធរថៃចាប់ខ្លួន

http://www.prakpheaktra.com January 30, 2018

ព្រះសង្ឃខ្មែរមួយអង្គត្រូវសមត្ថកិច្ចកម្លាំងអាជ្ញាធរខេត្តរ៉ាក់យ៉ងប្រទេសថៃឃាត់ខ្លួនបន្ទាប់ពីយកចង្ហាន់ប្រជាពលរដ្ឋថៃប្រគេនទៅបោះចោលក្នុងធុងសំរាម យកតែលុយសុទ្ធ។ កាលពីព្រឹកថ្ងៃច័ន្ទទី៣០ ខែមករា ឆ្នាំ២០១៨ កម្លាំងអាជ្ញាធរខេត្តរ៉ាក់យ៉ងប្រទេសថៃបានឃាត់ខ្លួនព្រះសង្ឃកម្ពុជា០១អង្គ ឈ្មោះ សំ សារុធ នៅត្រង់ចំណុច ឃុំក្រសែរប៉ិន ខេត្តរ៉ាក់យ៉ង ប្រទេសថៃ។ យោងតាមរបាយការណ៍ពីកន្លែងកើតហេតុបានឲ្យដឹងថា ព្រះសង្ឃខាងលើបានដើរបិណ្ឌបាតចង្ហាន់ពីប្រជាពលរដ្ឋថៃនៅក្នុងភូមិឃុំកើតហេតុ ហើយបន្ទាប់មកព្រះសង្ឃរូបនោះបានយកចង្ហាន់ដែលប្រជាពលរដ្ឋថៃប្រគេនយកទៅបោះចោលនៅក្នុងធុងសំរាម ទុកតែលុយសុទ្ធ រួចត្រូវប្រជាពលរដ្ឋថៃមកទាន់រាយការណ៍ជូនសមត្ថកិច្ចថៃអោយធ្វើការចាប់ខ្លួនយកទៅសឹកដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ចាប់ខ្លួនជនសង្ស័យ៦០នាក់ ពាក់ព័ន្ធនឹងអំពើជួញដូរស្ត្រីជនជាតិវៀតណាម នៅភាគពាយព្យប្រទេសចិន

https://www.dap-news.com/kh/ ព្រហស្បតិ៍, 01 កុម្ភៈ ២០១៨ 07:44 ប្រែសម្រួល: ម៉ៅ បុប្ផាមករា ID:102

**គុនមីង៖** ទីភ្នាក់ងារព័ត៌មានចិនស៊ិនហួ បានចុះផ្សាយនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ថា ក្រុមអាជ្ញាធរនៅខេត្ត យូណាន បានប្រកាសឲ្យដឹងនៅថ្ងៃពុធនេះថា ប៉ូលិសនៅស្ថានីយរថភ្លើង នៅភាគពាយព្យប្រទេសចិន បានធ្វើការឃាត់ខ្លួនក្រុមជួញដូរ មនុស្សដែលឆ្លងកាត់ព្រំដែន និងបានជួយសង្គ្រោះស្ត្រីវៀតណាមបានចំនួន១៧នាក់ ។ សរុបជនសង្ស័យមានចំនួន៦០នាក់ត្រូវបានចាប់ខ្លួន ។ ប៉ូលិសនៅឯស្ថានីយរថភ្លើង នៅខេត្ត យូណាន បានបញ្ជាក់អំពីអត្តសញ្ញាណបុរសម្នាក់ និងស្ត្រីម្នាក់ដែលកាន់សំបុត្រជាច្រើន ដោយមិនត្រឹមត្រូវនឹងលេខសម្គាល់នៅក្នុងអត្តសញ្ញាណបណ្ណ នៅក្នុងខែកុម្ភៈកាលពីឆ្នាំមុន ។ បុរសនោះបានឆ្លើយសារភាពថា គាត់បាននាំក្រុមស្ត្រីវៀតណាមទាំងនោះចូលមកក្នុងក្រុង Hekou ក្នុងខេត្ត យូណាន ការស៊ើបអង្កេតនៅក្នុងករណីនេះនៅតែបន្តនៅឡើយ ៕

# ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៨

## អនុវត្តដីការឃាត់ខ្លួនស្ត្រីម្នាក់ពីបទលក់ដូរមនុស្សទៅប្រទេសចិន

http://cambodiapolice.com/ 9:46 am 2 កុម្ភៈ 2018

បាត់ដំបង៖ នៅថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១២៖០៤នាទី នៅភូមិម៉ាណោក ឃុំតាលាស ស្រុកមោងឫស្សី កម្លាំងនគរបាលខេត្តបានអនុវត្ត

តាមបញ្ជារបស់លោក នួន.សាន ព្រះរាជអាជ្ញាអមសាលាដំបូង ឃាត់ខ្លួនជនសង្ស័យ ១នាក់ឈ្មោះ នឿម.សុភាព ភេទស្រី អាយុ ២៩ឆ្នាំរស់នៅភូមិ.ឃុំខាងលើ ពីបទលក់ដូរមនុស្សដោយមានគោលដៅ (ទៅប្រទេសចិន) ជនរងគ្រោះឈ្មោះ សូ.ពេជ្រ ភេទស្រី អាយុ ២៦ឆ្នាំ រស់នៅភូមិ.ឃុំជាមួយគ្នា។ ករណីនេះ ជនសង្ស័យត្រូវបានសមត្ថកិច្ចជំនាញកសាងសំណុំរឿង បញ្ជូនទៅសាលាដំបូងខេត្ត ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់៕

## លោក អូស្មាន ហាស្សាន់ ស្នើឲ្យដៃគូម៉ាឡេស៊ីបន្តផ្តល់កិច្ច សហការល្អ ដល់ពលករកម្ពុជា ដែលកំពុងធ្វើការងារ នៅម៉ាស៊ី

http://nokorwatnews.com/ ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៨

ភ្នំពេញ៖ លោកអូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយក រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានអង្គការមូលនិធិអភិវឌ្ឍន៍មុស្លិមកម្ពុជា បានទទួលជួប ពិភាក្សាការងារជាមួយ គណៈប្រតិភូ សហករណ៍ជាតិម៉ាឡេស៊ី (ANGKASA) ដឹកនាំដោយ លោក Dato' Abdul Fattah Abdullah ប្រធានសហករណ៍ជាតិម៉ាឡេស៊ី និងជាប្រធានសហករណ៍អាស៊ានក្នុងគោលបំណង ដើម្បីសិក្សាផ្លាស់ប្តូរបទពិសោធន៍ការងារពាណិជ្ជកម្ម វិនិយោគ ទីផ្សារការងារពលករកម្ពុជា និងការងារ សហគមន៍ឥស្លាមកម្ពុជា។ ទន្ទឹមនឹងនេះ លោកអូស្មាន ហាស្សា ន់ ក៏បានស្នើឲ្យដៃគូរ ម៉ាឡេស៊ីបន្តផ្តល់កិច្ចសហការល្អ ដល់ពលករកម្ពុជា ដែលកំពុងធ្វើការងារនៅម៉ាស៊ីផងដែរ ។ ជំនួបនេះ បានប្រព្រឹត្ត ទៅកាលពីរសៀលថ្ងៃព្រហស្បត៏១រោច ខែមាឃ ឆ្នាំរកានព្វស័កព.ស២៥៦១ ត្រូវនិងថ្ងៃទី០១ កុម្ភៈ ឆ្នាំ២០១៨ នៅស្នាក់ការអង្គការមូលនិធិអភិវឌ្ឍន៏មុស្លិមកម្ពុជា ។

លោក អូស្មាន ហាស្សាន់ បានបញ្ជាក់ថា៖ ដោយមានការសហប្រតិបត្តិការយ៉ាងល្អរវាងរាជរដ្ឋាភិបាលកម្ពុជា និង ម៉ាឡេស៊ី ក្រោមការដឹកនាំប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាក្នុងការដឹកនាំប្រទេស ដែលធ្វើឲ្យមានសុខសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស ធ្វើឲ្យគ្រប់សាសនា នៅកម្ពុជាគ្មានទំនាស់ និង រីសអើងនឹងគ្នា ជាពិសេសក្រោមឆត្រ័គណបក្សប្រជាជនកម្ពុជា ក្រោយទទួលបានជ័យជម្នះ ក្នុងការបោះឆ្នោតជាតិ កន្លងមក បានតែងតាំងមុខតំណែងជូន ដល់ថ្នាក់ដឹកនាំឥស្លាមដែលមានចំនួន៧០០ពាន់នាក់ ស្មើនឹង៤ភាគរយ នៃចំនួនប្រជាជន១៥លាន នាក់ មានតំណែងជារដ្ឋមន្ត្រី ២ រូប (លោក អូស្មាន ហាស្សាន់ និងលោកហ្សាការីយ៉ា អាដាម ជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ជាសមាជិកព្រឹទ្ធស ភា ជាសមាជិករដ្ឋសភា ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មន្ត្រីនានា នៅតាមបណ្តាក្រសួងស្ថាប័នខេត្តក្រុង ស្រុកខ័ណ្ឌនានាទូទាំងប្រទេស) ដែលជាការបង្ហាញពីការជឿ ទុកចិត្តដល់សហគមន៍ឥស្លាម ក្នុងការចូលរួមអភិវឌ្ឍន៍ សហគមន៍ និងប្រទេសជាតិពី សម្តេចតេជោ នាយករដ្ឋមន្ត្រី ជាពិសេសបង្កើតឲ្យមានស្ថាប័នគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជាដែលមាន លោក សុះ កំរី ជា ចាងហ្វាង ធ្វើឲ្យប្រមុខថ្នាក់ដឹកនាំ នាបណ្តាប្រទេសឥស្លាមនៅទូទាំងពិភពលោក ជាពិសេសរាជរដ្ឋាភិបាល និង ប្រជាជនម៉ាឡេស៊ី មានការអបអរសាទរ កោតសរសើរគោរពស្រលាញ់ពេញចិត្តចំពោះការដឹកនាំរបស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី ។

លោក Dato' Abdul Fattah Abdullah ប្រធានសហករណ៍ជាតិម៉ាឡេស៊ី បានបញ្ជាក់ថា៖ ម៉ាឡេស៊ី ជាប្រទេសមួយស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានផ្ទៃដី ៣៣០,៤៣៦ ម៉ែត្រការេ ប្រជាជន ៣០ លាននាក់ មានរដ្ឋចំនួន ១៤ និងក្រុងធំៗចំនួន៣ ក្នុងនោះ ក្រុងកូឡាលំពួរ ជាទីក្រុងពាណិជ្ជកម្ម និង ក្រុងពុត្រាចាយ៉ា ជាទីក្រុងមណ្ឌលរដ្ឋបាលនៃរាជរដ្ឋាភិបាល។ ម៉ាឡេស៊ី ជាប់លំដាប់ទី៤ ក្នុងការដាក់ទុនវិនិយោគនៅកម្ពុជា បន្ទាប់ពី ចិន កូរ៉េ ជប៉ុន សឹង្ហបុរី ។ ANGKASA ជាសហករណ៍ជាតិ ម៉ាឡេ ស៊ីដ៏ធំមួយបង្កើតឡើងឆ្នាំ១៩៦៦ មានដៃគូសហការណ៍ចំនួន ១៣,៤២៨ និងសមាជិក ៧,០៦៦,២២២ លាននាក់ នឹងដើមទុន ១៣០, ៧៤០, ៦៨ លានរីង្គិតម៉ាឡេស៊ី ដែល បានចូលរួមគ្នាមកពីគ្រប់មជ្ឈដ្ឋាន ការងាររកស៊ីនៅម៉ាឡេស៊ី ៕ សំរិត

# សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ស្នើឱ្យភាគីថៃជួយគាំពារពលករខ្មែរដែលកំពុងធ្វើការស្នាក់នៅក្នុងប្រទេសថៃ

http://www.akp.gov.kh/kh/ AKP ភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨

នៅក្នុងជំនួបពិភាក្សាការងារជាមួយឯកឧត្តមសាស្ត្រាចារ្យ ផនពេជ្រ វិចិតធុលឆ័យ (Pornpetch Wichit cholchai) ប្រធានសភានីតិប្បញ្ញត្តិថៃ សម្ដេចអគ្គមហាពញាចក្រីហេង សំរិនប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានស្នើឱ្យភាគីថៃជួយគាំពារពលករខ្មែរដែលកំពុងធ្វើការស្នាក់នៅក្នុងប្រទេសថៃ។

សម្ដេចបានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលថៃ ក៏ដូចជាអាជ្ញាធរ មានសមត្ថកិច្ចពាក់ព័ន្ធរបស់ថៃ ដែលបានបង្កលក្ខណៈងាយស្រួល ទាំងលក្ខខណ្ឌការងារ ក៏ដូចជាកិច្ចការពារចំពោះពលករកម្ពុជា ដែលកំពុងធ្វើការស្នាក់នៅក្នុងប្រទេសថៃ។ នេះគឺជាយុទ្ធសាស្ត្រឈ្នះឈ្នះទាំងអស់គ្នា ផ្ដល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ព្រោះថាប្រទេសថៃត្រូវការកម្លាំងពលកម្ម ហើយពលករកម្ពុជាក៏ត្រូវការប្រាក់ចំណូល ដើម្បីរួមចំណែកអភិវឌ្ឍន៍ទាំងអស់គ្នា។ សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជាទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅព្រះរាជាណាចក្រថៃ រយៈពេលបីថ្ងៃ ពីថ្ងៃទី០១ ដល់ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨ តបតាមការអញ្ជើញរបស់ឯកឧត្តមសាស្ត្រាចារ្យ ផនពេជ្រ វិចិត ធុលឆ័យ (Pornpetch Wichit cholchai) ប្រធាន សភានីតិប្បញ្ញត្តិថៃ។ ដំណើរទស្សនកិច្ចនេះក្នុងគោលបំណង លើកកម្ពស់ទំនាក់ទំនង ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសនិងប្រជាជាតិទាំងពីរ កម្ពុជា-ថៃ ឱ្យកាន់តែរឹងមាំទ្វេឡើងថែមទៀត ជាពិសេសពង្រីកកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននីតិប្បញ្ញតិយើងទាំងពីរឱ្យកាន់តែជិតស្និទ្ធ និងស៊ីជម្រៅបន្ថែមទៀត។

ក្នុងជំនួបដែលបានធ្វើឡើងនៅវិមានរដ្ឋសភាថៃ ឯកឧត្តមសាស្ត្រាចារ្យ ផនពេជ្រ វិចិតធុលឆ័យ បានស្វាគមន៍យ៉ាងកក់ក្ដៅចំពោះដំណើរទស្សនកិច្ចរបស់សម្ដេចប្រធានរដ្ឋសភា និងគណៈប្រតិភូកម្ពុជា។ ឯកឧត្តមបានលើកឡើងថាកាលពី៨ឆ្នាំមុន សម្ដេចធ្លាប់បានអញ្ជើញមកទស្សនកិច្ចនៅប្រទេសថៃម្ដង ហើយពេលនេះឯកឧត្តមមានកិត្តិយសយ៉ាងក្រៃលែង ដែលបានជួបពិភាក្សាផ្ទាល់ជាមួយសម្ដេច ដើម្បីពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំឡើងរវាងប្រទេសទាំងពីរ ពិសេសស្ថាប័ននីតិប្បញ្ញត្តិ។ ឯកឧត្តមសាស្ត្រា ផនពេជ្រ វិចិតធុលឆ័យ បានបន្តថា ឯកឧត្តមធ្លាប់បានដឹកនាំ គណៈ ប្រតិភូសភាថៃ មកចូលរួមប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី១ នៃមហាសន្និបាតលើកទី១០ របស់សភាតំបន់អាស៊ី (APA) ដែលសភាកម្ពុជាធ្វើជាម្ចាស់ផ្ទះ កាលពីឆ្នាំ២០១៧។ និយាយជារួមសភាប្រទេសកម្ពុជា និងសភាប្រទេសថៃបានរួមសហការជាមួយគ្នាយ៉ាងច្រើននាពេលកន្លងមក ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និង ពហុភាគី ។

សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន បានលើកឡើងថា កម្ពុជា-ថៃ ជាប្រទេសភូមិផងរបងជាមួយ ហើយប្រជាជនប្រទេសទាំងពីរ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នាតាំងពីយូរណាស់មកហើយ មានប្រពៃណី សិល្បៈវប្បធម៌ស្រដៀងគ្នា ដែលអាចនិយាយបានថា ជាប្រទេសបងប្អូនជាមួយគ្នា។ "ខ្ញុំពិតជាមោទនភាពបំផុត ដោយសង្កេតឃើញពីវឌ្ឍនភាពនៃទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃប្រទេសយើងទាំងពីរ កម្ពុជា-ថៃ មានការរីកចម្រើនជាលំដាប់លើគ្រប់វិស័យ គ្រប់កម្រិត ក្នុងស្មារតីភាតរភាពស្និទ្ធស្នាលក្នុងភាពជាដៃគូ ហើយកិច្ចសហប្រតិបត្តិការនេះបានគ្របដណ្ដប់លើគ្រប់វិស័យ ដែលបានផ្ដល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ដើម្បីឧត្តមភាពទាំងសងខាង" ។

ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការស្ថាប័ននីតិប្បញ្ញត្តិ នៃប្រទេសទាំងពីរវិញ សម្ដេចអគ្គមហាពញាចក្រី បានលើកឡើងថាសភាប្រទេសទាំងពីរគួរបង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្នាឱ្យកាន់តែល្អប្រសើរថែមទៀត។ កិច្ចសហប្រតិបត្តិការនេះគួរតែធ្វើនៅគ្រប់កម្រិត រួមមានថ្នាក់ដឹកនាំជាន់ខ្ពស់ ក្រុមមិត្តភាពសភាទាំងពីរ គណៈកម្មការ

ជំនាញរបស់រដ្ឋសភា រហូតដល់អគ្គលេខាធិការដ្ឋានរដ្ឋសភា។ សម្តេចបន្តថា អគ្គលេខាធិការរដ្ឋសភាកម្ពុជានិងថៃ គួរពិនិត្យកែលម្អចំណុចខ្វះខាត នៃអនុស្សរណៈកិច្ចព្រមព្រៀង ដែលមានស្រាប់ សំដៅធ្វើឱ្យកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរ។

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ក៏បានជម្រាបជូនភាគីថៃអំពីស្ថានការណ៍នយោបាយ នៅក្នុងប្រទេសកម្ពុជាដោយ សម្តេចបានគូសបញ្ជាក់ថា សភាពការណ៍នយោបាយនៅកម្ពុជាបច្ចុប្បន្ន មានលក្ខណៈកាន់តែល្អប្រសើរ បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានទប់ស្កាត់ទាន់ពេលវេលា នូវឧបាយកលប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ តាមរយៈការបំផុសធ្វើបដិវត្តន៍ពណ៌របស់គណបក្សប្រឆាំង ដោយមានការជួយជ្រោមជ្រែងពីខាងក្រៅប្រទេស។ កន្លងមកគណបក្សនេះតែងតែបំពាន ញុះញង់ បង្កឱ្យមានអស្ថិរភាព អសន្តិសុខ រំលោភបំពានច្បាប់ រដ្ឋធម្មនុញ្ញ ដែលបង្ខំឱ្យតុលាការកំពូលចាត់ការតាមនីតិវិធីច្បាប់ រំលាយគណបក្សនេះ និងហាមឃាត់សិទ្ធិធ្វើនយោបាយរយៈ ពេល ៥ឆ្នាំ៕ ដោយ ប៉ាល់ សុង

## នាយករដ្ឋមន្ត្រីថៃ ជំរុញឲ្យរដ្ឋសភា កម្ពុជា-ថៃ មានកិច្ច សហប្រតិបត្តិការល្អ

https://www.dap-news.com/kh/ សុក្រ, 02 កុម្ភៈ ២០១៨ 11:42 ដោយ: ស សំណាង ID:012

ភ្នំពេញ ៖នៅថ្ងៃទី២ នៃដំណើរទស្សនកិច្ចជាផ្លូវការ និងមិត្តភាព នៅប្រទេសថៃ ដែលត្រូវនឹង ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៨នេះ គណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជា ដឹកនាំដោយ សម្តេច ហេង សំរិន ប្រធានរដ្ឋសភា បានចូលជួបសម្តែងការគួរសមជាមួយ លោក ប្រាយុទ្ធ ច័ន្ទអូចា នាយក រដ្ឋមន្ត្រីថៃ ក្នុងនោះលោកជំរុញស្ថាប័ននីតិប្បញ្ញត្តិទាំងពីរប្រទេស ត្រូវខិតខំថែរក្សា និង ជំរុញទំនាក់ទំនងនេះឲ្យកាន់តែល្អ រឹងមាំបន្ថែមទៀត។ លោក ប្រាយុទ្ធ ច័ន្ទអូចា បានមានប្រសាសន៍បន្តថា ទំនាក់ទំនងប្រទេសថៃ និងកម្ពុជា នាពេលបច្ចុប្បន្នមានការរីកចម្រើនខ្លាំងដែលមិនធ្លាប់មានពីមុនមក។

នាយករដ្ឋមន្ត្រីថៃបានអះអាងថា លោកនឹងខិតខំថែរក្សាពលករខ្មែរដែលកំពុងធ្វើការនៅក្នុងប្រទេសខ្លួនហើយ នៅខែមិថុនា ឆ្នាំ២០១៨នេះ ពលករខ្មែរនឹងអាចទទួលបាននូវឯកសារស្របច្បាប់។ លោកនាយករដ្ឋមន្ត្រីក៏បានលើកឡើងថា ទំនាក់ទំនងរវាងប្រជាពលរដ្ឋទាំងពីរប្រទេស នឹងកាន់តែមានលក្ខណៈងាយស្រួលបន្ថែមទៀត នាពេលខាងមុខនេះ ដោយសារតែការតភ្ជាប់ផ្លូវរថភ្លើងកម្ពុជា-ថៃ។

សម្តេច ហេង សំរិន បានថ្លែងអំណរគុណចំពោះនាយករដ្ឋមន្ត្រីថៃ ដែលបានវាយតម្លៃខ្ពស់ អំពីវឌ្ឍនភាព នៃទំនាក់ទំនងរវាងប្រទេសទាំងពីរ។ សម្តេចប្រធានរដ្ឋសភា បានសម្តែងពេញចិត្តដោយសង្កេតឃើញថា ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ មានការរីកចម្រើនខ្លាំងទាំងវិស័យនយោបាយ ការទូត សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ វប្បធម៌ ទេសចរណ៍ រួមទាំងវិស័យផ្សេងៗទៀត៕

## ក្រឡាប់រថយន្តលើទឹកដីថៃ មានពលករខ្មែរស្លាប់របួសជាច្រើននាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៨ម៉ោង ១០:៥៥ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ តាមសេចក្តីរាយការណ៍បឋមបានឲ្យដឹងថា មានករណីក្រឡាប់រថយន្តលើទឹកដីថៃ ដែលមានពលករខ្មែរស្លាប់របួសជាច្រើននាក់ នៅវេលាម៉ោង៥ទាបភ្លឺព្រឹកថ្ងៃទី០២ ខែកុម្ភៈនេះ ក្នុងស្រុកអារញ្ញខេត្តស្រះកែវ ប្រទេសថៃ ។ ជនរងគ្រោះទាំងនោះមានអ្នកស្លាប់ម្នាក់ ឈ្មោះ ជៀម សុខ ភេទប្រុស និងម្នាក់ទៀតឈ្មោះ សុខ វ៉ាន់លី ភេទស្រី ហើយមានអ្នករបួសធ្ងន់៣នាក់ទី១-ឈ្មោះ វ៉ាន់ លុក ភេទប្រុស ទី២-ឈ្មោះ ណាង លី ភេទស្រី ទី៣- ឈ្មោះ អ សារិន ភេទស្រី និងមានអ្នករបួសស្រាល១០នាក់ផ្សេងទៀត សរុប១៥នាក់ ។ តាមសេចក្តីរាយការណ៍បន្តថា ពលករទាំងនោះមិនមែនជាពលករស្របច្បាប់ទេ គឺពលករលួចលាក់ ហើយអ្នកស្លាប់ និងអ្នករបួសស្រាលពេល

នេះស្ថិតក្នុងមន្ទីរពេទ្យស្រុកអារញ្ញ ឯអ្នករបួសធ្ងន់ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យក្នុងខេត្តស្រះកែវហើយ ។ ប្រភពថា ពលករទាំងនោះទើបចេញពីកម្ពុជាក្នុងស្រុកអូរជ្រៅខេត្តបន្ទាយមានជ័យ ៕

## ពលករខ្មែរ០២នាក់ ត្រូវកម្លាំងអាជ្ញាធរថៃចាប់ខ្លួនបន្ទាប់ពីជាប់ពាក់ព័ន្ធក្នុងករណីអំពើឃាតកម្មរំលោភ សម្លាប់ស្ត្រីជនជាតិឡាវម្នាក់

http://www.prakpheaktra.com February 1, 2018

នៅព្រឹកថ្ងៃព្រហស្បតិ៍ទី០១ ខែកុម្ភៈ ឆ្នាំ២០១៨ នេះកម្លាំងអាជ្ញាធរតម្រួតខេត្តរ៉ាក់យ៉ង ប្រទេសថៃ បានធ្វើការឃាត់ខ្លួនពលករខ្មែរចំនួន ០២នាក់ សង្ស័យជាប់ពាក់ព័ន្ធក្នុងករណីរំលោភសេពសន្ថវៈហើយសម្លាប់ស្ត្រីជនជាតិឡាវម្នាក់កាលពីថ្ងៃទី២៩ ខែ មករា ឆ្នាំ២០១៨កន្លងទៅ ស្ថិតនៅក្នុងភូមិ១ សង្កាត់ណាមដក ស្រុកមឿង ខេត្តរ៉ាក់យ៉ង ។ ពលករខ្មែរទាំងពីរនាក់ត្រូវបានអាជ្ញាធរថៃចាប់ខ្លួននោះ 1.មានឈ្មោះ ភក្តិ អាយុ ២៧ឆ្នាំ ទី2.មានឈ្មោះ ឡេង អាយុ ២៤ ឆ្នាំ ជនសង្ស័យទាំងពីរនាក់ធ្វើការសំណង់នៅភូមិឃុំកើតហេតុ។

យោងតាមរបាយការណ៍របស់សមត្ថកិច្ចថៃបានឲ្យដឹងថា នៅថ្ងៃកើតហេតុស្ត្រីជនជាតិឡាវ ឈ្មោះ វី សិង អាយុ៣៦ ឆ្នាំបានបាត់ខ្លួន កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨កន្លងទៅ ក្រោយមកត្រូវបានគេប្រទះឃើញសាកសពហើមនៅក្នុងស្រះទឹកមួយកន្លែង ស្ថិតនៅក្បែរកន្លែងកសាងរបស់ពលករខ្មែរទាំងពីរនាក់ធ្វើការ។ តាមឆ្លើយបំភ្លឺរបស់ពលករខ្មែរម្នាក់ឈ្មោះ រ៉ុង អាយុ៣០ឆ្នាំ បានប្រាប់អោយដឹងថា នៅថ្ងៃកើតហេតុរូបគាត់បានអង្គុយផឹកសុរាជាមួយពលករខ្មែរម្នាក់ឈ្មោះ រាំង និងឈ្មោះ ភក្តិ ហើយមានស្ត្រីជនជាតិឡាវ កំពុងឈររើសថង់នៅក្បែរស្រះទឹក ខណៈពេលនោះបុរសឈ្មោះ ភក្តិ បានដើរទៅនិយាយលេងជាមួយស្ត្រីជនជាតិឡាវខាងលើ ហើយក្រោយមកត្រូវបានគេប្រទះឃើញសាកសពស្ត្រីរងគ្រោះស្លាប់អណ្តែតទឹកនៅក្នុងស្រះទឹកតែម្តង។

តាមការបញ្ជាក់របស់សមត្ថកិច្ចថៃបានប្រាប់ថា បច្ចុប្បន្នពលករខ្មែរទាំងពីរនាក់បានបដិសេធថា មិនបានសម្លាប់ស្ត្រីជនជាតិឡាវខាងលើឡើយ ក៏ប៉ុន្តែសមត្ថកិច្ចថៃបានរកឃើញភស្តុតាងមួយចំនួនរបស់ស្ត្រីរងគ្រោះនៅក្នុងបន្ទប់ស្នាក់នៅរបស់ពលករខ្មែរទាំងពីរនាក់ យ៉ាងណាមិញសមត្ថកិច្ចថៃបានជឿជាក់ថា ពលករខ្មែរទាំងពីរនាក់ជាប់ពាក់ព័ន្ធនឹងករណីឃាតកម្មរំលោភសម្លាប់ស្ត្រីជនជាតិឡាវខាងលើនេះ បច្ចុប្បន្នកម្លាំងសមត្ថកិច្ចថៃកំពុងស្វែងរកភស្តុតាងបន្ថែមដើម្បីចាត់វិធានការលើរឿងនេះ។

## មានប៉ាស្ព័រដើរលេង ចង់ធ្វើវីសាធ្វើការ០២ឆ្នាំនៅក្នុងប្រទេសថៃ (ចុចអាន)

http://www.prakpheaktra.com February 1, 2018

ចំពោះបងប្អូនពលករខ្មែរដែលកំពុងកាន់ប៉ាស្ព័រដើរលេង ហើយវីសារ២ខែហើយកំពុងធ្វើការខុសច្បាប់ សូមប្រញាប់អោយថៅកែថៃរបស់ខ្លួនទៅទំនាក់ទំនងមន្ទីរការងារថៃ (ក្រុមការចាត់អាន) ខេត្ត-ក្រុង ដើម្បីសុំកូតាចូលពលករមកធ្វើការតាមរយៈប្រព័ន្ធMOU។ បន្ទាប់ពីថៅកែរបស់បងប្អូនទទួលបានបៃកូតានាំចូលពលករតាមMOUនោះ ជំហានបន្តទៀតគឺតំរូវអោយថៅកែរបស់ពលករទំនាក់ទំនងទៅក្រុមហ៊ុនដែលទទួលរត់ការឯសារពលករ MOU បន្ទាប់មកទៀតក្រុមហ៊ុននឹងរត់ការឯកសាររបស់បងប្អូនទៅក្រសួងការងារនៅប្រទេសរបស់យើង ដោយមានរយៈពេលប្រមាណជាង45ថ្ងៃ ទើបឯកសារនោះវិលត្រឡប់ដល់ជាយដែនខ្មែរ-ថៃ នៅពេលនោះបងប្អូនត្រូវវិលត្រឡប់ចុះទៅធ្វើឯកសារ និងវីសាការងារច្បាប់ធ្វើការងារនៅគោលដៅដែលក្រុមហ៊ុនបានណាត់ជួប រួចចូលមកវិញតាមរយៈវីសាការងារ MOU ជាមួយនឹងកិច្ចសន្យាធ្វើការចំនួន០២ឆ្នាំដែលបានកំណត់។

*រីឯតំលៃសេវាកម្មវិញចំពោះអ្នកមានលិខិតឆ្លងដែនស្រាប់គឺតំលៃមានចាប់ពី 14000฿-16000฿ អាស្រ័យទៅលើក្រុមហ៊ុននីមួយៗដែលគេបានកំណត់។ ចំពោះពលករដែលគ្មានអ្វីទាំងអស់ រីឯតំលៃសេវាកម្មវិញហាក់បីជាខ្ពស់បន្តិចហើយ ដោយមានចាប់ពី 18000฿-25000฿ អាស្រ័យទៅលើក្រុមហ៊ុនជាអ្នកកំណត់។ ដូច្នេះហើយបើសិនជា

ពេលនេះបងកំពុងកាន់លិខិតឆ្លងដែនទេសចរណ៍ និងវីសាដើរលេងធ្វើការនៅក្នុងប្រទេសថៃ សូមបងប្អូនប្រញាប់ រួសរាន់អោយថៅកែរបស់បងប្អូនទៅទំនាក់ទំនងជាមួយមន្ទីរការងារថៃជាបន្ទាន់ ដើម្បីរៀបចំធ្វើឯកសារស្របច្បាប់ អោយបានត្រឹមត្រូវអោយបានលឿន និងឆាប់បំផុត ដើម្បីជៀសវាងនូវពេលសមត្ថកិច្ចថៃចុះត្រួតពិនិត្យឯកសារធ្វើការ បងប្អូននិងថៅកែអាចត្រូវមានទោសពីបទលួចធ្វើការដោយគ្មានច្បាប់អនុញ្ញាត។

បញ្ជាក់អំឡុងពេលដែលក្រុមហ៊ុនកំពុងដើររឿងធ្វើឯកសារ និងច្បាប់ការងារ MOU ពលករខ្លួនឯងត្រូវមានការ ប្រុងប្រយ័ត្ននៅក្នុងពេលបំពេញការងារ ព្រោះមិនទាន់ក្លាយជាពលករស្របច្បាប់ពេញសិទ្ធនៅឡើយទេ ដូច្នេះត្រូវរក្សា ខ្លួនប្រាណខ្លួនឯងអោយបានល្អ ដើម្បីទៅទទួលវីសារ និងច្បាប់ការងារនៅឯជាយដែន។

## ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៨

## បើកវគ្គបណ្តុះបណ្តាលយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ

http://cambodiapolice.com/ 10:37 am 5 កុម្ភៈ 2018

ភ្នំពេញ ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារ អនីតិជន មានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធី ប្រតិបត្តិការ និងការប្រើប្រាស់អាវុធ ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាន នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ,លោក អេរិច មេលឡ៊ីម នាយកផ្នែកស៊ើបអង្កេត នៃអង្គការ មេត្រីអន្តរជាតិ និងលោក រ៉ូប៊ីត ស្តេតុន នាយកបណ្តុះបណ្តាលប៉ូលីសអន្តរជាតិ ប្រតិបត្តិការ យុទ្ធវិធី និងប្រឆាំងភេរ វកម្ម នៅព្រឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៨ ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានមាន ប្រសាសន៍ថា វគ្គសិក្សានេះ យើងធ្លាប់ បានសិក្សាជាច្រើនលើករួចមកហើយ ក្នុងការបំពេញចំណេះដឹង បន្ថែមដល់ នាយនគរបាលកម្ពុជា ពិសេសនាយកដ្ឋានប្រឆាំងការ ជួញដូរមនុស្ស ក៏ដូចជាអង្គការ AIMSWAT បានយកចិត្ត ទុកដាក់លើ ការងារស៊ើបអង្កេត ប្រមូលព័ត៌មានរួមគ្នា ទើបទទួលបានលទ្ធផល តែហេតុអ្វីបានជាយើងនៅតែបន្តបើក វគ្គនេះជាបន្តបន្ទាប់ ? ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន បានប្រសាសន៍ ទៀតថា ការបំពេញសមត្ថភាព ការទទួលខុសត្រូវរបៀបរបប ក្នុងការធ្វើការងារ ការប ង្ក្រាបបទល្មើសជាក់ស្តែង យើងត្រូវតែ បំពេញបន្ថែម ព្រោះថាមានតែការធ្វើផងនិងរៀនសូត្រដកពិសោធន៍ ផង ទើប យើងទទួលបាននូវលទ្ធផលល្អក្នុងកិច្ចប្រតិបត្តិការ ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានប្រសាសន៍ ទៀតថា អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បានប្តូររូបភាពចំហមក ជាការលួចលាក់ ហើយជ្រកក្រោម រូបភាពស្របច្បាប់ដូចជា ៖ ហាង ម៉ាស្សា កោសជប់ ខារ៉ាអូខេ ហាងលក់កាហ្វេ ហាងអ៊ុតសក់ ផ្ទះសំណាក់ និង សណ្ឋាគារ និងបានប្តូរពីកន្លែងទីប្រជុំជនទៅតំបន់ ជាយរាជធានី និងខេត្តកណ្តាល រួមទាំងបណ្តាខេត្តជាប់ព្រំដែន ដែលមានជីវភាពរីកចម្រើន ។ ពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធនេះ ចាប់ពី ថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨ ដោយមានសិក្ខាកាមចូលរួមចំនួន ២០ នាក់ ៕

## នាយករដ្ឋមន្ត្រីថៃអះអាងថា ប្រទេសថៃខិតខំថែរក្សាពលករខ្មែរដែលកំពុងធ្វើការនៅក្នុងប្រទេសរបស់ខ្លួន

http://www.akp.gov.kh/kh/ AKP ភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨

ឯកឧត្តម ប្រាយុទ្ធ ច័ន្ទអូ៊ចា នាយករដ្ឋមន្ត្រីថៃបានអះអាងថា ប្រទេសថៃខិតខំថែរក្សាពលករខ្មែរដែលកំពុងធ្វើ ការនៅក្នុងប្រទេសខ្លួន ហើយនៅក្នុងខែមិថុនា ឆ្នាំ២០១៨នេះ ពលករខ្មែរនឹងអាចទទួលបាននូវ ឯកសារស្របច្បាប់។

នេះបើតាមការឱ្យដឹងពីនាយកដ្ឋានព័ត៌មានរដ្ឋសភា កាលពីព្រឹកថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨នេះ នៅក្នុងជំនួបសម្តែងការគួរសម របស់គណៈប្រតិភូជាន់ខ្ពស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលដឹកនាំដោយសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ជាមួយឯកឧត្តម ប្រាយុទ្ធ ច័ន្ទអូចា នាយករដ្ឋមន្ត្រីនៃប្រទេសថៃ។ ក្នុងជំនួបសម្តែងការគួរសមនោះឯកឧត្តម ប្រាយុទ្ធ ច័ន្ទអូចា បានស្វាគមន៍យ៉ាងកក់ក្តៅ និងវាយតម្លៃខ្ពស់ ចំពោះដំណើរទស្សនកិច្ចរបស់ សម្តេចប្រធានរដ្ឋសភានៅប្រទេសថៃ។ ក្នុងនាមនាយករដ្ឋមន្ត្រីនិងរដ្ឋសភាថៃ ឯកឧត្តមសូមគាំទ្រ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការគ្នាដ៏ល្អ នៃស្ថាប័នសភាប្រទេសទាំងពីរ។ ឯកឧត្តម សូមជំរុញស្ថាប័ននីតិប្បញ្ញត្តិទាំងពីរប្រទេស ត្រូវខិតខំថែរក្សា និងជំរុញទំនាក់ទំនងនេះឱ្យកាន់តែល្អ រឹងមាំបន្ថែមទៀត។

ឯកឧត្តម ប្រាយុទ្ធ ច័ន្ទអូចា បានមានប្រសាសន៍បន្តថា ទំនាក់ទំនងប្រទេសថៃ និងកម្ពុជា នាពេលបច្ចុប្បន្ននេះ មានការរីកចម្រើនខ្លាំងណាស់ មិនធ្លាប់មានពីមុនមកទេ។ ក្នុងនាមជាថ្នាក់ដឹកនាំថៃ ឯកឧត្តមបានជួបពិភាក្សាការងារជាច្រើនលើក ជាមួយសម្តេចតេជោ ហ៊ុន សែន ពីបញ្ហាព្រំដែន បញ្ហាពាណិជ្ជកម្ម ហើយនៅក្នុងជំនួបទាំងនោះម្តងៗ មានផ្លែផ្កាជាវិជ្ជមាន។ ឯកឧត្តមនាយករដ្ឋមន្ត្រី បានអះអាងថា ប្រទេសថៃខិតខំថែរក្សាពលករខ្មែរ ដែលកំពុងធ្វើការនៅក្នុងប្រទេសខ្លួន ហើយនៅក្នុងខែមិថុនា ឆ្នាំ២០១៨នេះ ពលករខ្មែរនឹងអាចទទួលបាននូវឯកសារស្របច្បាប់។ ឯកឧត្តមនាយករដ្ឋមន្ត្រី ប្រាយុទ្ធ ច័ន្ទអូចា បានលើកឡើងថា ទំនាក់ទំនងរវាងប្រជាពលរដ្ឋទាំងពីរប្រទេស នឹងកាន់តែមានលក្ខណៈងាយស្រួលបន្ថែមទៀត នាពេលខាងមុខនេះ ដោយសារតែការតភ្ជាប់ផ្លូវរថភ្លើងកម្ពុជា-ថៃ។

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន បានថ្លែងអំណរគុណចំពោះប្រសាសន៍ដ៏មានអត្ថន័យរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី ដែលបានវាយតម្លៃខ្ពស់អំពីវឌ្ឍនភាព នៃទំនាក់ទំនងរវាងព្រះរាជាណាចក្រយើងទាំងពីរ( កម្ពុជា-ថៃ ) និងសមិទ្ធផលនានាដែលប្រសូត្រចេញពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដោយបាននាំមកនូវឧត្តមប្រយោជន៍ដល់ប្រជារាស្ត្រទាំងសងខាង។ ក្នុងនាមរដ្ឋសភាកម្ពុជា សម្តេចក៏បានវាយតម្លៃខ្ពស់ និងអបអរសាទរចំពោះសមិទ្ធផលដ៏ធំធេង ដែលរាជរដ្ឋាភិបាល និងប្រជារាស្ត្រថៃសម្រេចបាន ក្នុងការកសាងអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឆ្ពោះទៅសង្គមមួយកាន់តែមានភាពជឿនលឿន ក្រោមព្រះរាជកិច្ចដឹកនាំដ៏ថ្លៃថ្លារបស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រថៃឡង់ដ៏ និងរូបឯកឧត្តមផ្ទាល់ជានាយករដ្ឋមន្ត្រី។ សម្តេចប្រធានរដ្ឋសភា បានសម្តែងនូវក្តីរីករាយ ពេញចិត្ត ដោយសង្កេតឃើញថា ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ មានការរីកចម្រើនខ្លាំង ទាំងវិស័យនយោបាយ ការទូត សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ វប្បធម៌ ទេសចរណ៍ រួមទាំងវិស័យផ្សេងៗទៀត។ ទាំងនេះមិនត្រឹមតែបាននាំមកនូវផ្លែផ្កាសម្រាប់ប្រទេសទាំងពីរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរួមចំណែកយ៉ាងខ្លាំងក្លាដល់ការថែរក្សាសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍទាំងក្នុងតំបន់ និងសកលលោកផងដែរ។

ឆ្លៀតក្នុងឱកាសនេះ សម្តេចប្រធានរដ្ឋសភា បានពាំនាំមកនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ជូនចំពោះ ឯកឧត្តមនាយករដ្ឋមន្ត្រី និងថ្នាក់ដឹកនាំគ្រប់រូប នៃព្រះរាជាណាចក្រថៃ នាឱកាសនេះផងដែរ។

ឯកឧត្តម ប្រាយុទ្ធ ច័ន្ទអូចា ក៏បានវាយតម្លៃនិងកោតសរសើរចំពោះ ពលីកម្មរបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ដែលបានចូលរួមចំណែកក្នុងការដឹកនាំនិងកសាងប្រទេសកម្ពុជារហូតមក។ ឯកឧត្តមបានជូនពរឱ្យកម្ពុជាទទួលបានជោគជ័យនៅក្នុងដំណើរការរៀបចំការបោះឆ្នោតរដ្ឋសភានីតិកាលទី៦នាពេលខាងមុខនេះ៕ ដោយ ប៉ាល់ សុង

## ពលករខ្មែរ ៣០នាក់ ត្រូវបានអាជ្ញាធរខេត្ត ស៊ិនបុរី ចាប់ទារអោយបង់ ៩០០,០០០ បាត ជាថ្នូរនឹងការដោះលែងអោយមានសេរីភាព

http://peoplenews.asia/ ដោយ ៖ សុខ សាន្ត ថ្ងៃទី04 ខែ02 ឆ្នាំ2018 ម៉ោង 9:10 PM

តាមរយៈ បណ្តាញសង្គមហ្វេសបុក បានបញ្ជាក់ថាពលករ ចំនួន៣០នាក់ត្រូវបានអាជ្ញាធរប្រទេសថៃ ចាប់ខ្លួន ខណៈដែលកំពុធ្វើការនៅក្នុងវិស័យសំណង់ នៅខេត្តស៊ិនបុរីប្រទេសថៃ ដោយទារអោយបង់ ៩០០,០០០ បាត ជាថ្នូរនឹងការដោះលែងអោយមានសេរីភាព ។

តាមការបញ្ជាក់ពីពលករដែលត្រូវបានចាប់ខ្លួនបញ្ជាក់ថា ពួកគាត់ទាំងអស់គឺសុទ្ធតែបានបំពេញបណ្ណ័ស្នាក់នៅនិងធ្វើការស្របច្បាប់នៅក្នុងប្រទេសថៃរួចអស់ហើយនាពេលកន្លងមក។ដោយគ្មានជំរើស ក្នុងការដោះស្រាយលុយជាមួយអាជ្ញាធរប៉ូលីសនៅខេត្តស៊ិនបុរី ប្រទេសថៃ គឺកំពុងបន្តឃុំខ្លួននៅឡើយ ហើយថ្ងៃស្អែក ទី4 ខែកុម្ភៈ នេះគេនឹងបញ្ជូនទៅឃុំខ្លួននៅគុកធំហើយ។ តាមការអោយដឹងពីពលករដែលកំពុងឃុំខ្លួនបានបញ្ជាក់ថារហូតមកដល់ពេលនេះពុំមានស្ថាប័ន ឬស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃមកជួយអន្តរាគមន៍នៅឡើយទេ។ សូមអំពាវនាវដល់ស្ថានទូតខ្មែរប្រចាំនៅ ប្រទេសថៃមេត្តាជួយដោះស្រាយផងចុះ។មិនអាចសមការបំភ្លឺពីស្ថានទូតខ្មែរនៅប្រទេសថៃបានទេជុំវិញករណីនេះ ។

## ថៃបញ្ជូនសពពលករខ្មែរ២នាក់ឲ្យសមត្ថកិច្ចតាមច្រកព្រំដែនប៉ោយប៉ែត

https://www.rfa.org/khmer/news/ ដោយ ម៉ៅ សុជានី 2018-02-03

សមត្ថកិច្ចថៃ បញ្ជូនសាកសពពលករខ្មែរចំនួន ២នាក់ ត្រឡប់មកកម្ពុជា តាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី៣ ខែកុម្ភៈ។ ពលករទាំង ២នាក់នោះស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍នៅពេលពួកគេធ្វើដំណើរតាមរថយន្តនៅស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ កាលពីព្រឹកថ្ងៃទី២ ខែកុម្ភៈ។ មន្ត្រីអង្គការសង្គមស៊ីវិលប្រចាំខេត្តបន្ទាយមានជ័យ លើកឡើងថា ពលករដែលគ្រោះថ្នាក់ចរាចរណ៍នៅប្រទេសថៃ ភាគច្រើនគឺជាពលករធ្វើការខុសច្បាប់។ សមត្ថកិច្ចប្រចាំការច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត អះអាងថា ក្រោយពេលសមត្ថកិច្ចថៃ បញ្ជូនសាកសពពលករខ្មែរទាំង ២នាក់មកប្រគល់ឲ្យអាជ្ញាធរខ្មែរភ្លាម គឺអាជ្ញាធរបានប្រគល់ទៅឲ្យសាច់ញាតិភ្លាមៗ ដើម្បីយកទៅបុណ្យតាមបែបសាសនានៅឯស្រុកកំណើត។

មន្ត្រីទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ប្រចាំច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត លោក យ៉ាល់ ប៊ុនពៅ ឲ្យដឹងនៅថ្ងៃទី៣ កុម្ភៈ ថា ជនរងគ្រោះទាំង ២នាក់ រួមមានឈ្មោះ ខុម វណ្ណី ភេទស្រី អាយុ ៣៥ឆ្នាំ រស់នៅស្រុករុក្ខគិរី ខេត្តបាត់ដំបង និងម្នាក់ទៀតឈ្មោះសុខ ជាតិ ភេទប្រុស អាយុ ២២ឆ្នាំ រស់នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង។ មន្ត្រីព្រំដែនរូបនេះអះអាងទៀតថា គ្រោះថ្នាក់ចរាចរណ៍នេះក៏បណ្ដាលឲ្យពលករចំនួន ១២នាក់ របួសធ្ងន់ និងស្រាលផងដែរ៖ «បាទ! ធម្មតាគ្រោះថ្នាក់គេមិនអាចយកមកភ្លាមៗទេ សមត្ថកិច្ចគេយកទៅព្យាបាលនៅមន្ទីរពេទ្យ ហើយអ្នករបួសគេយកទៅមន្ទីរពេទ្យអារញ្ញហ្នឹងឯង ព្រោះអីវានៅកៀកនឹងមន្ទីរពេទ្យហ្នឹងផង ដូច្នេះគេដឹកអ្នករបួសអ្នកស្លាប់យកទៅមន្ទីរពេទ្យអារញ្ញទាំងអស់ហ្នឹង»។ លោកបញ្ជាក់ទៀតថា ក្នុងចំណោមអ្នករងរបួលនោះ មានកុមារម្នាក់របួសធ្ងន់ដោយបាក់ភ្លៅ ហើយអ្នករបួសមួយចំនួនធំកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ស្រុកអារញ្ញ និងមួយចំនួនទៀតបានវិលត្រឡប់មកព្យាបាលនៅកម្ពុជា។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា កត់សំគាល់ថា បញ្ហាគ្រោះថ្នាក់ចរាចរណ៍ចំពោះពលករខ្មែរតែងកើតមានជាញឹកញាប់ គឺភាគច្រើនជាពលករឆ្លងដែនដោយខុសច្បាប់ ហើយដំណើរតាមរយៈរថយន្តឈ្នួលរបស់មេខ្យល់ជួញដូរពលករខុសច្បាប់។ លោកបន្ថែមទៀតថា គ្រោះថ្នាក់ភាគច្រើនដោយសាររថយន្តបើកបរក្នុងល្បឿនលឿន ដូចជាការបើករត់គេចពីការចាប់របស់សមត្ថកិច្ចថៃ និងបើកតាមផ្លូវកាត់ជាដើម៖ «នៅឆ្នាំ២០១៧ យើងឃើញក្រឡាប់ធេះឡានស្លាប់ពលករដោយខ្លះក៏របួសទៅ ដោយសារតែពួកគេទៅធ្វើគ្មានច្បាប់ បើសិនជាគេមានច្បាប់ត្រឹមត្រូវ គឺគ្មានពលករណាមួយត្រូវភ័យព្រួយរឿងប៉ូលិសថៃ ចាប់ទេ ចំណែកទៅតាមមេខ្យល់ជានាយកទៅហ្នឹង គឺភាគច្រើនជួបគ្រោះថ្នាក់តាមផ្លូវ»។ មន្ត្រីសង្គមស៊ីវិលរូបនេះលើកឡើងទៀតថា ដើម្បីកាត់បន្ថយការស្លាប់របស់ពលករខ្មែរ គឺអាជ្ញាធរពាក់ព័ន្ធត្រូវបន្ធូរបន្ថយទៅលើការធ្វើលិខិតឆ្លងដែនជូនពលករឲ្យបានប្រសើរជាងពេលបច្ចុប្បន្ន និងឲ្យបានឆាប់ ដើម្បីពួកគេមានលទ្ធភាពទៅធ្វើការនៅប្រទេសថៃ ស្របច្បាប់ឲ្យបានគ្រប់ៗគ្នា។

មន្ត្រីទំនាក់ទំនងព្រំដែនប៉ោយប៉ែត លោក យ៉ាល់ ប៊ុនពៅ ឲ្យដឹងថា មួយរយៈចុងក្រោយនេះអាជ្ញាធរថៃ បានបញ្ជូនសាកសពពលករខ្មែរត្រឡប់មកកម្ពុជា តាមច្រកប៉ោយប៉ែត ស្ទើររៀងរាល់ខែ។ ដោយឡែកកាលឆ្នាំ២០១៧ កន្លងទៅ លោកថា អាជ្ញាធរថៃ បានបញ្ជូនសពពលករខ្មែរប្រមាណ ១៦០នាក់ ប្រគល់ឲ្យអាជ្ញាធរកម្ពុជា តាមច្រកព្រំដែននានា រវាងប្រទេសទាំងពីរ៕

## ទីតាំងធ្វើប័ត្រស៊ីជម្ពូ ជូនពលករខ្មែរ,ឡាវ,ភូមាភកចាប់ផ្តើមបើកដំណើរការហើយនៅថ្ងៃច័ន្ទនេះ

http://www.prakpheaktra.com February 4, 2018

ដើម្បីភាពងាយស្រួលដល់បងប្អូនពលករកម្ពុជាកំពុងស្នាក់នៅធ្វើការក្នុងប្រទេសថៃ ដែលមិនបានបញ្ជាក់អត្តសញ្ញាណ,ធ្វើវីសា,ពិនិត្យសុខភាព, សុំច្បាប់អនុញ្ញាតការងារ, និងសពុលភាពស្នាក់នៅបន្ត។ នៅព្រឹកថ្ងៃច័ន្ទទី05 ខែកុម្ភៈ ឆ្នាំ2018 នេះ សូន្យOSS (OneStopService) នឹងចាប់បើកដំណើរការជួយសម្រួលបញ្ហារបស់បងប្អូនពលករខ្មែរដែលដូចការរៀបរាប់ខាងលើ។

ចំពោះបងប្អូនពលករខ្មែរដែលអាចទៅទំនាក់ទំនងធ្វើឯកសារនៅសូន្យOSS (OneStopService) នៅថ្ងៃស្អែកបានរួចមាន៖

1.ពលករកំពុងកាន់ប័ត្រស៊ីជម្ពូធ្វើការនេសាទ និងផ្នែកការងារសមុទ្រ ទាំងមានលិខិតឆ្លង និងប័ត្រស៊ីជាច់ 01.11.2017។

2.ពលករកំពុងកាន់លិខិតបញ្ជាក់ទំនាក់ទំនង(លុងបៀន)ទាំងមានលិខិតឆ្លងនិងមិនទាន់លិខិតឆ្លងដែន។

3.ពលករកំពុងកាន់ប័ត្រស៊ីជម្ពូមានសពុលភាពផុតកំណត់នៅ31.03.2018 ទាំងមានលិខិតឆ្លងនិងមិនទាន់មាន។

*សេវាកម្មនៅសូន្យOSS (OneStopService) រួមមាន៖

1.ធ្វើប័ត្រស៊ីជម្ពូ 2.ពិនិត្យសុខភាព 3.វ៉ៃត្រាវីសារ 4.ធ្វើច្បាប់អនុញ្ញាតធ្វើការ

អាស្រ័យហេតុនេះ សូមបងប្អូនពលករខ្មែរទាំងអស់ប្រញាប់រួសរាន់អោយថៅកែរបស់បងប្អូនទៅទំនាក់ទំនងមន្ទីរការងារខេត្ត ដើម្បីលេខណាត់ទៅធ្វើប្រវត្តិរូប, ប័ត្រស៊ីជម្ពូ, វីសារការងារ, ច្បាប់អនុញ្ញាតធ្វើការ អោយបានគ្រប់គ្នាៗ នៅការិយាល័យ(OneStopService)ទូទាំងខេត្តក្រុងនៅក្នុងប្រទេសថៃអោយបានត្រឹមត្រូវតាមសេចក្តីប្រកាសរបស់ក្រសួងការងារថៃ។

## សេចក្តីជូនដំណឹងរបស់ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok February 3 at 6:48pm

ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៏ សូមជូនដំណឹងដល់ បងប្អូនពលករកម្ពុជាដែលកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណព័ណ៌ស៊ីជំពូ) លិខិតបញ្ជាក់ទំនាក់ទំនងរវាងពលករនិងនិយោជក និងសៀវភៅធ្វើការផ្នែកនេសាទ (seabook) ដែលកំពុងធ្វើការ និងស្នាក់នៅប្រទេសថៃ មេត្តាជ្រាបថា អាជ្ញាធរថៃ នឹងបើកដំណើរការការិយាល័យចក្រចេញចូលតែមួយទូទាំងប្រទេស ចំនួន ៧៦ កន្លែង ដើម្បីបន្តសុពលភាពការស្នាក់នៅ និងធ្វើការ ជូនដល់បងប្អូនពលករកម្ពុជារហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨។

សូមបងប្អូនពលករកម្ពុជាប្រញាប់រួសរាន់ ទៅចុះឈ្មោះពន្យា សុពលភាពការស្នាក់នៅ និងធ្វើការ នៅតាមការិយាល័យច្រកចេញចូលតែមួយ ដែលមានទីតាំងស្ថិតនៅក្នុងខេត្តដែលបងប្អូនធ្វើការ ចាប់ពីថ្ងៃទី ៥ ខែកុម្ភៈ ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៨។ សូមបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ មេត្តាជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយបន្ត។ សូមអគុណ

ព្រះរាជាណាចក្រកម្ពុជា

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា
ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍

លេខ: ០៩៦ /១៨/សកប៤

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីជូនដំណឹង

ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សូមជូនដំណឹងដល់បងប្អូនពលករកម្ពុជាដែលកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណព័ណ៌ស៊ីជំពូ) លិខិតបញ្ជាក់ទំនាក់ទំនងរវាងពលករនិងនិយោជក និងសៀវភៅធ្វើការផ្នែកនេសាទ (seabook) ដែលកំពុងធ្វើការ និងស្នាក់នៅប្រទេសថៃមេត្តាជ្រាបថា អាជ្ញាធរថៃ នឹងបើកដំណើរការការិយាល័យចក្រចេញចូលតែមួយទូទាំងប្រទេស ចំនួន ៧៦ កន្លែង ដើម្បីបន្តសុពលភាពការស្នាក់នៅ និងធ្វើការ ជូនដល់បងប្អូនពលករកម្ពុជា**ហួតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនពលករកម្ពុជាប្រញាប់រួសរាន់ ទៅចុះឈ្មោះពន្យាសុពលភាពការស្នាក់នៅ និងធ្វើការ នៅតាមការិយាល័យច្រកចេញចូលតែមួយ ដែលមានទីតាំងស្ថិតនៅក្នុងខេត្តដែលបងប្អូនធ្វើការ **ចាប់ពីថ្ងៃទី ៥ ខែកុម្ភៈ ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៨**។

ក្នុងករណីបងប្អូនពលករកម្ពុជា មានចម្ងល់ពាក់ព័ន្ធនឹងបញ្ហានេះ សូមទំនាក់ទំនងមកទូរស័ព្ទមន្ត្រីស្ថានទូតកម្ពុជានៅក្រុងបាងកក លេខ ០២ ៩៥៧ ៥៨៥១ /០៨៦ ៧៩៩ ៩៩៥៧ / ០៩៤ ០៩២ ៥៩០៥ / ០៦៤ ៧៥៤ ៧៤០១ /០៨២ ៤២២ ០០១១ និង ០៨២ ៤២២ ០០៤៤។

សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១២រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១
បាងកក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៨

អាសយដ្ឋាន 518/4 Pracha Uthit Road, Soi Ramkamhaeng 39, Wangthonglang, Bangkok 10310, Kingdom of Thailand
ទូរស័ព្ទ: (៦៦-២) ៩៥៧ ៥៨៥១/៩៥៧ ៥៨៥២ ទូរសារ:(៦៦-២) ៩៥៧ ៥៨៥០ អ៊ីម៉ែល: camemb.tha@mfa.gov.kh

## ឃាត់ខ្លួនពលករខ្មែរ 40នាក់ បន្ទាប់ពីទិញលេខរៀងក្លែងក្លាយយកទៅធ្វើប៉ាស្ព័រ

http://www.prakpheaktra.com February 5, 2018

កម្លាំងអាជ្ញាធរតម្រួតខេត្តរ៉ាក់យ៉ងបានធ្វើការឃាត់ខ្លួនពលករខ្មែរប្រមាណជាង 40នាក់ បន្ទាប់ពីយកលេខរៀងក្លែងក្លាយមកត្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅការិយាល័យសូន្យម៉ាយ៉ង។ កាលពីថ្ងៃសៅរ៍ទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨ កន្លងទៅមានករណីពលករខ្មែរប្រមាណជាង 40នាក់ត្រូវកម្លាំងអាជ្ញាធរតម្រួតខេត្តរ៉ាក់យ៉ង ប្រទេសថៃឃាត់ខ្លួន យោងតាមប្រភពម្ចាស់ទំព័រហ្វេសប៊ុកឈ្មោះ Manith Pattaya បានរៀបរាប់អោយដឹងថា ករណីពលករខ្មែរចំនួន 40នាក់បាននាំយកលេខរៀងក្លែងក្លាយទៅត្រួតសញ្ញាតិធ្វើប៉ាស្ព័រនោះ បានកើតឡើងនៅវេលាម៉ោង០២រសៀលស្ថិតនៅក្នុងទីតាំងសូន្យអូចប់ម៉ាយ៉ង បន្ទាប់ពីពលករទាំងអស់នោះបានទិញលេខរៀងត្រួតសញ្ជាតិ ពីក្រុមអ្នករកស៊ីរត់លេខរៀង ហើយត្រូវភ្នាក់ងារធ្វើប៉ាស្ព័រនៅក្នុងសូន្យត្រួតពិនិត្យដឹងថា លេខរៀងដែលពលករទាំងអស់នោះយកមកធ្វើមិនមែនជាលេខរៀងត្រឹមត្រូវ ទើបរាយការណ៍អោយកម្លាំងអាជ្ញាធរតម្រួតខេត្តរ៉ាក់យ៉ងមកនាំខ្លួនពលករខ្មែរទាំងអស់យកទៅធ្វើការសាកសួរនៅអធិការដ្ឋានតម្រួតខេត្ត ដើម្បីស្រាវជ្រាវតាមចាប់ខ្លួនមេខ្លោង ដែលក្លែងបន្លំលេខរៀងយកទៅដាក់ទោសតាមផ្លូវច្បាប់។

## ពលរដ្ឋខ្មែរ០២បានស្លាប់និងជាង១០នាក់ទៀតរងរបួសធ្ងន់ ដោយសារឆ្លងដែនខុសច្បាប់ចូលទៅស្វែងរកការងារធ្វើនៅប្រទេសថៃ

http://www.prakpheaktra.com February 2, 2018

ពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃចំនួន០២នាក់ បានស្លាប់បាត់បង់ជីវិត និងជាង១០នាក់ទៀតបានរងរបួសធ្ងន់បន្ទាប់ពីជួបឧបទ្ទវហេតុក្រឡាប់រថយន្តតាមផ្លូវ។ កាលពីវេលាម៉ោង០៤:៣០នាទីទៀបភ្លឺថ្ងៃសុក្រទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ មានករណីឧបទ្ទវហេតុគ្រោះថ្នាក់ក្រឡាប់រថយន្ត TOYOTA HIREVO ពីរបាងមួយគ្រឿងបណ្តាលឲ្យពលរដ្ឋខ្មែរចំណាកស្រុកចំនួន១៣នាក់បានរងរបួសធ្ងន់។ ហេតុការណ៍ឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរនេះបានកើតឡើងនៅលើផ្លូវជាតិបាយផាត់លៀងមឿងត្រង់ចំណុចមុខវត្តប៉ាសួនខាង ស្ថិតក្នុងស្រុកអារញ្ញយាថេត ខេត្តស្រះកែវ ប្រទេសថៃ។ ក្នុងករណីគ្រោះថ្នាក់ដោយឧបទ្ទវហេតុនេះបណ្តាលឱ្យមានពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចំនួនចំនួន 13នាក់បានរងរបួស និងស្លាប់បាត់បង់ជីវិត។

យោងតាមរបាយការណ៍របស់សមត្ថកិច្ចថៃបានចុះទៅអន្តរាគមន៍ដល់កន្លែងកើតហេតុបានឲ្យដឹងថានៅកន្លែងកើតហេតុពលរដ្ឋខ្មែរមិនស្គាល់អត្តសញ្ញាណចំនួន០២នាក់បានស្លាប់បាត់បង់ជីវិតក្នុងនោះមានស្រ្តី០១នាក់ និងបុរស០១នាក់ បន្ទាប់ពីនោះមានមនុស្សប្រុសស្រីចំនួន១១នាក់ទៀតបានរងរបួសដេកស្រែកពេញផ្លូវ។ បច្ចុប្បន្នជនរងគ្រោះទាំងអស់ត្រូវបានភ្នាក់ងារសង្គ្រោះស្រុកអារញ្ញយាថេត ខេត្តស្រះកែវបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យស្រុកអារញ្ញ ចំណែកឯបើកបររថយន្តកើតហេតុសមត្ថកិច្ចថៃកំពុងធ្វើការស្រាវជ្រាវចាប់ខ្លួនមកផ្តន្ទាទោសតាមច្បាប់ផ្លូវច្បាប់។

## ពលករខ្មែរ០១នាក់ ធ្វើការនៅថៃ ដេកស្លាប់នៅក្នុងបន្ទប់យ៉ាងអាណោចអាធ័ម

http://www.prakpheaktra.com February 2, 2018

កាលពីថ្ងៃច័ន្ទទី២៩ ខែមករា ឆ្នាំ២០១៨ កន្លងទៅថ្មីនេះៗមានករណីបុរសពលករខ្មែរវ័យ៥០នាក់ ឈ្មោះ ហែម សម្បត្តិ អាយុ ៥០ឆ្នាំ សញ្ជាតិខ្មែរមុខរបរជាពលករធ្វើការនៅក្នុងខេត្តសាមុតប្រាកាន បានដេកស្លាប់បាត់បង់ជីវិតនៅក្នុងបន្ទប់ស្នាក់លេខ១៥ នៅស្ថិតក្នុងច្រក(សាប់ដែង)សង្កាត់ថេបផារ៉ាក់ ស្រុកសៅធុង ខេត្តសាមុតប្រាកាន

ប្រទេសថៃ។ បច្ចុប្បន្នសាកសពពលករខ្មែរខាងលើត្រូវអាជ្ញាធរថៃបញ្ជូនទៅរក្សាទុកនៅមន្ទីរពេទ្យបាងសៅធុង ខេត្តសាមុតប្រាកាន ដើម្បីរង់ចាំសាច់ញាតិទំនាក់ទំនងមកទទួលយកទៅធ្វើបុណ្យតាមប្រពៃណី។

## ស្វាត់ៗ. អាជ្ញាធរថៃចុះចាប់ពលករធ្វើការខុសច្បាប់បានចំនួន ០៩នាក់

http://www.prakpheaktra.com February 3, 2018

នៅព្រឹកថ្ងៃសៅរ៍ទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨ កម្លាំងអាជ្ញាធរតម្រួតក្រុងប៉ាតាយា ស្រុកបាងឡាម៉ុង ខេត្តឈុនបុរី ប្រទេសថៃ ។ បានបើកកិច្ចព្រឹត្តិការណ៍ចុះបង្ក្រាបពលករបរទេសដែលកំពុងធ្វើការខុសច្បាប់នៅក្នុងតំបន់ទេសចរណ៍ក្រុងប៉ាតាយ៉ា ដើម្បីទប់ស្កាត់បញ្ហាពលករចំណាកខុសច្បាប់ និងអំពើជួញដូរមនុស្ស តាមនយោបាយរបស់អគ្គនាយកដ្ឋានតម្រួត។ ក្នុងកិច្ចព្រឹត្តិបត្រការណ៍ចុះបង្ក្រាបពលករអន្តប្រវេសន៍ធ្វើការខុសច្បាប់លើកនេះកម្លាំងអាជ្ញាធរក្រុងប៉ាតាយា ធ្វើឃាត់ខ្លួនបានពលករចំណាកស្រុកខុសច្បាប់សញ្ជាតិភូមាចំនួន០៨នាក់ និងជនចិន០១នាក់ ក្រោយពេលឃាត់ខ្លួនពលករខុសច្បាប់ទាំងអស់ ត្រូវកម្លាំងអាជ្ញាធរក្រុងប៉ាតាយាបានបញ្ជូនពលករខុសច្បាប់ទោះទៅកាន់អធិការតម្រួតក្រុងដើម្បីធ្វើការសាកសួរនិងចាត់វិធានការតាមផ្លូវច្បាប់។ ហើយក្នុងនោះដែរលោកអធិការតម្រួតក្រុងប៉ាតាយាបានធ្វើការអំពាវនាវដល់និយោជិកថៃ ដែលកំពុងគ្រប់គ្រងពលករបរទេសសូមអោយពលករធ្វើការអោយត្រូវនិងលក្ខខ័ណ្ឌច្បាប់ការងារ និងហាមទទួលពលករខុសច្បាប់អោយធ្វើការ បើមិនដូច្នេះទេនឹងត្រូវមានទោសចាប់ ឬផាកពិន័យជាប្រាក់ចាប់ពី 400.000បាត ដល់ 800.000បាត។ ដកស្រង់ព័ត៌មាន:naewna

## ក្រសួងការងារថៃ ប្រកាស អំពាវនាវឲ្យថៅកែថៃ នាំពលករទៅធ្វើប័ត្រស៊ីជម្ពូនៅសូន្យ

OSS( OneStopService )

http://www.prakpheaktra.com February 3, 2018

ក្រសួងការងារថៃ ចេញសេចក្តីជូនដំណឹងដល់និយោជកថៃទាំងអស់អោយប្រញាប់ប្រញាល់នាំពលករទាំងបីប្រភេទដូចខាងក្រោម ទៅធ្វើឯកសារប្រវត្តិរូប និងសេវាកម្មចំនួននៅក្នុងសូន្យ OSS (OneStopService) ចាប់តាំងពីថ្ងៃច័ន្ទទី05 ខែកុម្ភៈ ឆ្នាំ2018 ខាងមុខនេះទូទាំងខេត្តក្រុងនប្រទេសថៃ។

1.ពលករដែលកំពុងកាន់ប័ត្រស៊ីជម្ពូប្រភេទនេសាទនិងផ្នែកការងារសមុទ្រ

2.ពលករដែលកំពុងកាន់មានលិខិតបញ្ជាក់ទំនាក់ទំនងរវាងពលករនិងនិយោជក(ប៉ៃចាប់គូរ)

3.ពលករដែលកំពុងកាន់ប័ត្រស៊ីជម្ពូដែលមានសពុលភាពផុតកំណត់នៅ(31.03.2018)

ត្រូវប្រញាប់អោយថៅកែថៃនាំខ្លួនទៅធ្វើឯកសារប្រវត្តិរូបមួយចំនួននិងសេវាកម្មផ្សេងៗទៀតបានត្រឹមត្រូវតាមសេចក្តីប្រកាសរបស់ក្រសួង។

## រងគ្រោះជាង ១ទសវត្សរ៍ ក្នុងជីវិតជាស្ត្រីបម្រើការងារតាមផ្ទះនៅក្រៅប្រទេស

http://www.postkhmer.com កែវ វតនា and ប៉ាន់ រចនា | Publication date 26 January 2018 | 12:13 ICT

ជាង ១៣ឆ្នាំមកហើយដែល អ្នកស្រី អេង ពៅ ត្រូវបានឃ្លាតឆ្ងាយពីប្រទេសកំណើត និងត្រូវបានទទួលរងអំពើហិង្សា និងកេងកម្លាំងពលកម្មនៅក្រៅប្រទេស។ អ្នកស្រី ពៅ បានរត់ចេញពីផ្ទះនៅពេលអាយុបាន១៦ ឆ្នាំដោយសារឪពុកចុងធ្វើបាប។ គាត់បានមករស់នៅជាមួយម្តាយចិញ្ចឹមឈ្មោះ មាហ៊ីយ៉ា។ កាលឆ្នាំ ២០០៥ គាត់បានសម្រេចចិត្តទៅធ្វើការជាស្ត្រីបម្រើការងារតាមផ្ទះនៅប្រទេស អារ៉ាប៊ីសាអ៊ូឌីតបន្ទាប់ពីប្តីរបស់គាត់បានចាកចេញទៅធ្វើពលករ

នៅប្រទេសថៃហើយបានបាត់បង់ជីវិតនៅទីនោះ។ ប៉ុន្តែក្តីសង្ឃឹមថានឹងរកលុយដើម្បីផ្គត់ផ្គង់ កូនអាយុ៤ឆ្នាំ និងម្តាយចិញ្ចឹមរបស់ខ្លួនទៅជាភាពងងឹតសូន្យសុង បន្ទាប់ពីអ្នកស្រីបានទៅដល់។ កែវ វេតនា and ប៉ាន់ រចនា

## ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៨

## សម្តេចតេជោ រំលឹកអនុសាសន៍៨ចំណុច ដែលដាបញ្ហាចាស់ ត្រូវពិនិត្យមើល

http://www.rasmeinews.com/ February 7, 2018, 12:09 PM

(ភ្នំពេញ) ៖ នៅព្រឹក ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ នេះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រីនៃកម្ពុជាបន្តចុះជួបជាមួយ កម្មករ កម្មការិនីជាង១៥.០០០នាក់មកពីរោងចក្រសហគ្រាសចំនួន៧ នៅតំបន់កប់ស្រូវ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

១- ត្រូវអនុវត្តប្រាក់ខែអប្បបរមា ១៧០ ដុល្លារ ឲ្យបានត្រឹមត្រូវ

២-ត្រូវអនុវត្តការចុះពិនិត្យនៅតាមមន្ទីរពេទ្យរដ្ឋ ចំពោះការពិនិត្យសុខភាព និងការព្យាបាល កម្មករ-កម្មការិនីរោងចក្រ រួមទាំងកីឡាករ- កីឡាការិនី ក្រុមប្រឹក្សាភូមិឃុំក៏ត្រូវបាន អនុវត្តន៍ដូចគ្នាជាពិសេស រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងការងារ ត្រូវធ្វើឲ្យបានហ្មត់ចត់ អនុវត្តការជិះរថយន្តក្រុង ដោយមិនគិតថ្លៃ ត្រូវរៀបចំចំណត ឲ្យបានត្រឹមត្រូវ។

៣-ត្រូវអនុវត្តចំពោះស្ត្រីមានផ្ទៃពោះ សំរាលកូននឹងទទួលបាន ពេលវេលាឈប់សម្រាក ពីការងាររយៈពេល៣ខែហើយហើយនៅទទួលបានប្រាក់ខែ១២០%

៤-ត្រូវអនុវត្តការបើកផ្តល់សាច់ប្រាក់ ចំពោះកម្មការិនីឆ្លងទន្លេ។ សូមកោតសរសើរចំពោះបេឡាជាតិ របបសន្តិសុខសង្គមនិងក្រសួងសេដ្ឋកិច្ច ដែលបានបើកផ្តល់ជាទៀងទាត់ ដល់កម្មការិនី។ ឥឡូវនេះអង្គការអន្តរជាតិ សរសើរយើង តែយើងមិនត្រូវការឲ្យអ្នកណាសសើរទេ កិច្ចការនេះយើងត្រូវតែធ្វើ ដើម្បីសុខមាលភាព ប្រជាពលរដ្ឋ។

៥-ត្រូវអនុវត្តចំពោះរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព។កម្មករ-កម្មការិនី មិនចាំបាច់បង់ទៀតទេ គឺម្ចាស់ក្រុមហ៊ុនជាអ្នកបង់ជំនួស ១០០%ចាប់ពីឆ្នាំ២០១៨នេះតទៅ។ចំណូលចេះតែ កើនចំណាយធ្លាក់ចុះ។

៦-អនុវត្តតាមដាន ជាប្រចាំការអនុវត្តន៍បញ្ហា ទឹក ភ្លើង ត្រូវខិតខំបន្តតទឹកតភ្លើងដល់ផ្ទះរបស់កម្មករ ដែលនៅឆ្ងាយដែលមិនទាន់ទៅដល់ ឲ្យបានគ្រប់គ្រាន់ និងតំលៃផ្ទះជួល កុំឲ្យមានការឡើងថ្លៃ ក្នុងឆ្នាំ២០១៨។

៧-អនុវត្តប្រាក់សោធននិវត្តន៍ ចាប់ពីឆ្នាំ២០១៩កម្មករ នឹងទទួលបានប្រាក់ចូលនិវត្តន៍ (ប្រាក់រ៉ឺត្រែត) ត្រូវអនុវត្តតាមលក្ខខណ្ឌ ឲ្យបានត្រឹមត្រូវមិនមែន ចូលធ្វើការមួយថ្ងៃ មានប្រាក់ចូលសោធននិវត្តន៍នោះទេ ប្រាក់បៀវត្សន៍ដែលចេះតែបន្តឡើងរាល់ឆ្នាំនេះមិនមែនបាន មកពីបក្សប្រឆាំងនោះទេ គឺបានមកពីការខិតខំ របស់រាជរដ្ឋាភិបាលកម្ពុជា។

៨-ត្រូវបន្តយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាផ្សេងៗ ដែលពលករទៅក្រៅ ប្រទេសជួយសម្រួល បែបបទលិខិតបទដ្ឋានផ្លូវច្បាប់នានាដើម្បីទទួលបាន លក្ខខណ្ឌការងារ ល្អប្រសើរ។ ដោយ៖**វិបុល/sn**

## ឆ្នាំ២០១៧ មានភាពមិនប្រក្រតីតាមព្រំដែនកើតឡើងចំនួន៣៨៨លើក

http://bayontv.com.kh/ 06/02/2018

ភ្នំពេញ៖ នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិបានបើកសន្និបាតបូកសរុបសភាពការណ៍ និងកិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈសុវត្ថិភាពសង្គមប្រចាំឆ្នាំ២០១៧ និងដាក់ចេញទិសដៅឆ្នាំ២០១៨ នៅព្រឹកថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨។ នាយឧត្តមសេនីយ៍ នេត សាវឿន អះអាងថា ស្ថានភាពសន្តិសុខតាមតំបន់ព្រំដែនមានស្ថានភាពស្ងប់ស្ងាត់ល្អ ប៉ុន្តែក៏មានសកម្មភាពមិនប្រក្រតីកើតឡើងចំនួន៣៨៨លើកផងដែរ។

បើតាមរបាយការណ៍របស់អគ្គស្នងការបានបញ្ជាក់ថា បញ្ហាកើតឡើងរវាងព្រំដែនកម្ពុជា និងថៃមានចំនួន ៣៦៥លើក កម្ពុជា-វៀតណាម១៥លើក និងកម្ពុជា-ឡាវ ៨លើកក្នុងនោះមានការរំលោភដែនអាកាស ការរាយលួស បន្លា ការរុករានដីធ្វើចំការ ការឈូសឆាយធ្វើផ្លូវជាដើម។ របាយការណ៍បានឱ្យដឹងផងដែរថា ក្នុងឆ្នាំ២០១៧នេះថៃបានចាប់បញ្ជូនពលរដ្ឋខ្មែរត្រឡប់មកវិញចំនួន១៣.៣៩៦នាក់និងសាកសពចំនួន៣៦នាក់៕

## កម្មសិក្សាការី នៅធ្វើការនៅប្រទេសជប៉ុនមើលថែមនុស្ស តម្រូវឲ្យចេះភាសាជប៉ុន ងាយស្រួលទំនាក់ទំនង

http://www.cen.com.kh/ February 7, 2018

ភ្នំពេញ៖ប្រធានអង្គការ JCIA បានអះអាងថានឹងខិតខំពន្លឿន ទៅលើការបណ្តុះបណ្តាលធនធានមនុស្សកម្មសិក្សាការី ទៅធ្វើការនៅប្រទេសជប៉ុន ដែលតម្រូវឲ្យពួកគាត់ ចេះភាសាជប៉ុន ឲ្យបានច្រើន ដើម្បីងាយស្រួលទំនាក់ទំនង ព្រោះការងារនេះធ្វើរវាងមនុស្ស និងមនុស្ស ដែលអាចមានបញ្ហាខ្លះ នឹងកើតមានឡើង អំឡុងពេលធ្វើកិច្ចការនេះផងដែរ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុញ្ញាតឲ្យ លោក Fumio Yamada ប្រធានអង្គការ JCIA ដឹកនាំគណប្រតិភូជប៉ុន ជួបពិភាក្សាការងារពាក់ព័ន្ធ ទៅលើការបញ្ជូនកម្មសិក្សាការី ទៅធ្វើការនៅប្រទេសជប៉ុន ផ្នែកថែទាំមនុស្សចាស់ នៅទីស្តីការក្រសួង ថ្ងៃអង្គារទី៦ ខែកុម្ភៈ ឆ្នាំ២០១៨។

លោក Fumio Yamada លើកឡើងថា អង្គការJCIA និងក្រសួងសង្គមកិច្ចកម្ពុជាមានបំណងចង់បញ្ជូនកម្មសិក្សាការីទៅបណ្តុះបណ្តាលនៅប្រទេសជប៉ុន ដោយសារធនធានមនុស្សផ្នែកថែទាំមនុស្សចាស់នៅប្រទេសជប៉ុនមានកម្រិតទាបនៅឡើយ បន្ទាប់មកកម្មសិក្សាការី ក៏អាចយកជំនាញនេះ មកប្រើប្រាស់នៅកម្ពុជាផងដែរ។ ជាមួយគ្នានេះដែរ កម្ពុជានឹងមានចំនួនមនុស្សចាស់ កើនឡើងដូចប្រទេសជប៉ុនដែរ អញ្ចឹងក៏ត្រូវការអ្នកដែលមានសមត្ថភាព ខាងថែទាំមនុស្សចាស់។ ជាមួយគ្នានេះ ទាក់ទងទៅនឹងសេវាថែទាំមនុស្សចាស់ ខាងអង្គការរបស់លោក នឹងគៀគរអ្នកវិនិយោគទុន របស់ជប៉ុន មកកម្ពុជា កាន់តែច្រើនបន្ថែមទៀត ដូច្នេះគឺ ត្រូវការការសហការ និងការគាំទ្រជាមួយក្រសួងការងារអោយបានច្រើន។

ជាការឆ្លើយតបលោករដ្ឋមន្ត្រីមានប្រសាសន៍ថា ទាក់ទងសេវាថែទាំមនុស្សចាស់ដែលលោក Yamada បានលើកឡើងនេះ វាជាប្រធានបទ ដែលយើងកំពុងចាប់ដៃគ្នាធ្វើកិច្ចការនេះ។ កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឲ្យប្រើប្រាស់ នូវគោលនយោបាយស្តីពីមនុស្សចាស់ ហើយដូច្នេះក្រោមគោលនយោបាយនេះ ត្រូវការអភិវឌ្ឍនូវធនធានមនុស្ស សេវាថែទាំមនុស្សចាស់នេះ ជាចាំបាច់។ លោកលើកឡើងថា "កន្លងមកខ្ញុំបានទទួលមិត្តភក្តិជប៉ុនច្រើនដែលបានចាប់អារម្មណ៍លើបញ្ហានេះ ឥឡូវនេះ ក្រៅពី JCIA ដែលមានកម្មវិធីសម្រាប់ការអភិវឌ្ឍ និងបណ្តុះបណ្តាលថែទាំមនុស្សចាស់ យើងមានក្រុមហ៊ុនមួយចំនួន ដែលជាដៃគូរបស់យើងដែរ កំពុងតែរៀបចំមជ្ឈមណ្ឌល ឬសាលាបណ្តុះបណ្តាលជំនាញថែទាំមនុស្សចាស់នេះ ហើយប្រទេសទាំងពីរក៏អាចសហការគ្នា បញ្ជូនកម្មសិក្សាការីទៅធ្វើការផ្នែកនេះដែរ នេះជាឱកាសដែលយើង បានធ្វើជាដៃគូរជាមួយគ្នា ដើម្បីបញ្ជូនកម្មសិក្សាការីទៅជប៉ុន"។ លោក បន្តថា "ឥឡូវនេះកម្មសិក្សាការីខ្មែរនៅប្រទេសជប៉ុន គឺមានជាង៦៣ពាន់នាក់ ហើយមួយថ្ងៃទៅមួយថ្ងៃក៏មានការជ្រើសរើស ការបណ្តុះបណ្តាល និងការបញ្ជូនទៅកាន់តែច្រើន អញ្ចឹងទេខាងCJIA ក៏ខំប្រឹងរកដៃគូបន្ថែមទៀតដើម្បីរួមចំណែកក្នុងការបណ្តុះបណ្តាល និងបញ្ជូនទៅ ក្រៅពីការគាំទ្រដល់គម្រោងរបស់មជ្ឈមណ្ឌលក៏យើងត្រូវគិតដល់កិច្ចសហប្រតិបត្តិការបើកទូលាយបន្ថែមទៀត"។

លោក Fumio Yamada សង្កត់ធ្ងន់ថា JCIA មិនត្រឹមតែ ខិតខំពន្លឿន ទៅលើការបណ្តុះបណ្តាលខាងធនធានមនុស្សទេ គឺយើងនឹងផ្តល់ខាងគ្រូបង្គោលដើម្បីហ្វឹកហាត់ទៅដល់កម្មសិក្សាការីផងដែរ។ កម្មសិក្សាការីថែទាំ

មនុស្សចាស់ វាខុសប្លែកពីកម្មសិក្សាការី ផ្សេងៗទៀត គឺតម្រូវឲ្យគាត់ចេះភាសាជប៉ុន ឲ្យបានច្រើន ដើម្បីងាយស្រួលទំនាក់ទំនង ព្រោះកិច្ចការងារនេះ យើងធ្វើរវាងមនុស្ស និងមនុស្ស អញ្ចឹងវាអាចមានបញ្ហាខ្លះ នឹងកើតមានឡើងអំឡុងពេលធ្វើកិច្ចការនេះផងដែរ៕ ដោយៈបញ្ញាស័ក្តិ

## ពលករខ្មែរ២៩នាក់ត្រូវទាហ៊ានឈុតខ្មៅនិងតម្រួតថៃឃាត់ក្នុងខេត្តសឹង្ហបុរី ប្រទេសថៃ

http://cambodiapolice.com/ 2:20 pm 6 កុម្ភៈ 2018

បន្ទាយមានជ័យ ៖ ពលករខ្មែរប្រុស.ស្រីចំនួន២៩នាក់ ដែលធ្វើការសំណង់ត្រូវទាហ៊ានឈុតខ្មៅនិងតម្រួតថៃឃាត់ខ្លួនកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨ នៅការដ្ឋានសំណង់មួយកន្លែងក្នុង ខេត្តសឹង្ហបុរី ប្រទេសថៃ។ ប្រភពព័ត៌មានបានអោយដឹងថា នៅពេលក្រុមសមត្ថកិច្ចចម្រុះចុះឃាត់ខ្លួនពលករខ្មែរប្រុស.ស្រីចំនួន២៩នាក់ ឃើញមានកម្លាំងយោធាឈុតខ្មៅថៃ និងតម្រួតយោធារួមជាមួយកម្លាំងនគរបាលអន្តោប្រវេសន៍ថៃ១ក្រុមជាច្រើននាក់ បានចុះឃាត់ខ្លួនពលករខ្មែរកំពុងធ្វើការងារក្នុងការដ្ឋានសំណង់មួយកន្លែង ស្ថិតភូមិបាងម៉ៃ ស្រុកមឿងខេត្តសឹង្ហបុរី ប្រទេសថៃ។ ព័ត៌មានទទួលបានឲ្យដឹងថា ពលករខ្មែរក្រោយពេលកម្លាំងចម្រុះថៃឃាត់ ត្រូវបានបញ្ជូនទៅប៉ូលីសផ្នែកអន្តោប្រវេសន៍ថៃ ដើម្បីធ្វើការពិនិត្យលិខិតស្នាមដោយរកឃើញថា ពលករខ្មែរចំនួន២៩នាក់នេះធ្វើការដោយគ្មានច្បាប់អនុញ្ញាត ពលករធ្វើការខុសច្បាប់មិនបានចុះបញ្ជីធ្វើការងារ ហើយឆ្លងដែនធ្វើការងារដោយខុសច្បាប់ ។

ក្រោយពេលដែលកម្លាំងចម្រុះចាប់ខ្លួនពលករខ្មែរចំនួន២៩នាក់ ចោទប្រកាន់ខុសច្បាប់ ត្រូវបានមន្ត្រីស្ថានទូតកម្ពុជា កំពុងធ្វើការទំនាក់ទំនងជាមួយភាគីថៃ ដើម្បីជួយដល់ប្រជាពលរដ្ឋខ្មែរត្រូវថៃចាប់ខ្លួន ៕

## តម្រួតអន្តោប្រវេសន៍ថៃ បើកយុទ្ធនាការចុះត្រួតពិនិត្យ ឯកសារធ្វើការពលករបរទេស នៅតាមរោងចក្រ

http://www.prakpheaktra.com February 7, 2018

នៅព្រឹកថ្ងៃអង្គារ ទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨ កម្លាំងអាជ្ញាធរតម្រួតខេត្តសាមុតសាខនប្រទេសថៃ បានធ្វើយុទ្ធនាការចុះត្រួតពិនិត្យឯកសារធ្វើការរបស់ពលករបរទេស ដែលកំពុងធ្វើការនៅក្នុងរោងចក្រសហគ្រាសតូចធំមួយចំនួនក្នុងខេត្តសាមុតសាខន ដោយមានការចូលរួមសហការពីកម្លាំងតម្រួតអន្តោប្រវេសន៍និងកម្លាំងទាហានដឹកដោយសម្ថកិច្ចក្រសួងការងារថៃ ដើម្បីទប់ស្កាត់បញ្ហាពលករចំណាកស្រុកខុសច្បាប់លបលួចធ្វើការដោយគ្មានច្បាប់អនុញ្ញាត ។ ក្នុងកិច្ចសហប្រតិបត្តិការចុះត្រួតពិនិត្យឯកសារធ្វើការរបស់ពលករបរទេសក្នុងរោងចក្រសហគ្រាសខាងលើនេះ កម្លាំងអាជ្ញាធរថៃធ្វើការត្រួតពិនិត្យពលករបរទេសចំនួន៤៨នាក់ ក្នុងមានពលករបរទេសចំនួន០៥នាក់ ធ្វើការខុសថៅកែដោយម្ចាស់សហគ្រាសខាងលើបញ្ជាក់ប្រាប់ថាពលករទាំង០៥នាក់ កំពុងស្ថិតក្នុងការប្តូរថៅកែនៅក្រសួងការងារ ក្នុងនោះដែរសម្ថកិច្ចបានធ្វើការជាសតឿនដល់ថៅកែ សហគ្រាសខាងលើប្រញាប់ធ្វើរឿងប្តូរថៅកែអោយចប់សព្វគ្រប់ក្នុងរយៈពេល១៥ថ្ងៃបើមិនដូច្នេះទេនិងត្រូវមានទោសចាប់ផាកពិន័យតាមផ្លូវច្បាប់។

## អ្នកដែលត្រូវទៅតប័ត្រស៊ីជម្ពូនិងធ្វើវីសា 2ឆ្នាំ នៅទីក្រុងបាងកក សូមអានអត្ថបទនេះ.!

http://www.prakpheaktra.com February 6, 2018

សេចក្តីជូនដំណឹងដល់បងប្អូនពលករខ្មែរដែលកំពុងស្នាក់នៅក្នុងទីក្រុងបាងកក ប្រទេសថៃ ទាំងមានប័ត្រស៊ីជម្ពូ និងលិខិតលុងបៀន ដែលកំពុងត្រៀមខ្លួនទៅតប័ត្រស៊ីជម្ពូ និងត(វីសារ២ឆ្នាំ) នៅសូន្យ OSS (វ៉ាន់ស្តប់សឺវីត) អោយបានជ្រៀបថា ចំពោះទីតាំងតប័ត្រស៊ីជម្ពូនិងធ្វើ(វីសា២ឆ្នាំ)នៅក្នុងទីក្រុងបាងកក បានតំរូវអោយបងប្អូនពលករខ្មែរត្រូវមានលិខិតត្រួតសុខភាពពីមន្ទីរពេទ្យខាងក្រៅសិនទើប បងប្អូនអាចទៅធ្វើ(វីសា២ឆ្នាំ)និងប័ត្រស៊ីជម្ពូនៅសូន្យ (វ៉ាន់ស្តប់សឺវីត)បាន។ ពោះនៅក្នុងសូន្យ (វ៉ាន់ស្តប់សឺវីត) ក្នុងទីក្រុងបាងកកមួយចំនួនមិនមានសេវាកម្មពិនិត្យសុខ

ភាពជូនពលករឡើយ ដូច្នេះសូមបងប្អូនពលករខ្មែរទាំងមានលិខិតលុងបៀននិងប័ត្រស៊ីជម្ពូ សូមទំនាក់ទំនងសាកសួរព័ត៌មានលំអិតអោយបានច្បាស់ដើម្បីកុំអោយខាតពេលវេលាក្នុងការធ្វើដំណើរទៅសូន្យខាងលើ។

## ឧទ្ធរណ៍បើកសវនាការ រឿងស្ត្រីម្នាក់លក់កូនស្រីឲ្យរួមភេទ ជាមួយបុរសបរទេស

http://www.postkhmer.com/ គីម សារុំ | Publication date 06 February 2018 | 13:01 ICT

ភ្នំពេញៈសាលាឧទ្ធរណ៍នៅថ្ងៃទី ៦ ខែកុម្ភៈនេះ បានបើកសវនាការជំនុំជម្រះស្ត្រីជាប់ចោទម្នាក់ទាក់ទងនឹងការលក់កូនស្ត្រីអាយុក្រោម ១៥ ឆ្នាំឲ្យរួមភេទជាមួយជនបរទេស ប្រព្រឹត្តកាលពីឆ្នាំ ២០១០ ហើយត្រូវបានតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់ពន្ធនាគារ១០ឆ្នាំ។

តាមរបាយការណ៍នគរបាលប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញបង្ហាញថា ស្ត្រីជាប់ចោទឈ្មោះចាន់ផល្លី អាយុ ៤៤ ឆ្នាំរស់នៅសង្កាត់ផ្សារថ្មីទី ៣ ខណ្ឌដូនពេញបានទាក់ទងជាមួយជនជាតិអាមេរិកាំងម្នាក់និងបានលក់កូនស្រីខ្លួនឈ្មោះច.ម.លឲ្យទៅរួមភេទជាមួយបុរសនោះ។ ប៉ុន្តែបន្ទាប់ពីធ្វើសកម្មភាពបានប៉ុន្មានដងមកគឺនៅថ្ងៃទី ២៦ ខែតុលាឆ្នាំ ២០១០ ក៏ត្រូវនគរបាលឃាត់ខ្លួនបានទាំងបុរសបរទេស និងក្មេងរងគ្រោះ។

ទោះយ៉ាងណា នៅក្នុងបន្ទប់សវនាការនៅថ្ងៃនេះស្ត្រីជាប់ចោទបានទទួលកំហុស និងសុំតុលាការបន្ថយទោស ខណៈមេធាវីការពារគាត់ក៏សន្និដ្ឋានដូចគ្នា៕

## អភិបាលខេត្តប៉ៃលិន ស្នើឲ្យថៃបើកច្រកព្រំដែនថ្មី១ទៀត

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង 06:50

លោក កើត សុជា អភិបាលខេត្តប៉ៃលិន បានស្នើឱ្យភាគីថៃ ធ្វើការពិនិត្យពីលទ្ធភាពបើកច្រកព្រំដែនថ្មី១ទៀត សម្រាប់ការធ្វើចរាចរណ៍ដឹកទំនិញ និងកសិកផលចេញចូលឆ្លងព្រំដែនរវាងខេត្តប៉ៃលិន និងខេត្តចាន់បុរីនៃប្រទេសទាំង២។ សំណើនេះ ធ្វើឡើងក្នុងជំនួបរវាងលោក កើត សុជា ជាមួយគណៈប្រតិភូថៃដែលដឹកនាំដោយលោកនាយឧត្តមសេនីយ៍ លូកភីត សេងគង់ លេខាធិការគណៈកម្មាធិការ ពាណិជ្ជកម្ម ឧស្សាហកម្ម និងពលករ នៃរដ្ឋសភាថៃកាលពីចុងសប្តាហ៍កន្លងទៅនេះ នៅសាលាខេត្តប៉ៃលិន។ ក្នុងឱកាសនោះដែរ លោក កើត សុជា បានសំណូមពរដល់ភាគីថៃបន្តកិច្ចសហប្រតិបត្តិការលើការនាំចេញ កសិផលឆ្លងដែនរវាងខេត្តចាន់បុរី-ប៉ៃលិន ការប្រើប្រាស់បណ្ណឆ្លងព្រំដែនថ្មី បញ្ហាពលករខ្មែរឆ្លងដែន ខុសច្បាប់ និងបទល្មើសឆ្លងដែននានា។

ជាការឆ្លើយតប លោក លូកភីត សេងគង់ បានមានលើកឡើងថា ប្រតិភូថៃ ដែលមកខេត្ត ប៉ៃលិននាពេលនេះ គឺក្នុងគោលបំណងមកសិក្សាពីកិច្ចសហការ និងបញ្ហាប្រឈមនានា រវាងខេត្តជាប់ព្រំដែនរវាងប្រទេសទាំងពីរ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ឧស្សាហកម្ម និងពលករ។ ចំណែកសំណូមពររបស់អភិបាលខេត្តប៉ៃលិន ភាគីថៃបានបញ្ជាក់ថា នឹងយកទៅពិភាក្សាជាមួយថ្នាក់ដឹកនាំជំនាញពាក់ព័ន្ធ និងរាជរដ្ឋាភិបាលថៃ ដើម្បីរកលទ្ធភាព និងដំណោះស្រាយក្នុងការបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង២ ឲ្យបានកាន់តែល្អប្រសើរឡើង។

សូមបញ្ជាក់ថា បច្ចុប្បន្នច្រកព្រំដែនអន្តរជាតិរវាងខេត្តប៉ៃលិន និងខេត្តចាន់បុរី មាន ចំនួន ១គឺច្រកទ្វារព្រំដែនអន្តរជាតិព្រំ ដែលស្ថិតនៅភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ឈមនឹងភូមិបានផាកាត ឃុំខ្លងយ៉ៃ ស្រុកពោងណាំរ៉ន ខេត្តចាន់បុរី ប្រទេសថៃ ដោយជាច្រកព្រំដែនដឹកទំនិញចេញចូលផង និងភ្ញៀវទេសចរផង ដែលមានលក្ខណៈតូចចង្អៀត៕

# តុលាការផ្តន្ទាទោស អនិកជនខ្មែរ-អាមេរិកម្នាក់ ដាក់ពន្ធនាគារ១០ខែ រឿងឆបោកលុយពលករខ្មែរអស់លុយរាប់ម៉ឺនដុល្លារ

http://www.freshnewsasia.com/ 2018-02-07

(ភ្នំពេញ)៖ លោក សេង លាង ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨នេះ បានប្រកាសសាលក្រមផ្តន្ទាទោស បុរសអនិកជនខ្មែរ-អាមេរិក ម្នាក់ឈ្មោះ វ៉ន្ត យ៉េនវីលៀម (Vorn Yen Viliam) ភេទប្រុស អាយុ៤៧ឆ្នាំ ដាក់ពន្ធនាគារ កំណត់រយៈពេល១០ខែ និងពិន័យជាប្រាក់ចំនួន៣លានរៀល ចូលជាថវិការដ្ឋ និងបង្គាប់ឲ្យជន ជាប់ចោទសងសំណង ទៅដើមបណ្តឹងចំនួន៧នាក់ ចន្លោះពី២លានរៀល ទៅ ៥,៨០០ដុល្លារដុល្លារ ពីបទឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ អំឡុងឆ្នាំ២០១៥ យោងតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

នៅក្នុងសវនាការកាលពីព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨កន្លងទៅ ជនជាប់ចោទបានបដិសេធថា ខ្លួនមិនបានប្រព្រឹត្ត ដូចការចោទប្រកាន់របស់តុលាការនោះទេ។ នេះបើយោងតាមមន្ត្រីតុលាការ បានប្រាប់ភ្នាក់ងារព័ត៌មាន Fresh News ប្រចាំនៅតុលាការនៅព្រឹកនេះ។ គួររំលឹកថា ជនជាប់ចោទត្រូវបានកម្លាំងកងរាជអាវុធហត្ថឃាត់ខ្លួនកាលពីរសៀលថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧កន្លងទៅ នៅចំណុចហាងកាហ្វេ Park Coffee ក្បែរផ្សារសុវណ្ណាតាមពាក្យបណ្តឹងរបស់ពលរដ្ឋរងគ្រោះជាង១០នាក់ ដែលអះអាងថា បានចាញ់បោកជនជាប់ចោទ ក្នុងម្នាក់ៗ ចន្លោះពី ៣,០០០ដុល្លារ ទៅ ៦,០០០ដុល្លារ ដោយសន្យាថានាំពួកគេទៅធ្វើការ នៅប្រទេសអូស្ត្រាលី៕

# មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ អំពាវនាវឲ្យអាជ្ញាធរ លុបបំបាត់ច្រករបៀងនានានៅតាមព្រំដែន ដែលជាមុខសញ្ញានាំទំនិញឆ្លងដែន និងនាំពលករឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2018-02-07

**(ព្រះវិហារ)៖** ថ្លែងនៅក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់ឆ្នាំ ២០១៨ របស់រដ្ឋបាលខេត្តព្រះវិហារ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨នេះ លោក ងី ចន្ទ័ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានជំរុញឲ្យអាជ្ញាធរខេត្ត និងស្រុកនៅតាមព្រំដែន ត្រូវលុបបំបាត់ច្រករបៀងនានា ដែលជាមុខសញ្ញានាំទំនិញឆ្លងដែន និងនាំពលករឆ្លងដែនខុសច្បាប់ ឲ្យមានប្រសិទ្ធភាពបំផុត និងតម្លាភាព។

លោក ងី ចន្ទ័ផល បានលើកឡើងថា «**ច្រករបៀងដែលកើតមានឡើងនៅតាមព្រំដែន គឺជាច្រកដែលនាំទំនិញខុសច្បាប់ ហើយក៏ជាច្រកដែល នាំពលករឆ្លងដែនខុសច្បាប់ផងដែរ។ ដូច្នេះសូមអាជ្ញាធរដែលនៅជាប់ព្រំដែន ត្រូវលុបបំបាត់ច្រករបៀងនេះ ឲ្យមានប្រសិទ្ធិភាពតាមគ្រប់ រូបភាពដែលអាចធ្វើទៅបាន និងត្រូវបន្តយកចិត្តទុកដាក់ការពារទឹកដី អធិបតេយ្យភាព ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ តាមតំបន់ព្រំដែន ការបង្កើនទប់ស្កាត់បទល្មើសឆ្លងដែនរួមមាន៖ បទល្មើសឆ្លងដែនខុសច្បាប់ បទល្មើសគ្រឿងញៀន និងបទល្មើសផ្សេងៗទៀត**»។

លោក ងី ច័ន្ទផល បានបន្តថា ក្នុងនាមអាជ្ញាធរដែនដី ត្រូវបន្តកិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ នៅតាមបន្ទាត់ព្រំដែន ត្រូវបន្តយកចិត្តទុកដាក់ ថែរក្សាការពារបូរណភាពទឹកដី អធិបតេយ្យភាពទឹកដី ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ នៅតាមបន្ទាត់ព្រំដែន ការបង្កើតទប់ស្កាត់បទល្មើស បទល្មើសឆ្លងដែន ឆ្លងកាត់ព្រំដែនគ្រប់ប្រភេទទាំងទំនិញទាំងឧក្រិដ្ឋកម្មឆ្លងដែន និងលើកកម្ពស់ការ ទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរ កម្លាំងមានសមត្ថកិច្ចនៅតាមមូលដ្ឋាន។

លោក ងី ច័ន្ទផល បានលើកឡើងថា ក្នុងន័យនេះរដ្ឋបាលខេត្ត ត្រូវផ្សព្វផ្សាយលើកទឹកចិត្តឲ្យប្រជាពលរដ្ឋប្រើប្រាស់បណ្ណព្រំដែន កម្ពុជា-ថៃ ចេញចូលឆ្លងកាត់ព្រំដែន ដោយធ្វើតាមច្រកចេញចូលតែមួយ ឲ្យមានប្រសិទ្ធិភាព និងតម្លាភាព ក្នុងករណីមានប្រជាពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ហើយត្រូវអង្គាធរប្រទេសជិតខាងបញ្ជូន ឲ្យត្រឡប់មកវិញ អាជ្ញាធរខេត្ត និងសមត្ថកិច្ចប្រចាំការតាមច្រកទ្វារព្រំដែន ត្រូវសហការគ្នាជិតស្និទ ជាមួយសមត្ថកិច្ចប្រទេសជិតខាង ក្នុងការប្រគល់ទទួលបងប្អូនទាំងនោះ ដោយត្រូវយកចិត្តទុកដាក់អំពីសុវត្ថិភាព សុខភាព ជំរកស្នាក់នៅបណ្តោះអាសន្ន អាហារ និងការវិវត្តន៍ត្រឡប់ទៅស្រុកវិញ ព្រមទាំងណែនាំប្រជាពលរដ្ឋយើងឲ្យយល់ពីបញ្ហាប្រឈមនានា ដែលបណ្តាលឲ្យរងគ្រោះដោយការឆ្លងដែនខុសច្បាប់។

លោក ងី ចន្ទ័ផល បានបញ្ជាក់ថា ថ្នាក់ដឹកនាំគ្រប់ថ្នាក់រដ្ឋបាល ត្រូវពង្រឹងរបៀបរបបធ្វើការងារទំនាក់ទំនងការងារសាមគ្គីភាពឯកភាពផ្ទៃក្នុង ឲ្យបានល្អស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាថ្នាក់ដឹកនាំ គ្រប់លំដាប់ថ្នាក់ត្រូវពង្រឹងការដឹកនាំរបស់ខ្លួន ដោយឈរលើគោលការណ៍ បំពេញការងារជាក្រុម ហើយត្រូវស្តាប់មតិយោបល់នានា ឲ្យបានគ្រប់ជ្រុងជ្រោយដោយមិនត្រូវផ្អែកលើមតិ យោបល់បុគ្គលរបស់ខ្លួនមុន និងធ្វើការសម្រេចចិត្តនេះជាក្រឹត្យក្រម នៃអភិបាលកិច្ច។ ចំពោះថ្នាក់ឃុំសង្កាត់ ក៏ត្រូវពង្រឹងការងាររបៀបរបបរបស់ខ្លួនមេឃុំ ចៅសង្កាត់ ស្មៀន មេភូមិ មេក្រុម ត្រូវពិនិត្យវាយតម្លៃចំពោះអកប្បកិរិយា ក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន៕

## ស្ត្រីជាប់ចោទលក់កូនសុំឲ្យបន្ថយទោស

http://www.postkhmer.com/ គីម សារុំ | Publication date 07 February 2018 | 09:44 ICT

ភ្នំពេញៈ ស្ត្រីជាប់ចោទម្នាក់កាលពីម្សិលមិញបានសុំចៅក្រមនៃសភាស៊ើបសួរសាលាឧទ្ធរណ៍ឲ្យបន្ថយទោសពាក់ព័ន្ធករណីយកកូនស្រីទៅលក់ឲ្យជនបរទេសដើម្បីរួមភេទកាលពីឆ្នាំ ២០១០ ហើយត្រូវតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់ពន្ធនាគារ ១០ ឆ្នាំ។

តាមអង្គហេតុ ស្ត្រីជាប់ចោទឈ្មោះ ចាន់ ផល្លី អាយុ ៤៩ ឆ្នាំមានកូនស្រីម្នាក់អាយុ ១៤ ឆ្នាំឈ្មោះ ច.ម.ល រស់នៅផ្ទះលេខ ៣១C សង្កាត់ផ្សារថ្មីទី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញបានទាក់ទងជាមួយបុរសជនជាតិអាមេរិកាំងម្នាក់ដើម្បីលក់កូនស្រីខ្លួនឲ្យរួមភេទ។ លុះនៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១០ សមត្ថកិច្ចបានចុះបង្ក្រាបក្នុងផ្ទះស្ត្រីជាប់ចោទហើយឆែកឃើញស្រោមអនាម័យ និងសម្ភារមួយចំនួនទៀតហើយបានឃាត់ខ្លួនគាត់ជាម្ចាស់ផ្ទះតែម្តង។ សំណុំរឿងនេះត្រូវសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសកាលពីថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១១ ដាក់ពន្ធនាគារ ១០ ឆ្នាំចោទបទ «សមគំនិតក្នុងអំពើទិញពេស្យាចារកុមារ» តាមមាត្រា ៣៤ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ និងធ្វើអាជីវកម្មផ្លូវភេទ។ ចំណែកបុរសជាតិអាមេរិកម្នាក់ត្រូវចាប់បញ្ជូនទៅអាមេរិកវិញ។

ក្នុងបន្ទប់សវនាការពីម្សិលមិញស្ត្រីជាប់ចោទមិនបានឆ្លើយច្រើនទេដោយគ្រាន់តែប្រាប់ចៅក្រមថា៖ «ខ្ញុំទទួលស្គាល់កំហុសរបស់ខ្ញុំដែលលក់កូនស្រីឲ្យគេរួមភេទ ប៉ុន្តែកូនខ្ញុំបន្ទាប់ពីសមត្ថកិច្ចរំដោះបានពីហេតុការណ៍នោះ ខាងអង្គការមួយគេយកនាងទៅរស់នៅក្នុងមណ្ឌលគេហើយ។ ខ្ញុំសុំឲ្យតុលាការបន្ថយទោសដល់ខ្ញុំផងព្រោះខ្ញុំជាប់ពន្ធនាគារបាន ៩ ឆ្នាំ ២ ខែហើយនៅសល់តែ ៨ ខែទៀតប៉ុណ្ណោះនឹងគម្រប់ឆ្នាំឃុំខ្លួនខ្ញុំហើយ»។ លោកព្រះរាជអាជ្ញា ង៉ែត សារ៉ាត តំណាងមហាអយ្យការសន្និដ្ឋានថាស្ត្រីជាប់ចោទបានសារភាព ប៉ុន្តែសមត្ថកិច្ចឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែង។ «ការផ្តន្ទាទោសរបស់សាលាដំបូងរាជធានីភ្នំពេញត្រឹមត្រូវ ហើយដូច្នេះខ្ញុំសូមតម្កល់សាលក្រមទុកជាបានការដដែល»។ លោក នូ ចន្ថា មេធាវីការពារសិទ្ធិស្ត្រីជាប់ចោទសន្និដ្ឋានថាក្នុងអង្គហេតុនេះជនបរទេសនោះត្រូវបញ្ជូនទៅប្រទេសគេវិញឯកូនក្តីលោកក៏បានជាប់ពន្ធនាគារជាង ៩ ឆ្នាំហើយដែរ។ លោកថ្លែងថា៖ «សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យពិចារណាតម្រឹមទោសរបស់កូនក្តីខ្ញុំឲ្យនៅត្រឹម ៩ ឆ្នាំ ២ ខែនេះបានហើយ»។ ក្រោយជំនុំជម្រះលោកចៅក្រម ប៉ាក ច័ន្ទសំបូរ ប្រធានក្រុមប្រឹក្សាជំនុំជម្រះថ្លែងថា សាលដីកានេះនឹងប្រកាសនៅថ្ងៃទី ១ ខែមីនាខាងមុខ៕

## បង្ក្រាបទីតាំងម៉ាស្សាកោសជប់យីហោ ម៉ាស្សាខ្មែរបុរាណ ឃាត់ខ្លួនមនុស្ស៩នាក់ ក្នុងនោះបុរស៣នាក់ជាភ្ញៀវ

http://nokorwatnews.com/ ថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០១៨

ភ្នំពេញ៖ កម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន ក្រសួងមហាផ្ទៃ សហការជាមួយអង្គការ NGO និងនគរបាលមូលដ្ឋាន និងមានការសម្របសម្រួលពីព្រះរាជអាជ្ញារង កុល ប៊ុន បានធ្វើការចុះបង្ក្រាបទីតាំងម៉ាស្សាកោសជប់មួយកន្លែង យីហោ ម៉ាស្សាខ្មែរបុរាណ ដាក់ស្តែងឃាត់ខ្លួនមនុស្សប្រុសស្រី៩នាក់ ក្នុងនោះបុរស៣នាក់ជាភ្ញៀវផងដែរ ។ ករណីចុះបង្ក្រាបទីតាំងហាងម៉ាស្សាខាងលើនេះ បានធ្វើឡើងកាលពីវេលាម៉ោង៩យប់ ថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ថិតនៅចំណុចផ្ទះលេខ២៥៤ ផ្លូវលេខ៣៧១ ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

យោងតាមប្រភពពីមន្ត្រីនគរបាលដែលចុះបង្ក្រាបដាក់ស្តែង បានឲ្យដឹងថា ប្រតិបត្តិការនេះ ដឹកនាំដោយលោកវរៈសេនីយ៍ឯក ឆាន វុធ នាយការិយាល័យ និងនាយកដ្ឋានការជួញដូរមនុស្សនិងអនិតិជន រួមទាំងលោក កាន់ វណ្ណារិទ្ធ អនុប្រធាននាយកដ្ឋាន ដោយមានការចូលរួមដោយអង្គការ NGO និងមានការសម្របសម្រួលដោយលោក កុល ប៊ុន ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ បច្ចុប្បន្នមនុស្សប្រុស ស្រីទាំង៩នាក់ ដែលសមត្ថកិច្ចឃាត់ខ្លួន ត្រូវបានកម្លាំងនគរបាលបញ្ជូនទៅមន្ទីរប្រឆាំងការជួញដូរមនុស្សនិងអនិតិជនក្រសួងមហាផ្ទៃ ដើម្បីធ្វើការសាកសួរនិងកសាងសំណុំរឿងចាត់ការបន្តតាមនីតិវិធី ៕ ស តារា

## ពលករត្រូវសង្គ្រោះពី អារ៉ាប៊ី សាអ៊ូឌីត ថាខ្លួនត្រូវគេបង្ខំឲ្យធ្វើការដូចទាសករ

http://www.postkhmer.com/ យន់ ស៊ីនាត and Daphne Chen | Publication date 07 February 2018 | 14:01

**ភ្នំពេញ៖** កាលពី ១៣ ឆ្នាំមុនបុរស ២ នាក់បានមកផ្ទះរបស់អ្នកនាង អេង ពៅ ក្នុងខេត្តត្បូងឃ្មុំ និងបានគោះទ្វារផ្ទះរបស់នាង។ អ្នកនាង ពៅ ដែលកាលពេលនោះអាយុប្រមាណជា ២១ ឆ្នាំមិនបានចាំឈ្មោះពួកគេទេ។ អ្វីដែលនាងចាំគឺពួកគេសន្យាផ្តល់ឲ្យនូវការងារជាស្ត្រីបម្រើតាមផ្ទះនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីតប្រាក់ខែ ១៨០ ដុល្លារក្នុងមួយខែជាមួយនិយោជកចិត្តល្អផ្តល់អាហារហូបចុក សម្លៀកបំពាក់ និងសេរីភាពទូរស័ព្ទមកផ្ទះតាមការចង់។

១៣ ឆ្នាំក្រោយមកអ្នកនាង អេង ពៅ ទើបដឹងថានាងគឺជាទាសករម្នាក់។ អ្នកនាង ពៅ បានថ្លែងខណៈកំពុងជូតទឹកភ្នែក និងរៀបរាប់អំពីការរំលោភបំពានរយៈពេលជាងមួយទសវត្សរ៍ និងការរត់គេចដែលបានធ្វើឲ្យអ្នកនាង ត្រូវបានបញ្ជូនត្រឡប់មកប្រទេសវិញតាមរយៈការជួយពីក្រសួងការងារកាលពីខែមុនថា៖ «[ខណៈកំពុងនៅក្នុងប្រទេសអារ៉ាប៊ីសាអ៊ូឌីត] ខ្ញុំស្ទើរតែបាត់បង់ជីវិត»។ អ្នកនាង ពៅ ឥឡូវនេះគឺជាស្ត្រីទី ២ ត្រូវបានជួយសង្គ្រោះចេញពីស្ត្រីបម្រើការងារតាមផ្ទះប្រមាណ ១០០ នាក់ដែលត្រូវបានជ្រើសរើសដោយលោកអះម៉ាត់ យ៉ះយ៉ា ដែលជាមេដឹកនាំសហគមន៍អ៊ិស្លាមក្នុងឆ្នាំ ២០០៥ ដើម្បីទៅធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត ក្រោមកម្មវិធីដែលក្រសួងការងារឥឡូវនេះ និយាយថាខុសច្បាប់។

លោក យ៉ះយ៉ា បានទទួចថាលោកត្រូវបានផ្តល់ឲ្យនូវការអនុញ្ញាតច្បាស់លាស់ក្នុងការជ្រើសរើស និងបញ្ជូនស្ត្រីបម្រើការងារតាមផ្ទះ តាមរយៈប្រកាសមួយស្តីពី «ការអនុញ្ញាតឲ្យក្រុមហ៊ុន ACCEPT Group ជ្រើសរើសបណ្តុះបណ្តាល បញ្ជូននិង គ្រប់គ្រងពលករកម្ពុជាទៅធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត] ដែលចុះហត្ថលេខាដោយលោក ញ៉េប ប៊ុនជិន ដែលជារដ្ឋមន្ត្រីការងារកាលពេលនោះ និងជាតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបច្ចុប្បន្ន។

ប៉ុន្តែលោក ប៊ុនជិន នៅពេលទាក់ទងបានថ្លែងថាលោកបានផ្តល់ការអនុញ្ញាតដល់លោក យ៉ះយ៉ា តែដើម្បី « ស្វែងរកទីផ្សារ» ហើយរាយការណ៍មកក្រសួងវិញ។ លោក ប៊ុនជិន ថ្លែងថា៖ «ខ្ញុំនិយាយថានេះជាពេលវេលាត្រឹមត្រូវដោយសារទីផ្សារបានបើកចំហមួយរយៈហើយវាជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលដើម្បីស្វែងរក និងបញ្ជូនពលករចំណាកស្រុកទៅប្រទេសផ្សេងៗ» ។ ទោះបីយ៉ាងណាក្តីលោកបន្តថា៖ «ខ្ញុំប្រាកដថា ខ្ញុំមិនបានផ្តល់សិទ្ធិនូវកិច្ចព្រមព្រៀងបច្ចេកទេសណាមួយដើម្បីបញ្ជូនស្ត្រីបម្រើការងារតាមផ្ទះទៅប្រទេសអារ៉ាប៊ីសាអ៊ូឌីតនោះទេ»។ គេមិនដឹងថាតើមាន

ស្ត្រីចំនួនប៉ុន្មាននាក់នៅក្នុងក្រុមរបស់អ្នកនាង ៣៧ មានសំណាងបានត្រឡប់មកប្រទេសកម្ពុជាវិញដោយសុវត្ថិភាពនោះទេ។

លោក យ៉ះយ៉ា ដែលជាមេដឹកនាំសហគមន៍អ៊ិស្លាមល្បីម្នាក់ថ្លែងថាលោកបានបាត់ដានពួកគេ បន្ទាប់ពីក្រសួងដកអាជ្ញាប័ណ្ណរបស់លោក ទើបតែបីខែបន្ទាប់ពីទទួលបានលិខិតអនុញ្ញាត។ លោក យ៉ះយ៉ា ថា៖ «វាមិនស្ថិតនៅក្នុងការទទួលខុសត្រូវរបស់ខ្ញុំទៀតទេ»។ ខ្ញុំបារម្ភ ប៉ុន្តែតើខ្ញុំអាចធ្វើអ្វីបាន? គ្មាននរណាម្នាក់ទាក់ទងមកខ្ញុំ ដូច្នេះតើខ្ញុំអាចដឹងអំពីស្ថានភាពនៅទីនោះយ៉ាងម៉េចទៅ?»។ កាលពេលនោះបុគ្គលិកក្រុមហ៊ុនជ្រើសរើសពលកររបស់លោក យ៉ះយ៉ា បានចុះទៅឃុំស្វាយឃ្លាំង ក្នុងស្រុកក្រូចឆ្មារ ខណៈអ្នកនាង ៣៧ កំពុងចង់ផ្លាស់ប្តូរជីវិតរបស់ខ្លួន។

អ្នកនាង ៣៧ បានរត់ចេញពីឪពុកចុងដែលមានលក្ខណៈបំពាននៅអាយុ ១៦ ឆ្នាំ។ អ្នកនាងមិនចេះអក្សរ និងរស់នៅជាមួយម្តាយចិញ្ចឹមអាយុ ៥៤ ឆ្នាំឈ្មោះ ស្លិះ ម៉ាស់យ៉ាន់ ហើយនៅទីបំផុតបានរៀបការជាមួយក្មួយប្រុសរបស់ម៉ាស់យ៉ាន់ និងមានកូនប្រុសម្នាក់។ នៅពេលទៅដល់ទីភ្នាក់ងារជ្រើសរើសស្ត្រីបម្រើការងារតាមផ្ទះនៅទីក្រុង Jeddah អ្នកស្រី ៣៧ និងស្ត្រីបម្រើការងារតាមផ្ទះដទៃៗទៀតត្រូវបានគេរឹបអូសយកលិខិតឆ្លងដែន និងបំបែកឲ្យរស់នៅផ្សេងគ្នា។ បន្ទាប់ពីធ្វើការងារបានពីរបីខែជាមួយគ្រួសារមួយ អ្នកនាងត្រូវបានគ្រួសារនោះប្រាប់ឲ្យរើអីវ៉ាន់ចេញ។ ភ្លាមៗនោះអ្នកនាង ៣៧ ត្រូវបានបញ្ជូនទៅផ្ទះមួយទៀតដែលមានចម្ងាយជាង ២០០០ គីឡូម៉ែត្រគឺនៅទីក្រុង Riyadh។ នៅទីនោះអ្នកនាង ៣៧ បាននិយាយថាប្តីប្រពន្ធក្នុងវ័យអាយុជាង ៥០ ឆ្នាំបានបង្ខំអ្នកនាងឲ្យធ្វើការងារ ២០ ម៉ោងក្នុងមួយថ្ងៃ និងហូបរបស់នៅសល់ ហើយចាក់សោឃុំអ្នកនាងនៅក្នុងផ្ទះ នៅពេលពួកគេចាកចេញ និងកាត់ផ្តាច់លទ្ធភាពប្រើប្រាស់ទូរស័ព្ទ។ អ្នកនាងបន្តថា នៅពេលអ្នកនាងសួររកប្រាក់ខែ ពួកគេស្រែកដាក់នាង។ នៅពេលបុណ្យរ៉ាម៉ាដាន អ្នកនាងត្រូវបានផ្តល់ឲ្យនូវការងារច្រើនដែលស្ទើរតែមិនអាចដេកបានរយៈពេលជាច្រើនសប្តាហ៍។ បន្ទាប់ពីស្ថានភាពដូចទាសកររយៈពេល ៥ ឆ្នាំ អ្នកនាង ៣៧ បានព្យាយាមរត់ប៉ុន្តែត្រូវគេចាប់បាន។ អ្នកនាងថ្លែងថា៖ «ពួកគេបានចាប់ផ្តើមវាយខ្ញុំ ទះកំផ្លៀង មុខខ្ញុំ និងទាត់ខ្លួនខ្ញុំ»។ «បុរសទាំង ២ នាក់នោះគឺជាឪពុក និងកូនបានវាយខ្ញុំយ៉ាងខ្លាំង...បន្ទាប់មកពួកគេឃុំខ្ញុំនៅជាន់ក្រោមដី ហើយប្រពន្ធបុរសនោះបានមកដល់ ហើយចាប់ផ្តើមវាយខ្ញុំដែរ»។

ខណៈកំពុងអង្គុយនៅក្នុងភោជនីយដ្ឋានតូចមួយរបស់គ្រួសារដែលមានពេទ្យធ្មេញផងដែរនោះអ្នកនាង ៣៧ មានអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំងនៅពេលកំពុងរៀបរាប់អំពីការចាក់សោនៅក្នុងជាន់ក្រោមដីរយៈពេលច្រើនថ្ងៃហើយទទួលរងការវាយដំ។ «ខ្ញុំមិនអាចទាក់ទងនរណាបាន។ ខ្ញុំគ្មានមិត្តភក្តិ ឬគ្មាននរណាជួយខ្ញុំ»។ ត្រឡប់មកត្បូងឃ្មុំវិញ ម្តាយចិញ្ចឹមរបស់អ្នកនាង ៣៧ និង មីង បានថ្លែងថា ពួកគាត់បានទៅជួបលោក យ៉ះយ៉ា ចំនួន ២ ដងម្តងប្រហែល ២ ឆ្នាំបន្ទាប់ពីនាងបានបាត់ខ្លួន និងម្តងទៀត ៣ ឆ្នាំក្រោយមក ខណៈការអះអាងនេះត្រូវលោក យ៉ះយ៉ា បដិសេធ។

អ្នកស្រី ម៉ាស់យ៉ាន់ ដែលជាម្តាយចិញ្ចឹមរបស់អ្នកនាង ៣៧ បានថ្លែងទាំងទឹកភ្នែកថានៅទីបំផុតអ្នកស្រីបាន «សន្មតថានាងបានស្លាប់»។ ប្តីរបស់អ្នកនាង ៣៧ បានធ្វើការជាអ្នកនេសាទនៅប្រទេសថៃ និងបានស្លាប់នៅក្នុងការប្លន់មួយមិនយូរប៉ុន្មានបន្ទាប់ពីអ្នកនាង ៣៧ បានចាកចេញ។ កូនប្រុសរបស់អ្នកនាង ៣៧ ឥឡូវនេះធាត់ កាលពីមុនស្គមមានតែឆ្អឹង។ អ្នកស្រី ម៉ាស់យ៉ាន់ ថ្លែងថា៖ «ខ្ញុំស្ទើរតែភ្លេចនាង»។ នៅទីក្រុង Riyadh អ្នកនាង ៣៧ បានសម្រេចចិត្តព្យាយាមរត់គេចម្តងទៀត លើកនេះក្នុងអំឡុងបុណ្យរ៉ាម៉ាដានធំនៅសួនច្បាររបស់គ្រួសារនោះ។ ដោយគ្មានយកអ្វីជាប់នឹងខ្លួនច្រើន អ្នកនាង ៣៧ បានរត់ទៅប៉ុស្តិ៍នគរបាលក្នុងស្រុក ដែលនគរបាលបានបដិសេធជួយនាង។ បន្ទាប់មកអ្នកនាងបានដើរដោយគ្មានគោលដៅអស់រយៈពេលជាច្រើនម៉ោងរហូតដល់អ្នកនាងទៅដល់មុខផ្ទះចម្លែកមួយ និងបានលុតជង្គង់សុំការជួយ។ ប្រពន្ធម្ចាស់ផ្ទះនេះអាណិតនាង ហើយនៅទីបំផុតបានយកអ្នកនាង ៣៧ ធ្វើជាអ្នកបម្រើក្នុងផ្ទះ និងផ្តល់លេខទូរស័ព្ទទំនាក់ទំនងមកគ្រួសារ។ វាចំណាយពេលមួយឆ្នាំទៀតសម្រាប់អ្នកនាង ៣៧ និងគ្រួសាររបស់អ្នកនាង ដើម្បីស្វែងរកពលរដ្ឋជនជាតិកម្ពុជាម្នាក់នៅក្នុងប្រទេសអារ៉ាប៊ីសាអ៊ូឌីត ដែលបុរសម្នាក់នោះជាមន្ត្រីរដ្ឋាភិបាល ដែលនៅទីបំផុតអ្នកនាង ៣៧ បានរៀបការជាមួយ។ បុរសម្នាក់នេះមានឆន្ទៈជួយបញ្ជូនអ្នកនាងត្រឡប់មកប្រទេសកំណើតវិញ។ នៅត្រឹមរយៈពេល អ្នកនាង៣៧បានត្រឡប់មកដល់ព្រលានយន្តហោះភ្នំពេញកាលពីខែមុនតាមរយៈការជួយពីមន្ត្រីក្រសួងការងារ លោក ឧស្មាន ហាស្សាន់ អ្នកនាង ៣៧ បានជាប់នៅក្នុងប្រទេសអារ៉ាប៊ីសាអ៊ូឌីតរយៈពេល

១៣ ឆ្នាំ។ អ្នកតស៊ូមតិដើម្បីសិទ្ធិការងារថ្លែងថាសាច់រឿងរបស់អ្នកនាង ពៅ គឺជាឧទាហរណ៍នៃហានិភ័យដែលពលករចំណាកស្រុកជួបប្រទះនៅពេលទៅធ្វើការនៅក្រៅប្រទេស រួមមានដូចជាការរំលោភបំពានសិទ្ធិមនុស្ស។

លោក មឿន តុលា នៅអង្គការ Central ថ្លែងថាករណីរបស់អ្នកនាងពៅ «គឺជារឿងគួរឲ្យរន្ធត់ ជាពិសេសដោយសារអ្នកនាងត្រូវបានកាត់ផ្ដាច់ពីគ្រួសារអស់រយៈពេលជាង ១០ ឆ្នាំ»។ បើតាមលោក តុលា លិខិតអនុញ្ញាតដែលបានចុះហត្ថលេខាដោយលោក ប៊ុនជិន ហាក់ដូចជារំលោភច្បាប់ដោយបានអនុញ្ញាតឱ្យក្រុមហ៊ុន Yahya បញ្ជូនពលករបម្រើការងារតាមផ្ទះទៅប្រទេសអារ៉ាប៊ីសាអ៊ូឌីតទោះបីជាការពិតរដ្ឋាភិបាលមិនទាន់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយរដ្ឋនៅឈូងសមុទ្រនោះក៏ដោយ។ លោក តុលា បន្តថា៖ «វាគួរតែមានវិធានការរដ្ឋបាលត្រឹមត្រូវដើម្បីប្រឆាំងនឹងអ្នកដែលបានផ្ដល់អាជ្ញាប័ណ្ណហើយវាក៏គួរតែមានវិធានការដាក់លាក់ចំពោះក្រុមហ៊ុន ... ដើម្បីព្រមានដល់អ្នកជ្រើសរើស ឬក្រុមហ៊ុនឯកជនដែលមិនអនុវត្តតាម»។

អ្នកស្រី សូហ្វា រីណា ជាអ្នកស្រាវជ្រាវជនជាតិចាមថ្លែងថារដ្ឋាភិបាលគួរតែពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងរបស់ខ្លួនដែលមានស្រាប់ជាមួយប្រទេសអារ៉ាប៊ីសាអ៊ូឌីត ដោយសារតែមានករណីរំលោភបំពានលើអ្នកស្រី ពៅ និងមានករណីជាច្រើនផ្សេងទៀតដែលបានកើតឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ប្រទេសកម្ពុជា និងអារ៉ាប៊ីសាអ៊ូឌីតបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់មួយដើម្បីចាប់ផ្ដើមការពិភាក្សាចុងក្រោយអំពីការបញ្ជូនពលករបម្រើការងារតាមផ្ទះកាលពី ២ ឆ្នាំមុន ប៉ុន្តែកិច្ចព្រមព្រៀងនោះមិនដែលបានបញ្ចប់នោះទេ។

ទោះបីយ៉ាងនេះក្ដីក៏នៅតែមានក្រុមហ៊ុនជ្រើសរើសពលករចំនួន ១៨ នៅតែបានទទួលការអនុញ្ញាតឱ្យបញ្ជូនពលករបម្រើការតាមផ្ទះទៅកាន់រដ្ឋក្នុងឈូងសមុទ្រនោះដដែល ប៉ុន្តែពលករដែលបានវិលត្រឡប់មកកម្ពុជាវិញនិយាយថាពួកគេបានទៅតាមរយៈឈ្មួញកណ្ដាលឯករាជ្យ។

អ្នកស្រី ហ្សារីយ៉ា បានថ្លែងថា៖ «ស្ត្រីម្នាក់នេះត្រូវបានបញ្ជូនត្រឡប់មកវិញ ប៉ុន្តែវាបានផ្ដល់សញ្ញាមួយឱ្យយើងគួរតែមានការប្រុងប្រយ័ត្នជាងមុន។ ឥឡូវនេះយើងបានដឹងពីបញ្ហានោះ។ យើងមិនចង់ឲ្យបញ្ហាបែបនោះកើតឡើងជាថ្មីម្ដងទៀតទេ»។

អ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ មិនបានឆ្លើយសំណួរទាក់ទងទៅនឹងស្ថានភាពនៃអនុស្សរណៈនៃការយោគយល់គ្នានេះទេ ហើយសំណួរថាតើក្រសួងមានបានធ្វើការស៊ើបអង្កេតលើករណីរំលោភបំពានពលករបម្រើការងារតាមផ្ទះនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត កាលពីអតីតកាលដែរឬក៏អត់? លោកសួរបានលើកឡើងតាមរយៈសារមួយថា៖ «នៅពេលណាយើងទទួលបានពាក្យបណ្ដឹង និងព័ត៌មាននោះយើងនឹងធ្វើអន្តរាគមន៍»។

ប៉ុន្តែលោកស្រី ជូ ប៊ុនអេង ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃបានថ្លែងថាវាមិនងាយស្រួលទេ សម្រាប់ករណីរបស់អ្នកស្រី ពៅ ក្នុងការស្វែងរកយុត្តិធម៌ពីអ្នករំលោភបំពានលើរូបគាត់។ លោកស្រីបន្តថា៖ «គាត់អាចដាក់ពាក្យបណ្ដឹងបាន ប៉ុន្តែការសម្រេចគឺអាស្រ័យលើតុលាការនៅទីនោះ [នៅអារ៉ាប៊ីសាអ៊ូឌីត]។ មិនមែននៅខាងយើងទេ»។ ចំពោះអ្នកស្រី ពៅ ការទទួលបានយុត្តិធម៌ហាក់ដូចជានៅឆ្ងាយណាស់។ គាត់នៅតែមានបញ្ហាចំពោះការនិយាយភាសាអារ៉ាប់ជំនួសឱ្យការនិយាយភាសាខ្មែរនៅឡើយ ហើយត្រូវចំណាយពេលវេលាយូរដើម្បីបំភ្លេចអំពីការរំលោភបំពានលើរូបនាង។ លើសពីនេះអ្នកស្រី ពៅ កំពុងព្យាយាមផ្សារភ្ជាប់ទំនាក់ទំនងជាមួយគ្រួសាររបស់នាងឡើងវិញ បន្ទាប់ពីនាងអវត្តមានអស់រយៈពេល ១៣ ឆ្នាំមកហើយនោះ។

អ្នកស្រី ម៉ាយ៉ាន ថ្លែងថានៅពេលអវត្តមានរបស់អ្នកស្រី ពៅ គឺពិតជាលំបាកខ្លាំងណាស់សម្រាប់កូនប្រុសរបស់គាត់។ ដោយអ្នកស្រីបានរំឭកថា ពេលនោះកូនអ្នកស្រី ពៅ គឺគ្រាន់តែជាក្មេងប្រុសតូចម្នាក់ដែលមានអាយុទើបតែ ៦ ឬ ៧ ឆ្នាំប៉ុណ្ណោះ ហើយគាត់តែងតែយំនៅពេលក្មេងៗដទៃទៀតសើចចំអកឲ្យគាត់ថាជាក្មេងដែលត្រូវឪពុកម្ដាយបោះបង់ចោល។ អ្នកស្រីថ្លែងថារហូតមកដល់ពេលនេះកូនអ្នកស្រី ពៅ ឈ្មោះ ស្មាន សុគ្រី អាយុ ១៨ ឆ្នាំហើយ ប៉ុន្តែនៅមិនទាន់និយាយរកម្ដាយរបស់គាត់នៅឡើយទេ បើទោះបីជាមានការជំរុញក្ដី។ ប៉ុន្តែគាត់និយាយថាគាត់សប្បាយចិត្តនៅពេលម្ដាយរបស់គាត់ត្រឡប់មកផ្ទះវិញ។ សុគ្រី ថា៖ «ខ្ញុំគ្រាន់តែអៀន»។ «ខ្ញុំមិនដែលគិតថាខ្ញុំនៅមានម្ដាយនោះទេ»។ ប៉ុន្តែនៅពេលអ្នកស្រី ពៅ ដាក់ដៃលើស្មាដើម្បីថតរូប សុគ្រី បានងាកចេញមិនឲ្យគាត់ដាក់ដៃឱប

ទេ។ អ្នកស្រី ពៅ និយាយថា៖ «គាត់ខឹងខ្ញុំ នៅពេលនោះទឹកភ្នែកគាត់បានហូរម្តងទៀតហើយការពិតនេះហាក់ដូចជាបានធ្វើឱ្យគាត់សោកសៅខ្លាំងបំផុត»៕ PS /NS

## សេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូត ករណីពលករខ្មែរចំនួន ២៩នាក់ត្រូវបានអាជ្ញាធរថៃឃាត់ខ្លួននៅខេត្តស៊ីងបុរី ប្រទេសថៃ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok

ព្រះរាជាណាចក្រកម្ពុជា

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា

ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០៥៥ /១៨/សកប៥

### សេចក្តីប្រកាសព័ត៌មាន

យោងតាមការចុះផ្សាយរបស់ គណនីហ្វេសប៊ុកឈ្មោះ Ngan Tit កាលពីថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១៨ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ មានការសោកស្តាយចំពោះការលើកឡើងរបស់ម្ចាស់គណនីហ្វេសប៊ុករូបនេះ ដែលបានលើកឡើងថា *"ពលករចំនួន ៣០នាក់ ត្រូវបានអាជ្ញាធរខេត្តស៊ីងបុរី ទារអោយបង់ ៩០០,០០០បាត ជាថ្នូរនឹងការដោះលែងអោយមានសេរីភាពវិញ ដោយគ្មានការចូលរួមដោះស្រាយពីស្ថានទូតខ្មែរប្រចាំប្រទេសថៃ "។*

ដើម្បីចៀសវាងការយល់ច្រឡំ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សូមធ្វើការបំភ្លឺជូនសារធារណជន ដូចតទៅ៖

១. ស្ថានទូត មិនមែនមិនដោះស្រាយបញ្ហាជូនបងប្អូនពលករនោះទេ ប៉ុន្តែស្ថានទូត ពុំទទួលបានការទំនាក់ទំនងពីបងប្អូនពលករ មិត្តភ័ក្ត និងសាច់ញាតិរបស់ពលករ ឱ្យជួយដោះស្រាយលើករណីនេះ ហើយអាជ្ញាធរថៃ ក៏មិនបានជូនដំណឹងមកស្ថានទូតដែរ។

២. បន្ទាប់ពីទទួលបានព័ត៌មានពីបណ្តាញសង្គមហ្វេសប៊ុក នាព្រឹកថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១៨ ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករ តំណាងឱ្យឯកឧត្តមឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះទៅការិយាល័យប៉ូលីស ស្រុកស៊ីងបុរី ខេត្តស៊ីងបុរី ប្រទេសថៃ ដើម្បីដោះស្រាយបញ្ហា។ ពលករទាំងអស់សរុបចំនួន ២៩នាក់ គឺជាពលករដែលមានលិខិតឆ្លងដែន/លិខិតធ្វើដំណើរនិងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស(OCWC) ទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារត្រឹមត្រូវ ប៉ុន្តែពលករទាំងអស់នោះបានធ្វើការខុសនិយោជក និងទីកន្លែងធ្វើការ ដែលមានបញ្ជាក់នៅក្នុងប័ណ្ណអនុញ្ញាតការងារ ទើបសមត្ថកិច្ចថៃឃាត់ខ្លួន។

៣. អនុលោមតាមមាត្រាទី ១២១ របស់ព្រះរាជក្រឹត្យថៃស្តីពីការគ្រប់គ្រងការធ្វើការរបស់ពលករបរទេស គឺមិនត្រូវបានអនុញ្ញាតឱ្យពលករធ្វើការខុសនិយោជក និងទីកន្លែងធ្វើការដែលមានបញ្ជាក់ច្បាស់ក្នុងប័ណ្ណអនុញ្ញាតការងារ ប្រសិនបើពុំដូច្នោះទេ ពលករនឹងត្រូវមានទោសពិន័យមិនលើសពី ១០០,០០០បាត ក្នុងពលករម្នាក់។

៤. បច្ចុប្បន្ន សមត្ថកិច្ច កំពុងតែកសាងសំណុំរឿង ដើម្បីបញ្ជូនទៅតុលាការសម្រេចសេចក្តី ក្នុងការពិន័យ និងដោះលែងវិញ ដោយនិយោជកថ្មីបានបញ្ជាក់ថានឹងចេញប្រាក់ពិន័យទាំងអស់ជំនួសពលករ និងដំណើរការប្តូរនិយោជកជូនពលករទាំងអស់។

អាសយដ្ឋាន 518/4 Pracha Uthit Road, Soi Ramkamhaeng 39, Wangthonglang, Bangkok 10310, Kingdom of Thailand
ទូរស័ព្ទ: (៦៦-២) ៩៥៧ ៥៨៥១/៩៥៧ ៥៨៥២ ទូរសារ:(៦៦-២) ៩៥៧ ៥៨៥០ អ៊ីម៉ែល: camemb.tha@mfa.gov.kh

សូមបញ្ជាក់ផងដែរថា ជាក់ស្តែង ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃឡង់ដ៍ តែងតែយកចិត្តទុកដាក់ចំពោះបងប្អូនពលករ និងពលរដ្ឋកម្ពុជា ដែលចូលមកស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃទាំងស្របច្បាប់ និងមិនទាន់ស្របច្បាប់ តាមរយៈការសម្រួលនីតិវិធីនៃការចេញឯកសារបញ្ជាក់នានា ការបើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ ប័ណ្ណOCWC លិខិតបញ្ជាក់បុគ្គលតែមួយ ការផ្តល់សេវាប្រឹក្សាយោបល់ការដោះស្រាយបញ្ហាដូចជា គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ចរាចរណ៍ ជំលោះរវាងពលករនិងនិយោជកថៃ អាជ្ញាធរមានសមត្ថកិច្ចថៃឃាត់ខ្លួន រងគ្រោះដោយសារចាញ់បោកមេខ្យល់ ឬការជួញដូរមនុស្ស ជាដើម ព្រមទាំងជួយសម្របសម្រួលជាមួយភាគីថៃ ដើម្បីឱ្យបងប្អូនពលករមិនទាន់ស្របច្បាប់ទាំងអស់ក្លាយជាពលករស្របច្បាប់ នឹងទទួលបានសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗ ស្របតាមច្បាប់ និងបទដ្ឋានអន្តរជាតិ ជាពិសេសស្របតាមច្បាប់ការងារថៃ។

ក្នុងករណីបងប្អូនពលករកម្ពុជា មានបញ្ហាទាក់ទងការស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ បងប្អូនត្រូវធ្វើការទំនាក់ទំនងមកមន្ត្រីស្ថានទូតកម្ពុជានៅទីក្រុងបាងកក តាមរយៈទូរស័ព្ទលេខ ០២ ៩៥៧ ៥៨៥១/០៨៦ ៧៩៩ ៩៩៥៧ / ០៩៤ ០៩២ ៥៩០៥ / ០៦៤ ៧៥៤ ៧៤០១/០៨២ ៤២២ ០០១១ និង ០៨២ ៤២២ ០០៤៤។ ក្នុងករណីដែលបងប្អូនបានធ្វើការទំនាក់ទំនងហើយ មន្ត្រីដែលទទួលបន្ទុកមិនបានធ្វើការដោះស្រាយជូនបងប្អូន សូមបងប្អូនធ្វើការសរសេរលិខិត ផ្ញើមកស្ថានទូតតាមរយៈអាសយដ្ឋាន អាគារលេខ ៥១៨/៤ ផ្លូវប្រាធាអ៊ុធិត (ប្រករ៉ាមឃឹមហេង ៣៩) សង្កាត់វាំងថុងឡាង ខណ្ឌវាំងថុងឡាង ទីក្រុងបាងកក ១០៣១០ ទូរសារលេខ (៦៦-២) ៩៥៧ ៥៨៥០ និងអ៊ីម៉ែល camemb.tha@mfa.gov.kh។

ឆ្លៀតឱកាសនេះ ស្ថានទូតសូមប្រកាសផ្សព្វផ្សាយជាសាធារណៈឱ្យគ្រប់ពលរដ្ឋខ្មែរទាំងអស់ ដែលរស់នៅក្រៅប្រទេស ចាំបាច់ត្រូវទាក់ទងមកស្ថានទូតកម្ពុជា នៅពេលបងប្អូនជួបប្រទះគ្រប់បញ្ហាទាំងអស់ពាក់ព័ន្ធនឹងការ រស់នៅ និងប្រកបការងារនៅក្រៅប្រទេស។

សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ០៦រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

បាងកក ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៨

## ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៨

### បេក្ខជនតំណាងរាស្ត្របក្សប្រឆាំងម្នាក់ទៀតត្រូវចាប់ខ្លួនពាក់ព័ន្ធការបញ្ជូនពលករទៅក្រៅប្រទេស

https://www.rfa.org/khmer/ ដោយ ទីន ហ្សាការីយ៉ា 2018-02-07

នគរបាលនៃក្រសួងមហាផ្ទៃ ចាប់ខ្លួនបេក្ខជនតំណាងរាស្ត្រមិនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ មណ្ឌលកំពង់ចាម ឈ្មោះ អ៊ីស្មាអែល ពិនឧស្មាន នៅថ្ងៃទី៧ ខែកុម្ភៈ ពីបទទាក់ទងបញ្ជូនពលករខ្មែរទៅក្រៅប្រទេស។

ប្រធានក្រុមការងារគណបក្សសង្គ្រោះជាតិ ខែត្រត្បូងឃ្មុំ លោក វ៉ាន់ ណារិទ្ធ និងជាតំណាងរាស្ត្រមណ្ឌលកំពង់ចាម ដែលកំពុងភៀសខ្លួននៅក្រៅប្រទេសបញ្ជាក់ថា លោកមិនទាន់ដឹងពីមូលហេតុពិតប្រាកដពីការចាប់ខ្លួនបេក្ខជនតំណាងរាស្ត្រ លោក អ៊ីស្មាអែល ពិនឧស្មាន នេះទេ ប៉ុន្តែលោកបញ្ជាក់ថា ការចាប់ខ្លួននេះពាក់ព័ន្ធនឹងរឿងនយោបាយ៖ «»។ លោក វ៉ាន់ ណារិទ្ធ ឲ្យដឹងទៀតថា លោក អ៊ីស្មាអែល ពិនឧស្មាន ធ្លាប់បានភៀសខ្លួនទៅនៅប្រទេសថៃ មួយរយៈដើម្បីសុវត្ថិភាព ព្រោះថា គណបក្សប្រជាជនកម្ពុជា បញ្ចុះបញ្ចូលលោកឲ្យចុះចូលជាមួយគណបក្សកាន់អំណាចជាច្រើនដងនៅអំឡុងពេលរដ្ឋាភិបាលរំលាយគណបក្សសង្គ្រោះជាតិ កាលពីឆ្នាំ២០១៧ ក៏ប៉ុន្តែលោក អ៊ីស្មាអែល មិនក្បត់ឆន្ទៈរបស់ខ្លួន។ ក៏ប៉ុន្តែដោយឃើញភាពស្ងប់ស្ងាត់ លោក អ៊ីស្មាអែល ក៏សម្រេចចិត្តវិលទៅទីក្រុងភ្នំពេញវិញ សមត្ថកិច្ចក៏ចាប់ខ្លួនតែម្តង។

ព្រះរាជអាជ្ញារងសាលាដំបូងរាជធានីភ្នំពេញ លោក សេង ហៀង បានចេញដីកាបង្គាប់ឲ្យនាំខ្លួនលោក អ៊ីស្មាអែល ពិនឧស្មាន កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៨ ដើម្បីសាកសួរពីដំណើររឿងនាំចេញមិនស្របច្បាប់។

ប្រភពជិតស្និទ្ធនឹងលោក អ៊ីស្មាអែល ឲ្យដឹងថា លោក អ៊ីស្មាអែល គឺជាប្អូនជីដូនមួយរបស់លោក អូស្មាន ហាស្សាន់ រដ្ឋលេខាធិការក្រសួងការងារ។ លោកបញ្ជាក់ថា លោក អ៊ីស្មាអែល កន្លងមកក៏ធ្លាប់បានចូលរួមជាមួយពលរដ្ឋរាប់ពាន់នាក់ជំទាស់គម្រោងសាងសង់ផ្លូវកាត់វិហារឥស្លាមបឹងកក់ ប្រឆាំងនឹងលោក អូស្មាន ហាស្សាន់ ដែលយល់ព្រមឲ្យសាលាក្រុងធ្វើផ្លូវចេញពីក្រុមហ៊ុនស៊ូកាគូ កាត់វិហារបឹងកក់ នោះ៕

### បើកតវីសារ 2ឆ្នាំនៅសូន្យវ៉ាន់ស្តុបស៊ីវីត

http://www.prakpheaktra.com February 7, 2018

ចំពោះបងប្អូនពលករដែលមានប៉ាស្ព័រ និងវីសារផុតកំណត់ថ្ងៃទី៣១ ខែ០៣ ឆ្នាំ២០១៨ ខាងមុខនេះ បងប្អូនអាចធ្វើដំណើរទៅតវីសារ(២ឆ្នាំ)នៅសូន្យ OSS (OneStopService) នៅក្នុងខេត្តក្រុងដែលបងប្អូនពលកររស់នៅ បានដោយមានតំលៃសេវាកម្មដូចខាងក្រោម។

1.វីសារ 500បាត

2.ត្រួតសុខភាព 500បាត

3.ប្រកាន់សុខភាព3200បាត

4.ច្បាប់អនុញ្ញាតធ្វើការ 1800បាត+100 បាត

## គប័ត្រស៊ីជម្ពូថ្មីអស់ត្រឹមតែ1400฿ ប៉ុណ្ណោះ

http://www.prakpheaktra.com February 7, 2018

ដំណឹងល្អ បងប្អូនដែលមិនបានត្រួតសញ្ជាតិធ្វើប៉ាស្ព័ររួចរាល់ ឥឡូវនេះបងប្អូនពលករខ្មែរដែលទាំងមានលិខិតលុងបៀននិងប័ត្រស៊ីជម្ពូអាចទៅតប័ត្រស៊ីជម្ពូថ្មីនៅក្នុងទីតាំងសូន្យវ៉ាន់ស្តប់សីវីតទូទាំងប្រទេសថៃ បានក្នុងតម្លៃត្រឹមតែ1400 ប៉ុណ្ណោះ ហើយនៅពេលបងប្អូនតប័ត្រស៊ីជម្ពូរួច បងប្អូនអាចស្នាក់នៅធ្វើការបន្តរហូតដល់ថ្ងៃទី ៣១ ខែ០៦ ឆ្នាំ២០១៨ ក៏ប៉ុន្តែបងប្អូនត្រូវរៀបចំធ្វើធ្វើប៉ាស្ព័រអោយបានត្រឹមត្រូវក្នុងរយៈពេលតប័ត្រស៊ីជម្ពូរួច បើមិនដូច្នេះទេបងប្អូននឹងក្លាយទៅជាពលករខុសច្បាប់។

## ថៃ រៀបចំបង្កើតតុលាការពិសេសពីរ ដើម្បីដោះស្រាយវិវាទពលករចំណាកស្រុក

http://www.postkhmer.com/ Leonie Kijewski | Publication date 07 February 2018 | 21:21 ICT

ភ្នំពេញៈប្រទេសថៃ កំពុងរៀបចំបង្កើតតុលាការពិសេសចំនួនពីរ ដើម្បីដោះស្រាយវិវាទរបស់ពលករនៅក្នុងឧស្សាហកម្មនេសាទខុសច្បាប់ ដែលកំពុងតែមានចំនួនយ៉ាងច្រើន។

លោក Papop Siamham អ្នកសម្របសម្រួលមូលនិធិសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ នៅក្នុងប្រទេសថៃបានថ្លែងថា តុលាការ ដែលមានមូលដ្ឋាននៅទីក្រុងបាងកកទាំងពីរនេះ នឹងជួយដោះស្រាយរឿងក្ដីដែលកើតឡើងក្រោយថ្ងៃទី ១ ខែកុម្ភៈ។ លោកមានប្រសាសន៍ថា៖«តុលាការនេះ នឹងជួយសម្រួលដល់តុលាការសាលាដំបូង ក្នុងការវិនិច្ឆ័យសំណុំរឿង ដែលទាក់ទងទៅនឹងវិវាទរបស់កម្មករ ក្នុងវិស័យនេសាទឲ្យបានលឿនជាងមុន»។ លោកបានបន្ថែមថា ចំណាត់ការនេះ ត្រូវបានប្រកាសកាលពីសប្ដាហ៍មុន ប៉ុន្តែកាលបរិច្ឆេទថ្ងៃចាប់ផ្ដើមនៅមិនទាន់ច្បាស់នៅឡើយ។ កម្លាំងពលកម្មនៅក្នុងឧស្សាហកម្មនេសាទរបស់ប្រទេសថៃ ភាគច្រើន គឺជាជនបរទេស ហើយមានពលករចំណាកស្រុកកម្ពុជាជាច្រើននាក់ ត្រូវបានឈ្មួញបង្ខំឲ្យពួកគេចូលទៅធ្វើការ នៅក្នុងឧស្សាហកម្មមួយនេះ។ សហភាពអឺរ៉ុបកាលពីឆ្នាំ ២០១៥ បានឲ្យកាតលឿងមួយ ទៅឲ្យ«ឧស្សាហកម្មនេសាទរបស់ថៃ»នេះដោយពួកគេបានស្នើឱ្យមានការត្រួតពិនិត្យឲ្យបានហ្មត់ចត់។

លោក Daniel Murphy អ្នកប្រឹក្សាយោបល់ផ្នែកសិទ្ធិការងារ បានថ្លែងនៅក្នុងអ៊ីម៉េលថា តុលាការនេះ ភាគច្រើន ត្រូវបង្កើតឡើង ដើម្បីដោះស្រាយដូចអ្វីដែលលោក Jaruvat Waisaya ប្រធានគណៈកម្មការកិច្ចការច្បាប់និងវិវាទ បានលើកឡើង ដែលវាជាចំនួនដ៏ច្រើនបំផុតមួយ នៅតំបន់អាស៊ី។ ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក រាយការណ៍ថា ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ តុលាការព្រហ្មទណ្ឌថៃបានដោះស្រាយសំណុំរឿងក្នុងឧស្សាហកម្មនេសាទបានជាង ៤០០០ ករណី។ លោក Murphy ថ្លែងថា ទោះបីជាយ៉ាងណាក៏ដោយ ចំណាត់ការនេះ នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ លោកបញ្ជាក់ថា៖«ខ្ញុំសង្ឃឹមថា យើងអាចនឹងមើលឃើញកម្រិតនៃការប្ដេជ្ញាចិត្តស្រដៀងគ្នានេះទៅនឹងការអនុវត្តន៍បទបញ្ជាការងាររបស់ថៃ និងការអនុវត្តវិធានការ ដើម្បីកែលម្អជីវិតរស់នៅរបស់កម្មករក្នុងវិស័យនេសាទទាំងមូល ដើម្បីការពារពួកគេ ពីការបង្ខំឲ្យធ្វើពលកម្មដោយបង្ខំ»៕ NS

# ស្ថានទូតកម្ពុជា ប្រចាំនៅម៉ាឡេស៊ី វៀតណាម និងចិន អន្តរាគមន៍ ជួយពលរដ្ឋខ្មែរ ១៨នាក់

https://www.dap-news.com ព្រហស្បតិ៍, 08 កុម្ភៈ ២០១៨ 11:13 ដោយ: ដើមអម្ពិល ID:013

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

## ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរចំនួន១៨នាក់

------------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**៦នាក់** (បុរស២នាក់ និងនារី៤នាក់) ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង៦នាក់នោះ បានមកដល់កម្ពុជាជាបន្តបន្ទាប់ នៅថ្ងៃទី**០២** និងទី**០៦** ខែ**កុម្ភៈ** ឆ្នាំ**២០១៨**។

**២.** ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុង**ហូជីមិញ** បានសហការជាមួយអាជ្ញាធរវៀតណាម រៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ**៩នាក់** (ក្នុងនោះកុមារ៥នាក់) មានអាយុចន្លោះពី០១ឆ្នាំដល់២៨ឆ្នាំ មកពីខេត្តស្វាយរៀង ដែលចូលទៅស្នាក់នៅនិងប្រកបរបរលក់ឆ្នោតដោយខុសច្បាប់នៅវៀតណាម។ អាជ្ញាធរវៀតណាម បានរៀបចំអោយពលរដ្ឋខ្មែរស្នាក់នៅបណ្តោះអាសន្នក្នុងមជ្ឈមណ្ឌលគាំពារសង្គមក្នុងទីក្រុងហូជីមិញ មុនពេលបញ្ជូនមកស្ថានអគ្គកុងស៊ុល។

ស្ថានអគ្គកុងស៊ុល នឹងជូនពលរដ្ឋទាំង៩នាក់ មកកម្ពុជាវិញ នៅថ្ងៃទី**០៨** ខែ **កុម្ភៈ** ឆ្នាំ **២០១៨** ដើម្បីប្រគល់ជូនអាជ្ញាធរកម្ពុជា ចាត់ចែងបញ្ជូនបន្តទៅស្រុកកំណើត។

**៣.** ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ ប្រទេស**ចិន** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ចិន អន្តរាគមជួយស្ត្រីខ្មែរ**៣នាក់** ដូចមានរាយនាមខាងក្រោម ដែលត្រូវបានមេខ្យល់នាំធ្វើដំណើរពីភ្នំពេញទៅរៀបការនិងស្នាក់នៅដោយខុសច្បាប់នៅខេត្តជាំងស៊ី ប្រទេសចិន៖

(១) ឈ្មោះ **ស.ស.ភ** អាយុ២២ឆ្នាំ មកពីខេត្តកំពង់ចាម បានទៅដល់ប្រទេសចិន នៅខែមិនា ឆ្នាំ២០១៧។

(២) ឈ្មោះ **រ.ណ** អាយុ២២ឆ្នាំ មកពីខេត្តត្បូងឃ្មុំ បានទៅដល់ប្រទេសចិន អំឡុងឆ្នាំ២០១៣។

(៣) ឈ្មោះ **ហ.អ.ល** អាយុ២១ឆ្នាំ មកពីខេត្តកណ្តាល បានទៅដល់ប្រទេសចិន អំឡុងឆ្នាំ២០១៣។

ស្ថានអគ្គកុងស៊ុល បានផ្តល់កន្លែងស្នាក់នៅ អាហារបរិភោគ សម្ភារៈប្រើប្រាស់ និងរៀបចំឯកសារធ្វើដំណើរដល់ស្ត្រីខ្មែរទាំង**៣នាក់** ហើយពួកគេបានមកដល់កម្ពុជាវិញ នៅថ្ងៃទី**០២** ខែ **កុម្ភៈ** ឆ្នាំ**២០១៨** ។

ថ្ងៃ ព្រហស្បតិ៍ ៨រោច ខែ មាឃ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៨

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

# ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៨

## ក្រុមប្រទេសដែលបញ្ជូនពលករទៅថៃ នឹងជួបប្រជុំគ្នានៅកម្ពុជា នាចុងខែក្រោយ

http://kleykley.sabay.com.kh/ ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០១៨ ម៉ោង 17:07

មន្ត្រីរដ្ឋាភិបាល ដែលធ្វើការខាងប្រឆាំងអំពើជួញដូរមនុស្សរបស់កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា គ្រោងនឹងជួបគ្នាជាត្រីភាគី នៅចុងខែមីនា ឆ្នាំ២០១៨ ដើម្បីកំណត់បញ្ហា ភាពប្រឈម និងដាក់ចេញនូវដំណោះស្រាយរួមគ្នា ពាក់ព័ន្ធនឹងសុវត្ថិភាព សិទ្ធិ និងផលប្រយោជន៍របស់ពលករទាំងបីប្រទេស ដែលកំពុងធ្វើការនៅប្រទេសថៃ។កិច្ចប្រជុំត្រីភាគីដែលគ្រោងនឹងរៀបចំឡើងនៅកម្ពុជានេះ គឺខណៈដែលពលករជាច្រើនមកពីប្រទេសទាំងបីនេះ កំពុងតែធ្វើទេសន្តប្រវេសន៍ ចូលទៅធ្វើការនៅទឹកដីថៃ និងមួយចំនួន រកការងារធ្វើដោយខុសច្បាប់ ហើយជួបបញ្ហាប្រឈមជាច្រើន។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយភាគីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា នៅព្រឹកថ្ងៃទី៨ ខែកុម្ភៈនេះ នៅទីស្តីការក្រសួងមហាផ្ទៃ។លោកស្រី ជូ ប៊ុនអេង បញ្ជាក់ថា កិច្ចប្រជុំក្រុមប្រទេស ដែលជាប្រភពបញ្ជូនពលករ ទៅធ្វើការងារនៅប្រទេសថៃ ដែលគ្រោងរៀបចំនៅចុងខែមីនា ឆ្នាំ២០១៨ខាងមុខនេះ គឺធ្វើយ៉ាងណារកវិធីសាស្ត្ររួមមួយ យកទៅសម្របសម្រួល និងពិភាក្សាជាមួយប្រទេសគោលដៅ ដោយចាប់ផ្តើមពីប្រទេសថៃ ដើម្បីឲ្យមានកិច្ចសហប្រតិបត្តិការ ក្នុងការធានាសុវត្ថិភាពផ្នែកច្បាប់ ការគោរពសិទ្ធិ និងផលប្រយោជន៍របស់ពលករ។

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃរូបនេះបន្តថា កិច្ចប្រជុំរបស់ប្រទេសទាំងបី ក៏នឹងរកវិធីគ្រប់គ្រងលំហូរពលករដែលមិនប្រក្រតី ជៀសវាងភាពរងគ្រោះដោយអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចគ្រប់រូបភាព។ លោកស្រី ជូ ប៊ុនអេង បានអះអាងថា ប្រសិនបើការគ្រប់គ្រងទេសន្តប្រវេសន៍នេះ បានល្អប្រសើរនោះ នឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនក្នុងការលើកកម្ពស់ជីវភាពពលករ និងរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចជាតិផងដែរ៕ អត្ថបទ៖ លីហៀង

## ដោះលែងបរទេស ៧នាក់ ដែលរងការចោទរឿងរំលោភអាសអាភាស នៅសៀមរាប

http://www.postkhmer.com/ នៀម ឆេង | Publication date 08 February 2018

សៀមរាបៈ ភ្ញៀវបរទេសចំនួន ៧នាក់ ក្នុងចំណោម ១០នាក់ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ចេញដីកាដោះលែងឲ្យនៅក្រៅឃុំ កាលពីថ្ងៃទី៧ ខែកុម្ភៈនេះ ក្រោយពួកគេបាននៅក្នុងពន្ធនាគារខេត្តតាំងពីចុងខែមករា ដោយសារសមត្ថកិច្ចចាប់ខ្លួន ពាក់ព័ន្ធនឹងរាំបែបអាសអាភាស។

លោកយិន ស្រាង អ្នកនាំពាក្យសាលាដំបូងខេត្តសៀមរាប បានបញ្ជាក់នូវការដោះលែងក្រៅឃុំនេះ តែមិនទាន់បញ្ជាក់ក្នុងចំណោមមនុស្សទាំង១០នាក់ ដែលបានចាប់ខ្លួនមានសញ្ជាតិអ្វីខ្លះនោះទេ។ លោកបាននិយាយថា៖.«៧នាក់ហ្នឹង បានដោះនៅក្រៅឃុំហើយ គិតថាកាលពីម្សិលមិញ។ តែខ្ញុំមិនបានដឹងពួកគាត់ជានរណាខ្លះនោះទេ។ អ្នកសម្រេចដោះលែងគឺចៅក្រម ឆៃ វីរៈ»។

ចំណែកលោកមេធាវី អ៊ុច សុកត្រា ការពារក្តីឲ្យបរទេសទាំង១០ បាននិយាយថា លោកសុំឲ្យតុលាការដោះលែងកូនក្តី ៧នាក់ ឲ្យនៅក្រៅឃុំ ដោយសារ ពួកគាត់មិនពាក់ព័ន្ធនឹងការរៀបចំពិធីជប់លៀងនោះ។

គួរបញ្ជាក់ថា ភ្ញៀវទេសចរបរទេសចំនួន ១០ នាក់ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២៥ ខែមករា ហើយត្រូវតុលាការចោទក្រោយមានការបង្រ្កាប ទីតាំងរាំបែបអាសអាភាស នៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប និងត្រូវតុលាការចោទប្រកាន់ពីបទ ««ផលិតរូបភាពអាសអាភាស» ដែលអាចប្រឈមនឹងការជាប់ទោសពី ១ខែ ដល់ ១ឆ្នាំ បើសិនគេរកឃើញកំហុស។ ជនដែលត្រូវឃាត់ខ្លួនទាំងនោះមកពីប្រទេសអង់គ្លេស កាណាដា និងនូវែលសេឡង់៕

## បិទផ្ទះសំណាក់ទ្វារនាគជ្រកក្រោមស្លាកម៉ាស្សា

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៨ម៉ោង ០៧:០០ឃឹម ឈឿន

រាជធានីភ្នំពេញ ៖ នគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ កាលពីវេលាម៉ោង៨និង៥០នាទី យប់ថ្ងៃទី០៦ ខែកុម្ភៈ បានបង្ក្រាបផ្ទះរកស៊ីជួញដូរផ្លូវភេទ ដែលជ្រកក្រោមស្លាកម៉ាស្សានិងកោសជប់មួយកន្លែង មានស្លាកឃីហោ ម៉ាស្សាខ្មែរបុរាណ អាសយដ្ឋានលេខ២៥៤ ផ្លូវលេខ៣៧១ ភូមិក្បាលទំនប់១ សង្កាត់បឹងទំពុន២ ខណ្ឌមានជ័យ ។ នៅក្នុងការបង្ក្រាបនេះ សមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីចំនួន៦នាក់ ដែលក្នុងនោះមានទាំងមេការស្រីម្នាក់ផង និងមនុស្សប្រុស៣នាក់ ។

តាមសមត្ថកិច្ចឱ្យដឹងថា ការចុះបង្ក្រាបទីតាំងខាងលើ គឺកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនរាជធានីភ្នំពេញ ដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី សំបូរ បណ្ណារិទ្ធ អនុប្រធាននាយកដ្ឋាន ដោយមានការអនុញ្ញាតពីលោក គុល បុន តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សហការជាមួយអង្គការINGO និងអាជ្ញាធរមូលដ្ឋាន ។ ជាមួយនឹងការឃាត់ខ្លួនមនុស្ស សមត្ថកិច្ចក៏ដកហូតបានស្រោមអនាម័យដែលប្រើប្រាស់ហើយមួយចំនួន យកទៅជាវត្ថុតាងឬទុកត្រាំស្រាថ្នាំ និងមិនទាន់ប្រើប្រាស់មួយចំនួន និងម៉ូតូ២គ្រឿង ។

ក្រោយពីឃាត់ខ្លួនទាំងមនុស្សនិងវត្ថុតាងត្រូវបានបញ្ជូនទៅការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ ។ ចំណែកផ្ទះម៉ាស្សាខាងលើត្រូវបានសមត្ថកិច្ចបិទទ្វារជាបណ្ដោះអាសន្ន ដែលសង្ស័យថាបើរត់ការត្រូវនឹងបានបើកវិញឱ្យតែចេះគោរពច្បាប់ ៕

## វៀតណាមបញ្ជូនពលរដ្ឋខ្មែររស់នៅនិងលក់ឆ្នោតខុសច្បាប់៩នាក់ត្រឡប់មកស្រុកវិញ

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2018-02-08

ពលរដ្ឋខ្មែរ ៩នាក់ ដែលទៅរស់នៅ និងលក់ឆ្នោតខុសច្បាប់ ត្រូវបានអាជ្ញាធរវៀតណាម ចាប់ឃាត់ខ្លួននឹងបញ្ជូនត្រឡប់មកកម្ពុជាវិញ។ ពលរដ្ឋ និងមន្ត្រីសង្គមស៊ីវិលស្នើឲ្យអាជ្ញាធរ និងរដ្ឋាភិបាលកម្ពុជា អនុវត្តច្បាប់អន្តោប្រវេសន៍ឲ្យបានតឹងរ៉ឹងដូចវៀតណាម ព្រោះសព្វថ្ងៃនេះជនជាតិវៀតណាម ច្រើនណាស់រស់នៅ និងចូលមកកត់ឆ្នោតខុសច្បាប់នៅទឹកដីកម្ពុជា។ ពលរដ្ឋខ្មែរចំនួន ៩នាក់ ដែលត្រូវបានអាជ្ញាធរវៀតណាម បញ្ជូនមកកម្ពុជាវិញនោះ ក្នុងនោះក៏មានកុមារផងដែរ។

អាជ្ញាធរវៀតណាម បានបញ្ជូនពលរដ្ឋខ្មែរទាំងនោះឲ្យស្នាក់នៅបណ្ដោះអាសន្ន ក្នុងមជ្ឈមណ្ឌលគាំពារសង្គមមួយនៅក្រុងហូជីមិញ រួចទើបបញ្ជូនទៅស្ថានអគ្គកុងស៊ុលកម្ពុជា ហើយចុងក្រោយបញ្ជូនពួកគេទៅខេត្តស្វាយរៀង។ ពលរដ្ឋខ្មែរបានរិះគន់រដ្ឋាភិបាលកម្ពុជាថា បានបណ្ដែតបណ្ដោយពលរដ្ឋវៀតណាម ឲ្យចូលមករស់នៅ និងជាពិសេសចូលលក់ឆ្នោតខុសច្បាប់នៅខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ជារៀងរាល់ថ្ងៃ។

ពលរដ្ឋរស់នៅខេត្តស្វាយរៀងម្នាក់ ប្រាប់អាស៊ីសេរី ដោយសុំមិនបញ្ចេញឈ្មោះព្រោះខ្លាចប៉ះពាល់សុវត្ថិភាព អះអាងថា នៅខេត្តស្វាយរៀង សព្វថ្ងៃជនជាតិវៀតណាម ចូលមកកត់លេខឆ្នោតខុសច្បាប់រាល់ថ្ងៃ ប៉ុន្តែគ្មានអាជ្ញាធរមានសមត្ថកិច្ចណាបង្ក្រាបឡើយ។ ពលរដ្ឋរូបនេះចង់ឃើញអាជ្ញាធរខេត្តមានវិធានការផ្លូវច្បាប់លើជនជាតិវៀតណាម ទាំងនោះ៖ «»។

ទាក់ទងការចោទប្រកាន់នេះ អាស៊ីសេរី មិនអាចសុំការបំភ្លឺពីអភិបាលខេត្តស្វាយរៀង លោក ប៉ែន វិបុល បានទេ នៅថ្ងៃទី៨ ខែកុម្ភៈ នេះ។ អ្នកនាំពាក្យសមាគមអាដហុក (ADHOC) លោក ស៊ឹង សែនករុណា យល់ថា ប្រទេសកម្ពុជា ដែលមានច្បាប់អន្តោប្រវេសន៍ដែរ គួរអនុវត្តច្បាប់នេះឲ្យបានត្រឹមត្រូវ។ លោកសង្កេតឃើញអាជ្ញាធរកម្ពុជា ផ្ដល់ការអនុគ្រោះច្រើនចំពោះពលរដ្ឋវៀតណាម ដែលរស់នៅ និងរកស៊ីនៅកម្ពុជា ខណៈវៀតណាម រឹតត្បិតពលរដ្ឋខ្មែរដែលរស់នៅលើទឹកដីខ្លួន៖ «»។

របាយការណ៍ដែលចុះជំរឿនជាង ១ឆ្នាំកន្លះ ចាប់ពីខែមីនា ឆ្នាំ២០១៥ ដល់ខែសីហា ឆ្នាំ២០១៦ បង្ហាញថា ជនអន្តោប្រវេសន៍វៀតណាម រស់ក្នុងប្រទេសកម្ពុជា ប្រមាណ ១៦ម៉ឺននាក់ អ្នករស់នៅស្របច្បាប់មានតែជាង ៣ម៉ឺននាក់ប៉ុណ្ណោះ។ ខេត្តជាប់ព្រំដែនវៀតណាម រួមមាន ខេត្តស្វាយរៀង ព្រៃវែង និងខេត្តកណ្តាល តែងតែមានជនជាតិវៀតណាម ចូលមកលេងឆ្នោតខុសច្បាប់ជារៀងរាល់ថ្ងៃ៕

## អាជ្ញាធរថៃ បើកយុទ្ធនាការត្រួតពិនិត្យបង្ក្រាបជនអន្តោប្រវេសន៍និងពលករខុសច្បាប់

http://www.prakpheaktra.com February 8, 2018

នៅព្រឹកថ្ងៃព្រហស្បតិ៍ទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ កម្លាំងសមត្ថកិច្ចអាជ្ញាធរខេត្តប្រាក់ជួបគីរីខាន់ ប្រទេសថៃ ប្រកាសបើកព្រឹត្តិបត្រការណ៍ចុះត្រួតពិនិត្យឯកសារស្នាក់នៅរបស់ជនជាតិបរទេស និងពលករខុសច្បាប់ ដែលកំពុងធ្វើការស្នាក់នៅក្នុងក្រុងហួហ៊ីន ដើម្បីទប់ស្កាត់បញ្ហាពលករចំណាកស្រុកខុសច្បាប់ និងជនជាតិបរទេសស្នាក់នៅហួសរយៈពេលទិដ្ឋាការវីសារដែលកំណត់។ ក្នុងកិច្ចព្រឹត្តិបត្រការណ៍នេះមានការអញ្ជើញចូលរួមពីសំណាក់តម្រួតអន្តោប្រវេសន៍,តម្រួតទេសចរណ៍,និងអាជ្ញាធរមូលដ្ឋាននៅក្នុងខេត្តផងដែរ។

## អតីតសមាជិកគណបក្សសង្គ្រោះជាតិម្នាក់ ត្រូវបានចាប់ខ្លួន ក្រោមការចោទពីបទជួញដូរមនុស្ស

http://www.postkhmer.com/ នៀម ឆេង | Publication date 08 February 2018 | 21:21 ICT

**ភ្នំពេញ**:លោក អ៊ីស្មាអែល ពិនឧស្មាន អតីតសមាជិក គណបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួន ក្នុងរាជធានីភ្នំពេញកាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៨ ដោយរងការចោទប្រកាន់ពីបទជួញដូរមនុស្ស ចំណែកឯមន្ត្រីនគរបាលមិនបានផ្តល់ព័ត៌មានលំអិត អំពីមូលហេតុដែលគាត់ត្រូវបានចាប់ខ្លួននោះទេ។ លោក ពិនឧស្មាន ដែលជាអ្នកធ្វើស្លាកលេខឡាន នឹងកំពុងមានដីកាចាប់ខ្លួនផងដែរនោះ ត្រូវបានប៉ូលីសប្រឆាំងការជួញដូរមនុស្សចាប់ខ្លួន។

លោក ប៉ុល ពិធេយ្យ ប្រធាននាយកដ្ឋាននគរបាល ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសំដៅដល់ពាក្យដែលត្រូវបានប្រើប្រាស់សម្រាប់ករណីការជួញដូរមនុស្សក្នុងច្បាប់កម្ពុជាថា៖«គាត់ត្រូវបានចាប់ខ្លួនពីបទឆ្លងព្រំដែនខុសច្បាប់ និងត្រូវបានចាប់ខ្លួនតាមពាក្យបណ្តឹង»។

លោក អ៊ីសា អូស្មាន អតីតមេដឹកនាំចលនារបស់គណបក្សសង្គ្រោះជាតិ បានបញ្ជាក់ថា លោកពិនឧស្មាន ត្រូវបានចាប់ខ្លួន នៅក្នុងខណ្ឌឫស្សីកែវ ក្នុងរាជធានីភ្នំពេញ ហើយត្រូវបានឃុំខ្លួននៅស្នងការដ្ឋាននគរបាលជាតិ។ ដីការកោះហៅរបស់ប៉ូលីស ដែលបានចេញកាលពីខែវិច្ឆិកា បានជម្រាបឱ្យលោក ពិនឧស្មាន បង្ហាញខ្លួននៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ ទាក់ទងពីបទបញ្ជូនពលករជាស្ត្រីច្រើននាក់ទៅបរទេស។ បន្ទាប់មកដីកាចាប់ខ្លួន ចុះថ្ងៃទី ៥ ខែកុម្ភៈ បានតម្រូវឱ្យអាជ្ញាធរ ចាប់ខ្លួនលោក ពិនឧស្មាន និងនាំខ្លួន ទៅកាន់នាយកដ្ឋានដដែល ឲ្យបានមុនថ្ងៃទី៦ខែមីនា ហើយពេលនេះគឺបានលើកឡើងអំពីពាក្យបណ្តឹងរបស់លោក ឡោះ អូស្មាន ។

អតីតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោកម៉ៅ មុនីវណ្ណ បានថ្លែងថា លោកគ្រាន់តែបានឮថា មានការចាប់ខ្លួន លោកពិនឧស្មាន ដែលធ្លាប់បានឈរឈ្មោះជាបេក្ខជនបម្រុង នៅខេត្តកំពង់ចាម ក្នុងអំឡុងពេលបោះឆ្នោតជាតិឆ្នាំ ២០១៣។ លោកបញ្ជាក់ថា៖ «បន្ទាប់ពីការបោះឆ្នោត គាត់គឺជាសមាជិកក្រុមការងាររបស់គណបក្សសង្គ្រោះជាតិ នៅខេត្តត្បូងឃ្មុំ»។ លោកបានបន្ថែមថា ករណីនេះ អាចជាប់ទាក់ទងទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់គណបក្សកាន់អំណាច ដើម្បីធ្វើឱ្យអតីតមន្ត្រីគណបក្សប្រឆាំងចុះចូល៕ NS

# សេចក្តីប្រកាសព័ត៌មាន ស្តីពីការជ្រើសរើសណែនាំតម្រង់ទិស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី

https://www.mlvt.gov.kh/ សុក្រ, 09 កុម្ភៈ 2018 12:43

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃសុក្រ ៩រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ នៅទីក្រុង Putrajaya ប្រទេសម៉ាឡេស៊ី ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំគណៈប្រតិភូកម្ពុជាអញ្ជើញចូលរួមពិភាក្សាការងារថ្នាក់រដ្ឋមន្ត្រីលើកទី៤ ជាមួយឯកឧត្តម Dato' Sri Richard Riot Anak Jaem រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស នៃប្រទេសម៉ាឡេស៊ី ដើម្បីបន្តពិភាក្សាលើការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ ស្តីពីការជ្រើសរើសណែនាំតម្រង់ទិស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ីឱ្យបានឆាប់រហ័ស ដើម្បីធានាដល់ការការពារសិទ្ធិ និងអត្ថប្រយោជន៍របស់ពលករកម្ពុជាទៅធ្វើការនៅទីនោះ។

ក្នុងជំនួបនៃកិច្ចប្រជុំនេះ ភាគីទាំងពីរបានសម្តែងនូវការពេញចិត្តយ៉ាងខ្លាំងនូវលទ្ធផលដ៏ល្អនៃកិច្ចសហប្រតិបត្តិការនាពេលកន្លងមក ហើយក៏បានពិភាក្សា និងឯកភាពគ្នាលើនីតិវិធី និងលក្ខខណ្ឌនានាសម្រាប់ការណែនាំតម្រង់ទិស និងការចេញវិញ្ញាបនបត្របញ្ជាក់សមត្ថភាពពលករខ្មែរមុនពេលចេញដំណើរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ដោយអនុលោមទៅតាមខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នាដែលភាគីទាំងពីរបានចុះហត្ថលេខាកាលពីខែធ្នូ ឆ្នាំ២០១៥ និងស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនានានៃប្រទេសទាំងពីរ។

ទន្ទឹមនឹងនេះ ភាគីទាំងពីរបានឯកភាពគ្នា ចាប់ផ្តើមដំណើរការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ីលើកដំបូងនាខែមិថុនា ឆ្នាំ២០១៨ នេះ។

សូមបញ្ជាក់ថា ភាគីទាំងពីរបានបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ពលករខ្មែរដែលទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។

ថ្ងៃសុក្រ ៩រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨

## ក្មេងអាយុ១៥ឆ្នាំម្នាក់ ត្រូវបានថៃចាប់ខ្លួនបទឆ្លងដែនចូលកាប់ឈើគ្រញូងខុសច្បាប់ ឥឡូវបញ្ជូនមកកម្ពុជាវិញ

http://www.rasmeinews.com/ February 9, 2018, 11:30 AM34

(ឧត្តរមានជ័យ)៖ ក្មេងប្រុសអាយុ១៥ឆ្នាំម្នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនខ្លួនអោយវិលត្រលប់មកកម្ពុជាវិញ បន្ទាប់ពីរូបគេបានឆ្លងដែនចូលកាប់ឈើគ្រញូងនៅទឹកដីថៃដោយខុសច្បាប់ ហើយឥឡូវថៃបានបញ្ជូនមកវិញបន្ទាប់ពីជាប់ពន្ធនាគារនៅទីនោះ អស់រយៈពេលប្រមាណជា២ខែ។ ក្មេងប្រុសរូបនោះត្រូវបានថៃបញ្ជូនមកកាលពីវេលាម៉ោង១៤និង៣០នាទី ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨ នៅច្រកអន្តរជាតិជាំស្រងាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយអាជ្ញាធរកម្ពុជាទទួលយក ធ្វើការអប់រំហើយក៏អោយវិលត្រលប់ទៅលំនៅដ្ឋានវិញ។ ក្មេងប្រុសរូបនោះមានឈ្មោះ សែន ម៉ៅ អាយុ១៥ឆ្នាំ មានទីលំនៅភូមិគ្រួស ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ក្មេងប្រុសរូបនោះត្រូវបានយោធាថៃចាប់ខ្លួនកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧កន្លងទៅនេះ ខណៈពេលដែលឆ្លងដែនចូលទៅកាប់ឈើគ្រញូងនៅក្នុងទឹកដីថៃ ក្នុងភូមិសាស្ត្រច្រកទឹកជប់ ក្នុងខេត្តស៊ីសាកេត ។

សមត្ថកិច្ចនិយាយថា នៅថ្ងៃកើតហេតុនោះក្មេងប្រុសនិងបក្សពួកមួយក្រុម បានឆ្លងដែនទៅកាប់ឈើគ្រញូងនៅកន្លែងកើតហេតុ ហើយត្រូវបានទាហានថៃបាញ់រះ ហើយចាប់ខ្លួនបានក្មេងប្រុសខាងលើ ដោយឡែកបក្សពួកក្មេងប្រុសមួយចំនួនទៀតបានរត់គេចខ្លួនចូលមកកម្ពុជា ដោយឡែកអាជ្ញាធរថៃចាប់បានតែក្មេងប្រុសខាងលើម្នាក់ យកទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេតចាប់ពីពេលនោះមក ឥឡូវក្មេងនោះបានវិលត្រលប់មកកាន់កម្ពុជាវិញហើយ៕L ដោយ៖បាយ័ន

## ពលរដ្ឋខ្មែរ៦នាក់ ឆ្លងដែនខុសច្បាប់ចូលកាប់ឈើក្រញូងក្នុងដីថៃ ត្រូវបានអាជ្ញាធរថៃ បញ្ជូនឲ្យកម្ពុជាវិញ

http://cambodiapolice.com 12:28 pm 9 កុម្ភៈ 2018 10 បោះពុម្ភ អ៊ីម៉ែល

ឧត្តរមានជ័យ ៖ អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន៦នាក់ មកស្រុកកំណើតវិញតាមច្រកអន្តរជាតិជាំសាង៉ាំ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ពាក់ព័ន្ធករណីចូលកាប់ឈើក្រញូងនៅព្រឹកថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨។

សមត្ថកិច្ចបានឲ្យដឹងថាពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរថៃបញ្ជូនមកវិញរួមមានទី១-ឈ្មោះ ចេង ផល្លា ភេទប្រុស អាយុ២៣ឆ្នាំ រស់នៅភូមិរំលេក ឃុំបាស្រែ ស្រុកអង្គរបូរី ខេត្តតាកែវ ចាប់ខ្លួនថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥, ទី២-ឈ្មោះ អួន ម៉ៅ ភេទប្រុស អាយុ៤៥ឆ្នាំ, ទី៣-ឈ្មោះ វ័ន្ត ឡាន ភេទប្រុស អាយុ២៤ឆ្នាំ, ទី៤-ឈ្មោះ ឆៃ ឡាន់ ភេទប្រុស អាយុ២៤ឆ្នាំ, ទី៥-ឈ្មោះ វ័ន្ត ហាន ភេទប្រុស អាយុ៤៥ឆ្នាំ, ទី៦-ឈ្មោះ ជន គឿន ភេទប្រុស អាយុ៣៧ឆ្នាំ ហើយនាក់ទាំង៥ រស់នៅភូមិអង្គាំផ្អែម ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ចាប់ខ្លួនថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ជាប់គុកនៅខេត្តនគររាជសីម៉ា ប្រទេសថៃពីបទឆ្លងដែនខុសច្បាប់កាប់ឈើក្រញូងក្នុងទឹកដីថៃចូលតាមច្រក ចំការគរ ខេត្តបន្ទាយមានជ័យ។ បច្ចុប្បន្ន ប្រជាពលរដ្ឋទាំង៦នាក់ខាងលើ ត្រូវបានសមត្ថកិច្ច ធ្វើការអបរំហើយ បានអោយវិលត្រឡប់ទៅលំនៅឋានវិញរៀងៗខ្លួន ៕

# ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៨

## បញ្ជូនជនសង្ស័យម្នាក់ទៅតុលាការពាក់ព័ន្ធករណីឃោសនាជ្រើសរើសពលករិនីទៅធ្វើការនៅប្រទេសអារ៉ាប់ប៊ីសាអូឌីតដោយខុសច្បាប់

http://cambodiapolice.com/blog/ 3:54 pm 9 កុម្ភៈ 2018

ភ្នំពេញ ៖ កម្លាំងនគរបាល នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅព្រឹកថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨នេះ បានបញ្ជូនខ្លួនជនសង្ស័យម្នាក់ពាក់ព័ន្ធករណីឃោសនាជ្រើសរើសពលការិនីឲ្យទៅធ្វើការនៅប្រទេសអារ៉ាប់ប៊ីសាអូឌីតដោយខុសច្បាប់ ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

នគរបាលប្រឆាំងការជួញដូរមនុស្ស បានឲ្យដឹងថា ជនសង្ស័យឈ្មោះ អ៊ីស្មាអែល ពិនឧស្ម័ន ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិ ខ្មែរ-ឥស្លាម មុខរបរធ្វើស្លាកលេខរថយន្ត ទីកន្លែងកំណើត ភូមិត្រពាំងឈូក ឃុំបឹង ស្រុកបារាយណ៍ ខេត្តកំពង់ធំ បច្ចុប្បន្នស្នាក់នៅ ផ្ទះលេខ៣៦H ផ្លូវលំ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ នគរបាលប្រឆាំងការជួញដូរមនុស្ស បញ្ជាក់ថា កាលពីអំឡុងឆ្នាំ២០០៤ ជនសង្ស័យខាងលើ បានឃោសនាក្នុងភូមិថា ឈ្មោះ អះម៉ាត់ យ៉ះយ៉ា ត្រូវជាពូរបស់ខ្លួនត្រូវការជ្រើសរើសពលការិនីបញ្ជូនទៅធ្វើការជាជំនួយការមេផ្ទះនៅប្រទេសអារ៉ាប់ប៊ីសាអូឌីត ប្រាក់ឈ្នួល ២២០ដុល្លារអាមេរិច កិច្ចសន្យាការងាររយៈពេល២ឆ្នាំ ចំពោះឯកសារ បែបបទ លិខិតឆ្លងដែន និងសោហ៊ុយធ្វើដំណើរ ឈ្មោះ អះម៉ាត់ យ៉ះយ៉ា ជាអ្នកចំណាយ ។

បន្ទាប់មកបានអូសទាញពលរដ្ឋក្នុងភូមិ ២នាក់ មានឈ្មោះ ស រទ ហៅ ម សណ ភេទស្រី អាយុ ១៥ឆ្នាំ និងឈ្មោះ អ ព ភេទស្រី អាយុ ៤២ឆ្នាំ ក្រោយមកបានចំនួន ២០នាក់ទៀត ហើយនាំទៅប្រគល់ឲ្យឈ្មោះ អះម៉ាត់ យ៉ះយ៉ា ភេទប្រុស អាយុ ៦០ឆ្នាំ ជនជាតិ ខ្មែរ-ឥស្លាម ផ្ទះលេខ៣៤ ផ្លូវលេខ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ ។ ពេលនោះដោយ ឈ្មោះ ស រទ អាយុ ១៥ឆ្នាំ ត្រូវបានឈ្មោះ អះម៉ាត់ យ៉ះយ៉ា ក្លែងអត្តសញ្ញាណដោយប្រើឯកសាររបស់ឈ្មោះ ម សណ អាយុ ២២ឆ្នាំវិញ ហើយបានបញ្ជូនទៅធ្វើជាស្ត្រីបម្រើតាមផ្ទះនៅប្រទេសអារ៉ាប់ប៊ីសាអូឌីត ។ នៅប្រទេសអារ៉ាប់ប៊ីសាអូឌីត ជនរងគ្រោះត្រូវបានថៅកែកេងប្រវ័ញ្ចកម្លាំងពលកម្ម បិទសិទ្ធសេរីភាព ហើយក្នុងនោះឈ្មោះ ស រទ ត្រូវបានគេលក់ទៅថៅកែជាម្ចាស់ទី១ ទៅថៅកែទី២ ក្នុងតម្លៃ ២០០០០ដុល្លារ ឲ្យធ្វើការងារផ្ទះ ហើយរងការរំលោភផ្លូវភេទ និងមិនទទួលបានប្រាក់ឈ្នួលតាំងពីពេលបញ្ជូនទៅ រហូតដល់អំឡុងខែសីហា ឆ្នាំ២០១៧ ។

នគរបាលប្រឆាំងការជួញដូរមនុស្ស បានឲ្យដឹងទៀតថា ឈ្មោះ ស រទ ត្រូវបានឈ្មោះ អាម៉ាត់ យ៉ះយ៉ា បញ្ជូនទៅធ្វើការជាជំនួយការមេផ្ទះនៅប្រទេសអារ៉ាប់ប៊ីសាអូឌីត តាមចក្រអន្តរជាតិប៉ោយប៉ែត ឆ្លងកាត់ប្រទេសថៃ និងបន្តឡើងយន្តហោះដល់គោលដៅប្រទេសអារ៉ាប់ប៊ីសាអូឌីត ។ នគរបាលប្រឆាំងការជួញដូរមនុស្ស បញ្ជាក់ថា ជនរងគ្រោះទាំងអស់ទើបតែសង្គ្រោះបានចំនួន ២នាក់ប៉ុណ្ណោះ ដោយមានការអន្តរាគមន៍ពី ឯកឧត្តម ឧស្មាន់ ហាសាន់ សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សង្គ្រោះមកកម្ពុជាវិញ ។ ដោយឡែកជនរងគ្រោះនៅសល់ក្នុងប្រទេសអារ៉ាប់ប៊ីសាអូឌីតមិនទាន់ដឹងពីសុខទុក្ខនៅឡើយ ។ បច្ចុប្បន្នជនសង្ស័យឈ្មោះ អ៊ីស្មាអែល ពិនឧស្ម័ន និងវត្ថុតាង កំពុងស្ថិតក្នុងចំណាត់ការរបស់សាលាដំបូងរាជធានីភ្នំពេញ រីឯជនសង្ស័យឈ្មោះ អះម៉ាត់ យ៉ះយ៉ា និងបក្សពួកសមត្ថកិច្ចកំពុងស្នើសុំដីកាស្វែងរកចាប់ខ្លួនដើម្បីយកមកផ្តន្ទាទោសតាមច្បាប់ ។

សូមជម្រាបថា ជនសង្ស័យឈ្មោះ អ៊ីស្មាអែល ពិនឧស្ម័ន ត្រូវបានកម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចាប់ខ្លួនតាមពាក្យបណ្ដឹងរបស់ម្ដាយជនរងគ្រោះ ហើយត្រូវនគរបាលចាប់ខ្លួនបានកាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨នេះ ខណៈជនសង្ស័យកំពុងធ្វើដំណើរនៅក្នុងភូមិសាស្ត្រ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងដកហូតបានវត្ថុតាងមួយចំនួន ៕

## សមត្ថកិច្ចកំពុងតាមចាប់លោក អះម៉ាត់ យ៉ះយ៉ា ពាក់ព័ន្ធនឹងការបញ្ជូនពលករទៅក្រៅប្រទេស

http://www.postkhmer.com/ យន់ ស៊ីនាត and Daphne Chen date 12 February 2018 09:02 ICT

**ភ្នំពេញៈ** លោក អះម៉ាត់ យ៉ះយ៉ា អតីតរដ្ឋលេខាធិការក្រសួងសង្គមកិច្ច កំពុងត្រូវបានសមត្ថកិច្ចនគរបាលស្វែងរកចាប់ខ្លួនដែលពាក់ព័ន្ធនឹងការបញ្ជូនស្ត្រីដោយខុសច្បាប់ទៅធ្វើការនៅប្រទេស អារ៉ាប៊ី សាអ៊ូឌីត បន្ទាប់ពីក្មួយប្រុសគាត់ម្នាក់ត្រូវសមត្ថកិច្ចចាប់កាលពីថ្ងៃពុធ ប៉ុន្តែលោកអះអាងថា នោះគឺជារឿងដែលគេប្រឌិតឡើងដើម្បីចាប់ខ្លួនលោកប៉ុណ្ណោះ។

ការស្វែងរកចាប់ខ្លួននេះ បើទោះបីជាមិនមានការបញ្ជាក់ឲ្យច្បាស់ពីមន្ត្រីនគរបាល កាលពីម្សិលមិញក្តី ប៉ុន្តែព័ត៌មានពីគេហទំព័ររបស់នគរបាលជាតិចុះផ្សាយកាលពីថ្ងៃ៩ កុម្ភៈ ឲ្យដឹងថា ការស្វែងរកដីកាចាប់ខ្លួនលោក អះម៉ាត់ យ៉ះយ៉ា គឺពាក់ព័ន្ធនឹងបុរសម្នាក់ដែលជាក្មួយគាត់ ឈ្មោះ អ៊ីស្មាអែលពិន ឧស្មាន ដែលគេដឹងថា អតីតសមាជិកគណបក្សសង្គ្រោះជាតិត្រូវបានចាប់ខ្លួនក្នុងរាជធានីភ្នំពេញកាលពីថ្ងៃពុធ ខណៈគាត់កំពុងធ្វើដំណើរនៅក្នុងភូមិសាស្ត្រ សង្កាត់ច្រាំងចំរេះ ២ ខណ្ឌឫស្សីកែវ រាជធានី ភ្នំពេញទាក់ទងនឹងការបញ្ជូនមនុស្សទៅធ្វើការនៅក្រៅប្រទេស។

តាមព័ត៌មានពីនគរបាលសរសេរថា៖ «បច្ចុប្បន្នជនសង្ស័យឈ្មោះ អ៊ីស្មាអែល ពិនឧស្មាន និងវត្ថុតាងកំពុងស្ថិតក្នុងចំណាត់ការរបស់សាលាដំបូងរាជធានីភ្នំពេញ រីឯជនសង្ស័យ ឈ្មោះ អះម៉ាត់ យ៉ះយ៉ា និងបក្ខពួកសមត្ថកិច្ចកំពុងស្នើសុំដីកាស្វែងរកចាប់ខ្លួនដើម្បីយកមកផ្តន្ទាទោសតាមច្បាប់»។ តាមការរៀបរាប់របស់នគរបាលបានឲ្យដឹងថា ជនសង្ស័យ អ៊ីស្មាអែល ពិនឧស្មាន កាលពីឆ្នាំ ២០០៤ បានដើរឃោសនាក្នុងភូមិថា ពូខ្លួន គឺលោក អះម៉ាត់ យ៉ះយ៉ា ដែលមានក្រុមហ៊ុនជ្រើសរើសពលករត្រូវការជ្រើសរើសជំនួយការមេផ្ទះ ធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត។ បើតាមព័ត៌មាននគរបាលថាបន្ទាប់មកបានអូសទាញពលរដ្ឋក្នុងភូមិ ២ នាក់មានឈ្មោះ ស.រ.ទ ហៅ ម.ស.ណ ភេទស្រី អាយុ ១៥ ឆ្នាំ និងឈ្មោះ អ.ព ភេទស្រី អាយុ ៤២ ឆ្នាំ ក្រោយមកបានចំនួន ២០ នាក់ទៀតហើយនាំទៅប្រគល់ឲ្យឈ្មោះ អះម៉ាត់ យ៉ះយ៉ា...។ ពេលនោះដោយ ឈ្មោះ ស.រ.ទ អាយុ ១៥ ឆ្នាំ ត្រូវបានឈ្មោះ អះម៉ាត់ យ៉ះយ៉ា ក្លែងអត្តសញ្ញាណដោយប្រើឯកសាររបស់ឈ្មោះ ម.ស.ណ អាយុ ២២ ឆ្នាំវិញហើយបានបញ្ជូនទៅធ្វើជាស្ត្រីបម្រើតាមផ្ទះនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត។

លោក អះម៉ាត់ យ៉ះយ៉ា ត្រូវបានរដ្ឋាភិបាលដកចេញពីតំណែងជារដ្ឋលេខាធិការនៅក្រសួងសង្គមកិច្ចផងដែរក្រោយពីមានការពាក់ព័ន្ធនឹងការបញ្ជូនពលការិនីជាអនីតិជនទៅធ្វើការខុសច្បាប់នៅប្រទេស អារ៉ាប៊ី សាអ៊ូឌីត។ ទោះយ៉ាងណាលោក អះម៉ាត់ យ៉ះយ៉ា បានប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីម្សិលមិញថា លោកកំពុងស្ថិតនៅ «កន្លែងមានសុវត្ថិភាព» និងបានបដិសេធថាជារឿងមិនពិត និងសុទ្ធតែត្រូវបានប្រឌិតឡើង ដោយលោក អូស្មាន ហាស្សាន់ រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បី «ចោទប្រកាន់ខ្ញុំ ដើម្បីចង់ចាប់ខ្ញុំដាក់គុក» តែប៉ុណ្ណោះ។ លោកបានបន្តថា៖ «ខ្ញុំសូមស្បថចំពោះព្រះ អាឡោះ ខ្ញុំស្បថចំពោះព្រះថាទាំងនេះគឺជាល្បែង។ គេចង់ចាប់ខ្ញុំតែប៉ុណ្ណោះ»។ លោក អះម៉ាត់ យ៉ះយ៉ា ថ្លែងថា៖ «ខ្ញុំមិនដែលបញ្ជូនស្ត្រីបម្រើការងារតាមផ្ទះឆ្លងតាមប្រទេសថៃដោយមិនមានខ្ញុំ និង TK នោះទេ។ ពីព្រោះនេះពាក់ព័ន្ធនឹងការគាំទ្រហិរញ្ញវត្ថុ ឬការរៀបចំ»។

លោកថា៖ «ទី ១ ខ្ញុំត្រូវធ្វើឲ្យប្រាកដថា នៅព្រំដែនពួកគេអាចបោះត្រាសម្រាប់យើងចូលទៅប្រទេសថៃ ទី ២ ខ្ញុំត្រូវស្វែងរកសណ្ឋាគារសម្រាប់ពួកគេ។ ទី ៣ ខ្ញុំត្រូវយកពួកគេទៅមន្ទីរពេទ្យដើម្បីពិនិត្យសុខភាព។ ទី ៤ ខ្ញុំត្រូវទៅស្ថានទូតអារ៉ាប៊ីសាអ៊ូឌីតដើម្បីទទួលបានទិដ្ឋាការ។ ទី ៥ ខ្ញុំត្រូវទិញសំបុត្រទៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត។ ដូច្នេះការរៀបចំទាំងអស់នេះ ខ្ញុំធ្វើវាដោយខ្លួនឯង។ ខ្ញុំមិនដែលបញ្ជូននរណាម្នាក់ទៅទីនោះ...នេះគួរឲ្យអស់សំណើច។ លោក យ៉ះយ៉ា បានបន្តថា៖ «ចំពោះឈ្មោះ អេង ៣៧ [អ.ព] អ្នកដឹងទេ នៅពេលនាងត្រឡប់មកវិញ ហើយពួកគេ

ទាក់ទងជាមួយ អូស្មាន ហាស្សាន់។ គាត់ទាក់ទងនាង និងប្ដីថ្មីរបស់នាងដើម្បីចោទប្រកាន់ខ្ញុំដើម្បីចាប់ខ្ញុំដាក់ពន្ធនាគារ នោះហើយជារឿង។ នេះជាការប្រឌិត។ ដូច្នេះរឿងនេះមិនពិតទាល់តែសោះ។ ខ្ញុំហ៊ានស្បថ។ អូស្មាន ហាស្សាន់ ខឹងខ្ញុំដោយសារមិនអាចសាងសង់ផ្លូវ។ ពួកគេមិនអាចចោទប្រកាន់ខ្ញុំបានចំពោះរឿងផ្លូវ»។

លោកបានអះអាងថា៖ «នគរបាលបានឃ្លាំមើលផ្ទះរបស់ខ្ញុំកាលពីល្ងាចថ្ងៃសុក្រ។ ដីកាចាប់ខ្លួនដែលពួកគេធ្វើឡើង ខ្ញុំគិតថាម្សិលមិញនៅម៉ោង ២ ។ ប៉ុន្តែខ្ញុំមិនដឹងថា ពួកគេចេញជាសាធារណៈឬអត់នោះទេ ខ្ញុំអត់ដឹង។ លោក អះម៉ាត់ យ៉ះយ៉ា គឺជាពូរបស់លោក អូស្មាន ហាស្សាន់ ហើយបានចាញ់ក្ដីក្នុងបុរសពីបទបរិហារកេរ្តិ៍ និងត្រូវសាលាដំបូងរាជធានីភ្នំពេញកាត់ក្ដីឲ្យសងជំងឺចិត្តទៅលោក អូស្មាន ហាស្សាន់ ១០០ លានរៀល និងបង់ពិន័យរដ្ឋ ៥ លានរៀលកាលពីខែសីហាឆ្នាំ ២០១៦ ទាក់ទងនឹងគម្រោងធ្វើផ្លូវកាត់តំបន់បឹងកក់ ក្បែរវិហារចាមដែលក្រុមលោក អះម៉ាត់ យ៉ះយ៉ា បានជំទាស់យ៉ាងខ្លាំង។

ទោះបីជាយ៉ាងណាលោក អូស្មាន ហាស្សាន់ បានលើកឡើងថា៖ «ការចាប់ខ្លួនរបស់ អះម៉ាត់ យ៉ះយ៉ា គឺជាតួនាទីរបស់សមត្ថកិច្ចគឺនគរបាលដែលទទួលបន្ទុកខាងកិច្ចការទាំងអស់នោះ ហើយបើមានការដោះស្រាយទៅលើអ្នកពាក់ព័ន្ធផ្សេងៗទៀតនោះជាសមត្ថកិច្ចរបស់តុលាការ។ ចំណែកខាងក្រសួងការងារគឺយើងមានតួនាទីក្នុងការជួយជនរងគ្រោះត្រឡប់មកផ្ទះវិញដោយសុវត្ថិភាព។ លោកបានបញ្ជាក់ថា៖ «កន្លងទៅជនរងគ្រោះគឺបានប្ដឹងក្រុមហ៊ុន អះម៉ាត់ យ៉ះយ៉ា នោះហើយ តែក្រុមហ៊ុនវាមានអ្នកពាក់ព័ន្ធច្រើនធ្វើការហើយខ្ញុំមិនអាចឆ្លើយនឹងតួនាទីរបស់សមត្ថកិច្ចឡើយ។ ចំពោះខាងក្រសួងការងារគឺពិនិត្យមើលដូចជា៖១. កាលណាក្រុមហ៊ុនណាដែលបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសដោយមិនមានការដឹងឮពីក្រសួងការងារគឺត្រូវប្រឈមមុខនឹងផ្លូវច្បាប់ ២. ការនាំពលករដែលមិនទាន់គ្រប់អាយុគឺជាការនាំអនីតិជនទៅធ្វើការខុសច្បាប់ហើយត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ៣. បើទោះនោះជាក្រុមហ៊ុនស្របច្បាប់ក៏ដោយ តែបើមិនគោរពលក្ខខណ្ឌតម្រូវដោយក្រសួងការងារនោះទេក្រុមហ៊ុនទាំងនោះក៏ត្រូវទទួលខុសត្រូវលើផ្លូវច្បាប់ដែរ»៕

## លោកអូស្មាន ហាស្សាន់៖ ប្រតិកម្មចំពោះ វិទ្យុអាស៊ីសេរីដែលបានផ្សាយព័ត៌មាន ពីការចាប់ខ្លួន លោក អ៊ីស្មាអែល ពិនឧស្មាន គឺពាក់ព័ន្ធនឹងរឿងនយោបាយថាជាការផ្សាយបំភ្លើសដើម្បីកេងចំណេញនយោបាយ

http://nokorwatnews.com/ ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៨

ភ្នំពេញ៖ លោកអូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះ បណ្ដាលវិជ្ជាជីវៈ បានប្រតិកម្មយ៉ាងដាច់អហង្ការ ទៅ កាន់ប្រព័ន្ធព័ត៌មានអាស៊ីសេរី តាមអនឡាញ កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ កន្លងទៅ បានចេញព័ត៌មានបែបកេងយក ចំណេញនយោបាយ ខុសពីការពិត ដោយបានផ្សាយថា ការដែលលោក អ៊ីស្មាអែល ពិនឧស្មាន ត្រូវបាន នគរបាល នៃក្រសួងមហាផ្ទៃឃាត់ខ្លួន គឺជារឿងដែលពាក់ព័ន្ធនឹងនយោបាយ ដោយផ្អែកទៅលើការអះអាងដោយអគតិ របស់ អតីតប្រធានក្រុមការងារ គណបក្សសង្គ្រោះជាតិខេត្តត្បូងឃ្មុំ លោក វណ្ណារិទ្ធ និងជាអតីតតំណាងរាស្ត្រខេត្តកំពង់ចាម ហើយលោកចាត់ទុកថា សារព័ត៌មានមួយនេះ គឺបានចុះផ្សាយក្នុងចេតនាបង្កបរិយាកាសមិនល្អ ហើយ មិនមែនជាសារព័ត៌មាន ដែលឈរ លើវិជ្ជាជីវៈត្រឹមត្រូវ ពិតប្រាកដ និង អព្យាក្រឹត្យនោះទេ។

លោក អូស្មាន ហាស្សាន់ បានប្រតិកម្ម ចំពោះវិទ្យុអាស៊ីសេរីបែបនេះ កាលពីរសៀលថ្ងៃសៅរ៍ ១០រោច ខែមាឃ ឆ្នាំរកានព្វស័កព.ស២៥៦១ ត្រូវនិងថ្ងៃទី១០ កុម្ភៈ ឆ្នាំ២០១៨ ក្នុងនាមតំណាងឲ្យសមាជិករាជរដ្ឋាភិបាលបានអះអាងថា៖ តាមពិតលោក អ៊ីស្មាអែល ពិនឧស្មាន ដែលត្រូវ បានកម្លាំងសមត្ថកិច្ចនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចាប់ខ្លួន គឺមិនមែនពាក់ព័ន្ធនឹងរឿងនយោ បាយសូម្បីតែបន្តិចណាឡើយ ផ្ទុយទៅវិញ

វាជាការអនុវត្តយ៉ាងត្រឹមត្រូវទៅតាមច្បាប់ របស់កម្លាំងសមត្ថកិច្ច ខណៈជនសង្ស័យរូបនេះ មានការពាក់ព័ន្ធ នឹងករណីបញ្ជូនពលករខុសច្បាប់ទៅបម្រើការងារនៅប្រទេសអារ៉ាប៊ីសាអូឌីត ការជួញដូរមនុស្ស និង ករណីរំលោភបំពានកម្លាំងពលកម្មលើស្ត្រី និងអនីតិជនផងដែរ ។

ការប្រតិកម្មរបស់លោក អូស្មាន ហាស្សាន់ បានធ្វើ ឡើងបន្ទាប់ពី សារពត៌ត៌មានអាស៊ីសេរី បានផ្សាយព័ត៌មានមិនពិត បែបកេងចំណេញនយោបាយ ដោយដកស្រង់សំដីរបស់ អតីត ប្រធានក្រុមការងារគណបក្សសង្រ្គោះជាតិខេត្តត្បូងឃ្មុំ លោក វណ្ណារិទ្ធ និងជាអតីតតំណាងរាស្ត្រខេត្តកំពង់ចាម ដែលបានផ្តល់បទសម្ភាសន៍ជាមួយអាស៊ីសេរីថា រឿងឃាត់ ខ្លួន ជនសង្ស័យខាងលើជារឿងនយោបាយ ហើយក៏បាន បញ្ជាក់ដោយសម្លេងថា ៖ បាទអាហ្នឹងតាមអ្វីដែលគាត់ធ្លាប់បញ្ជាក់ប្រាប់ខ្ញុំថា( គាត់មានគេបញ្ចុះបញ្ចូលគាត់នៅឯទីលំនៅ របស់គាត់មានការបញ្ចុះបញ្ចូលតែគាត់ មិន ចុះចូល ដោយសារគាត់យល់ថា គាត់មិនអាចធ្វើអ្វីដែលគាត់អាចក្បត់ឆន្ទៈរាស្ត្រអញ្ចឹងគាត់អត់ចូល ) ប៉ុន្តែក្រោយមកក៏ស្ងាត់ទៅវិញទៅ ហើយឥឡូវថ្ងៃនេះក៏លឺដំណឹងថាមានការចាប់ខ្លួន ។

សូមបញ្ជាក់ថា៖ ការឃាត់ខ្លួន ជនសង្ស័យ អ៊ីស្មាអែល ពិនឌស្មាន កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ កន្លងទៅនេះ គឺបន្ទាប់ពីក្រសួងមហាផ្ទៃ បានទទួលពាក្យណ្តឹងរបស់ ពល ការនីរងគ្រោះ ២រូប គឺទី១ កញ្ញាម៉ាត់ សាណាស់ ហៅ រ៉ទស់(អនីតិជន ) ត្រូវបានសង្រ្គោះអោយមកដល់កម្ពុជាវិញកាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ ខណៈស្រ្តីរងគ្រោះទី២ ឈ្មោះ អេង ពៅ ត្រូវបានសង្រ្គោះអោយមកដល់កម្ពុជាវិញកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ បន្ទាប់ពីបាត់ខ្លួន បាត់ ដំណឹងរយៈពេលពី ១២-១៣ឆ្នាំ ដែលអ្នកទាំង២ត្រូវបាន ក្រុមហ៊ុន Accept Group របស់ លោក អះម៉ាត់ យ៉ះយ៉ា អតីតរដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា ដែលត្រូវជាឪពុកមារបង្កើតរបស់ជនសង្ស័យ បានបញ្ជូនជនរងគ្រោះខាងលើទៅធ្វើជាស្រ្តីបម្រើការងារផ្ទះដោយខុសច្បាប់ នៅប្រទេសអារ៉ាប៊ីសសាអូឌីត និងត្រូវបានឈ្មួញម្ចាស់ផ្ទះលក់ជាបន្តបន្ទាប់ដោយដោយ កេងប្រវ័ញ្ចកម្លាំងពលកម្មមិនផ្តល់ប្រាក់បៀវត្សក្នុងរយៈពេលជាង១៣ឆ្នាំនេះ។

ប្រភពព័ត៌មានពីនគរបាលសមត្ថកិច្ចបានអោយដឹងដែរថា៖ តាមចម្លើយសារភាពជាក់ស្តែងរបស់ជនសង្ស័យ អ៊ីស្មាអែល ពិនឌស្មាន គឺរឿងទាំងអស់មានការទាក់ទងទាំងស្រុងជាមួយនឹង លោក អះម៉ាត់ យ៉ះយ៉ា ជាម្ចាស់ក្រុមហ៊ុន ដែល ពេលនេះសមត្ថកិច្ចកំពុងស្នើសុំដីកាស្វែងរកចាប់ខ្លួន ជាមួយ នឹងបក្សពួកដទៃទៀត ដើម្បីយកមកផ្តន្ទាទោសតាមច្បាប់ ៕ សំរិត

## បុរសខ្មែរឥស្លាមម្នាក់ត្រូវឃុំខ្លួនពាក់ព័ន្ធករណីជួញដូរមនុស្សក្រោមលេសទៅបម្រើការងារផ្ទះប្រទេសអារ៉ាប៊ីសាអូឌីត

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្ដិ៍ ចេញផ្សាយ ថ្ងៃទី 10 February, 2018

ភ្នំពេញ៖ បុរសខ្មែរឥស្លាមម្នាក់ ត្រូវជាក្មួយបង្កើតរបស់ លោក អះម៉ាត់ យ៉ះយ៉ា អតីតរដ្ឋ លេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែលជាប់ពាក់ព័ន្ធករណីនាំពលករទៅធ្វើការខុសច្បាប់នៅប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីត បានត្រូវតុលាការសម្រេចឃុំខ្លួនដាក់ពន្ធនាគារនៅថ្ងៃទី១០ ខែកុម្ភៈបន្ទាប់ពីលោក សេង ហៀង ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញសាកសួររួចហើយ។

បើតាមប្រភពមួយផ្សេងទៀតបានឱ្យដឹងថា តុលាការនឹងបន្តនីតិវិធីក្នុងសំណុំរឿងនេះ ដែលអាចពាក់ព័ន្ធជាមួយលោក អះម៉ាត់ យ៉ះយ៉ា ផងដែរ។ មន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស បានឲ្យដឹងថា ជនសង្ស័យឈ្មោះ អ៊ីស្មាអែល ពិនឌស្មន អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ-ឥស្លាម មុខរបរធ្វើស្លាកលេខរថយន្ត ទីកន្លែងកំណើត ភូមិត្រពាំងឈូក ឃុំបឹង ស្រុកបារាយណ៍ ខេត្តកំពង់ធំ បច្ចុប្បន្នស្នាក់នៅ ផ្ទះលេខ៣៦H ផ្លូវលំ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ត្រូវបានកម្លាំងនគរបាលប្រឆាំងការជួញ ដូរ មនុស្សនិងការពារអនីតិជន

ត្រូវបានចាប់ខ្លួនតាមពាក្យបណ្តឹង របស់ម្តាយជនរងគ្រោះ កាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨ នេះ ខណៈកំពុងធ្វើដំណើរនៅក្នុងភូមិសាស្ត្រ សង្កាត់ច្រាំងចំរេះ២ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ និងដកហូតបានវត្ថុតាងមួយចំនួន។

មន្ត្រីនគរបាលបញ្ជាក់ថា បើតាមរបាយការណ៍ កាលពីអំឡុងឆ្នាំ២០០៤ ជនសង្ស័យខាងលើបានឃោសនាក្នុងភូមិថា ឈ្មោះ អះម៉ាត់ យ៉ះយ៉ា ត្រូវជាពូរបស់ខ្លួន ត្រូវការជ្រើសរើសពលករនិរីបញ្ជូនទៅធ្វើការជាជំនួយការមេផ្ទះ នៅប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីត ដែលនឹងទទួលបានប្រាក់ឈ្នួល២២០ដុល្លារអាមេរិច កិច្ចសន្យាការងាររយៈពេល២ឆ្នាំ ចំពោះឯកសារបែបបទ លិខិតឆ្លងដែន និងសោហ៊ុយធ្វើដំណើរ ឈ្មោះ អះម៉ាត់ យ៉ះយ៉ា ជាអ្នកចំណាយ។ បន្ទាប់មកបានអូសទាញពលរដ្ឋក្នុង ភូមិ២នាក់ ក្រោយមកបានចំនួន២០នាក់ទៀត ហើយនាំទៅប្រគល់ឲ្យលោក អះម៉ាត់ យ៉ះយ៉ា ស្នាក់នៅផ្ទះលេខ៣៤ ផ្លូវលេខ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ ពេលនោះជនរងគ្រោះត្រូវបានលោក អះម៉ាត់ យ៉ះយ៉ា ធ្វើអត្តសញ្ញាណដោយប្រើឯកសារមិនប្រក្រតី ហើយបានបញ្ជូនចេញពី កម្ពុជា ទៅធ្វើជាស្ត្រីបម្រើតាមផ្ទះនៅប្រទេស អារ៉ាប់ប៊ីសាអ៊ូឌីត តែម្តង ។

តាមរបាយការណ៍បណ្តឹងរបស់ជនរងគ្រោះបានលើកឡើងថា នៅប្រទេសអារ៉ាប់ប៊ីសាអូឌីត ជនរងគ្រោះត្រូវបានថៅកែកេងប្រវ័ញ្ចកម្លាំងពលកម្ម បិទសិទ្ធិសេរីភាពហើយត្រូវបានគេលក់ទៅថៅកែពីម្ចាស់ទី១ ទៅថៅកែទី២ ក្នុងតម្លៃ២ម៉ឺនដុល្លារ ឲ្យធ្វើការងារផ្ទះ ហើយរងការរំលោភផ្លូវភេទនិងមិនទទួលបានប្រាក់ឈ្នួលតាំងពីពេលបញ្ជូនទៅដល់ប្រទេសអារ៉ាប៊ីសាអូឌីត រហូតដល់អំឡុងខែសីហា ឆ្នាំ២០១៧។

មន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស បន្ថែមថា ជនរងគ្រោះទាំងអស់ទើបតែសង្គ្រោះបានចំនួន២នាក់ប៉ុណ្ណោះ ដោយមានការអន្តរាគមន៍ពី លោក អូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងការងារ សហការជាមួយក្រសួងការបរទេស និងសហ ប្រតិបត្តិការអន្តរជាតិ សង្គ្រោះមកកម្ពុជាវិញ៕

## រដ្ឋាភិបាលបណ្តេញបរទេស៧នាក់ ពាក់ព័ន្ធអំពើអាសអាភាស

http://www.yobminh.com/ បញ្ញា | February 12, 2018 | ព័ត៌មានជាតិ | No Comments

ជនបរទេស៧នាក់ដែលទទួលបានការអនុញ្ញាតឲ្យនៅក្រៅឃុំត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជាហើយកាលពីចុងសប្តាហ៍ ដោយមិនអនុញ្ញាតឲ្យចូលកម្ពុជាវិញឡើយ។ នេះបើតាមការបញ្ជាក់របស់អ្នកនាំពាក្យតុលាការ និងមេធាវី ។ លោក យិន ស្រាង អ្នកនាំពាក្យសាលាដំបូងខេត្តសៀមរាប បានប្រាប់ភ្នំពេញប៉ុស្ដិ៍ថា ជនបរទេសទាំង៧នាក់ត្រូវបានប្រាប់ឲ្យចាកចេញពីកម្ពុជាហើយ។ លោកនិយាយថា៖ «គេបានឲ្យគាត់នៅក្រៅឃុំបណ្តោះអាសន្ន គេបានដាក់លក្ខខណ្ឌឲ្យ គាត់ចាកចេញពីកម្ពុជា អត់ឲ្យគាត់ ត្រឡប់មកវិញទេ។ គេបានប្រគល់លិខិតឆ្លងដែនឲ្យ ហើយគាត់ចាកចេញទៅអស់ហើយឥឡូវនេះ»។

កាលពីថ្ងៃពុធ ជនបរទេសចំនួន៧នាក់ ត្រូវបានតុលាការខេត្តសៀមរាបដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ក្រោយពេលជនបរទេសចំនួន១០នាក់ ត្រូវបានសម្ថកិច្ចឃាត់ខ្លួន ហើយតុលាការសម្រេចឃុំខ្លួនពួកគេបណ្តោះអាសន្ននៅពន្ធនាគារ ដោយចោទថា ផលិតរូបភាពអាសអាភាស និងរាំច្រៀងបែបអាសអាភាស កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ នៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប។ ប៉ុន្តែកាលពីថ្ងៃសៅរ៍ ស្ត្រីជនជាតិកាណាដា២នាក់ឈ្មោះ Eden Kazoleas អាយុ១៩ឆ្នាំ និងឈ្មោះ Jessica Drolet អាយុ២៦ឆ្នាំ បានធ្វើដំណើរទៅដល់ប្រទេសកាណាដាហើយ។

លោកអ៊ូច សុភត្រា មេធាវីការពារជនបរទេសទាំង១០នាក់ក៏បានប្រាប់ឲ្យដឹងដែរថា ជនបរទេសទាំង៧នាក់ដែលត្រូវបានចោទប្រកាន់ថា ផលិតរូបភាពអាសអាភាសនេះ មិនត្រូវបានលើកលែងបទចោទ គឺគ្រាន់តែទទួលបានការនៅក្រៅឃុំបណ្តោះអាសន្ន ដោយមានការធានា ប៉ុណ្ណោះ។ លោកសុភត្រា និយាយថា៖«នៅក្នុងដីកាសម្រេច

ដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យហ្នឹង ថៅក្រមតម្រូវឲ្យជនជាប់ចោទទាំងអស់ចេញក្រៅប្រទេសកម្ពុជា។ នៅក្នុងនោះមិនបាននិយាយពីការលើកលែងចោទប្រកាន់ទេ។ ទីមួយគឺហាមមិនឲ្យនៅក្នុងស្រុក ទីពីរមិនឲ្យធ្វើសកម្មភាពអ្វីមួយដែលពាក់ព័ន្ធដល់សណ្តាប់ធ្នាប់សាធារណៈ គឺហាម២ចំណុចនេះ។ តែមិនមានការនិយាយពីការលើកលែងចោទប្រកាន់ទេ ព្រោះបើលើកលែងទាល់តែមានដីកាដំណោះស្រាយមួយទៀត»។

កាលពីថ្ងៃទី២៥ ខែមករា ជនបរទេស៨៧នាក់ត្រូវបានសមត្ថកិច្ចប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនខេត្តសៀមរាប ឃាត់ខ្លួនដោយសារពួកគេបានប្រមូលផ្តុំគ្នារៀបចំពិធីជប់លៀងដែលអាជ្ញាធរនិយាយថា «រាំបែបអាសអាភាស» ហើយបានអប់រំ ជនទាំងនោះ ចំនួន ៧៧នាក់ រួចឲ្យត្រឡប់ទៅវិញ ប៉ុន្តែជនបរទេស១០នាក់ដែលសង្ស័យថាជាអ្នករៀបចំកម្មវិធី ត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្ត។ រហូតមកទល់ពេលនេះ មានជនបរទេស៣នាក់ទៀតដែលកំពុងស្ថិតនៅក្នុងពន្ធនាគារនៅឡើយ។

តាមរយៈសារព័ត៌មាន iheartradio ជនជាតិកាណាដាដែលបានទៅដល់ប្រទេសរបស់ពួកគេបាននិយាយថា ពួកគេមិនបានដឹង ហើយមិនបានគិតថា ការចូលរួមក្នុងពិធីជប់លៀងស្លៀកពាក់ប៊ីគីនី ធ្វើឲ្យប៉ះពាល់ដល់វប្បធម៌របស់ប្រទេសកម្ពុជាទេ។ ពួកគេបានបដិសេធថាពួកគេមិនបានចូលរួមក្នុងការផលិតរូបភាពអាសអាភាសដូចការចុះផ្សាយឡើយ៕

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារីៈ ស្ត្រីខ្មែរនៅតែប្រឈមការរើសអើង ហិង្សា និងចំណាកស្រុកប្រថុយប្រថាន

http://www.freshnewsasia.com/ 2018-02-12

(ភ្នំពេញ)៖ លោកស្រី អ៉ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី បានលើកឡើងថា ស្ត្រីនៅកម្ពុជានៅតែប្រឈម បញ្ហារើសអើង ក្នុងសង្គម បន្ទុកគ្រួសារ និងផ្ទះសម្បែង កម្រិតទាបនៃការអប់រំ និងជំនាញ អំពើហិង្សា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។

លោកស្រីរដ្ឋមន្ត្រី បានគូសបញ្ជាក់ដូច្នេះក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១៨របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា និងជាអនុប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅព្រឹកថ្ងៃចន្ទ ១២រោច ខែមាឃ ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨នេះ។ លោកស្រី អ៉ឹង កន្ថាផាវី បានថ្លែងបញ្ជាក់ទៀតថា បញ្ហាប្រឈមទាំងនេះ បានបង្កហានិភ័យក្នុងភាពងាយរងគ្រោះរបស់ស្ត្រី និងអាចរារាំងការរីកចម្រើន នៃស្ថានភាពស្ត្រីក្នុងសង្គមដែលកំពុងវិវត្តយ៉ាងលឿន ដើម្បីប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចក្នុងតំបន់ និងឆាកអន្តរជាតិ៕

## ពលករខ្មែរ 27នាក់ ទៀតហើយត្រូវកម្លាំងអាជ្ញាធរថៃចាប់ខ្លួនបន្ទាប់ពីធ្វើការខុសច្បាប់ការងារ

http://www.prakpheaktra.com February 9, 2018

កម្លាំងអាជ្ញាធរថៃប្រចាំខេត្តឈុមផន ប្រទេសថៃចាប់ខ្លួនពលករខ្មែរនិងភូមាចំនួន២៧នាក់ ក្នុងករណីធ្វើការខុសលក្ខខ័ណ្ឌនៃច្បាប់អនុញ្ញាតការងារ។ កាលពីថ្ងៃព្រហស្បតិ៍ទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ម្សិលមិញនេះកម្លាំងសមត្ថកិច្ចតម្រួតខេត្តឈុមផន ប្រទេសថៃ បានធ្វើការចុះឃាត់ខ្លួនពលករខ្មែរនិងភូមាចំនួន ២៧នាក់ ខណៈកំពុងធ្វើការសំណង់នៅក្នុងការដ្ឋានសាងសង់ហាងទំនើបមួយកន្លែងស្ថិតនៅក្នុងខេត្តឈុមផន ។ យោងតាមរបាយការណ៍របស់សមត្ថកិច្ចថៃបានអោយដឹងថា ក្នុងព្រឹត្តិបត្រការណ៍ចុះចាប់ខ្លួនពលករខុសច្បាប់ខាងលើកម្លាំងអាជ្ញាធរថៃ បានរកឃើញពលករខ្មែរធ្វើការខុសច្បាប់ និងខុសលក្ខខ័ណ្ឌការងារសរុបចំនួន២៧នាក់ ក្នុងនោះមានពលករសញ្ជាតិភូមាចំនួន០២នាក់ផងដែរ។

តាមការរៀបរាប់របស់ពលករទាំងអស់បានដឹងថា ពួកគេទាំងអស់គ្នាទើបតែប្តូរមកធ្វើការនៅក្នុងខេត្តឈុមផន នេះបានត្រឹមតែរយៈពេល០៥ថ្ងៃប៉ុណ្ណោះ ដោយមានថៅកែថៃឈ្មោះ វិសេត ស៊ីធុមម៉ា អាយុ៤៥ឆ្នាំ ជាអ្នកទទួលមកធ្វើការ។ បច្ចុប្បន្នសមត្ថកិច្ចថៃកំពុងធ្វើការតាមស្រាវជ្រាវរកចាប់ខ្លួនថៅកែថៃខាងលើ ដើម្បីយកមកផ្តន្ទាទោសតាមច្បាប់។

## មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ចុះអន្តរាគមន៍ ករណីពលករខ្មែរម្នាក់ ធ្លាក់ពីលើអាគារស្លាប់

http://www.prakpheaktra.com February 9, 2018

យោងតាមព័ត៌មានរបស់កាសែតថៃ sanook កាលពីព្រឹកថ្ងៃ ០៩ ខែកុម្ភៈ ឆ្នាំ២០១៨ មាន ពលករកម្ពុជា ១រូប បានស្លាប់បាត់បង់ជីវិតក្នុងឧបទ្ទវហេតុធ្លាក់ពីលើអគារកំពុងសាងសង់ជាន់ទី៤ នៅច្រកលេខ៤៣ ផ្លូវប្រារាមកៅ សង្កាត់ហ៊ួម៉ាក ខណ្ឌបាងកាពិ ទីក្រុងបាងកក ប្រទេសថៃ។ បន្ទាប់ពីទទួលបានព័ត៌មាននេះភ្លាម នាពេលរសៀលក្នុងថ្ងៃដដែលក្រុមការងារទីប្រឹក្សាទទួលលបន្ទុកពលករ តំណាងឱ្យឯកឧត្តមឯកអគ្គរាជទូតនៃស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃបានចុះមកចូលរួមរំលែកទុក្ខ និងឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមគ្រួសារសព។

ពលករដែលបានស្លាប់បង់ជីវិត មានឈ្មោះ ឆោន ប៉ោច ភេទស្រី កើតនៅឆ្នាំ ១៩៧៦ មានអាសយដ្ឋាននៅភូមិខ្ទីង ឃុំបុស្សរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ជាមួយគ្នានេះក្រុមការងារស្ថានទូត ក៏បានជួយសម្រួលរៀបចំឯកសារ និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីយកសពទៅធ្វើបុណ្យតាមប្រពៃណី នៅព្រះរាជាណាចក្រកម្ពុជាវិញ ដោយនិយោជក ជួយចេញថ្លៃដឹកជញ្ជូនសព និងថ្លៃរៀបចំកម្មវិធីបុណ្យសព។

## ចាប់ពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចំនួន 26នាក់ និងមធ្យោបាយដំណើរចំនួន 03គ្រឿង

http://www.prakpheaktra.com February 10, 2018

ពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ ចំនួន២៦នាក់ ត្រូវកម្លាំងអាជ្ញាធរថៃចាប់ខ្លួន។ កាលពីវេលាម៉ោង១១នាព្រឹកថ្ងៃសៅរ៍ទី១០ ខែកុម្ភៈ ឆ្នាំ២០១៨ កម្លាំងអាជ្ញាធរតម្រួតអន្តោប្រវេសន៍ខេត្តស្រះកែវប្រទេសថៃ បានធ្វើការបង្ក្រាបរថយន្តដឹកពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចំនួន០៣គ្រឿង ព្រមទាំងធ្វើការឃាត់ខ្លួនបានពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចំនួន២៦នាក់ ខណៈពេលកំពុងធ្វើដំណើរដោយរថយន្តខាងលើចេញពីទឹកដីស្រុកអារញ្ញយាថេតឆ្ពោះទៅកាន់ទីក្រុងបាងកកប្រទេសថៃ ។

យោងតាមប្រភពព័ត៌មានរបស់អាជ្ញាធរថៃបានអោយដឹងថាពលរដ្ឋខ្មែរខុសច្បាប់អស់បានធ្វើដំណើរឆ្លងដែនខុសច្បាប់ចូលមកក្នុងប្រទេសថៃតាមរយៈច្រកព្រំដែនធម្មជាតិ ដោយមានមេខ្យល់នាំផ្លូវ និងមានជនជាតិថៃជាអ្នកដឹកជញ្ជូនបន្តទៅកាន់កន្លែងដែលពលរដ្ឋចំណាកស្រុកទាំងអស់នោះធ្វើការ ដោយគិតតំលៃសេវាកម្មធ្វើដំណើរក្នុងមនុស្សម្នាក់ចាប់ពី១៨០០฿-២៧០០฿ ។ បច្ចុប្បន្នពលរដ្ឋខ្មែរខុសច្បាប់ទាំងអស់ត្រូវបានសមត្ថកិច្ចតម្រួតអន្តោប្រវេសន៍ខេត្តស្រះកែវឃាត់ខ្លួនយកទៅធ្វើការសាកសួរនៅអធិការតម្រួតអន្តោប្រវេសន៍ខេត្តស្រះកែវ ជាមួយមេខ្យល់ថៃ និងវត្ថុតាងមានមានរថយន្តToyota revo ចំនួនបីគ្រឿងដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## តំលៃសេវាកម្មធ្វើវីសារពីរឆ្នាំនៅសូន្យ OSS ( OneStopService )

http://www.prakpheaktra.com February 11, 2018

តំលៃធ្វើវីសារពីរឆ្នាំនៅសូន្យOSS( OneStopService )ចំពោះពលករមានប័ត្រស៊ីជម្ពូ និងលិខិតឆ្លងដែនត្រួតសញ្ជាតិហើយ មានដូចខាងក្រោម៖

1.តំលៃសេវាកម្មប័ត្រស៊ីជម្ពូចំនួន80฿

2.តំលៃសេវាកម្មវ៉ៃត្រាវីសារពីរឆ្នាំចំនួន500฿

3.តំលៃសេវាកម្មត្រួតសុខភាពចំនួន500฿

4.តំលៃសេវាកម្មប្រកាន់សុខភាពពីរឆ្នាំចំនួន3200฿

5.តំលៃសេវាកម្មបអនុញ្ញាតធ្វើការពីឆ្នាំចំនួន1900฿

*សរុបតំលៃសេវាកម្មធ្វើទាំងអស់មានចំនួន6180฿

-តំលៃសេវាកម្មធ្វេ ីវីសារពីរឆ្នាំចំពោះពលករមានលិខិតលុងបៀននិងលិខិតឆ្លងដែនត្រួតសញ្ជាតិហើយមានដូចខាងក្រោម៖

1.តំលៃសេវាកម្មធ្វើប័ត្រស៊ីជម្ពូចំនួន80฿

2.តំលៃសេវាកម្មវ៉ែត្រាវីសារពីរឆ្នាំចំនួន500฿

3.តំលៃសេវាកម្មត្រួតសុខភាពចំនួន500฿

4.តំលៃសេវាកម្មប្រកាន់សុខភាពពីរឆ្នាំចំនួន3200฿

5.តំលៃសេវាកម្មបែអនុញ្ញាតធ្វើការពីឆ្នាំបីខែចំនួន2225฿

*សរុបតំលៃសេវាកម្មធ្វើទាំងអស់ចំនួន6505฿

បញ្ជាក់តំលៃសេវាកម្មធ្វើវីសារពីរឆ្នាំនេះចំពោះនៅតាមខេត្តប៉ុណ្ណោះ ចំពោះតំលៃសេវាកម្មធ្វើវីសារពីរឆ្នាំនៅក្នុងសូន្យ OSSទីក្រុងបាងកកវិញគឺមានតំលៃទៀបជាងតាមប្រម៉ាណ500฿ប៉ុណ្ណោះ។

## ពលករខ្មែរម្នាក់ ជាប់ពាក់ព័ន្ធក្នុងករណីអាករសម្លាប់ជនជាតិថៃ

http://www.prakpheaktra.com February 11, 2018

ពលករខ្មែរធ្វើការសំណង់នៅក្នុងប្រទេសថៃ០១នាក់ ត្រូវកម្លាំងអាជ្ញាធរថៃតាមចាប់ខ្លួនបន្ទាប់ពីផឹកស៊ីស្រវឹងអាករសម្លាប់ជនជាតិថៃម្នាក់។ កាលពីព្រឹកថ្ងៃអាទិត្យទី១១ ខែកុម្ភៈ ឆ្នាំ២០១៨ មានករណីបុរសពលករខ្មែរម្នាក់ផឹកស៊ីស្រវឹងឈ្លោះគ្នា រួចប្រើអំពើហិង្សាកាប់លើបុរសជនជាតិថៃ ម្នាក់បណ្តាលឱ្យស្លាប់ភ្លាមៗរួចរត់គេចខ្លួនបាត់។

ករណីមានជម្លោះនៅក្នុងវង់ផឹកស៊ីកាប់គ្នាស្លាប់នេះបានកើតឡើងកាលពីវេលាម៉ោង០៩ ស្ថិតក្នុងឃ្លាំងស្តុកស្រូវមួយកន្លែងស្ថិតនៅភូមិ៥ សង្កាត់សេណា ស្រុកមឿង ខេត្តណាខនសុវ៉ាន តាមប្រភពព័ត៌មានពីកន្លែងកើតហេតុបានឲ្យដឹងថា មុនពេលកើតហេតុគេឃើញបុរសពលករខ្មែរម្នាក់ឈ្មោះ Son Sum ជាកម្មករធ្វើការសំណង់នៅក្បែរនោះបានអង្គុយផឹកសុរាជាមួយនឹងបុរសជនជាតិថៃវ័យ៦១ឆ្នាំ នៅកន្លែងកើតហេតុ តែក្រោយមកមិនដឹងជាមានរឿងអ្វីស្រាប់តែគេប្រទះឃើញ បុរសជនជាតិថៃខាងលើដេកស្លាប់ក្បែរបាវស្រូវ ព្រមទាំងមានស្លាកស្នាមកាប់នឹងកាំបិតនិងត្រូវគេអាករស្លាប់ ហើយនៅក្រោយពេលកើតហេតុបុរសពលករខ្មែរខាងលើបានរត់គេចខ្លួនទៅផ្ទះថៅកែ ហើយគេចបន្តទៅទៀត បច្ចុប្បន្នកម្លាំងសមត្ថកិច្ចថៃកំពុងធ្វើការតាមស្រាវជ្រាវរកចាប់ខ្លួនបុរសពលករខ្មែរខាងលើ ដើម្បីយកផ្តន្ទាទោសតាមច្បាប់ផ្លូវ។

## ក្រឡាប់ឡានដឹកពលករខ្មែរ ធ្វើការបេះផ្លែមៀន បណ្តាលឱ្យមានមនុស្សរងរបួសជាច្រើននាក់

http://www.prakpheaktra.com February 11, 2018

ពលករខ្មែរធ្វើការបេះផ្លែមៀននៅខេត្តចាន់បុរី ប្រទេសថៃជួបឧបទ្ទវហេតុគ្រោះថ្នាក់ក្រឡាប់រថយន្តពេលទៅធ្វើការបណ្តាលឲ្យមានមនុស្សរងរបួសជាច្រើននាក់។ អាណិតខ្លាំងណាស់ពលករខ្មែរធ្វើការបេះមៀននៅខេត្តចាន់បុរីប្រទេសថៃ បានជួបឧបទ្ទវហេតុគ្រោះថ្នាក់ក្រឡាប់រថយន្តដឹកពលករបណ្តាលអោយពលករខ្មែរប្រមាណជិត៣០នាក់រងរបួសធ្ងន់ និងស្រាល។ ករណីគ្រោះថ្នាក់ក្រឡាប់ខាងលើនេះត្រូវម្ចាស់អាខោនហ្វេសប៊ុកឈ្មោះ เล็ก แก้วจันทร์ បានយកមកបង្ហោះនៅលើបណ្តាញសង្គមហ្វេសប៊ុកកាលពីថ្ងៃសុក្រទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨កន្លងទៅ ។

## ចាប់ខ្លួនពលករធ្វើការខុសច្បាប់ចំនួន 21នាក់ នៅតំបន់ភូមិភាគឥសាន

http://www.prakpheaktra.com February 12, 2018

អាជ្ញាធរថៃចាប់ខ្លួនពលករបរទេសលួចធ្វើការខុសច្បាប់ចំនួន២១នាក់ នៅក្នុងសិប្បកម្មកែច្នៃឈើមួយកន្លែងនៅតំបន់ភូមិភាគឥសាននៃប្រទេសថៃ។ យោងតាមប្រភពព័ត៌មានពីទូរទស្សន៍ប៉ុស្តិ៍លេខ៧ថៃបានចុះផ្សាយកាលពីពេលថ្មីកន្លងទៅអោយដឹងថា នៅរសៀលថ្ងៃសុក្រទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ កម្លាំងសមត្ថកិច្ចអាជ្ញាធរមូលដ្ឋានថៃ និងកម្លាំងទាហានថៃប្រមាណជាង១០០នាក់ បានធ្វើយុទ្ធនាការចុះត្រួតពិនិត្យសិប្បកម្មកែច្នៃឈើមួយកន្លែងស្ថិតនៅក្នុងខេត្តបឹងកានប្រទេសថៃ បានរកឃើញពលករបរទេសកំពុងធ្វើការខុសច្បាប់ចំនួន២១នាក់ ក្នុងនោះមានពលករខ្មែរធ្វើការគ្មានច្បាប់អនុញ្ញាតចំនួន០២នាក់ និងជនជាតិចិនកាន់លិខិតឆ្លងដែនទេសចរណ៍ គ្មានច្បាប់អនុញ្ញាតធ្វើការចំនួន០៤នាក់ ក្រោយពេលឃាត់ខ្លួនពលករខុសច្បាប់ទាំងអស់ត្រូវអាជ្ញាធរថៃបញ្ជូនទៅកាន់អធិការដ្ឋានតម្រួតអន្តោប្រវេសន៍ខេត្តបឹងកានដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ពលករខ្មែរម្នាក់ ធ្វើការចិញ្ចឹមបង្កងត្រូវស្លាបកង្ហារម៉ាស៊ីន កាប់ត្រូវស្ទើរតែដាច់ប្រដាប់ភេទ

http://www.prakpheaktra.com February 10, 2018

កាលពីថ្ងៃសុក្រទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ មានករណីបុរសពលករខ្មែរ០១នាក់ធ្វើការចញ្ចឹមបង្កងនៅក្នុងខេត្តត្រាត ប្រទេសថៃ បានរងគ្រោះថ្នាក់ត្រូវផ្ចិតស្លាបចាក់ម៉ាស៊ីនវ៉ៃទឹកចញ្ចឹមបង្កងកាប់ត្រូវភ្លៅស្ទើរតែដាច់ដល់ប្រដាប់ភេទ ករណីគ្រោះថ្នាក់ខាងលើនេះបានកើតឡើងក្នុងបរិវេណស្រះទឹកចិញ្ចឹមបង្កងមួយកន្លែង ស្ថិតនៅក្នុងសង្កាត់ហួយរ៉ែង ស្រុកមឿង ខេត្តត្រាត ប្រទេសថៃ យោងតាមប្រភពព័ត៌មានរបស់ខេត្តត្រាតបានអោយដឹងថា មុនពេលកើតហេតុបុរសរងគ្រោះបានចុះទៅធ្វើការនៅក្នុងស្រះទឹកកើតហេតុ តែចៃដន្យបានកើតឧបទ្ទវហេតុត្រូវស្លាបម៉ាស៊ីនវ៉ៃទឹកកាប់ចំកណ្តាលអោយរងរបួសធ្ងន់។ បច្ចុប្បន្នបុរសពលករខ្មែរខាងលើត្រូវបានភ្នាក់ងារសង្គ្រោះ( សារ៉ាំងខេត្តត្រាត )បញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តត្រាតប្រទេសថៃ។

## ពលករហ្វីលីពីនរាប់ពាន់នាក់នៅគុយវ៉ែត ចង់ត្រឡប់មកប្រទេសកំណើតវិញ

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង 14:20

ប្រជាជនហ្វីលីពីនជាង ២២០០នាក់ បានសម្រេចទទួលយកសំណើរបស់លោកប្រធានាធិបតី Rodrigo Duterte ដែលផ្តល់ឲ្យនូវការធ្វើមាតុភូមិនិវត្តន៍ពីប្រទេសគុយវ៉ែត ក្រោយលេចចេញរបាយការណ៍ ស្តីពីការធ្វើទុក្ខបុកម្នេញលើពលករហ្វីលីពីន។ នេះបើតាមរដ្ឋមន្ត្រីក្រសួងការងារហ្វីលីពីន បាននិយាយ កាលពីថ្ងៃអាទិត្យម្សិលមិញ។ លោក Duterte កាលពីថ្ងៃសុក្រ បានស្នើឲ្យក្រុមហ៊ុនអាកាសចរណ៍ហ្វីលីពីន និងប៉ាស៊ីហ្វិក Cebu ផ្តល់នូវជើងហោះហើរឲ្យពលករហ្វីលីពីន ដែលចង់ចាកចេញពីគុយវ៉ែត។ ការថ្លែងដូច្នេះ បន្ទាប់ពីសពពលករហ្វីលីពីនម្នាក់ ត្រូវបានគេប្រទះឃើញក្នុងទូរទឹកកក នៅអគារបោះបង់ចោលមួយកន្លែង។

គួរបញ្ជាក់ថា ហ្វីលីពីនផ្អាកបញ្ជូនពលកររបស់ខ្លួនទៅប្រទេសគុយវ៉ែតកាលពីខែមករា បន្ទាប់ពីលេចចេញនូវរបាយការណ៍បញ្ជាក់ថា មានការធ្វើទុក្ខបុកម្នេញពីសំណាក់ចៅហ្វាយ រហូតឈានដល់មានការធ្វើអត្តឃាត។ លោក Duterte បាននិយាយថា ការផ្អាកនេះ គឺនឹងធ្វើឡើងជារៀងរហូត៕ ប្រភព៖ Reuters ៖ អ៊ឹម ម៉េងស៊ាង

# ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨

## ឯកឧត្តមរដ្ឋមន្ត្រី និងគណៈប្រតិភូបានវិលត្រឡប់មកមាតុប្រទេសវិញ បន្ទាប់ពីបំពេញទស្សនៈកិច្ចនៅប្រទេសម៉ាឡេស៊ី

https://www.mlvt.gov.kh/ សុក្រ, 09 កុម្ភៈ 2018 19:34 | Written by MLVT

កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨នេះ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំគណៈប្រតិភូកម្ពុជា ធ្វើដំណើរទៅកាន់ ទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ដើម្បីចូលរួមក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីបច្ចេកទេសជាន់ខ្ពស់លើកទី៥ និងថ្នាក់រដ្ឋមន្ត្រីលើកទី៤ ក្នុងការអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលម៉ាឡេស៊ី ស្តីពី "ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី "។

បន្ទាប់ពីដឹកនាំគណៈប្រតិភូកម្ពុជាដើម្បីអញ្ជើញចូលរួម ក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីបច្ចេកទេសជាន់ខ្ពស់លើកទី៥ និងថ្នាក់រដ្ឋមន្ត្រីលើកទី៤ ជាមួយ ឯកឧត្តម Dato' Sri Richard Riot Anak Jaem រដ្ឋមន្ត្រីក្រសួងធនធានមនុស្សនៃប្រទេសម៉ាឡេស៊ី នៅទីក្រុង Putrajaya ដើម្បីបន្តពិភាក្សាលើការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ ស្តីពីការជ្រើសរើស ណែនាំតម្រង់ទិស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ីឱ្យបានឆាប់ ដើម្បីជានាដល់ការការពារសិទ្ធិ និងអត្ថប្រយោជន៍របស់ពលករកម្ពុជាទៅធ្វើការនៅទីនោះ។ នាល្ងាចថ្ងៃសុក្រ ៩កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨នេះ ឯកឧត្តមរដ្ឋមន្ត្រី និងគណៈប្រតិភូបានវិលត្រឡប់មកដល់មាតុប្រទេសវិញដោយសុវត្ថិភាព។

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរ២នាក់មកកម្ពុជាវិញតាមច្រកអន្តរជាតិជាំ

http://www.rasmeinews.com/ February 13, 2018, 7:27 AM

(ឧត្តរមានជ័យ)៖ ប្រភពព័ត៌មានបានឱ្យដឹងថា អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន២នាក់ មកកម្ពុជាវិញតាមច្រកអន្តរជាតិជាំ ស្រុកអន្លង់វែងកាលពីម៉ោង១១និង៣០នាទី ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលត្រូវចាប់ខ្លួនថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ពីបទឆ្លងដែនកាប់ឈើក្រញូងខុសច្បាប់ក្នុងទឹកដីថៃ។

សមត្ថកិច្ចបានឱ្យដឹងថាជនពីរនាក់នោះជាប់គុកនៅខេត្តអូរប៊ុន ចូលតាមច្រកភូមិសាស្ត្រក្បាលអូរស្វាយ ស្ថិតនៅភូមិទំនប់អភិវឌ្ឍន៍ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ។សមត្ថកិច្ចបានបន្តថា១/ វ៉ុត សុរិទ្ធ ភេទប្រុស ១៧ឆ្នាំ២/ អង់ ឡុង ភេទប្រុស ១៧ឆ្នាំនាក់ទាំង២រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕S/

## ឆ្នាំ២០១៧៖ ស្ត្រីខ្មែរជិត២ម៉ឺននាក់ចេញទៅធ្វើការនៅក្រៅប្រទេស ខណៈរបាយការណ៍ថាស្ត្រីទទួលបានចំណូលតិចជាងបុរស

http://km.rfi.fr/cambodia/ ដោយ វ៉ា សំណព្វ 12/02/2018

ឆ្នាំ២០១៧កន្លងទៅនេះ មានស្ត្រីខ្មែរសរុបជិត២ម៉ឺននាក់ បានចេញទៅបម្រើការងារនៅក្រៅប្រទេសក្នុងចំណោមពលករសរុបជាង៥ម៉ឺននាក់។ នេះបើតាមរបាយការណ៍របស់លោកស្រី អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។ ទន្ទឹមគ្នានេះ ស្ត្រីខ្មែរនៅតែប្រឈមនឹងការរើសអើង អំពើហិង្សា និងចំណាកស្រុកដោយប្រថុយប្រថាន។

នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៧ ដែលលើកឡើងដោយរដ្ឋមន្ត្រីក្រសួងកិច្ចការនារីកម្ពុជា លោកស្រី អ៊ឹង កន្ថាផាវី បានកត់សំគាល់ថា មានស្ត្រីខ្មែរសរុបជិត២ម៉ឺននាក់ បានចេញទៅបម្រើការងារនៅក្រៅប្រទេស ក្នុងចំណោម

ពលករសរុបជាង៥ម៉ឺននាក់។ ដោយក្នុងនោះ ១៨,០៩៧នាក់ បានទៅធ្វើការងារស្របច្បាប់នៅប្រទេសថៃ ជប៉ុន និងសិង្ហបុរី និង១,៦៣១នាក់ ក្នុងចំណោមពលករ-ពលការិនីសរុប៥,៩៦៧នាក់ដែលទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង។ នេះបើតាមការលើកឡើងរបស់លោកស្រីរដ្ឋមន្ត្រី នៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដោយមានការចូលរួមពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ផង នៅព្រឹក ថ្ងៃទី១២ កុម្ភៈ ឆ្នាំ២០១៨នេះ។

ក្រៅពីនេះ លោកស្រីរដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានឲ្យដឹងដែរថា ចំនួនស្ត្រី ជាមន្ត្រីរាជការស៊ីវិលមានរហូតដល់ទៅ៤១ភាគរយ នៃចំនួនមន្ត្រីរាជការសរុបជាង២១ម៉ឺននាក់ (២១៤,០១០នាក់)។ ចំនួននេះ បានកើនឡើងប្រមាណ១ភាគរយបើធៀបនឹងឆ្នាំ២០១៦។ ប៉ុន្តែយ៉ាងណាក៏ដោយ លោកស្រីរដ្ឋមន្ត្រី បានលើកឡើងថា ស្ត្រីកម្ពុជានៅតែប្រឈមនឹងការរើសអើង រងនូវអំពើហិង្សា និងចំណាកស្រុកដោយប្រថុយប្រថាន ដែលបញ្ហានេះ បានបង្កហានិភ័យក្នុងភាពងាយរងគ្រោះរបស់ស្ត្រី និងអាចរារាំងដល់ការរីកចម្រើន នៃស្ថានភាពស្ត្រីក្នុងសង្គមដែលកំពុងវិវត្តយ៉ាងលឿន ដើម្បីប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចក្នុងតំបន់ និងឆាកអន្តរជាតិ។ ហើយក្នុងនោះបើតាមលោកស្រី នៅឆ្នាំ២០១៧កន្លងទៅនេះ មានពលការិនីកម្ពុជា សរុប៥៦២នាក់ត្រូវបានជួយសង្គ្រោះ និងបញ្ជូនឲ្យវិលត្រឡប់មកកម្ពុជាវិញ។

សូមបញ្ជាក់ថា ការលើកឡើងរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារីកម្ពុជា គឺធ្វើឡើងស្របពេលដែលប្រទេសកម្ពុជា និងពិភពលោកត្រៀមប្រារព្ធទិវាសិទ្ធនារីអន្តរជាតិ ៨ មីនាខាងមុខនេះ។ នៅក្នុងរបាយការណ៍ថ្មីរបស់អង្គការសហប្រជាជាតិសម្រាប់សិទ្ធិស្ត្រី នៅថ្ងៃទី ១២ កុម្ភៈ បានលើកឡើងថា ស្ត្រីនៅលើពិភពលោកនៅតែទទួលចំណូលមិនស្មើបុរសនោះទេ បើទោះបីជាការងារដូចគ្នាក៏ដោយ៕

### លោក អះម៉ាត់ យ៉ះយ៉ា ប្រតិកម្មចំពោះតុលាការចេញដីកាចាប់ខ្លួនលោកករណីក្លែងបន្លំឯកសារ

https://www.rfa.org/khmer/ ដោយ អាស៊ីសេរី 2018-02-12

អតីតរដ្ឋលេខាធិការក្រសួងសង្គមកិច្ច លោក អះម៉ាត់ យ៉ះយ៉ា ប្រតិកម្មចំពោះដីកាចាប់ខ្លួនលោកពាក់ព័ន្ធនឹងរឿងបញ្ជូនពលករទៅធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត កាលពីជាង ១០ឆ្នាំមុននោះថា ជារឿងប្រឌិតដើម្បីធ្វើបាបរូបលោក។ លោក អះម៉ាត់ យ៉ះយ៉ា ឲ្យដឹងនៅថ្ងៃទី១២ ខែកុម្ភៈ ថា៖ កាលពីឆ្នាំ២០០៥ លោកបានបង្កើតក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត ដោយក្រុមហ៊ុននេះអនុញ្ញាតពីក្រសួងការងារត្រឹមត្រូវ ក៏ប៉ុន្តែក្រុមហ៊ុននេះដំណើរការបានប្រមាណតែ ៣ខែប៉ុណ្ណោះ ក្រសួងបានបញ្ចប់អាជ្ញាប័ណ្ណទៅវិញ។ លោកអះអាងថា លោកមិនបានក្លែងឯកសារស្ត្រីដែលសមត្ថកិច្ចចោទប្រកាន់រូបលោកថា បានកែអាយុនោះឡើយ ព្រោះស្ត្រីរូបនោះមានលិខិតឆ្លងដែនស្រាប់ មុននឹងបានមកទាក់ទងលោកសុំបញ្ជូនទៅធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត ហើយស្ត្រីរូបនេះក៏ធ្លាប់បានពន្យល់ប្រាប់អំពីការកែឈ្មោះនេះដែរ តែលោកនៅតែមិនយល់ចំពោះសមត្ថកិច្ច និងតុលាការចេញដីកាចាប់ខ្លួនលោក។

លោក អះម៉ាត់ យ៉ះយ៉ា អះអាងថា ការចាប់ខ្លួនលោក អ៊ីស្មាឯល ពិនអូស្មាន នេះ គឺពាក់ព័ន្ធនឹងទំនាស់បុគ្គលរវាងលោក និងលោក អូស្មាន ហាស្សាន់ ក៏ត្រូវជាក្មួយរបស់លោកដែរ។ លោកបញ្ជាក់ថា លោក អ៊ីស្មាឯល ពិនអូស្មាននេះ ត្រូវជាបងប្អូនជីដូនមួយរបស់លោក អូស្មាន ហាស្សាន់។ លោកអះអាងថា មានសាច់ញាតិរបស់លោកប្រាប់លោកថា លោក អូស្មាន ហាស្សាន់ បានបញ្ចុះបញ្ចូលលោក អ៊ីស្មាឯល ពិនអូស្មាន ដើម្បីឲ្យធ្វើជាសាក្សី ថាលោក អ៊ីស្មាឯលនេះ ធ្លាប់បានធ្វើការជាមួយក្រុមហ៊ុនលោក ប៉ុន្តែលោក អ៊ីស្មាឯល បានបដិសេធ បញ្ហានេះហើយដែលឈានដល់ការចាប់ខ្លួនលោក អ៊ីស្មាឯល នោះ៖ «រឿងនេះវាយូរហើយ តាំងពីឆ្នាំ២០០៥ មកម្ល៉េះ ហើយរឿងអ៊ីស្មាឯល ពិនអូស្មាននេះ មិនជាប់ពាក់ព័ន្ធនឹងក្រុមហ៊ុនយើងទេ ហើយរឿងក្លែងបន្លំឯកសារនេះសាមីខ្លួន គឺស្ត្រីដែលត្រឡប់មកពីប្រទេសអារ៉ាប់ឆ្លើយប្រាប់អ្នកកាសែតថា ខ្លួនជាអ្នកកែឈ្មោះអាយុដោយខ្លួនឯង ហើយបានធ្វើលិខិតឆ្លងដែនមុននឹងមកសុំ

ការងារនៅក្រុមហ៊ុនរបស់ខ្ញុំ ដូច្នេះក្រសួងមហាផ្ទៃ ជាអ្នកទទួលខុសត្រូវរឿងនេះ ក្រុមហ៊ុនដឹងតែពីយកមកធ្វើការដោយយោងលើអាយុគាត់គ្រប់ ដែលសំអាងនៅក្នុងប៉ាសស្ព័ររបស់គាត់»។

សាលាដំបូងបានចេញដីការចាប់ខ្លួនលោក អះម៉ាត់ យ៉ះយ៉ា ពីបទក្លែងអត្តសញ្ញាណនេះ នៅក្រោយពីសមត្ថកិច្ចបានចាប់ខ្លួនបេក្ខជនតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោក អ៊ីស្មាឯល ពិនអូស្មាន ដែលត្រូវជាក្មួយរបស់លោក អះម៉ាត់ យ៉ះយ៉ា កាលពីថ្ងៃទី៧ ខែកុម្ភៈ ពាក់ព័ន្ធនឹងករណីដើរឃោសនារកពលករឲ្យក្រុមហ៊ុន Accept Group របស់លោក អះម៉ាត់ យ៉ះយ៉ា។

លោ អះម៉ាត់ យ៉ះយ៉ា បន្ថែមថា មូលហេតុចំបងដែលលោក អូស្មាន ហាស្សាន់ ធ្វើទុក្ខបុកម្នេញលោកមិនចេះចប់នេះ ដោយសារតែលោក អូស្មាន ហាស្សាន់ អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ូកាគូ ធ្វើផ្លូវចេញពីតំបន់បឹងកក់ ពុះរបងកាត់វិហារអ៊ីស្លាមបឹងកក់ ប៉ុន្តែពលរដ្ឋជាច្រើន រួមទាំងលោកផង បានជំទាស់ ហើយសុំឲ្យធ្វើផ្លូវវាងតាមរបង តែលោក អូស្មាន ហាស្សាន់ មិនព្រម៖ «រឿងពុះដីវិហារបឹងកក់ មិនមែនតែខ្ញុំម្នាក់ជាអ្នកអ្នកជំទាស់នោះទេ គឺសួរប្រជាមតិប្រជាពលរដ្ឋ ៨០ ទៅ ៩០% ហើយដែលជំទាស់ មិនមែនខ្ញុំប្រឆាំងទេ ហើយយើងសុំទទូចឲ្យរដ្ឋាភិបាលធ្វើវាងតាមរបង តែអូស្មាន ហាស្សាន់ មិនព្រម។ ...តាមខ្ញុំដឹងគឺពុះផ្លូវទៅ អូស្មាន ហាស្សាន់ ចង់សង់ខុនដូ សង់នេះសង់នោះនៅម្ខាងផ្លូវទៀតនៅទីនោះ ដោយសុំលុយពីអារ៉ាប់មក»។

អាស៊ីសេរី មិនអាចទាក់ទងលោក អូស្មាន ហាស្សាន់ ដើម្បីឆ្លើយតបពីការចោទប្រកាន់នេះ បាននៅឡើយទេ នៅថ្ងៃទី១២ ខែកុម្ភៈ។ លោក អះម៉ាត់ យ៉ះយ៉ា បញ្ជាក់ថា លោកមកដល់ទីសុវត្ថិភាពហើយ៕

## មន្ត្រីជាន់ខ្ពស់ក្រសួងការងារ ដឹកនាំគណៈប្រតិភូទៅទស្សនកិច្ចម៉ាឡេស៊ីដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកពលកម្ម និងធនធានមនុស្សម៉ាឡេស៊ី_កម្ពុជាឲ្យកាន់តែល្អ

http://nokorwatnews.com/ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៨

ភ្នំពេញ៖ គណៈប្រតិភូជាន់ខ្ពស់ នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយ លោក រដ្ឋមន្ត្រី អ៊ិត សំហេង អមដំណើរដោយ លោកអូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ បានចេញដំណើរ ទៅទស្សនកិច្ចផ្លូវការនៅប្រទេសម៉ាឡេស៊ី និងជួបពិភាក្សាការងារជាមួយលោក Dato'Sri Richard Riot Anak Jeam រដ្ឋមន្ត្រីធនជានមនុស្សម៉ាឡេស៊ី ក្នុងគោលបំណង ពង្រឹងទំនាក់ទំនងសាមគ្គីភាព មិត្តភាព ផ្នែកធនជានមនុស្ស និងបង្កើនទំនាក់ទំនងឲ្យកាន់តែល្អ រវាងលពករកម្ពុជា ដែលកំពុងធ្វើការងារ និងគ្រោងបញ្ជូនពលករខ្មែរទៅធ្វើការងារ នៅប្រទេសម៉ាឡេស៊ី ឲ្យមានការទទួលខុសត្រូវ និងយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាលទាំងពី ។

នេះបើតាមការបញ្ជាក់ឲ្យពីលោក អូស្មាន ហាស្សាន់ មុននិងចេញដំណើរ កាលពីរសៀលថ្ងៃ ចន្ទ១២រោច ខែមាឃ ឆ្នាំរកានព្វស័កព.ស២៥៦១ ត្រូវនឹងថ្ងៃទី១២ កុម្ភៈ ឆ្នាំ២០១៨ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញថា៖ គណៈប្រតិភូកម្ពុជា ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារទៅទស្សនកិច្ច នៅម៉ាឡេស៊ីពេលនេះ ក្នុងគោលបំណង ដើម្បីពង្រឹងទំនាក់ទំនងសាមគ្គីភាព មិត្តភាព ផ្នែកធនជានមនុស្ស និងបង្កើនទំនាក់ទំនងឲ្យកានតែល្អ រវាងលពករកម្ពុជាដែលកំពុងធ្វើការងារ និងគ្រោងបញ្ជូនពលករខ្មែរទៅធ្វើការងារតាមផ្ទះ នៅប្រទេសម៉ាឡេស៊ី ឲ្យមានការ ទទួលខុសត្រូវ និងយកចិត្ត ទុកដាក់ខ្ពស់ ពីរាជរដ្ឋា ភិបាលទាំងពី ។

លោកបន្តថា៖ ជាមួយគ្នា ម៉ាឡេស៊ី ក៏បានចូលរួមចំណែកអភិវឌ្ឍន៍លើកស្ទួយសហគមន៍ខ្មែរឥស្លាម តាមរយៈជំនួយឧបត្ថម្ភមនុស្សធម៌ ផ្សេងៗដូចជា ការផ្តល់អាហារូបករណ៍ដល់សិស្សនិស្សិត បានបន្តការសិក្សានៅតាម សកលវិទ្យាល័យនានានៅ ប្រទេសម៉ាឡេស៊ី ។ ម៉ាឡេស៊ីទទួលយកកម្លាំពលកម្ម កម្ពុជាទៅធ្វើការផ្នែក ការងារឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម និងរោងចក្រផ្សេងៗជាច្រើនម៉ឺននាក់។ មិនតែប៉ុណ្ណោះ ម៉ាឡេស៊ីបានចូលរួម ឧបត្ថម្ភកសាងវិហារ, សាលារៀន ,វគ្គបណ្តុះបណ្តាលគ្រូ បង្រៀន, សិក្ខាសាលាជំនាញហិរញ្ញវត្ថុឥស្លាម,ការគ្រប់គ្រងវិស័យហាឡាល

,ការ ប្រមូលវិស័យរ៉ាហ្គាហ្វ(ទាយផ្ទុទាន) គ្រប់គ្រងវិស័យហ្សាកាត់ (ការបរិច្ចាគទ្រព្យ) បច្ចេកទេស គ្រប់គ្រងហាជ្ជី (ការធ្វើធម្មយាត្រា) បច្ចេកវិទ្យាឧបត្ថម្ភដល់កុមារកំព្រា កម្មវិធីស្រាយបួស និងជំនួយគ្រោះធម្មជាតិជាដើម ។

លោកបន្តទៀតថា៖ យើងបាន ឃើញយ៉ាង ច្បាស់ហើយថា សន្តិភាពដែលយើងកំពុងមាន នាពេលបច្ចុប្បន្ន បានបង្កលក្ខណៈឲ្យកម្ពុជា ផ្តល់កិត្តិយស ស្មើមុខស្មើមាត់ ក្នុងកាធ្វើទំនាក់ទំនងជាមួយបណ្តាប្រទេសដ៏ទៃទៀតលើឆាកអន្តរជាតិ យើងត្រូវរួមគ្នាថែរក្សា និងការពារសន្តិភាពដែលយើងកំពុងមាន និងបន្តការកសាងជាតិ យើងឲ្យកាន់តែរីកចំរើនបន្តទៀត ៕ សំរិត

## ពលករខ្មែរជាង៤ម៉ឺននាក់ នឹងទទួលបានការងារស្របច្បាប់នៅក្រៅប្រទេស

http://kleykley.sabay.com.kh/ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៨ ម៉ោង 09:56

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុញ្ញាតឲ្យក្រុមហ៊ុនឯកជនចំនួន ៨៥ និងតាមប្រព័ន្ធអនុគ្រោះមុខបរ (EPS) បានធ្វើការជ្រើសរើស និងបញ្ជូនពលករទៅធ្វើការដោយ ស្របច្បាប់នៅក្រៅប្រទេស ដែលមានពលករសរុបចំនួន ៤៥៧៩៧ នាក់ (ស្រីចំនួន ១៨២៨០ នាក់)។

ការបង្ហាញនេះ បានធ្វើឡើងក្នុងកិច្ចប្រជុំ ស្តីពីរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈនេះ។

ពលករដែលបញ្ជូនទៅធ្វើការនៅក្រៅប្រទេសមានដូចជា ប្រទេសថៃ ចំនួន ៣៥៦៧៤ នាក់ (ស្រី ១៥០៨០ នាក់)។ ប្រទេសជប៉ុន ចំនួន ២២៨០នាក់ (ស្រី ១២៤១នាក់)។ ប្រទេសសិង្ហបុរី ចំនួន ១៣៨នាក់ (ស្រី)។ ប្រទេសម៉ាឡេស៊ី ចំនួន ២៧នាក់ (ស្រី៧នាក់)។ ប្រទេសអារ៉ាប៊ីសាអូឌីត ចំនួន ១២នាក់ (ស្រី)។ តំបន់រដ្ឋាភិបាលពិសេសហុងកុង ចំនួន ៥នាក់ (ស្រី)។ ហើយបានបញ្ជូនពលករទៅធ្វើការនៅប្រទេសកូរ៉េតាមប្រព័ន្ធអនុគ្រោះមុខបរ (EPS) ចំនួន ៧៦៦១នាក់ (ស្រីចំនួន ១៧៩៧នាក់)៕ អត្ថបទ៖ សោភា

## ឆ្នាំ២០១៧សមត្ថកិច្ច បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្ម ផ្លូវភេទ មានកើនឡើង

http://bayontv.com.kh/ 13/02/2018

ភ្នំពេញ ៖ នៅក្នុងឆ្នាំ២០១៧ អគ្គស្នងការនគរបាលជាតិ សហការជាមួយព្រះរាជអាជ្ញាតាមរាជធានី-ខេត្ត បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្ម ផ្លូវភេទ បានចំនួន ១៥៩ករណី (លើ៩២ករណី បើធៀបនឹង ឆ្នាំ២០១៦ កើនឡើងចំនួន៦៧ករណី)។

របាយការណ៍ បានឲ្យដឹងថា សមត្ថកិច្ចឃាត់ខ្លួនជនសង្ស័យ និងបញ្ជូនទៅសាលាដំបូង បានចំនួន ២០៣ នាក់/១១៣នាក់ កើនឡើងចំនួន៩០នាក់ ស្រី៦១នាក់ អនីតិជន១៧នាក់ ត្រូវបានចាប់ខ្លួន។ ក្នុងចំណោមជនសង្ស័យដែលជាបរទេសចំនួន២០នាក់ មាន៨សញ្ជាតិរួមមាន ចិន៩នាក់ វៀតណាម៣នាក់ អង់គ្លេស២នាក់ ហូឡង់២នាក់ ជប៉ុន១នាក់ អាមេរិក១នាក់ រុស្ស៊ី១នាក់ និងឆេក១នាក់។

ដោយឡែកជនរងគ្រោះដែលសង្គ្រោះ បានក្នុងករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ៣៤៥នាក់/២៩៨នាក់ ថយចុះចំនួន៤៧នាក់ ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ ចំនួន១៣៨នាក់ អាយុពី១៥ទៅ១៧ ឆ្នាំ ចំនួន៤០នាក់ និងអាយុ១៨ឆ្នាំឡើង ចំនួន១៦៧នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ចចំនួន១២០នាក់ អង្គការចំនួន៥នាក់ និងទៅគ្រួសារចំនួន២២០នាក់។

របាយការណ៍ បានបន្តថា ករណីអំពើជួញដូរមនុស្សបង្ក្រាបបាន ៤៨/២២លើក កើន២៦ករណី ឃាត់ខ្លួនជនសង្ស័យចំនួន៧២នាក់ ស្រី៣៧នាក់ ជនបរទេសចំនួន៨នាក់ រួមមាន ចិន៣នាក់ ជប៉ុន១នាក់ វៀតណាម១នាក់ អាមេរិក១នាក់ រុស្ស៊ី១នាក់ និងអង់គ្លេស១នាក់។ សង្គ្រោះជនរងគ្រោះចំនួន១២៩នាក់ ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ ចំនួន៣២នាក់ (២៤.៨០%) អាយុពី១៥ទៅ១៧ឆ្នាំ ចំនួន១៩នាក់ (១៤.៧២%) និងអាយុ១៨ឆ្នាំឡើង៧៨នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច ចំនួន២៤នាក់ អង្គការ១នាក់ និងទៅគ្រួសារ១០៤នាក់៕

## លោករដ្ឋមន្ត្រីក្រសួងការងារថៃ ចុះត្រួតពិនិត្យសូន្យ( OneStopService )នៅក្នុងក្រុងកូរាត

http://www.prakpheaktra.com February 13, 2018

កាលពីថ្ងៃច័ន្ទទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ ម្សិលមិញនេះ លោករដ្ឋមន្ត្រីក្រសួងការងារថៃ បានចុះត្រួតពិនិត្យទីតាំងតប័ត្រស៊ីជម្ពូនិងធ្វើវីសារជូនពលករបរទេស ឬហៅថាសូន្យ (វ៉ាន់ស្តប់សឺវីត) ដែលទីតាំងស្ថិតនៅក្នុងហាងទំនើប Plaza JomSurat ជាន់ទី6 ក្នុងក្រុងកូរាត ខេត្តណាខនរាចស៊ីម៉ា ក្នុងឱកាសចុះត្រួតពិនិត្យសូន្យខាងលើលោករដ្ឋមន្ត្រីបានជួបសំណេះសំណាលជាមួយនិយោជក និងបងប្អូនពលករខ្មែរដែលបានចូលមកបំពេញសំណុំបែបបទធ្វើវីសារពីរឆ្នាំនៅក្នុងសូន្យខាងលើដែរ។ បន្ទាប់ពីចុះត្រួតពិនិត្យទីតាំងសូន្យ (OneStopService) ខាងលើលោករដ្ឋន្ត្រីបានអំពាវនាវឲ្យថៅកែថៃប្រញាប់នាំពលករបរទេសទាំងអស់ ទៅធ្វើប័ត្រស៊ីជម្ពូ និងវីសាការងារអោយបានត្រឹមត្រូវមុនថ្ងៃទី 31.03.2018 ហើយក្នុងនោះលោករដ្ឋមន្ត្រីបានបញ្ជាក់ប្រាប់ថៅកែថៃអោយនាំពលករទៅត្រួតពិនិត្យសុខភាពនៅមន្ទីរពេទ្យរដ្ឋជាមុនសិន។

## ស្ថានទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី និងចិន អន្តរាគមន៍ជួយ ពលរដ្ឋខ្មែរ ៦នាក់

https://www.dap-news.com/kh/ អង្គារ, ១៣ កុម្ភៈ ២០១៨ 12:22 ដោយ: ដើមអម្ពិល ID:012

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

### ស្ថានទូតកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរចំនួន៦នាក់

------------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**៥នាក់** (បុរស ២នាក់ និងនារី ៣នាក់) ដែលធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង៥នាក់នោះ បានមកដល់កម្ពុជាវិញជាបន្តបន្ទាប់ នៅថ្ងៃទី**១០** និងទី**១១** ខែ**កុម្ភៈ ឆ្នាំ២០១៨** ។

២. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ចិន** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចទីក្រុង Wuhan ខេត្តHubei របស់ចិន ជួយសង្គ្រោះយុវតីខ្មែរ**១នាក់** ឈ្មោះ**ភ.ប** អាយុ១៧ឆ្នាំ មកពីខេត្តកំពង់ចាម ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការជាមួយបុរសជនជាតិចិន។

ស្ថានទូត បានផ្តល់កន្លែងស្នាក់នៅ អាហារបរិភោគ សម្ភារៈប្រើប្រាស់ និងរៀបចំឯកសារធ្វើដំណើរ ហើយនាងបានមកដល់កម្ពុជាវិញ នៅថ្ងៃទី**០៨** ខែ **កុម្ភៈ ឆ្នាំ២០១៨** ។

ថ្ងៃ អង្គារ ១៣កើត ខែ មាឃ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៨
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

# ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨

## អាសូរណាស់ ! ព្រោះតែក្រពះជាប់គុកស្រុកគេស្ទើររាល់ថ្ងៃ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៨ម៉ោង ២៣:២៤ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ខ្មែរថៃ៣នាក់ត្រូវបានសមត្ថកិច្ចចម្រុះថៃចាប់ខ្លួនក្នុងតំបន់ឧទ្យានជាតិប៉ាងស៊ីដា ក្នុងខេត្តស្រះកែវ ប្រទេសថៃ នាព្រឹកថ្ងៃទី១៣ កុម្ភៈ ២០១៨ ដោយចោទប្រកាន់ថាចូលទៅលួចកាប់ឈើ គ្រញូង។ ការចាប់បានជនសង្ស័យទាំង៣គឺតាមរយៈកាមេរ៉ាសុវត្ថិភាព និងដានជើង ហើយសមត្ថកិច្ច តាមពីក្រោយរហូតដល់គោលដៅដែលជនសង្ស័យខ្មែរថៃជាង២០នាក់ កំពុងចែកសម្ភារគ្នាដើម្បីចូល រកកាប់ឈើគ្រញូង នេះបើយោងតាមការចុះផ្សាយរបស់គេហទំព័រថៃមួយ។

ជនសង្ស័យទាំង៣នាក់រួមមាន ១.ឈ្មោះ ប៉េ ស៊ឹបម៉ា ភេទប្រុស អាយុ៦៦ឆ្នាំ ជាជនជាតិថៃ ២.ឈ្មោះ តាំង ឡឹម ភេទប្រុស អាយុ៣៤ឆ្នាំ(ខ្មែរ) និង៣.ឈ្មោះ មៀ អ៊ាន ភេទប្រុស អាយុ៤៥ឆ្នាំ(ខ្មែរ)។ ករណីខាងលើសមត្ថកិច្ចថៃរឹបអូសបានរណាយន្ត២គ្រឿង កាំភ្លើងវែង១ដើម គ្រាប់២០៩គ្រាប់ និងស្បៀងអាហារមួយចំនួន។ ក្រោយសាកសួរជនសង្ស័យទាំង៣ប្រាប់ថា មានគ្នាសរុប២០នាក់ត្រូវថៅកែជាជនជាតិខ្មែរជួលឲ្យកាប់ឈើគ្រញូង ប៉ុន្តែមិនទាន់ទាំងបានកាប់ផងត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ជនសង្ស័យទាំង៣នាក់ ពេលនេះកំពុងត្រូវបានសមត្ថកិច្ចថៃឃុំខ្លួនបណ្តោះអាសន្នក្នុងខេត្តកើតហេតុ មុនពេលប្រឈមឡើងក្តីនៅតុលាការរបស់ថៃ។

គួរបញ្ជាក់ថា ព្រោះតែដើម្បីក្រពះ និងជីវភាពគ្រួសារ ពលករខ្មែរជាច្រើននាក់បានក្លាយជាជនរងគ្រោះជាបន្តបន្ទាប់ មានស្លាប់ និងរបួស ជាប់គុកនៅស្រុកគេដោយសារការលួចឆ្លងដែនខុសច្បាប់ មិនថាពលករទៅស្វែងរកការងារធ្វើតាមបណ្តាខេត្ត ក្នុងនោះរួមទាំងក្រុមពលករស៊ីឈ្នួលកាប ឬលីសែងឈើគ្រញូងផងដែរ ខណៈក្រុមមេខ្យល់ និងអ្នកនៅពីក្រោយខ្នងរួចផុតពីសំណាញ់ច្បាប់រហូត៕

## កម្ពុជា-ថៃឯកភាពបញ្ចប់ការផ្តល់ភាពស្របច្បាប់ជូនពលករខ្មែរ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៨ម៉ោង ១០:១៦អាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ៖ ភាគីកម្ពុជា និងភាគីថៃបានឯកភាពគ្នាបញ្ចប់ភាពស្របច្បាប់ជូនពលករខ្មែរដែលបម្រើការងារនៅប្រទេសថៃ ឲ្យបានបំណាច់ខែមិថុនា ឆ្នាំ២០១៨ ខាងមុននេះ ។ ការឯកភាពនេះធ្វើលើកឡើងរវាងជំនួបពិភាក្សាការងារលោក អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយលោក Pol Gen. Adul sangsingkeo រដ្ឋមន្ត្រីក្រសួង ការងារព្រះរាជាណាចក្រថៃដែលដឹកនាំប្រតិភូបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រ កម្ពុជាកាលពីរសៀលថ្ងៃ១៣ ១៤ កម្ភៈ ឆ្នាំ ២០១៨ នៅសណ្ឋាគារ ភ្នំពេញ ។

ភាគីទាំង២វាយតម្លៃកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរក្នុងការដោះស្រាយបញ្ហាពលករ កម្ពុជានៅថៃប្រកបដោយលទ្ធផលល្អ ។ មជ្ឈមណ្ឌលទាំង៣នៅបាងកកក៉ាកយ៉ង និងសុងខ្លាបានដំណើរការល្អ ។ បានធ្វើលិខិតធ្វើដំណើរ TD ប័ណ្ណ OCWC ដែលបានផ្តល់ជូនពលករ១ថ្ងៃ ១៧០០ ទៅ១៨០០នាក់ ។ មកទល់ពេលនេះនៅសល់ប្រហែល៣៤ម៉ឺននាក់ទៀត ដែលត្រូវបន្តផ្តល់ភាពស្របច្បាប់ រហូត ដល់ខែមិថុនា ឆ្នាំ ២០១៨ ។ ជាងនេះទៀតភាគីទាំង២ ឯកភាពកំណត់ពេលបញ្ចប់ការងារថ្ងៃបំណាច់ខែមិថុនា រៀបចំក្រុមការងារចល័ត និងមជ្ឈមណ្ឌលបន្ថែម ដើម្បីបង្កើនល្បឿនដល់៤០០០នាក់ ក្នុងមួយថ្ងៃ ។ ភាគីថៃកំណត់ទីតាំងរៀបចំបញ្ជីឈ្មោះ ពលករកម្ពុជា និងផ្តល់ទិដ្ឋាការស្នាក់នៅ និងទិដ្ឋាការកាងារជូនពលករកម្ពុជា ។ រៀបចំក្រុមចម្រុះប្រចាំការនៅក្រសួងការងារថៃ ដើម្បីដោះស្រាយបញ្ហាក្នុងប្រតិបត្តិការ នេះ ។ បង្កើនស្មារតីសហប្រតិបត្តិការបងប្អូនទៅ កាន់ តែជិតស្និទ្ធ ថែម ទៀត ។

ក្នុងជំនួបនោះដែរភាគីថៃសុំអញ្ជើញរដ្ឋមន្ត្រី និងក្រុមការងារបច្ចេកទេសកម្ពុជា ទស្សនកិច្ច នៅ ថៃក្នុងអំឡុងខែមិនា ឆ្នាំ២០១៨ នៅពេលតំណើរការផែនការថ្មី ៕

## កាត់ទោស ប្ដីប្រពន្ធ ២នាក់រឿងរៀបអន្ដរាក់ នាំស្ត្រីខ្មែរ ទៅលក់នៅស្រុកចិន

http://ann.com.kh/ ថ្ងៃពុធ, 14 ខែកុម្ភៈ 2018 10:22 ព្រឹក

ភ្នំពេញ៖ កាលពីរសៀលថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ម្សិលមិញ លោក អ៊ី ថាវរៈ ប្រធានក្រុមប្រឹក្សាចៅក្រម ប្រឹក្សាចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ បានបើកសវនាការ កាត់ទោសបុរសជនជាតិចិន និងប្រពន្ធខ្មែរ ពាក់ព័ន្ធសំណុំរឿង ដើរឃោសនា នាំនារីខ្មែរទៅរៀបការប្តីនៅប្រទេសចិន។

លោក សេង ហៀង ជាតំណាងអយ្យការសវនាការ បានចោទប្រកាន់លើឈ្មោះ ម៉ា ចាវហ្វូ ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិចិន និងឈ្មោះ ស៊ុ គន្ធា ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ពីបទ នាំចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែន ប្រព្រឹត្តកាលពីអំឡុងឆ្នាំ២០១៦ នៅខេត្តកណ្តាល និងរាជធានីភ្នំពេញ យោងតាមមាត្រា ១១ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលអាចប្រឈមការជាប់ពន្ធនាគារពី៧ឆ្នាំ ទៅ ១៥ឆ្នាំ។ នៅក្នុងសវនាការជនជាប់ចោទ បានបដិសេធការចោទប្រកាន់របស់តុលាការ ដោយអះអាងថា ពួកគេមានបំណងជួយឱ្យជនរងគ្រោះ បានប្តីនៅស្រុកចិន ក្រែងបានជីវភាពធូរជាជាងមុនតែប៉ុណ្ណោះ។

ចំណែកជនរងគ្រោះ ២នាក់ ទី១ឈ្មោះ ព.ស.ត និងទី២ឈ្មោះ ហ.ច.ប បានបញ្ជាក់ថា ជនជាប់ចោទ ទាំង២នាក់ និងបក្ខពួក២នាក់ទៀត ដែលកំពុងរត់គេចខ្លួន បានលួងលោមពួកនាង ឱ្យទៅរៀបការប្តីនៅស្រុកចិនទៅ បានលុយចាយច្រើន រស់ស្រួល និងអាចបានលុយផ្ញើឱ្យម្តាយឪពុកនៅស្រុក ថែមទៀតផង។ ក្រៅពីនេះក្រុមជនជាប់ចោទបានប្រាប់ថា ប្តីចិន ឱ្យថ្លៃទឹកដោះដំបូង ចំនួន ២០០០ដុល្លារទៅឪពុកម្តាយរបស់ពួកនាង។ ក្រោយពីពួកនាង ព្រមទៅរៀបការប្តី នៅប្រទេសចិន ក្រុមជនជាប់ចោទ បានរត់ការធ្វើឯកសារឆ្លងដែន និងនាំពួកនាង ឆ្លងទៅប្រទេសចិនតាមប្រទេសវៀតណាម។

នៅពេលទៅដល់ប្រទេសចិន ក្រុមជនជាប់ចោទ បានឱ្យពួកនាង ទៅរៀបការប្តី ចិន។ ក្រោយពីការរួចរស់នៅបានមួយរយៈ ប្តីចិន បានវាយធ្វើបាបពួកនាង និងបង្ខាំងពួកនាងទុកតែក្នុងផ្ទះ និងបម្រុងលក់បន្តឱ្យទៅផ្ទះបនស្រីទើបពួកនាង លួចរត់ឱ្យសមត្ថកិច្ចជូនទៅរកស្ថានទូតខ្មែរប្រចាំប្រទេសចិនដើម្បីជួយសង្គ្រោះ បានត្រលប់មកប្រទេសកម្ពុជាវិញ។ ជនរងគ្រោះទាំង២នាក់បានប្តឹងទាមទារ សំណង ពីជនជាប់ចោទ ក្នុងម្នាក់ៗ ចំនួន ២ម៉ឺនដុល្លារ។ ទោះជាយ៉ាងណាសំណុំរឿងនេះត្រូវតុលាការលើកពេលទៅប្រកាសសាលក្រមនៅព្រឹកថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ខាងមុខវិញ៕

## កងទ័ពឈរជើងតាមបន្ទាត់ព្រំដែនត្រូវធ្វើយ៉ាងណាទប់ស្កាត់បទល្មើសឱ្យបាន

http://www.rasmeinews.com/ February 14, 2018, 9:46 AM

(ព្រះវិហារ)មេបញ្ជាការប្រតិបត្តិការសឹករងខេត្តព្រះវិហារបានណែនាំនិងជំរុញឲ្យកម្លាំងកងទ័ពទាំងអស់ដែលឈរជើងការពារតាមខ្សែបន្ទាត់ព្រំដែនត្រូវធ្វើយ៉ាងណាទប់ស្កាត់នូវរាល់បទល្មើសឆ្លងដែនគ្រប់ប្រភេទ។ជាពិសេសការលួចឆ្លងដែនទៅកាប់ឈើគ្រញូងនិងបទល្មើសគ្រឿងញៀនឆ្លងដែនដើម្បីរក្សាសុខសុវត្ថិភាពជូនប្រជាពលរដ្ឋឲ្យខានតែបាន។ ការជំរុញឱ្យកងកម្លាំងរក្សាសុខសុវត្ថិភាពជូនពលរដ្ឋនេះកាលពីថ្ងៃទី១៣ខែកុម្ភៈឆ្នាំ២០១៨លោកឧត្តមសេនីយ៍ត្រីច័ន្ទសុភ័ក្រ្តាមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រះវិហារ រួមដំណើរដោយថ្នាក់ដឹកនាំតំបន់សឹក បានអញ្ជើញចុះសួរសុខទុក្ខនាយទាហាន នាយទាហានរង និងពលទាហាន នៅចំណុចនាគបួស របស់វរសេនាតូចលេខ១ ចំណុះឲ្យតំបន់ប្រតិបត្តិការសឹករងព្រះវិហារ។

ក្នុងដំណើរចុះសួរសុខទុក្ខនេះលោកមេបញ្ជាការបានផ្តាំផ្ញើដល់នាយទាហាននាយទាហានរង និងពលទាហានធ្វើយ៉ាងរក្សាសុខភាពឲ្យបានល្អទើបអាចសម្រេចរាល់ការងារទាំងឡាយរបស់អង្គភាពបាន។ លើសពីនេះលោកក៏បានជំរុញឲ្យកងកម្លាំងទាំងអស់ត្រូវធ្វើយ៉ាងណាទប់ស្កាត់ឲ្យបាននូវបទល្មើសទាំងឡាយ ដូចជា ការទប់ស្កាត់ពលករលួច

លបចូលកាប់ឈើគ្រញូងខុសច្បាប់ ការជួញដូរគ្រឿងញៀន។ល។ ពិសេសជាងនេះកងកម្លាំង គឺត្រូវធ្វើយ៉ាងណា រក្សាសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ។ នាឱកាសនោះ លោកមេបញ្ជាការ និងនាយទាហានបានជួយឧបត្ថម្ភថវិកា និងសម្ភារៈឧបភោគបរិភោគមួយចំនួន។លោក ច័ន្ទ សុភ័ក្រ្តា ជួយជាថវិកាចំនួន៤០០.០០០រៀល,មី៣កេស,ទឹកក្រូច១កេស,ត្រីខ១កេស,។ លោកវរសេនីយ៍ទោ យ៉ាន់ សុធា ថវិកា១៦០.០០០រៀល សម្រាប់ទិញធុងស្តុកទឹកចំនួន២ និងលោកវរសេនីយ៍ត្រី ហូ សិលា ថវិកា១៦០.០០០រៀល សម្រាប់ទិញធុងស្តុកទឹកចំនួន២។

បន្ទាប់ពីការចុះសួរសុខទុក្ខកងកម្លាំងនៅចំណុចនាគបួស របស់វរសេនាតូចលេខ២១ លោកមេបញ្ជាការ បានបន្តដំណើរចុះត្រួតពិនិត្យមើលលេណដ្ឋាន ដែលកំពុងកសាងសងនៅទីបញ្ជាការវរសេនាតូចលេខ២១ អណ្តូងរយផងដែរ៕ S/ដោយៈសៅវ៉ាន់ឌី

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចុះអនុស្សរណៈជាមួយមូលនិធិ ឈាន ឆាយ សហការគ្នាជួយពលករចំណាក់ស្រុក

http://cambodiapolice.com/blog/ 12:14 pm 14 កុម្ភៈ 2018

ភ្នំពេញៈ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨នេះ បានធ្វើការចុះអនុស្សរណៈជាមួយសមាគមមូលនិធិ ឈាន ឆាយ ដើម្បីមនុស្សធម៌ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសក្នុងចំណោមពលករទេសន្តរប្រវេសន៍នៅប្រទេសថៃ ហើយការចុះអនុស្សរណៈនេះ ក៏ដើម្បីសហការគ្នាជួយដល់ពលករ ខណៈពួកគេមានបញ្ហាអ្វីកើតឡើងជាដើមនោះ ។

ថ្លែងប្រាប់ដល់អ្នកសារព័ត៌មានក្រោយពីចុះអនុស្សរណៈនោះ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឲ្យដឹងថា ការចុះអនុស្សរណៈជាមួយមូលនិធិ ឈាន ឆាយ នេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីសហការគ្នាជួយដល់បងប្អូនពលករខ្មែរ ដែលធ្វើការនៅប្រទេសថៃ ពេលដែលពួកគេមានបញ្ហាអ្វីកើតឡើងនោះ។ លោកជំទាវរដ្ឋលេខាធិការ បានលើកឡើងទៀតថា សមាគមមូលនិធិ ឈាន ឆាយ នេះគឺមានស្នាក់ការនៅក្រុងប៉ោយប៉ែត ជាប់និងជាយដែនកម្ពុជា-ថៃ ហើយមូលនិធិនេះ គឺមានបណ្តាញច្រើននៅក្នុងប្រទេសថៃ ដូច្នេះពេលដែលពលករខ្មែរយើងមានបញ្ហាអ្វីកើតឡើង គឺសមាគមន ឈាន ឆាយ នេះបានដឹង ហើយគេនឹងរាយការណ៍បន្តដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយក្រុមការងារយើងនឹងចុះដើម្បីជួយ និងអន្តរាគមន៍ដល់បងប្អូនពលករទាំងនោះតែម្តង។

បើតាមលោកជំទាវបានឲ្យដឹងផងដែរថា នាពេលខាងមុខនេះ រាជរដ្ឋាភិបាលដែលមាន ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទានឹងធ្វើកន្លែងស្នាក់នៅបណ្តោះអាសន្ននៅ នឹងច្រកក្រុងប៉ោយប៉ែត ជូនដល់បងប្អូនពលករខ្មែរដែលត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនមកវិញ ហើយស្របពេលដែលគេបញ្ជូនមកវិញនោះ ក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនឹងធ្វើការសាកសួរដល់ពួកគេអំពីមូលហេតុដែលកើតឡើងចំពោះពួកគេផងដែរ ៕

## ដំណឹងល្អ, ក្រសួងការងារថៃ ប្រកាសពន្លឿនដំណើរការត្រួតសញ្ជាតិជូនពលករកម្ពុជាអោយមានភាពឆាប់រហ័សជាងមុន

http://www.prakpheaktra.com February 13, 2018

រដ្ឋមន្ត្រីក្រសួងការងារថៃ ប្រកាសបង្កើនល្បឿនដំណើរការត្រួតសញ្ជាតិជូនបងប្អូនពលករកម្ពុជាអោយបានមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ខាងខមុខនេះ។ កាលពីថ្ងៃអង្គារទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ព្រឹកមិញនេះ អ្នកនាំពាក្យក្រសួងការងារថៃ អ្នកស្រីភេតរ៉ាត់ បានមានប្រសាសន៍ថា លោកអាប់ដុលសែងសិងកែវរដ្ឋមន្ត្រីក្រសួងការងារថៃ ត្រៀមនិងធ្វើដំណើរទៅទស្សនកិច្ចជួបពិភាក្សាជាមួយឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា ដើម្បីជួប

ពិភាក្សា លើបញ្ហាត្រួតសញ្ជាតិជូនពលករកម្ពុជាដែលកំពុងធ្វើការស្នាក់នៅក្នុងប្រទេសថៃ អោយមានដំណើរការលឿនជាងមុននិងមានភាពឆាប់រហ័ស ដើម្បីជាប្រយោជន៍ដល់បងប្អូនពលករកម្ពុជា អោយបានរួចរាល់មុនថ្ងៃទី៣១ ខែមិថុនាឆ្នាំ២០១៨ខាងមុខនេះ។

## ដំណឹងល្អ ក្រសួងការងារថៃប្រកាសអនុញ្ញាតឲ្យពលករខ្មែរប្តូរថៅកែថ្មីបាន នៅសូន្យ

( OneStopService )

http://www.prakpheaktra.com February 13, 2018

យោងតាមលិខិតប្រកាសរបស់ក្រសួងការងារថៃលេខ (រ.ស០៣១៦/២៨៣៩០) ចេញសេចក្តីប្រកាសនៅថ្ងៃច័ន្ទទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ បានប្រកាសអនុញ្ញាតអោយពលករបរទេសមានខ្មែរ,ឡាវ,ភូមា កំពុងកាន់លិខិតបញ្ជាក់ទំនាក់ទំនងឬហៅថា(លិខិតលុងបៀន)និងតប័ត្រស៊ីជម្ពូ ដែលកំពុងធ្វើការខុសនិយោជក(ខុសថៅកែ) សូមប្រញាប់រួសរាន់អោយថៅកែថ្មីនាំទៅដំណើរការប្តូរថៅកែ អោយបានត្រឹមត្រូវនៅមុនថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៨ នៅក្នុងសូន្យ (OneStopService) គ្រប់ខេត្តក្រុងទូទាំងប្រទេសថៃ ដោយមិនចាំបាច់មានលិខិតចែងបញ្ជាក់ពីថៅកែដើមឡើយ។ អាស្រ័យហេតុនេះសូមបងប្អូនពលករខ្មែរដែលកំពុងធ្វើការខុសថៅកែទាំងអស់ សូមប្រញាប់រួសរាន់ទៅប្តូរថៅកែថ្មីអោយបានត្រឹមត្រូវតាមលក្ខខ័ណ្ឌច្បាប់ការងារថៃដែលបានបានកំណត់។

## ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨

## ពលករកម្ពុជានៅថៃនៅសល់៣៤ម៉ឺននាក់ទៀតមិនទាន់មានភាពស្របច្បាប់

http://www.rasmeinews.com/ February 14, 2018, 9:03 PM

(ភ្នំពេញ)៖ក្នុងជំនួបកិច្ចពិភាក្សាជាមួយគ្នាមួយក្នុងរាជធានីភ្នំពេញ ក្រសួងការងារកម្ពុជានិងក្រសួងការងាររបស់ប្រទេសថៃបានប្រកាសរួមគ្នាថារហូតមកដល់ពេលនេះពលករកម្ពុជាដែលកំពុងធ្វើការងារនៅប្រទេសថៃហើយមិនទាន់មានភាពស្របច្បាប់មានចំនួន៣៤ម៉ឺននាក់ទៀត ហេតុនេះក្រុមការងារប្រទេសទាំង២ត្រូវខិតខំធ្វើបន្តទៀតរហូតដល់ខែមិថុនាឆ្នាំ២០១៨ទើបចប់សព្វគ្រប់។

តាមរយៈជំនួបរវាង លោក បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយសមភាគីថៃ លោក Pol Gen. Adul sangsingkeo រដ្ឋមន្ត្រីក្រសួងការងារប្រទេសថៃ នាសណ្ឋាគារភ្នំពេញបានអោយដឹងថាក្នុងកិច្ចសហប្រតិបត្តិការដោះស្រាយបញ្ហាពលករកម្ពុជានៅថៃនាកន្លងមកទទួលបាននូវលទ្ធផលល្អ ក្នុងមជ្ឈមណ្ឌលទាំង៣នៅបាងកក ខេត្តរ៉ាក់យ៉ងនិង ខេត្តសុងខ្លា។ ជាមួយគ្នាក្រសួងការងារកម្ពុជាបានអោយដឹងដែរថាក្រុមការងារប្រទេសទាំងពីរបានធ្វើលិខិតធ្វើដំណើរTD ប័ណ្ណ OCWC ដែលបានផ្តល់ជូនពលករ១ថ្ងៃ ១៧០០ទៅ១៨០០នាក់ ។

មកទល់ពេលនេះនៅសល់ប្រហែល ៣៤ម៉ឺននាក់ទៀតដែលត្រូវបន្តផ្តល់ភាពស្របច្បាប់រហូតដល់ខែមិថុនាឆ្នាំ២០១៨។ ក្រៅពីនេះភាគីនៃក្រសួងការងារប្រទេសទាំងពីរបានព្រមព្រៀងគ្នាក្នុងការរៀបចំក្រុមការងារចល័ត និងមជ្ឈមណ្ឌលបន្ថែមដើម្បីបង្កើន ល្បឿនដល់៤០០០ក្នុងមួយថ្ងៃ ។ដោយឡែកភាគីថៃកំណត់ទីតាំង រៀបចំបញ្ជីឈ្មោះពលករកម្ពុជានិងផ្តល់ទិដ្ឋាការស្នាក់នៅ និងទិដ្ឋាការការងារជូនពលករកម្ពុជាបន្ថែមទៀតផងដែរ។

គួរបញ្ជាក់ថា បើតាម ឯកឧត្តម អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថាបច្ចុប្បន្នពលករកម្ពុជាទាំងស្របច្បាប់និងមិនស្របច្បាប់ដែលកំពុងបំពេញការងារនៅប្រទេសថៃមានសរុបចំនួន ១.០៥០.០០០នាក់ ។ ជាមួយគ្នាចំពោះកម្មករនេសាទកម្ពុជាដែលកំពុងធ្វើការងារនៅប្រទេសថៃដែរមានចំនួនសរុប ៤៧.០០០នាក់ ដោយក្នុងនេះក្រសួងនឹងរៀបចំឱ្យពួកគេមាលិខិតឆ្លងដែនមុនគេពីព្រោះថាក្រសួងការងារប្រទេសថៃក៏បានសំណូមពរក្នុងរឿងនេះរួចមកហើយផងដែរ៕ ដោយៈដេប៉ូ/sn

## ឯកឧត្តមបណ្ឌិត រដ្ឋមន្ត្រីបានជួបពិភាក្សាការងារ ជាមួយសមភាគីថៃ ឯកឧត្តម Pol Gen. Adul sangsingkeo រដ្ឋមន្ត្រីក្រសួងការងារ នៃព្រះរាជាណាចក្រថៃ

https://www.mlvt.gov.kh/ ពុធ, 14 កុម្ភៈ 2018 16:50

នៅសណ្ឋាគារភ្នំពេញ ថ្ងៃអង្គារ ១៣រោជ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០១៨ ។ ឯកឧត្តម បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជួបពិភាក្សាការងារ ជាមួយសមភាគីថៃ ឯកឧត្តម Pol Gen. Adul sangsingkeo រដ្ឋមន្ត្រីក្រសួងការងារ នៃព្រះរាជាណាចក្រថៃ ដែលបាន ដឹកនាំគណៈប្រតិភូអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅ ព្រះរាជាណាចក្រកម្ពុជា រយៈពេលពីរថ្ងៃទី១៣-១៤ កុម្ភៈ ឆ្នាំ ២០១៨ ។ **ក្នុងជំនួបពិភាក្សានេះទទួលបាននូវលទ្ធផលដូចតទៅ៖**

១-ភាគីទាំង២បានវាយតម្លៃខ្ពស់ទៅលើកិច្ចសហប្រតិបត្តិការ ក្នុងការដោះស្រាយបញ្ហាពលករកម្ពុជាទៅធ្វើការ នៅប្រទេសថៃប្រកបដោយលទ្ធផលល្អ។ ជាមួយគ្នានេះដែរ មជ្ឈមណ្ឌលចំនួន ៣កន្លែង ដែលក្រុមការងារចល័តចុះធ្វើ ឯកសាស្រេបច្បាប់ជូនដល់ពលករកម្ពុជានៅទីក្រុងបាងកក ខេត្ត រ៉ាកយ៉ង និង ខេត្តសុងខ្លាមានដំណើរការល្អ។ ក្រុម ការងារចល័តបានធ្វើលិខិតធ្វើដំណើរ(TD) និង ប័ណ្ណពលករកម្ពុជាធ្វើការនៅបរទេស( OCWC) ដោយផ្តល់ជូនពល ករកម្ពុជាក្នុងមួយថ្ងៃទទួលបានពី ១,៧០០-១,៨០០នាក់ ។ មកទល់ពេលនេះនៅសល់ប្រហែល ៣៤ម៉ឺននាក់ទៀត ដែលត្រូវបន្តផ្តល់ភាពស្របច្បាប់រហូតដល់ ខែមិថុនា ឆ្នាំ២០១៨។

២-ភាគីទាំងពីរ បានឯកភាពកំណត់ពេលបញ្ចប់ការងារផ្តល់ភាពស្របច្បាប់ជូនដល់ពលករកម្ពុជាអោយបាន ក្នុងបំណាច់ខែមិថុនា ឆ្នាំ២០១៨។ ទន្ទឹមនឹងនេះ ក៏រៀបចំក្រុមការងារចល័ត និង មជ្ឈមណ្ឌលមួយចំនួនបន្ថែមទៀត ដើម្បី បង្កើនល្បឿនធ្វើឯកសាស្រេបច្បាប់ជូនពលករកម្ពុជាអោយបានដល់៤,០០០នាក់ក្នុងមួយថ្ងៃ ។ រីឯភាគីថៃក៏បាន កំណត់ទីតាំងដើម្បី រៀបចំបញ្ជីឈ្មោះពលករកម្ពុជា និងផ្តល់ទិដ្ឋាការស្នាក់នៅ និង ទិដ្ឋាការការងារជូនពលករកម្ពុជា ទៀតផង។

៣-ភាគីទាំងពីរនឹងរៀបចំក្រុមចម្រុះប្រចាំការនៅក្រសួងការងារថៃដើម្បីដោះស្រាយបញ្ហាក្នុងប្រតិបត្តិការនេះ។

៤-ភាគីទាំងពីរបង្កើនស្មារតីសហប្រតិបត្តិការជាបងប្អូនអោយ កាន់តែជិតស្និទ្ធថែមទៀត។

៥-ភាគីថៃ បានអញ្ជើញឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារកម្ពុជា និងក្រុមការងារបច្ចេកទេសកម្ពុជាអញ្ជើញទៅ ទស្សនកិច្ចនៅព្រះរាជាណាចក្រថៃក្នុងអំឡុងខែមិនា ឆ្នាំ២០១៨ នៅពេលផែនការថ្មីនេះចាប់ផ្តើមដំណើរការ។ ជាការ ឆ្លើយតប ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានឯកភាពទទួលនូវការអញ្ជើញនេះពី ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ នៃ ព្រះរាជាណាចក្រថៃផងដែរ។ បន្ទាប់ពីជំនួបពិភាក្សាឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានរៀបចំអាហារពេលល្ងាចទទួល គណៈប្រតិភូក្នុង បរិយាកាសរីករាយនិងស្និទ្ធស្នាលបំផុត៕

## ទាហានថៃឃាត់ពលរដ្ឋខ្មែរជិត៣រយនាក់ ពីបទចូលទៅដីកជី និងឆ្លងដែនខុសច្បាប់

http://ann.com.kh/ **ថ្ងៃព្រហស្បតិ៍, 15 ខែកុម្ភៈ 2018 9:33 ព្រឹក**

បន្ទាយមានជ័យ៖ ទាហានប៉ារ៉ាថៃ កាលពីពេលថ្មីៗនេះ បានឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន ២៨៩នាក់ ខណៈ ដែលពួកគេបានឆ្លងដែនពីខេត្តបន្ទាយមានជ័យ ចូលទៅក្នុងខេត្តស្រះកែវ ប្រទេសថៃ។ ប៉ុន្តែយ៉ាងណាក៏ដោយ រហូត មកដល់ពេលនេះ មានតែពលរដ្ឋខ្មែរ១៥នាក់ប៉ុណ្ណោះ ក្នុងចំណោមនោះ ដែលត្រូវបានអាជ្ញាធរថៃ ឃាត់ទុក ពីបទឆ្លង ដែនខុសច្បាប់ ដើម្បីរង់ចាំធ្វើការដោះស្រាយតាមនីតិវិធី។ នេះបើយោងតាមរបាយការណ៍ដែលចេញដោយសាលា ស្រុកថ្មពួក នៃខេត្តបន្ទាយមានជ័យ ដែលត្រូវបានគេធ្វើការផ្សព្វផ្សាយជាសាធារណៈកាលពីថ្ងៃទី១៤ កុម្ភៈ ម្សិលមិញ

។ តាមរបាយការណ៍នោះ បានឲ្យដឹងថា ការចាប់ឃាត់ពលរដ្ឋខ្មែរទាំង២៨៩នាក់ខាងលើ គឺបានធ្វើឡើងចំនួន២ លើកផ្សេងគ្នា រួមមាន៖

លើកទី១៖ ក្នុងពេលដែលពលរដ្ឋខ្មែរចំនួន ២៧៤នាក់ ឆ្លងចូលទឹកដីថៃតាមច្រករបៀងព្រំដែនប្រាសាទតៀង ភូមិប្រាសាទតៀង និងច្រករបៀងព្រំដែនផ្នង់ ភូមិដងរ៉ែក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក តម្រង់ចូលទៅផ្សារស៊ូនសាម ខេត្តស្រះកែវ ក៏ត្រូវបានទាហានប៉ារ៉ាថៃប្រចាំស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ឃាត់ខ្លួននាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៨ ដោយចោទប្រកាន់ពីបទ «ទិញដីគីមីនាំចេញខុសច្បាប់»។ ដោយមានការជួយអន្តរាគមន៍ភ្លាមៗ ពីសំណាក់កម្លាំងអាជ្ញាធរ និងកងកម្លាំងសមត្ថកិច្ចកម្ពុជា ដែលបានចូលទៅសម្របសម្រួលជាមួយភាគីថៃ ទើបប្រជាពលរដ្ឋខ្មែរទាំងនោះ ត្រូវបានដោះលែងឲ្យត្រលប់មកប្រទេសកម្ពុជាវិញ។

លើកទី២៖ នាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ ទាហានថៃប្រចាំស្រុកតាប្រាយ៉ា ខេត្តស្រះកែវ បានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន ១៥នាក់ នៅភូមិខងផែង ឃុំថាប់ថៃ ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ដោយចោទពីបទ «លួចឆ្លងដែនខុសច្បាប់»។ កម្លាំងអាជ្ញាធរ និងកងកម្លាំងសមត្ថកិច្ចកម្ពុជា ក៏បានចូលទៅសម្របសម្រួលជាមួយភាគីថៃជាថ្មីទៀតដែរ ប៉ុន្តែការសម្របសម្រួលនេះមិនទាន់ទទួលបានលទ្ធផលវិជ្ជមាននៅឡើយទេ ដោយសារតែភាគីថៃមិនព្រមដោះលែងតាមការសម្របសម្រួល ហើយបានបញ្ជាក់ថា ពួកគេនឹងបញ្ជូនប្រជាពលរដ្ឋខ្មែរទាំង១៥នាក់នោះ ទៅបន្តនីតិវិធីនៅខេត្តស្រះកែវថែមទៀតផង ។

បើតាមសេចក្តីរាយការណ៍ថា បច្ចុប្បន្នអាជ្ញាធរថៃកំពុងតែចាត់វិធានការម៉ឺងម៉ាត់លើការចំណាកស្រុកខុសច្បាប់របស់ពលករពីប្រទេសនានា ចូលទឹកដីថៃ។ រដ្ឋាភិបាលថៃ បានចេញក្រឹត្យស្តីពីច្បាប់គ្រប់គ្រងពលករបរទេសដ៏តឹងរ៉ឹង ដែលចូលជាធរមានកាលពីថ្ងៃទី២៣ មិថុនាឆ្នាំ២០១៧ មានគោលដៅត្រួតពិនិត្យចំនួនពលករចំណាកស្រុកនៅប្រទេសថៃ ក៏ដូចជាពលករបរទេស ដែលកំពុងធ្វើការខុសច្បាប់នៅក្នុងប្រទេសថៃផងដែរ៕

## កម្ពុជា-ថៃ ពិភាក្សាគ្នាលើបត្យាប័ន អំពីទណ្ឌិតនៃប្រទេសទាំង ២

http://www.postkhmer.com/ បែន សុខហ៊ាន | Publication date 15 February 2018 | 13:20 ICT

**ភ្នំពេញ:** អាជ្ញាធរកម្ពុជា និងថៃ បានជួបពិភាក្សាបន្ថែមលើ «កិច្ចព្រមព្រៀងបត្យាប័ន» ពង្រឹងការធ្វើសមាហរណកម្មទណ្ឌិត ដើម្បីកាត់បន្ថយការប្រព្រឹត្តបទល្មើស ខណៈដែលសមត្ថកិច្ចថៃចុះទៅត្រួតពិនិត្យឥស្សរជនបក្សប្រឆាំងរបស់កម្ពុជាកំពុងលាក់ខ្លួនស្វែងរកសិទ្ធិជ្រកកោន។

លោក ចាន់ គឹមសេង អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃក្នុងដើមសប្តាហ៍នេះបានជួបប្រតិភូតំណាងនាយកដ្ឋានអប់រំកែប្រែនៃក្រសួងយុត្តិធម៌ថៃ ដែលដឹកនាំដោយលោក Krit Krasaedhibaya ប្រធានពន្ធនាគារពិសេសប្រចាំរាជធានីបាងកក និងមន្ត្រីស្ថានទូតថៃប្រចាំនៅកម្ពុជា ដើម្បីពិភាក្សាការងារមួយចំនួនរួមទាំងកិច្ចព្រមព្រៀងបត្យាប័នដែលបានអនុវត្តនាពេលកន្លងមករវាងប្រទេសទាំង ២។ ការពិភាក្សានេះក៏បានលើកអំពីកម្មវិធីនីតិសម្បទាជូនជនជាប់ឃុំ និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីពង្រឹងការធ្វើសមាហរណកម្មរបស់ទណ្ឌិតសំដៅកាត់បន្ថយការប្រព្រឹត្តបទល្មើសជាថ្មី។ នេះបើតាមទំព័រហ្វេសប៊ុកផ្លូវការរបស់អង្គភាពនេះ។

លោក នុត សាវនា អ្នកនាំពាក្យអគ្គនាយកដ្ឋានពន្ធនាគារដែលបានចូលរួមកិច្ចប្រជុំជាមួយគណៈប្រតិភូថៃ បានប្រាប់ភ្នំពេញ-ប៉ុស្តិ៍កាលពីម្សិលមិញថា ពិតជាមានការពិភាក្សាលើកិច្ចព្រមព្រៀងបត្យាប័ន និងពង្រឹងការធ្វើសមាហរណកម្មរបស់ទណ្ឌិត និងបញ្ហាមួយចំនួនទៀតមែន។ លោកថា ការភៀសខ្លួនសុំសិទ្ធិជ្រកកោនរបស់មន្ត្រីគណបក្សសង្គ្រោះជាតិ ដែលជាបក្សប្រឆាំងដ៏ធំនៅកម្ពុជា ខ្លះគឺគ្រាន់តែជាលេសដើម្បី «បិទបាំង» បទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះ។ លោកថ្លែងថា៖ «កន្លងមកត្រង់ថា ឯកសារដែលផ្ញើពីថៃមក វាជាភាសាថៃ ហើយសំណុំរឿងគេសម្រាប់ជនជាប់ឃុំម្នាក់ៗច្រើន ហើយយើងពិបាកក្នុងការបកប្រែដើម្បីស្វែងយល់ពីក្តីក្តាំរបស់គាត់ សម្រាប់ជនជាតិខ្មែរដែលត្រូវ

បញ្ជូនពីថៃមក។ អ៊ីចឹងទៅការអនុវត្តចេះតែបានហើយតែជាក់ស្តែងខ្លឹមសារនៃសាលក្រមសាលាក្តីរបស់ថៃបានចែងមក វាអនុវត្តទៅវាអត់បានពេញលេញ ដោយសារខ្លឹមសារហ្នឹងយើងក្តាប់អត់បាន ព្រោះការងារបរទេស ហើយយើងខ្វះធនធានមនុស្សដែលចេះភាសាថៃ»។

លោកថាបច្ចុប្បន្នកម្ពុជាមានពលរដ្ឋប្រមាណជាជាង ២០០០ នាក់កំពុងជាប់ពន្ធនាគារនៅប្រទេសថៃដែលភាគច្រើនពាក់ព័ន្ធនឹងអន្តោប្រវេសន៍ដោយខុសច្បាប់ ខណៈមានពលរដ្ឋថៃតែ ៥២ នាក់ប៉ុណ្ណោះដែលកំពុងជាប់ពន្ធនាគារនៅប្រទេសកម្ពុជា។ ប៉ុន្តែលោកមិនបានបញ្ជាក់ឲ្យដឹងទេថា ភាគីទាំង ២ បានជជែកអំពីសកម្មជនបក្សប្រឆាំងដែលកំពុងស្វែងរកសិទ្ធិជ្រកកោននៅប្រទេសជិតខាងមួយនេះ ឬយ៉ាងណានោះទេ តែលោកថា មន្ត្រីបក្សប្រឆាំងទាំងនោះបានប្រើលេសជាមន្ត្រីបក្សប្រឆាំងដើម្បីបានសិទ្ធិជ្រកកោនផ្នែកនយោបាយគេចពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

លោកថ្លែងថា៖ «បញ្ហាហ្នឹងគាត់រត់ទៅខ្លួនឯងភាគច្រើន អ្នកខ្លះមានដីកាចាប់ខ្លួន មិនមែនជាបទនយោបាយទេ គាត់ទៅប្រព្រឹត្តបទល្មើសដល់ពេលគេតាមចាប់ខ្លួនគាត់លើកហេតុផលនយោបាយដើម្បីសុំសិទ្ធិជ្រកកោន អាហ្នឹងអាងខ្លួនជាសកម្មជនបក្សប្រឆាំង ចេះតែធ្វើអ៊ីចឹង។ បទល្មើសព្រហ្មទណ្ឌ ហើយយកមកលាយឡំជាមួយរឿងនយោបាយ អាបញ្ហាអស់នេះ វាតែងតែកើតឡើងសម្រាប់ជនឱកាសនិយមខ្លះ»។ លោកបន្ថែមថា៖ «ធ្វើអ៊ីចឹងយើងអត់ទទួលខុសត្រូវទេ គេតាមចាប់ខ្លួនរឿងល្មើសផ្សេងៗ ពាក់ព័ន្ធនឹងព្រហ្មទណ្ឌសោះ រត់ទៅស្រុកគេថាខ្លួនឯងហ្នឹងជាអ្នកនយោបាយ។ នេះជាការមិនទទួលខុសត្រូវទេ»។ លោក នុត សាវនា បន្ថែមថាចំពោះអ្នកដែលមានដីកាចាប់ខ្លួន អគ្គស្នងការនគរបាលជាតិអាចស្នើឲ្យសមភាគីថៃជួយចាប់បញ្ជូនពួកគេឲ្យមកកម្ពុជាវិញ។

លោក សាវនា ថ្លែងថា៖ «អាហ្នឹងពាក់ព័ន្ធជាមួយអគ្គស្នងការ បើមានដីកាតាមចាប់ខ្លួន អាហ្នឹងប្រហែលជាគេអាចស្នើនាមត្រកូលហ្នឹងឲ្យថៃគេជួយចាប់មក ខាងខ្ញុំនេះ ខ្ញុំចាំតែទទួលទេ ចាប់ហើយតុលាការកាត់ទោស អាហ្នឹងបញ្ជូនមកខាងខ្ញុំ ខាងខ្ញុំទទួលតាមបញ្ជា»។

លោក គង់ ម៉ាស អតីតមន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិដែលកំពុងសុំសិទ្ធិជ្រកកោនសម្តែងការបារម្ភចំពោះចំណាត់ការរបស់អាជ្ញាធរថៃក្នុងការចុះត្រួតពិនិត្យដល់កន្លែងស្នាក់នៅរបស់មន្ត្រីបក្សប្រឆាំង។ លោកថា៖ «ឥឡូវនេះយើងកំពុងស្នើសុំមណ្ឌលមួយរបស់ UN ដើម្បីឲ្យ UN គេគិតគូរពីយើង ឥឡូវគេផ្តោតអារម្មណ៍មកលើយើងនៅពេលមានបញ្ហា។ ចាត់ទុកយើងជាករណីពិសេសដោយសារតែរដ្ឋសភាថៃគាំទ្រការរំលាយបក្សប្រឆាំងដល់អ៊ីចឹង UN ចាត់ទុកពួកយើងជាករណីពិសេស»។ លោកបន្ថែមថា៖ «ទី ១ យើងកំពុងខ្លាចការធ្វើបត្យាប័ន ទី ២ វាត្រូវការត្រួតពិនិត្យអ្នកដែលរស់នៅយូរថ្ងៃ មកធ្វើអីយូរម្ល៉េះ ២ ឬ ៣ ខែ ផ្ទះសំណាក់អី កន្លែងជួលវាត្រូវការពិនិត្យ តែបើយើងបានប័ណ្ណ UN វាស្រួល មានបញ្ហាអីវាអត់បញ្ជូនយើងទៅស្រុកខ្មែរទេ តែបើអត់មានប័ណ្ណគេមិនទាន់ឲ្យយើង វាមានហានិភ័យខ្ពស់»។ លោកថា មូលហេតុនៃការភៀសខ្លួនគឺ ដោយសាររឿងនយោបាយសុទ្ធសាធ។

លោកថ្លែងថា៖ «តាមពិតគ្នាយើងដែលមកវាតិចផង បើមកច្រើនល្អ យើងឲ្យគេដឹងថាស្ថានភាពស្រុកខ្មែរ គេនៅលែងបានហើយ អ្នកឯងធ្វើនយោបាយគាបគេពេក ធ្វើឲ្យគេមិនអាចនៅជាមួយអ្នកឯងបាន រឿងនេះជារឿងនយោបាយ យើងមកនេះព្រោះរឿងនយោបាយដើម្បីឲ្យអន្តរជាតិដឹងថាស្រុកខ្មែរមន្ត្រីបក្សប្រឆាំងមិនអាចនៅបានទេ ដោយសារការធ្វើទុក្ខបុកម្នេញមន្ត្រីនៅមូលដ្ឋានរហូតដល់ថ្នាក់ជាតិ»។ លោកបញ្ជាក់ថាពួកគេគ្មានបំណងទៅប្រទេសទី ៣ ទេឲ្យតែនយោបាយមានភាពល្អវិញ ពួកគេនឹងវិលទៅធ្វើការវិញហើយ៕

# ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨

## ពលករដែលមានវីសារផុតកំណត់ថ្ងៃទី30ខែ03ឆ្នាំ2018 សូមប្រញាប់រួសរាន់ទៅ(ត)វីសារពីរឆ្នាំនៅសូន្យOSS

http://www.prakpheaktra.com/ February 15, 2018

ក្រសួងការងារថៃប្រកាសអំពាវនាវដល់បងប្អូនពលករខ្មែរ,ឡាវ, ភូមា ដែលកំពុងកាន់លិខិតឆ្លងដែនធ្វើការមានវីសារផុតកំណត់ 31.03.2018 សូមអោយប្រញាប់រួសរាន់ អោយណាយចាង(ថៅកែថៃ)នាំទៅធ្វើវីសារការងារពីរឆ្នាំនៅទីតាំងសូន្យ (OneStopService) ដែលមានទូទាំងខេត្ត-ក្រុងនៅក្នុងប្រទេសថៃ។ ដកស្រង់ព័ត៌មាន:doe.go.th

## ពលករភូមាធ្វើការនៅប្រទេសថៃ ប្រមាណ 300នាក់ នាំគ្នាធ្វើបាតុកម្មទាមទារប្រាក់ឈ្នួលនៅថ្ងៃបុណ្យសខ្មោច

http://www.prakpheaktra.com/ February 15, 2018

ពលករសញ្ជាតិភូមាប្រមាណជាង300នាក់ នាំគ្នាធ្វើបាតុកម្មទាមទារឲ្យក្រុមហ៊ុនដំឡើងប្រាក់ឈ្នួលក្នុងថ្ងៃ 310฿ តាមការប្រកាសរបស់ក្រសួង។ កាលពីថ្ងៃពុធទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ ម្សិលមិញនេះ មានករណីពលករភូមាធ្វើការនៅក្នុងរោងចក្រផលិតគ្រឿងអលង្ការរបស់ក្រុមហ៊ុនហ្គោដិន ស្ថិតក្នុងភូមិ២ សង្កាត់ផាសាលួត ស្រុកម៉ែសត ខេត្តតាក ប្រទេសថៃ ប្រមាណជាង៣០០ នាក់បានដឹកនាំគ្នាធ្វើកូដកម្មទាមទារឲ្យក្រុមហ៊ុនដំឡើងប្រាក់ឈ្នួលជូនពួកគេតាមសេចក្តីប្រកាសរបស់ក្រសួងការងារថៃ។

យោងតាមប្រភពព័ត៌មានបានឱ្យដឹងថា ពលករភូមាដែលមកធ្វើកូដកម្មទាមទារប្រាក់ឈ្នួលទាំងអស់នោះត្រូវបានក្រុមហ៊ុនកាត់ប្រាក់ឈ្នួលពី ៣០៥฿ ក្នុងមួយថ្ងៃនៅសល់ត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ ព្រមទាំងត្រូវក្រុមហ៊ុនកាត់ថ្លៃបាយក្នុងមួយថ្ងៃ ៧៥฿ ទៀត ដូច្នេះហើយបានជាពួកគេទាមទារឲ្យអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធជួយបកស្រាយបញ្ហាចំពោះការកាត់ប្រាក់ឈ្នួលរបស់ពលករទាំងអស់នោះដែលត្រូវក្រុមហ៊ុនកាត់នារយៈពេលកន្លងមក។ លើសពីនេះទៀតពួកក្រុមពលករបានទាមទារឲ្យក្រុមហ៊ុនដំឡើងប្រាក់ឈ្នួលជូនតាមសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលថៃ ដែលបានកំណត់នាពេលកន្លងមកដោយបានកំណត់ប្រាក់ឈ្នួល (៣១០฿)ក្នុងមួយថ្ងៃ។

យ៉ាងណាមិញក្នុងការធ្វើកូដកម្មទាមទារដំឡើងប្រាក់ឈ្នួលរបស់ពលករភូមាលើកនេះកម្លាំងសមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធរបស់ថៃ បានធ្វើការចុះសម្រុះសម្រួលអោយពលករទាំងអស់មានការស្ងៀមស្ងាត់ព្រមទាំងអធិប្បាយអំពីហេតុផលរឿងការដំឡើងប្រាក់ឈ្នួល និងសន្យាយករឿងនេះទៅអោយក្រុមហ៊ុនខាងលើដោះស្រាយបញ្ហាជូននាពេលខាងមុខនេះ។

## អាជ្ញាធរថៃ ប្រកាសអនុវត្តច្បាប់ចាប់ខ្លួនពលករខុសច្បាប់នៅដើមខែមេសាខាងមុខនេះ

http://www.prakpheaktra.com/ February 15, 2018

នៅដើមខែបួនខាងនេះអាជ្ញាធរថៃ និងចាប់ផ្តើមអនុវត្តចាប់ខ្លួនពលករអន្តោប្រវេសន៍ខុសច្បាប់ដែលកំពុងធ្វើការនៅរស់ក្នុងប្រទេសថៃជាផ្លូវការហើយ។ សេចក្តីជូនដំណឹងដល់បងប្អូនពលករខ្មែរដែលកំពុងធ្វើការរស់នៅក្នុងប្រទេសថៃ ទាំងអស់អោយបានជ្រាបថា នៅដើមខែមេសា ឆ្នាំ2018 ខាងមុខនេះ កម្លាំងអាជ្ញាធរថៃនឹងចាប់ផ្តើមចុះអនុវត្តច្បាប់ចាប់ពលករបរទេសដែលធ្វើការខុសច្បាប់ជាផ្លូវការហើយ។ ដូច្នេះបងប្អូនពលករខ្មែរដែលមិនបានត្រួតសញ្ជាតិ (ធ្វើប៉ាស្ព័រ) សូមប្រញាប់រួសរាន់ទៅធ្វើប័ត្រស៊ីជម្ពូនៅសូន្យ OSS (OneStopService) និងធ្វើវីសារការងារពីរឆ្នាំ, ព្រមទាំងប្តូរថៅកែអោយបានត្រឹមត្រូវមុនថ្ងៃទី៣១ ខែ០៣ ឆ្នាំ២០១៨ ។ ហេតុនេះហើយសូមបងប្អូនពលករខ្មែរទាំងអស់ប្រញាប់រួសរាន់អោយណាយចាងនាំទៅធ្វើប័ត្រស៊ីជម្ពូ, វីសារការងារ, ប្តូរថៅកែ ឲ្យរួសរាន់ទាន់ពេលកំណត់។

## បរទេស ២ នាក់ទៀត ពាក់ព័ន្ធផលិតរូបអាសអាភាស ត្រូវដោះលែងនិងបណ្ដេញចេញ

http://www.postkhmer.com/ គង់ មេត្តា | Publication date 15 February 2018 | 17:52 ICT

**ភ្នំពេញៈ** ជនបរទេស ២ នាក់ទៀត ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ហើយបានបណ្ដេញចេញពីប្រទេសកម្ពុជា កាលពីដើមសប្ដាហ៍។ នេះបើតាមការបញ្ជាក់របស់អ្នកនាំពាក្យតុលាការ និង មេធាវីរបស់ពួកគេ នៅថ្ងៃនេះ។ ពួកគេស្ថិតក្នុងចំណោម ជនបរទេស ១០ នាក់ ដែលត្រូវបានចាប់ខ្លួន ទាក់ទិននឹងបទចោទថា «ផលិតរូបភាពអាសអាភាស» កាលពីថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៨ នៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប។ កាលពីសប្ដាហ៍មុន ពួកគេចំនួន ៧ នាក់ ត្រូវបានដោះលែង ហើយបានបណ្ដេញចេញទៅកាន់ប្រទេសរបស់ពួកគេវិញផងដែរ។

លោក យិន ស្រាង អ្នកនាំពាក្យសាលាដំបូងខេត្ត សៀមរាប បានប្រាប់ភ្នំពេញប៉ុស្ដិ៍ នៅថ្ងៃនេះថា អ្នកទាំងពីរត្រូវបានដោះលែងកាលពីថ្ងៃចន្ទ ទី ១២ និងចាកចេញពីកម្ពុជា នៅថ្ងៃអង្គារ ទី១៣ ខែកុម្ភៈនេះហើយ។ សរុបមក ជនបរទេសចំនួន ៩ នាក់រួចហើយ បានចាកចេញពីកម្ពុជា។

ចំណែកមេធាវី អ៊ុច សុភត្រា ដែលការពារក្ដីឲ្យបរទេសទាំង ១០ នាក់ បានឲ្យដឹងថា កូនក្ដីចំនួន ២ នាក់ ដែលទទួលបានការដោះលែងឲ្យនៅក្រៅឃុំ មានសញ្ជាតិ ន័រវែស និងហូឡង់។ ពួកគេ បានត្រឡប់ទៅកាន់ប្រទេសវិញតាំងពីថ្ងៃអង្គារ ទី១៣ ខែកុម្ភៈ។ លោកថាៈ«ដូច្នេះ កូនក្ដីរបស់ខ្ញុំ នៅក្នុងឃុំខ្លួនឯពន្ធនាគារ គឺសល់តែម្នាក់ប៉ុណ្ណោះ»។ មូលហេតុដែលលោក មិនបានដាក់សុំកូនក្ដីម្នាក់នេះ នៅក្រៅឃុំ គឺដោយសារមានរបាយការណ៍ថា គាត់ជាអ្នករៀបចំកម្មវិធីជប់លៀងនោះ។

## ថៃប្រើបច្ចេកវិទ្យាថតភ្នែករបស់កម្មករបម្រើការ លើទូកនេសាទ ក្នុងសមុទ្រ

http://km.rfi.fr/asia/ ដោយ ឈាង បុប្ផា 15/02/2018

នៅក្នុងឱកាសអបអរកំណែទម្រង់ នៅក្នុងផ្នែកឧស្សាហកម្មនេសាទសមុទ្រ រដ្ឋមន្ត្រីក្រសួងការងារថៃ នៅថ្ងៃព្រហស្បតិ៍ម្សិលមិញ បានលើកឡើងថា ក្រសួងបានប្រើបច្ចេកវិទ្យាថតភ្នែករបស់កម្មករលើទូកនេសាទ ក្នុងក្របខ័ណ្ឌនៃការចុះឈ្មោះពលករ ដែលបម្រើការក្នុងវិស័យឧស្សាហកម្មនេសាទថៃ។ នៅពីឆ្នាំ ២០១៥ សហភាពអឺរ៉ុបបានគំរាមលែងឲ្យនាំចូលគ្រឿងសមុទ្រពីប្រទេសថៃ បើសិនអាជ្ញាធរថៃមិនព្រមលុបបំបាត់ទាសភាព និងការជួញដូរមនុស្ស ដែលអង្គការការពារសិទ្ធិមនុស្សបានលើកឡើងថា នៅតែបន្តកើតមានទៅលើកម្មករដែលធ្វើការលើទូកនេសាទថៃ។

ក្នុងជំនួបដ៏ខ្លីជាមួយអ្នកកាសែត នៅថ្ងៃព្រហស្បតិ៍ម្សិលមិញ រដ្ឋមន្ត្រីក្រសួងការងារថៃ បាននិយាយថា តាំងពីខែតុលាឆ្នាំមុន គេបានប្រើបច្ចេកវិទ្យាថតភ្នែករបស់កម្មករប្រមាណ ៧ម៉ឺននាក់ ដែលកំពុងធ្វើការនៅលើទូកនេសាទថៃ។ នេះជាផ្នែកមួយនៃការចងក្រងទិន្នន័យ ដែលនឹងអាចជួយគេកំណត់អត្តសញ្ញាណ របស់ពលករដែលបម្រើការនៅក្នុងវិស័យឧស្សាហកម្មនេសាទ។ ក្រៅតែពីប្រើបច្ចេកវិទ្យាថតភ្នែក អាជ្ញាធរថៃ គ្រោងនឹងចុះប្រមូលផងដែរ ក្រយៅដៃ និងថតមុខកម្មករនៅលើទូកនេសាទ។

លោក ពេតចារ៉ាត ស៊ីណយ Petcharat Sinauy អនុលេខាអចិន្ត្រៃយ៍របស់ក្រសួងការងារវិញបានអះអាងថា បច្ចេកវិទ្យាបានជួយឲ្យអាជ្ញាធរចុះស្រង់ដោយប្រសិទ្ធិភាព តួលេខកម្មករដែលបម្រើការនៅលើទូកនេសាទថៃ។ ការថតមុខ ឬថតភ្នែករបស់កម្មករ ធ្វើឡើងដើម្បីឲ្យគេច្បាស់ក្នុងចិត្តថា កម្មករធ្វើការតែនៅលើទូកមួយ ដែលគេបានចុះឈ្មោះ ប៉ុន្តែ មិនអាចទៅធ្វើការនៅលើទូកមួយទៀត ក្នុងពេលតែមួយនោះទេ។ យុទ្ធនាការនេះធ្វើឡើងដើម្បីទប់ស្កាត់ការលក់ដូរជួញដូរកម្មករបរទេស ក្នុងចំណោមម្ចាស់ទូកនេសាទថៃ។

ជំនួញផ្នែកនេសាទថៃ ជាប់ចំណាត់ថ្នាក់លេខ ៤ ជំលើលោក ប៉ុន្តែពឹងអាស្រ័យខ្លាំងទៅលើកម្លាំងពលករបរទេសមកពីប្រទេសកម្ពុជា ភូមា និងឡាវ។ នៅឆ្នាំ ២០១៥ សហភាពអឺរ៉ុបបានចេញកាតលឿងព្រមានលែងឲ្យនាំចូលគ្រឿងសមុទ្រ ពីប្រទេសថៃ នៅក្រោយរបាយការណ៍របស់អង្គការការពារសិទ្ធិមនុស្សបានលើកឡើងពីការរំលោភសិទ្ធិមនុស្ស ការលក់ដូរកម្មករ និងអំពើហិង្សា ទៅលើកម្មករអន្តោប្រវេសន៍ នៅលើទូកនេសាទថៃ។ នៅឆ្នាំ ២០១៦ គេវាយតម្លៃថា ការនាំចេញ គ្រឿងសមុទ្រថៃ ទៅអឺរ៉ុប មានតម្លៃ ៤២៧លានអឺរ៉ូ។

រដ្ឋាភិបាលរបបសឹកថៃ បានចាប់បើកការបង្ក្រាបដោយចាប់ឃាត់ខ្លួនជនសង្ស័យជួញដូរមនុស្ស១០០នាក់ និងបានរំដោះជនរងគ្រោះ១៦០នាក់។ នៅក្នុងរបាយការណ៍របស់ខ្លួនចេញផ្សាយនៅខែមករាមុន អង្គការ Human Rights Watch បានវាតយម្លៃថា នៅ៣ឆ្នាំក្រោយនៃការដាក់សម្ពាធពីសហភាពអឺរ៉ុប សកម្មភាពបង្ក្រាបរបស់អាជ្ញាធរថៃ ផ្តល់លទ្ធផលបានតិចតួច និងថា អំពើហិង្សា ការកេងកម្លាំង បង្ខំឲ្យកម្មករអន្តោប្រវេសន៍ ធ្វើការ គ្មានស្គាល់យប់ថ្ងៃ និងក្នុងតម្លៃពលកម្មដ៏ទាប នៅតែបន្តមាន លើទូកនេសាទថៃ។

នៅឆ្នាំ២០១៤ និងឆ្នាំ២០១៥ អត្ថបទអង្កេតរបស់កាសែតអង់គ្លេស The Guardian និងទីភ្នាក់ងារអាមេរិកាំង Associated Press បានបង្ហាញថា ជារឿយៗជនអន្តោប្រវេសន៍ដែលមកពីភូមា កម្ពុជាជាដើមបាន ចាញ់បោកមេខ្យល់ធ្លាក់ក្នុងអន្ទាក់ របស់ពួកឈ្មួញជួញដូរ មនុស្ស ដែលបានលក់ពួកគេ ទៅឲ្យម្ចាស់ទូកនេសាទថៃ។ សាក្សីជាច្រើនបាននិយាយថា នៅពេលកម្មករបរទេស បានឡើងដល់ទូក ពួកគេត្រូវចាត់ទុកជាទាសករ ដែលអាចត្រូវម្ចាស់ទូក វាយធ្វើបាប ឬក៏អាចត្រូវគេសម្លាប់ បំបិទដាន ទៅក្នុងទឹកសមុទ្រ៕

## ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨

## ពលករខ្មែរខុសច្បាប់ចំនួន 04នាក់ ត្រូវបានមូលនិធិ LPN ជួយអន្តរាគមន៍ បន្ទាប់ពីត្រូវថៅកែបង្ខំឲ្យធ្វើការ

http://www.prakpheaktra.com/ February 18, 2018

យោងតាមប្រភពព័ត៌មានថៃរបស់ទូរទស្សន៍ប៉ុស្តិ៍លេខបី ថៃ បានចុះផ្សាយនៅរាត្រីថ្ងៃសៅរ៍ទី17 ខែកុម្ភៈ ឆ្នាំ 2018 ម្សិលមិញនេះអោយបានដឹងថា ពលករខ្មែរខុសច្បាប់ចំនួន 04នាក់ និងមួយចំនួនទៀតត្រូវសមត្ថកិច្ចក្រសួងការងារ និងអាជ្ញាធរមូលនិធិ LPN ជួយអន្តរាគមន៍បន្ទាប់ពីរងគ្រោះត្រូវថៅកែរោងចក្របង្ខំអោយធ្វើការ ខណៈពេលកំពុងបំពេញការងារនៅក្នុងរោងចក្រផលិតទឹកកក ស្ថិតនៅក្នុងខេត្តនុនថាកបុរី ប្រទេសថៃ ។

ប្រភពពីពលករខ្មែររងគ្រោះម្នាក់បានរៀបរាប់ប្រាប់អ្នកសារព័ត៌មានថៃអោយដឹងថា ពួកគាត់ធ្វើដំណើរខុសច្បាប់ចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ តាមរយៈច្រកព្រំដែនធម្មជាតិ ដោយមានមេខ្យល់ជនជាតិខ្មែរដូចគ្នានាំចូលក្នុងប្រទេសថៃ ហើយមានជនជាតិថៃនាំយកមកធ្វើការនៅក្នុងរោងចក្រផលិតខាងលើ ពលករដដែលបានបន្តទៀតថា នៅថ្ងៃដំបូងគាត់ត្រូវបានគេបង្ខំអោយកាន់ការុងច្រកទឹក តែគាត់មិនចេះធ្វើត្រូវថៅកែរោងចក្រកោះហៅទៅក្នុងអូហ្វិតទះកំផ្លៀងពីរទៅបីដៃ ព្រោះមិនទាន់យល់ពីការងារ។ លើសពីនេះទៀតគាត់ត្រូវគេឃុំមិនអោយចេញទៅខាងក្រៅឡើយ ហើយនៅក្នុងបន្ទប់ស្នាក់នៅមានដែកសរសៃផ្សាបិតជិតជុំវិញព្រមទាំងមានកាមេរ៉ាសុវត្ថិភាពចាំឃ្លាំមើល24ម៉ោង និងមានមេការថៃដើរមកត្រួតពិនិត្យនៅគ្រប់ម៉ោង។

ដោយសារមូលហេតុដូចខាងលើនេះបានធ្វើឲ្យគាត់ទ្រាំលែងបានទើបធ្វើការស្នើសុំអោយមូលនិធិគាំពារពលករ (LPN) ជួយអន្តរាគមន៍ដល់ពួកគាត់ បច្ចុប្បន្នពលករខ្មែរទាំងអស់កំពុងស្ថិតនៅមើលថៃរបស់មូលនិធិក LPN ប្រទេសថៃ កំពុងធ្វើការសាកសួរអំពីរឿងដែលកើតឡើងនាពេលកន្លងមក។

## ចាញ់បោកមេខ្យល់ថាយកឯកសារទៅបំពេញបែបបទឲ្យ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៨ម៉ោង ១៣:៣០ម៉ឺត សារុន

ខេត្តបន្ទាយមានជ័យ ៖ ស្ត្រីជាពលករខ្មែរម្នាក់ឈរយំនៅចំណុចច្រកទ្វារអន្តរជាតិខ្លងលឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ឈមនឹងទឹកដីកម្ពុជាច្រកទ្វារអន្តរជាតិប៉ោយប៉ែត បន្ទាប់ពីតាមរកមេខ្យល់បោកប្រាក់មិនឃើញ ។ ហេតុការណ៍ខាងលើបានកើតឡើងកាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៨ នៅច្រកទ្វារអន្តរជាតិខ្មែរ-ថៃ ប៉ោយប៉ែតខ្លងលឹក ។ ស្ត្រីជាពលករម្នាក់នេះ មិនត្រូវបានគេស្គាល់អត្តសញ្ញាណនោះទេ ប៉ុន្តែប្រាប់គេឯងថា នាងទើបវិលត្រលប់ពីធ្វើការនៅរោងចក្រមួយក្នុងខេត្តឈុនបុរី ប្រទេសថៃ និងមានទីលំនៅខេត្តសៀមរាប ។ ស្ត្រីរងគ្រោះនិយាយថា នាងឆ្លងពីថៃមកកម្ពុជាតាមរយៈមេខ្យល់ម្នាក់ ដោយពេលទៅដល់ចំណុចរង្វង់មូលច្រកទ្វារអន្តរជាតិប៉ោយប៉ែត គេទារប្រាក់៧ម៉ឺនរៀលថា យកទៅវាយបិទឯកសារបែបបទចូលប្រទេស ។ នាងបន្តថា ក្រោយពីបុរសសង្ស័យទទួលប្រាក់ទៅបាត់មួយសន្ទុះគេបានយកលិខិតឆ្លងដែនមកឲ្យវិញ ។ នាងបន្តថា ដោយសង្ស័យក៏បើកមើលលិខិតឆ្លងដែន ស្រាប់តែមិនទាន់មានកាប្រថាប់ត្រាប់បិទឲ្យពីនគរបាលជំនាញច្រកទ្វារផង ។

ស្ត្រីខាងលើបានតាមរកមេខ្យល់ដល់ខាងដីថៃ ប៉ុន្តែមិនឃើញឡើយ បានត្រឹមតែរៀបរាប់ប្រាប់គេឯងទាំងទឹកភ្នែកថា មានប្រាក់បន្តិចបន្តួចទុកជាសោហ៊ុយជិះរថយន្តទៅស្រុក បែរត្រូវគេបោកអស់ទៀត ។ ដោយខ្លាចនាងគ្មានប្រាក់ទៅវាយបិទឯកសារនៅចំណុចបែបបទចូលប្រទេស បុរសខ្មែរម្នាក់បានជូននាងរងគ្រោះ១០០បាតប្រាក់ថៃហើយណែនាំនាងឲ្យវិលត្រលប់ទៅដីខ្មែរវិញ ។

ជុំវិញករណីខាងលើ លោក សេម មករា ប្រធានសេនាធិការ នគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ប្រាប់តាមទូរស័ព្ទនៅព្រឹកថ្ងៃ១៩ ខែកុម្ភៈ នេះថា មិនទាន់ទទួលបានព័ត៌មានខាងលើឡើយ ប៉ុន្តែលោកថា ក្រុមឆបោកពលករនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែតខ្លងលឹកកន្លងមក ខាងលោកចាប់បានជាបន្តបន្ទាប់បញ្ជូនឲ្យខាងជំនាញចាត់ការតាមច្បាប់ ។ លោកបញ្ជាក់ថា ការបំពេញឯកសារបិទបើកឆ្លងព្រំដែនទៅមកដីថៃ មិនត្រូវបានយកប្រាក់សូម្បីតែ១០០រៀល ។ ដើម្បីបញ្ចៀសនៅការរិះគន់នានា ក៏ដូចជាដើម្បីរក្សាបាបនូវសុវត្ថិភាពសន្តិសុខ និងសណ្តាប់ធ្នាប់ជូនភ្ញៀវជាតិ និងអន្តរជាតិឆ្លងកាត់ច្រកទ្វារអន្តរជាតិមួយនេះ សង្ឃឹមថាអាជ្ញាធរមានសមត្ថកិច្ច និងចាត់វិធានការលើក្រុមឆបោក ឬមេខ្យល់មិនឲ្យកើតមានទៀតឡើយ ៕

## ការទាមទាររកយុត្តិធម៌បន្ទាប់ពីការបញ្ជូនសាកសពអ្នកបម្រើស្រីហ្វីលីពីនមកពីកូវ៉ែត

http://km.rfi.fr/ ដោយ លីម ស៊ីវជួង17/02/2018

នៅហ្វីលីពីន សាច់ញាត្តិនិងអ្នកគាំទ្រជាង១០០នាក់បានទាមទាររកយុត្តិធម៌ជូនសាកសពស្ត្រីបម្រើការក្នុងផ្ទះជនជាតិហ្វីលីពីនម្នាក់ត្រូវបានរកឃើញនៅក្នុងទូកកមួយនៅក្នុងប្រទេសកូវ៉ែត ស្របពេលដែលសាកសពនោះត្រូវបានបញ្ជូនទៅកាន់ប្រទេសកំណើតវិញនាថ្ងៃសៅរ៍នេះ។ ហេតុការណ៍នេះ ក៏បានជះឥទ្ធិពលដល់ទំនាក់ទំនងការទូតរវាងហ្វីលីពីននិងកូវ៉ែតផងដែរ។

ស្ត្រីជនជាតិហ្វីលីពីនដែលសាកសពរបស់គាត់ត្រូវបានគេរកឃើញនោះ មានឈ្មោះថា Joanna Demafelis ដែលបានចាកចេញទៅធ្វើជាស្ត្រីបម្រើនៅប្រទេសកូវ៉ែតអស់រយៈពេល៤ឆ្នាំមកហើយ ក្នុងគោលបំណងស្វែងរកប្រាក់ចំណូលដើម្បីជួយសម្រាលដល់ជីវភាពក្រុមគ្រួសារនិងផ្គត់ផ្គង់ការសិក្សារបស់ប្អូនស្រី។ ការសម្លាប់និងដាក់សាកសពរបស់ Joanna នៅក្នុងទូកកត្រូវបានគេសន្និដ្ឋានថាជាទង្វើរបស់ថៅកែរបស់គាត់ ហើយការរកឃើញសាកសពនេះបានធ្វើអោយមានការខឹងសម្បារយ៉ាងខ្លាំងពីសំណាក់សាច់ញាតិ បណ្តាជនហ្វីលីពីន ព្រមទាំងរដ្ឋាភិបាលផងដែរ។

នាថ្ងៃសៅរ៍ទី១៧នេះ នៅពេលដែលសាកសពត្រូវបានបញ្ជូនត្រលប់ទៅហ្វីលីពីនវិញនោះ មាប្រជាជនរួមទាំងមន្ត្រីក្នុងតំបន់សរុបជាង១០០នាក់ បាននាំគ្នាលើកបដាទាមទារយុត្តិធម៌។ ឧបត្តិហេតុនេះក៏បានជះឥទ្ធិពលដល់ចំណងមិត្តភាពរវាងហ្វីលីពីននិងកូវ៉ែតផងដែរ ដោយប្រធានាធិបតីហ្វីលីពីនលោក Rodrigo Duterte បានចោទថា ថៅកែអារ៉ាប់តែងតែបំពានផ្លូវភេទទៅលើពលករហ្វីលីពីន បង្ខំពួកគេអោយធ្វើការ២១ម៉ោងក្នុងមួយថ្ងៃ និងពុំបានផ្តល់អាហារអោយពួកគេអោយបានសមស្របនោះទេ។ ជាងនេះទៅទៀត លោកក៏បានដាក់ចេញការហាមឃាត់ការបញ្ជូនពលករថ្មីទៅកាន់ប្រទេសកូវ៉ែតទៀត និងដាក់បញ្ជាអោយក្រុមហ៊ុនអាកាសចរណ៍នានាជួយសម្រួលដល់ការធ្វើដំណើរដល់ពលករហ្វីលីពីនជាង២៥ម៉ឺននាក់ផ្សេងទៀតនៅមជ្ឈិមបូព៌ាប្រសិនបើពួកគេមានបំណងចង់ត្រលប់ទៅប្រទេសកំណើតវិញ។

យ៉ាងតិច៦០ភាគរយនៃចំនួនពលករទាំងនោះធ្វើការជាអ្នកបម្រើក្នុងផ្ទះ ហើយពួកគេពុំត្រូវបានការពារដោយច្បាប់ពលកម្មនោះទេ។ មន្ត្រីការងារក្រសួងពលកម្មបានអោយដឹងកាលពីថ្ងៃសុក្រថា ក្រុមការងាររបស់ប្រទេសទាំងពីរកំពុងធ្វើការពិភាក្សាក្នុងការបង្កើតអនុស្សរណៈការពារសិទ្ធពលករហ្វីលីពីននៅកូវ៉ែត។

## ពលករហ្វីលីពីន១៧៧នាក់ ដែលរងការរំលោភបំពាន ធ្វើដំណើរមកដល់ប្រទេសខ្លួនវិញ ពីប្រទេសគុយវ៉ែត

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ១៩ កុម្ភៈ ២០១៨ 09:53 ប្រែសម្រួល: ស៊ុនលី ID:102

ម៉ានីល: ទីភ្នាក់ងារចិនស៊ិនហួចេញផ្សាយនៅថ្ងៃអាទិត្យ ទី១៨ ខែកុម្ភៈនេះបានឲ្យដឹងថា ពលករជនជាតិហ្វីលីពីនដែលជាអ្នកត្រូវបាន គេរំលោភបំពាននានាចំនួន១៧៧នាក់ បានត្រឡប់មកពីប្រទេសគុយវ៉ែតវិញហើយកាលពីថ្ងៃអាទិត្យ វានឹងធ្វើឲ្យចំនួនពលករហ្វីលីពីនដែលធ្វើមាតុភូមិនិវត្តន៍ សរុបកើនដល់១៧០០នាក់។

ក្រសួងការបរទេសនៃប្រទេសហ្វីលីពីនបាននិយាយថា ក្រុមពលករហ្វីលីពីនដែលមានឈ្មោះថា OFW ដែលភាគច្រើនសុទ្ធតែជាអ្នកផ្តល់សេវាកម្ម ផ្ទះសំបែងតាមរយៈការប្រើប្រាស់កម្មវិធីលើកលែងទោស របស់រដ្ឋាភិបាលគុយវ៉ែតត្រូវបានបញ្ជូនពីនិយោជក របស់ពួកគេមកដល់ទីក្រុងម៉ានីលវិញហើយ។ ទោះបីជាយ៉ាងណាក្តីក្រសួងការបរទេសហ្វីលីពីន នៅតែបន្តធ្វើការចរចាជាមួយរដ្ឋាភិបាលគុយវ៉ែត សម្រាប់ការពន្យារពេលកម្មវិធីលើកលែងទោស ដែលនឹងអនុញ្ញាតឱ្យក្រុមកម្មកររបស់ OFW ដែលគ្មានឯកសារដើម្បីរៀបចំនិងដំណើរការឯកសារ ចាំបាច់ដែលអាចឲ្យពួកគេធ្វើការងារដោយស្របច្បាប់នៅក្នុងប្រទេសគុយវ៉ែត៕

## UN៖ ៥ឆ្នាំចុងក្រោយ វិស័យការងារនៅកម្ពុជា មានវឌ្ឍនភាពខ្លាំង ជួយជំរុញកំណើនសេដ្ឋកិច្ច

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ១៩ កុម្ភៈ ២០១៨ 13:51 ដោយ: អេង ប៊ូឆេង ID:039

**ភ្នំពេញ៖** មន្ត្រីសម្របសម្រួលនៃ អង្គការសហប្រជាជាតិប្រចាំកម្ពុជា (UN) លោកស្រី Claire Vander Vaeren បានអះអាងថា វឌ្ឍនភាពនៃវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅកម្ពុជា បានជំរុញកំណើនសេដ្ឋកិច្ច ឲ្យមានការរីកចម្រើន យ៉ាងឆាប់រហ័ស ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ។

ក្នុងជំនួបពិភាក្សាការងារជាមួយ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ លោកស្រី Claire Vander Vaeren បានជម្រុញឲ្យរាជរដ្ឋាភិបាលកម្ពុជា បន្តកិច្ចសហប្រតិបត្តិការជាមួយ មន្ត្រីសម្របសម្រួលថ្មី របស់អង្គការសហប្រជាជាតិ ដែលនឹងមកដល់កម្ពុជា នាពេលខាងមុខដើម្បីបន្តវឌ្ឍនភាព ការងារទៅមុខទៀត ។ លោកថា "ក្នុងអាណត្តិការងាររយៈពេល ៥ឆ្នាំរបស់លោកស្រី លោកស្រីបានមើលឃើញថា វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជា ពិតជាមានវឌ្ឍនភាពរីកចម្រើន យ៉ាងឆាប់រហ័សគួរឲ្យកត់សម្គាល់ ។ ៥ឆ្នាំចុងក្រោយនេះ វិស័យការងារកម្ពុជាមាន វឌ្ឍនភាពយ៉ាងខ្លាំង" ។

លោកស្រីបានធ្វើការងារច្រើន ជាមួយគ្នាលើវិស័យការងារ ពិសេសវិស័យគាំពារសង្គម ការលើកកម្ពស់ប្រាក់ឈ្នួលអប្បបរមា ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការទប់ស្កាត់បញ្ហាដែលកើតមានពីការធ្វើចំណាកស្រុក ការផ្តល់អំណាចដល់ស្ត្រី ក្នុងវិស័យការងារ ហើយចុងក្រោយនេះ UN នឹងពិភាក្សាលើគម្រោងថ្មីទៀតផងដែរ ស្តីពីមុខរបរ និងការងារយុវជន ដែលមានការជួយ សម្របសម្រួលពីអង្គការ ILO ដែលជាអង្គការមួយដ៏សកម្ម ក្នុងការងារសហការជាមួយរាជរដ្ឋាភិបាល លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ចំណែកលោក អ៊ិត សំហេង បានលើកឡើងថា រាជរដ្ឋាភិបាល មានក្តីសោមនស្សរីករាយដែល ទទួលបានគម្រោងល្អៗជាច្រើន ក្នុងភាពជាដៃគូជាមួយ អង្គការសហប្រជាជាតិ និងគោលនយោបាយការងារ ដែលកម្ពុជាទទួលបាន ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ជាពិសេសគោលនយោបាយជាតិ ស្តីពីការ អប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ និងភាពជាដៃគូជាមួយអង្គការ ILO ដែលបានរួមគ្នាដោះស្រាយបញ្ហាផ្សេងៗ ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការ ៕

## ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨

### (ប្តូរថៅកែថ្មី) នៅសូន្យOneStopService ប្រញាប់រួសរាន់ឡើង

http://www.prakpheaktra.com/ February 19, 2018

ចំពោះបងប្អូនពលករខ្មែរ ដែលមានលិខិតលុងបៀន,ប័ត្រស៊ីជម្ពូ, ប៉ាស្ព័រត្រួតសញ្ជាតិ (TD) សូមប្រញាប់រួសរាន់អោយថៅកែថ្មីនាំទៅទំនាក់ទំនងប្តូរណាយចាងនៅក្នុងការិយាល័យសូន្យវ៉ាន់ស្តប់សឺវីត (OneStopService) ទូទាំងខេត្ត, ក្រុងនៅក្នុងប្រទេសថៃ អោយបានមុនថ្ងៃទី31 ខែមិនា ឆ្នាំ2018 តែប៉ុណ្ណោះ។

*បញ្ជាក់ការប្តូរណាយចាងនៅក្នុងការិយាល័យសូន្យវ៉ាន់ស្តប់សឺវីត អាចប្តូរចំពោះតែពលករដែលមានប័ត្រស៊ីជម្ពូ, លិខិតលុងបៀន, ប៉ាស្ព័រត្រួតសញ្ជាតិ (TD) តែប៉ុណ្ណោះ។ ចំពោះករណីមានប៉ាស្ព័រ MOU មិនអាចប្តូរនៅសូន្យ (OneStop.Service) ក្នុងប្រទេសថៃបានឡើយ។ ពត៌មានលម្អិតអំពីទីតាំងកន្លែងសូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ1694 ឬមួយខ្សែរទៀតតាមរយៈលេខទូរស័ព្ទ1506។

### ត្រៀមចាត់វិធានការចំពោះថៅកែថៃ ដែលជិះជាន់កម្លាំងពលកម្ម និងឲ្យប្រាក់ឈ្នួលទាបជាងការកំណត់របស់ក្រសួង

http://www.prakpheaktra.com/ February 20, 2018

រដ្ឋមន្ត្រីក្រសួងការងារថៃ ដាក់បញ្ជាអោយមន្ត្រីថ្នាក់ក្រោមចាត់វិធានការយ៉ាងដាច់ខាតចំពោះថៅកែថៃ ដែលមិនគោរពកិច្ចសន្យាការងារនិងគ្រប់គ្រងពលករខុសច្បាប់។ អ្នកនាំពាក្យក្រសួងការងារថៃ លោកស្រី តេតរ៉ាត់ សិនអួយ បានមានប្រសាសន៍ប្រាប់អ្នកយកព័ត៌មានក្នុងប្រទេសថៃ បន្ទាប់ចប់កិច្ចប្រជុំពិភាក្សានៅទីស្នាក់ការក្រសួងការងារកាលពីថ្ងៃច័ន្ទទី19 ខែកុម្ភៈ ឆ្នាំ2018 ម្សិលមិញនេះអោយដឹងថា លោក អាប់ដុល សែងសិងកែវ រដ្ឋមន្ត្រីក្រសួងការងារបានដាក់បញ្ជាអោយមន្ត្រីថ្នាក់ក្រោមចុះត្រួតពិនិត្យថៅកែដែលមិនគោរពកិច្ចសន្យាការងារ បន្ទាប់ពីមូលនិធិ LPN ប្រទេសថៃចុះអន្តរាគមន៍រំដោះពលករខ្មែរចំនួន14នាក់ និងពលករឡាវ07នាក់ និងជនជាតិ 05នាក់ ធ្វើការនៅរោងចក្រផលិតទឹកកក (បាងស៊ីមឿង ស្ថិតនៅក្នុងស្រុកបាងស៊ីមឿង ខេត្តនុនថាកបុរី ប្រទេសថៃកាលពីថ្មីៗកន្លងទៅនេះ។ ក្នុងករណីខាងលើ លោករដ្ឋមន្ត្រីបានបញ្ជាអោយមន្ត្រីថ្នាក់ក្រោម ចុះត្រួតពិនិត្យចាត់វិធានការយ៉ាងដាច់ខាតចំពោះថៅកែថៃដែលមិនគោរពកិច្ចសន្យាការងារបើកខែប្រាក់អោយពលករមិនគ្រប់តាមការកំណត់របស់ក្រសួងការងារ និងគ្រប់គ្រងពលករ ខុសច្បាប់អោយធ្វើការដោយគ្មានច្បាប់អនុញ្ញាតធ្វើការ ។ ប្រសិនបើជារកឃើញតម្រុយទាក់ទងក្នុងការបង្ខិតបង្ខំជិះជាន់កំលាំងពលករខុសច្បាប់អាចរាយការណ៍ជូននាយកដ្ឋានការពារ និងសុខុមាលភាពការងារតាមរយៈលេខទូរស័ព្ទ 1506 ចុចលេខ 3។

# ក្រសួងមហាផ្ទៃ និងក្រសួងការងារចេញប្រកាសរួម ដើម្បីពង្រឹងការងារ អធិការកិច្ចពលកម្មបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា

http://www.akp.gov.kh/ AKP ភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ** **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ១៧/០២.៤៧.ប្រក

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការពង្រឹងការងារអធិការកិច្ចពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ** **រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៥/នស/រកម/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញលិខិតលេខ ១២៣ សជណ.អវ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ស ម្រេ ច**

**ប្រការ១.-** ប្រកាសនេះមានគោលដៅដាក់បញ្ញត្តិ និងល័ក្ខខ័ណ្ឌគតិយុត្តលើការងារអធិការកិច្ចពលកម្មបរទេស ចំពោះម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តរាត្រី ជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២** ÷ មានតែក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសតែមួយប៉ុណ្ណោះ ដែលមានភារកិច្ចធ្វើអធិការកិច្ចហត្ថពលកម្មបរទេសតាមបណ្តាសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់លិខិតបង្គាប់ការរួមចេញ ដោយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានការងារ ដោយមានជូនដំណឹងជាមុន ឬមិនជូនដំណឹងក្នុងករណីចាំបាច់ណាមួយ។

**ប្រការ៣** ÷ ក្នុងពេលក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសចុះត្រួតពិនិត្យ ម្ចាស់ ឬនាយក សហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវសហការជាមួយក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសក្នុងការបង្ហាញឯកសារចាំបាច់នានា ដូចខាងក្រោម៖

| | |
|---|---|
| ១-លក្ខន្តិកៈក្រុមហ៊ុន/សហគ្រាសគ្រឹះស្ថាន ( ច្បាប់ដើម ) | មួយច្បាប់ |
| ២-វិញ្ញាបនបត្រចុះបញ្ជីកាចេញដោយក្រសួងពាណិជ្ជកម្មឬលិខិតមានតម្លៃស្មើ | មួយច្បាប់ |
| ៣-សេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក ( ច្បាប់ដើម ) | មួយច្បាប់ |
| ៤-សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចេញ-ចូល( ច្បាប់ដើម) | គ្រប់ចំនួន |
| ៥-លិខិតអនុញ្ញាតឲ្យប្រើប្រាស់ហត្ថពលកម្មបរទេស (កូតា) ( ច្បាប់ដើម ) | មួយច្បាប់ |
| ៦-កិច្ចសន្យាការងាររបស់ជនបរទេសជាភាសាខ្មែរដែលបានចុះបញ្ជិកាដោយក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត(ច្បាប់ដើម) | គ្រប់ជនបរទេស |
| ៧-លិខិតឆ្លងដែនរបស់ជនបរទេស( ច្បាប់ដើម និងថតចម្លង ) និងរូបថត៤X៦ | ចំនួន២សន្លឹក គ្រប់ជនបរទេស |
| ៨-ទិដ្ឋាការចូល និងទិដ្ឋាការពន្យារចុងក្រោយដែលអនុញ្ញាតឲ្យធ្វើការងាររបស់ជនបរទេស (ច្បាប់ដើម និងថតចម្លង) | គ្រប់ជនបរទេស |
| ៩-ប័ណ្ណ និងសៀវភៅការងាររបស់ជនបរទេស ( ច្បាប់ដើម និងថតចម្លង ) | គ្រប់ជនបរទេស |
| ១០-សៀវភៅច្បាប់ស្តីពីការងារ និងសៀវភៅច្បាប់ស្តីពីអន្តោប្រវេសន៍ | មួយច្បាប់ |

**ប្រការ៤** ÷ ជនបរទេសទាំងឡាយណាដែលប្រកបអាជីវកម្មខ្នាតតូច អាជីវកម្មរោប អាជីវកម្មពុំមាននាមករណ៍ អាជីវកម្មចល័ត អាជីវកម្មពេលរាត្រី អាជីវកម្មលើផ្ទៃទឹក ឬអាជីវកម្មផ្សេងៗទៀត ត្រូវមានលិខិតអនុញ្ញាតឲ្យប្រកបអាជីវកម្មដែលចេញឲ្យដោយស្ថាប័នមានសមត្ថកិច្ច ដើម្បីបំពេញបែបបទធ្វើប័ណ្ណការងារ និងសៀវភៅការងារ។

**ប្រការ៥** ÷ ការទទួលយកជនបរទេសឲ្យធ្វើការងារ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពឲ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។ គ្មានជនបរទេសណាម្នាក់អាចប្រកបមុខរបរណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានប័ណ្ណ និងសៀវភៅការងារ ដែលចេញឲ្យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៦** ÷ ក្នុងករណីម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តណាមួយ ដែលទទួលយកពលករបរទេសឲ្យធ្វើការងារ ឬពលករបរទេសដែលធ្វើការ ឬប្រកបមុខរបរណាមួយដោយគ្មានប័ណ្ណ និងសៀវភៅការងារ ត្រូវធ្វើការពិន័យជាប្រាក់ និងផ្តន្ទាទោសតាមទោសប្បញ្ញត្តិជំពូកទី១៦នៃច្បាប់

ស្តីពីការងារ និងផ្តន្ទាទោសតាមទោសប្បញ្ញត្តិជំពូកទី៥ និងការបណ្តេញចេញជំពូកទី៦នៃច្បាប់ស្តីពីអន្តោប្រវេសន៍។

**ប្រការ៧ ÷** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានការងារ រាយការណ៍សុំការដឹកនាំពីតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីចុះត្រួតពិនិត្យហត្ថពលកម្មបរទេសតាមបណ្តា សហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ករណីសង្ស័យថាមានការលាក់បំពួនប្រើប្រាស់ហត្ថពលកម្មបរទេសដោយខុសច្បាប់។

**ប្រការ៨ ÷** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានការងារ រាយការណ៍សុំការដឹកនាំពីតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីចុះត្រួតពិនិត្យហត្ថពលកម្មបរទេសតាមបណ្តាអាជីវកម្មពេលរាត្រី។

**ប្រការ៩ ÷** ពលករបរទេសរស់នៅតំបន់ព្រំដែន ដែលចូលមកប្រទេសកម្ពុជាក្នុងគោលបំណងប្រកបមុខរបរណាមួយដែលចូលព្រឹក-ចេញល្ងាច ឬស្នាក់នៅរយៈពេលខ្លី ត្រូវបំពេញបែបបទតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬអនុវត្តតាមកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសកម្ពុជា ត្រូវមានប័ណ្ណនិងសៀវភៅការងារ ។

**ប្រការ១០ ÷** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តណាមួយ ដែលគោរព និងអនុវត្តបានត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារ ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងផ្តល់ជូននូវលិខិត ឬប័ណ្ណសរសើរដើម្បីលើកទឹកចិត្ត។

**ប្រការ១១ ÷** ប្រកាសរួមលេខ២៧០៣ ប្រក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ ÷** អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គស្នងការនគរបាលជាតិ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងមហាផ្ទៃ និងក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋបាលរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសរួមនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ក្រសួងយុត្តិធម៌
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ដូចប្រការ១២
-ឯកសារ-កាលប្បវត្តិ

# ក្រសួងមហាផ្ទៃ និងក្រសួងការងារ ប្រកាសដាក់ទោសម្ចាស់ ឬនាយកសហគ្រាសណា ដែលទទួលយកពលករបរទេសធ្វើការ ដោយគ្មានបណ្ណ និងសៀវភៅការងារ

http://www.freshnewsasia.com/ 2018-02-20

**(ភ្នំពេញ)៖** ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសរួមគ្នា ដាក់ទោសម្ចាស់ ឬនាយកសហគ្រាសណា ដែលទទួលយកពលករបរទេស ឲ្យធ្វើការដោយគ្មានបណ្ណ និងសៀវភៅការងារ។ នេះបើយោងតាមប្រកាសអន្តរក្រសួង ដែលអង្គភាព Fresh News ទទួលបាននៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨នេះ។

ប្រកាសអន្តរក្រសួងស្តីអំពី ការពង្រឹងការងារ អធិការកិច្ច ហត្ថពលកម្មបរទេស ក្នុងប្រទេសកម្ពុជា បានឲ្យដឹងថា «**ក្នុងករណីម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តណាមួយ ដែលទទួលយកពលករបរទេសឲ្យធ្វើការងារ ឬពលករបរទេសដែលធ្វើការ ឬប្រកបរបរណាមួយដោយគ្មានបណ្ណ និងសៀវភៅការងារ ត្រូវធ្វើការពិន័យជាប្រាក់ ផ្តន្ទាទោសតាមទោសប្បញ្ញត្តិជំពូកទី១៦ នៃច្បាប់ស្តីពីការងារ និងផ្តន្ទាទោសប្បញ្ញត្តិជំពូកទី៥ និងការបណ្តេញចេញជំពូកទី១៦ នៃច្បាប់ស្តីពីអន្តោប្រវេសន៍**»។

ប្រកាសដដែលបានឲ្យដឹងទៀតថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តណាមួយ ដែលគោរព និងអនុវត្តន៍បានត្រឹមត្រូវ តាមច្បាប់ ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារ ក្រសួងទាំងពីរ នឹងផ្តល់ជូនលិខិត ឬបណ្ណសរសើរ ដើម្បីលើកទឹកចិត្ត៕

## ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨

# ថៃបញ្ជូនជនកម្ពុជាចំនួន២នាក់ មកស្រុកកំណើតវិញ បន្ទាប់ពីចេញពីពន្ធនាគារពីបទចូលកាប់ឈើគ្រញូង

http://www.rasmeinews.com/ February 20, 2018, 5:19 PM

(ឧត្តរមានជ័យ)៖ ជនជាតិកម្ពុជាចំនួន២រូប ត្រូវបានអាជ្ញាធរថៃបញ្ជូនមកឲ្យអាជ្ញាធរកម្ពុជា តាមច្រកអន្តរជាតិជាំស្រងាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលការបញ្ជូននេះ ធ្វើឡើងកាលពីវេលាម៉ោង១៣និង២៥នាទី ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨នេះ ខណៈពេលដែលជនទាំងពីរត្រូវបានថៃដោះលែងពីពន្ធនាគារ រឿងឆ្លងដែនខុសច្បាប់ទៅកាប់ឈើគ្រញូង។

ជនជាតិកម្ពុជាទាំងពីររូបដែលត្រូវថៃបញ្ជូនមកនោះ គឺទី១ឈ្មោះ សម ធីម ភេទប្រុស អាយុ៣៦ឆ្នាំ និងទី២ឈ្មោះ ម៉ាង ដា ភេទប្រុស អាយុ៣០ឆ្នាំ អ្នកទាំងពីររស់នៅភូមិត្រពាំងគគីរ ឃុំល្បើក ស្រុកឈូក ខេត្តកំពត។ សមត្ថកិច្ចកម្ពុជាដែលទទួលយកជនកម្ពុជាទាំងពីរបានបញ្ជាក់ថា កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦ ជនកម្ពុជាទាំងពីររូបបានឆ្លងដែនទៅកាប់ឈើគ្រញូងដោយខុសច្បាប់ នៅចំណុចច្រកត្រពាំងបី ក្នុងខេត្តស៊ីសាកេត ហើយត្រូវបានទាហានឈុតខ្មៅថៃចាប់ខ្លួនដាក់ពន្ធនាគារនៅខេត្តស៊ីសាកេត តាំងពីពេលនោះមក។

ក្រោយពីចាប់ខ្លួនបានដាក់ពន្ធនាគារកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨នេះ គឺមានរយៈពេល២ឆ្នាំគត់ដែលពួកគេជាប់ពន្ធនាគារ ទើបត្រូវបានដោះលែងឲ្យមានសេរីភាពវិញ ហើយក៏បានបញ្ជូនមកកាន់កម្ពុជាវិញ។ ក្រោយពីធ្វើការអប់រំរួចហើយ សមត្ថកិច្ចកម្ពុជា បានឲ្យជនទាំងពីរវិលត្រលប់ទៅកាន់ស្រុកកំណើតវិញ៕L ដោយ៖ បាយ័ន

# ស្ថានទូតកម្ពុជា ប្រចាំប្រទេស ៣ អន្តរាគមន៍ជួយពលរដ្ឋខ្មែរ ១១នាក់

https://www.dap-news.com ថ្ងៃពុធ, ២១ កុម្ភៈ ២០១៨ 10:16 ដោយ: ដើម អម្ពិល ID:102

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
------

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
------

## ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរចំនួន១១នាក់

-----------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**៨នាក់** (បុរស ៣នាក់ និងនារី៥នាក់) ដែលទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង ៨នាក់នោះ បានមកដល់កម្ពុជាវិញ នៅថ្ងៃទី**១៧** ខែកុម្ភៈ ឆ្នាំ២០១៨ ។

២. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**សិង្ហបុរី** បានជួយរៀបចំមាតុភូមនិវត្តន៍របស់ពលការិនីខ្មែរ១នាក់ អាយុ២៦ឆ្នាំ មកពីខេត្តកំពង់ធំ ដែលមិនអាចទ្រាំទ្រការងារលំបាកនៅសិង្ហបុរីបាន ។

ស្ថានទូត បានផ្តល់កន្លែងស្នាក់នៅ អាហារបរិភោគ និងជួយទាមទារលិខិតឆ្លងដែននិងសំបុត្រយន្តហោះពីភ្នាក់ងារនាំពលករ ហើយពលការិនីបានមកដល់កម្ពុជាវិញ នៅថ្ងៃទី**១០** ខែ **កុម្ភៈ ឆ្នាំ២០១៨** ។

៣. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេស**ថៃ** កំពុងធ្វើអន្តរាគមតាមផ្លូវច្បាប់ ដើម្បីជួយពលរដ្ឋខ្មែរ**២នាក់** មកពីខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ដែលត្រូវបានអាជ្ញាធរថៃចាប់ខ្លួនកាលពីថ្ងៃទី១២ ខែកុម្ភៈ ២០១៨ នៅឧទ្យានជាតិប៉ាងស៊ីដា ក្នុងស្រុកមឿង ខេត្តសាកែវ ពីបទឆ្លងដែនចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃដោយខុសច្បាប់។

បច្ចុប្បន្ន ពលរដ្ឋខ្មែរទាំង២នាក់ កំពុងជាប់ឃុំខ្លួនបណ្តោះអាសន្ននៅប៉ុស្តិ៍នគរបាលប៉ាងស៊ីដា ហើយស្ថានអគ្គកុងស៊ុល កំពុងសម្របសម្រួលជាមួយអាជ្ញាធរពាក់ព័ន្ធថៃ ដើម្បីពន្លឿនសំណុំរឿងនេះទៅតុលាការឲ្យបានឆាប់ និងត្រៀមផ្តល់មេធាវីថៃស្ម័គ្រចិត្តជួយការពារក្តីផងដែរ។

ថ្ងៃ ពុធ ៧កើត ខែ ផល្គុន ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៨
ជុំ សុន្ទរី
អ្នកនាំពាក្យ
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## អគ្គនាយកដ្ឋានគាំពារសុខមាលភាពការងារពលករ ព្រមានចាត់វិធានការចំពោះថៅកែ ដែលកាត់ប្រាក់ឈ្នួលពីពលករ

http://www.prakpheaktra.com/ February 21, 2018

អគ្គនាយកដ្ឋានគាំពារនិងសុខុមាលភាពការងារពលករ ប្រកាសតឿនដល់ថៅកែថៃ ហាមកាត់ប្រាក់ឈ្នួលនិងប្រាក់ថែមម៉ោងរបស់ពលករដាច់ខាត ក្នុងករណីបំពានច្បាប់និងត្រូវមានទោសពិន័យជាប្រាក់និងជាប់ពន្ធនាគារទៀតផង។ យោងតាមប្រសាសន៍របស់លោក Anantachai Uthaiwatana អគ្គនាយកនៃនាយកដ្ឋានការពារនិងសុខុមាលភាពការងារថៃបានមានប្រសាសន៍កាលពីថ្ងៃច័ន្ទ ទី19 ខែកុម្ភៈ ឆ្នាំ2018 កន្លងទៅអោយបានដឹងថាស្ដីពីច្បាប់គាំពារទាំងពលករថៃ និងពលករបរទេស ដើម្បីឲ្យធានានូវការការពារឲ្យមានភាពស្មើៗគ្នា រវាងកម្មករនិយោជិតទាំងអស់ ដើម្បីទទួលបានភាពស្របច្បាប់។ និងមិនមានការយល់ច្រឡំណាមួយលើបញ្ហានិយោជកកាត់ប្រាក់ឈ្នួលរបស់ពលករពីសំណាក់និយោជិត ឧទាហរណ៍ដូចជាថ្លៃម្ហូបអាហារថ្លៃ សំលៀកបំពាក់ធ្វើការជាដើម ក្នុងករណីនេះច្បាប់កគាំពារពលកម្មឆ្នាំ2541 បានប្រកាសហាមមិនឱ្យនិយោជកកាត់ប្រាក់ឈ្នួល និងប្រាក់ធ្វើការលើសម៉ោងការងារ ថ្ងៃសម្រាក និងប្រាក់ឈ្នួលថ្ងៃឈប់សម្រាកពីបុគ្គលិកឡើយ។ លុះត្រាតែមានការតម្រូវដោយច្បាប់ដូចជាការបង់ពន្ធបំណុលសហករណ៍ឬជាប្រាក់សន្សំជាដើម។

ក្នុងករណីនិយោជកថៃមិនគោរពតាមលក្ខខ័ណ្ឌច្បាប់គាំពារពលករនេះ នឹងត្រូវមានទោសជាប់ពន្ធនាគាររហូតដល់ 6 ខែ និងពិន័យមិនលើសពី 100.000 បាតឬទាំងយ៉ាងពីរ។ ហើយប្រសិនបើរកឃើញការបំពាន់ច្បាប់លើពលករ សូមទំនាក់ទំនងមករយៈ លេខទូរស័ព្ទផ្នែកការពារពលករលេខទូរស័ព្ទ 0 2245 7020, 0 2246 3096 ឬទូរសព្ទលេខទូរស័ព្ទលេខ 1506 ។

## ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨

## កំពូលជម្រះក្ដីបុរសម្នាក់ ដែលនាំមនុស្សទៅធ្វើកម្មករនេសាទនៅ ថៃ

http://www.postkhmer.com/ គឹម សារុំ | Publication date 21 February 2018 | 14:36 ICT

ភ្នំពេញៈ តុលាការកំពូលនៅថ្ងៃទី ២១ កុម្ភៈនេះ បានបើកសវនាការជំនុំជម្រះបុរសម្នាក់ពាក់ព័ន្ធនឹងការនាំយុវជនម្នាក់ទៅធ្វើជាកម្មករនេសាទនៅ ថៃ កាលពីឆ្នាំ ២០១៣ ជាសំណុំរឿងដែលតុលាការថ្នាក់ក្រោមផ្ដន្ទាទោសដាក់គុក ១៥ ឆ្នាំ។ តាមអង្គហេតុបុរសជាប់ចោទឈ្មោះឡូ ផល្លា អាយុ ៣៧ ឆ្នាំ រស់នៅខេត្តកណ្ដាល បានទៅធ្វើការនៅ ថៃ ជាអ្នកនេសាទត្រី។ លុះធ្វើការបាន ៦ ខែ ថៅកែខ្លួនខ្វះកម្មករហើយគាត់បានទូរស័ព្ទមកប្អូនប្រុសឲ្យទៅធ្វើការជាមួយ។ បន្ទាប់មក ប្អូនប្រុសគាត់បានបបួលបានមនុស្ស ១១ នាក់ទៅជាមួយ ។ អង្គហេតុបន្តថា បន្ទាប់ពីធ្វើការបានប៉ុន្មានខែ យុវជនឈ្មោះ ពៅ សៀងហៃ អាយុ ២៣ ឆ្នាំ បានពុលរលកហើយប្រាប់ជនជាប់ចោទថា ចង់ត្រឡប់មកផ្ទះវិញ។ បន្ទាប់មកជនជាប់ចោទបានទូរស័ព្ទប្រាប់ម្ដាយជនរងគ្រោះឲ្យផ្ញើលុយ និង យកយុវជននោះមកកម្ពុជាវិញ។ ពេលមកដល់ជនរងគ្រោះបានប្ដឹងសមត្ថកិច្ចឲ្យចាប់ជនជាប់ចោទតែម្ដង។

រឿងនេះត្រូវសាលាដំបូងខេត្តកណ្ដាល ផ្ដន្ទាទោសដាក់គុក ១៥ ឆ្នាំចោទពីបទ «នាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន » ហើយសាលាឧទ្ធរណ៍ ក៏បានតម្កល់សាលក្រមនេះផងដែរ។ ក្នុងបន្ទប់សវនាការលោកស្រី មេធាវី ថូ ណារី ដែលការពារជនជាប់ចោទ សន្និដ្ឋានថា កូនក្ដីលោកស្រីគ្មានចេតនានាំជនរងគ្រោះទៅថៃទេ តែជនរងគ្រោះលួចទៅដោយមិនប្រាប់ម្ដាយឲ្យដឹង។ យ៉ាងណា «ខ្ញុំសុំឲ្យកូនក្ដីខ្ញុំរួចខ្លួន » ។ ប៉ុន្ដែលោកស្រី យឹម ថាវី មេធាវីការពារសិទ្ធិឲ្យជនរងគ្រោះសន្និដ្ឋានថា កូនក្ដីលោកស្រីត្រូវបានប្អូនរបស់ជនជាប់ចោទបបួលទៅជាមួយហើយពេលទៅដល់ថៃបានទូរស័ព្ទគំរាមម្ដាយជនរងគ្រោះឲ្យផ្ញើលុយឲ្យ ដើម្បីបានកម្រៃក្នុងការងារនេះ។ លោកស្រីស្នើថា៖ «ខ្ញុំសូមតុលាការ

តម្កល់រឿងនេះទុកជាបានការដដែល » ។ សំណុំរឿងនេះត្រូវលោកចៅក្រម ស៊ឹង បញ្ញាវិឡ្ឍ ថ្លែងថា សាលដីកានឹងប្រកាសនៅថ្ងៃទី ២៦ កុម្ភៈ ខាងមុខ ៕

## បុរសម្នាក់បដិសេធការចោទថា នាំមនុស្សទៅធ្វើកម្មករនេសាទ

http://www.postkhmer.com/ គីម សារុំ | Publication date 22 February 2018 | 10:30 ICT

**ភ្នំពេញៈ** បុរសជាប់ចោទម្នាក់ពីម្សិលមិញបានបដិសេធនៅមុខចៅក្រមនៃតុលាការកំពូលពាក់ព័ន្ធនឹងបទចោទនាំយុវជនម្នាក់ទៅធ្វើកម្មករនេសាទនៅប្រទេសថៃកាលពីឆ្នាំ ២០១១ ខណៈរូបគេត្រូវបានតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់គុក ១៥ ឆ្នាំ។ ឆ្លើយក្នុងសវនាការ ខណៈតុលាការផ្តល់សិទ្ធិឲ្យជនជាប់ចោទប្រាប់ចៅក្រមថា ខ្លួនឈ្មោះ ឡូ ផល្លា អាយុ ៣៧ ឆ្នាំបានទៅធ្វើជាកម្មករនេសាទនៅប្រទេសថៃ។ លុះធ្វើបាន ៦ ខែ ថៅកែបានរកកម្មករបន្ថែមទើបខ្លួនបានទូរស័ព្ទមកប្រាប់ប្អូនប្រុសឈ្មោះ ឡូ ចិន្តា ឲ្យទៅ។ ជនជាប់ចោទបន្តថាពេលនោះប្អូនខ្លួនបាននាំមនុស្សក្នុងភូមិ ១១ នាក់រួមទាំងជនរងគ្រោះផង ហើយគាត់ក៏នាំឆ្លងដែនទៅដល់កន្លែងធ្វើការរបស់គាត់។ លុះជនរងគ្រោះចុះទូកនេសាទបានប៉ុន្មានថ្ងៃក៏ពុលរលកហើយក៏ពឹងឲ្យគាត់ទូរស័ព្ទប្រាប់ម្តាយឲ្យផ្ញើលុយទៅដើម្បីធ្វើសោហុយមកកម្ពុជាវិញ ។ ជនជាប់ចោទថា៖ «ពេលជននេះដល់ផ្ទះក៏ប្តឹងនគរបាល ហើយគំរាមចាប់ឪពុកម្តាយខ្ញុំ ពេលនោះខ្ញុំមកពីថៃដើម្បីបកស្រាយក៏ត្រូវគេចាប់ខ្ញុំតែម្តង។ ខ្ញុំមិនបាននាំជនរងគ្រោះទៅទេតែគេលួចទៅមិនឲ្យម្តាយដឹង។ ខ្ញុំសុំឲ្យតុលាការដោះលែងខ្ញុំដើម្បីបានប្រកបការងារចិញ្ចឹមម្តាយចាស់»។

ដោយឡែកឈ្មោះ ពៅ សៀងហៃ អាយុ ២៣ ឆ្នាំបានឆ្លើយក្នុងសវនាការពីម្សិលមិញដែរថា ជនជាប់ចោទបានកុហក ព្រោះប្អូនគាត់ពេលនោះប្រាប់ថាទៅថៃរកលុយបានច្រើន គាត់ក៏លួចទៅតាមមិនប្រាប់ម្តាយទេ។ តែពេលគាត់មិនអាចធ្វើការបានក៏ប្រាប់ ឡូ ផល្លា ហើយគេប្រាប់ថា ឲ្យគាត់ទូរស័ព្ទមកម្តាយដើម្បីយកលុយសងគេ ព្រោះគេថាចំណាយលុយអស់ច្រើនដើម្បីរត់ការ។ សៀងហៃ បន្តថា៖ «ឡូ ផល្លា ប្រាប់ខ្ញុំថាបើខ្ញុំមិនសងលុយទេ គេនឹងលក់ខ្ញុំបន្តទៀត ហើយរឿងដែលគាត់និយាយប្រាប់តុលាការជាការកុហកទាំងអស់»។

ទោះយ៉ាងណាលោកព្រះរាជអាជ្ញា ឧច គឹមសន តំណាងមហាអយ្យការសន្និដ្ឋានថា៖«ផ្អែកលើសាលក្រម និងសាលដីការបស់តុលាការថ្នាក់ក្រោម និងពិនិត្យលើអង្គហេតុបង្ហាញថាមានភ័ស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់។ ដូច្នេះខ្ញុំសូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ»។

ប៉ុន្តែលោកស្រី ថូ ណារី និងលោកស្រី ផល គុណកញ្ញា មេធាវីចាត់តាំងការពារសិទ្ធិជនជាប់ចោទសន្និដ្ឋានដូចគ្នាថារឿងនេះសាលាដំបូងខេត្តកណ្តាលបានប្រកាសសាលក្រមនៅថ្ងៃទី ៥ កក្កដាឆ្នាំ ២០១២ ផ្តន្ទាទោសដាក់ពន្ធនាគារកូនក្តីលោកស្រី ១៥ ឆ្នាំ និងបង្គាប់ឲ្យសងជនរងគ្រោះ ៣០ លានរៀល។ កូនក្តីលោកស្រីមិនសុខចិត្តប្តឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍តម្កល់ ១៥ ឆ្នាំដដែល។ លោកស្រីមេធាវីថា៖ «តាមពិតជនរងគ្រោះលួចទៅមិនប្រាប់ម្តាយ និងព្រមទៅខ្លួនឯង តែកូនក្តីខ្ញុំមានចេតនាត្រឹមត្រូវដើម្បីឲ្យគាត់បានមកផ្ទះវិញ។ សូមតុលាការឲ្យកូនក្តីខ្ញុំរួចពីបទចោទ»។

រីឯលោកស្រី យឹម ថាវី មេធាវីការពារសិទ្ធិឲ្យឈ្មោះ ពៅ សៀងហៃ សន្និដ្ឋានថា ជនជាប់ចោទបើចង់នាំប្អូនទៅហេតុអីក៏កៀរគរមនុស្សទៅច្រើនហើយពួកគេទៅសុទ្ធតែគ្មានច្បាប់ត្រឹមត្រូវទៀត។ បើដឹងថាខុសច្បាប់ហេតុអីក៏នាំពួកគេឆ្លងដែនរហូតដល់កន្លែងធ្វើការ។ «ខ្ញុំសូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ»។ ក្រោយជំនុំជម្រះលោកចៅក្រម ស៊ឹង បញ្ញាវុឌ្ឍ ថ្លែងថាសាលដីកានេះប្រកាសនៅថ្ងៃទី ២៦ កុម្ភៈខាងមុខ៕

## អាជ្ញាធរបាត់ដំបង ស្នើអាជ្ញាធរ ច័ន្ទបុរី កុំប្រើហិង្សាលើពលករខ្មែរ ពេលឆ្លងដែនខុសច្បាប់

https://www.dap-news.com ថ្ងៃពុធ, ២១ កុម្ភៈ ២០១៨ 16:08 ដោយៈ រិទ្ធិ ជ័យ ID:102

បាត់ដំបង៖ លោកឧត្តមសេនីយ៍ទោ អ៊ុច សុខុន ស្នងការនគរបាលខេត្តបាត់ដំបង បានស្នើដល់ភាគី ស្នងការនគរបាល ខេត្តច័ន្ទបុរី ប្រទេសថៃ ជួយផ្តល់ព័ត៌មាន ពីបញ្ហាលួចឆ្លងដែនខុសច្បាប់ ឬការប្រព្រឹត្តបទល្មើសផ្សេងៗរបស់ពលរដ្ឋខ្មែរ ក្នុងទឹកដីថៃ ចៀសវាងការប្រើហិង្សាលើពួកគាត់ ។ ក្នុងកិច្ចប្រជុំពិភាក្សាការងារ រឹតបន្តឹងកិច្ចសហប្រតិបត្តិការ រវាងនគរបាលខេត្តបាត់ដំបង និងខេត្តច័ន្ទបុរី នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ លោកឧត្តមសេនីយ៍ទោ អ៊ុច សុខុន បានស្នើដល់ភាគីខេត្តច័ន្ទបុរី បង្កើតឲ្យមានការផ្លាស់ប្តូរព័ត៌មាន ទាក់ទងនឹងស្ថានភាពសន្តិសុខ សណ្តាប់ធ្នាប់ព្រំដែន និងស្ថានភាពរបស់ប្រជាពលរដ្ឋ ដើម្បីរួមគ្នាពិភាក្សា ដោះស្រាយរាល់បញ្ហាប្រឈម ដែលកើតឡើងបានទាន់ពេលវេលា ។ ព្រមជាមួយនេះ លោកស្នងការ ស្នើឲ្យមានកិច្ចសហប្រតិបត្តិការ បង្ការទប់ស្កាត់ បង្ក្រាបបទល្មើសគ្រប់ប្រភេទ នៅតាមព្រំដែន ពិសេសឧក្រិដ្ឋកម្មឆ្លងដែន ។ សូមជូនដំណឹងបានទាន់ពេលវេលា មកសមត្ថកិច្ចកម្ពុជានៅព្រំដែន ក្នុងករណីមានការឃាត់ខ្លួនពលករខ្មែរ ដែលប្រព្រឹត្តិបទល្មើស នៅក្នុងទឹកដីថៃ ព្រមទាំងពិនិត្យមើលបញ្ហាដឹកពលករខ្មែរ តាមរថយន្តដែលដាក់ត្រួតគ្នាច្រើនៗផងដែរ ។

ជាការឆ្លើយតប លោកឧត្តមសេនីយ៍ត្រី ចារ៉ាន់ ជីតជឺជុន (JARUN JITJUAJUN) ស្នងការនគរបាលខេត្តច័ន្ទបុរី បានយល់ព្រមទទួលយក សំណើររបស់ស្នការនគរបាល ខេត្តបាត់ដំបង ដោយយកទៅពិនិត្យពិចារណា ។ លោកឧត្តមសេនីយ៍ត្រី ចារ៉ាន់ ជីតជឺជុន បានបញ្ជាក់ថា ចំពោះច្បាប់អន្តោប្រវេសន៍ របស់ខេត្តច័ន្ទបុរី នៅពេលណាឃាត់ខ្លួនបានពលករខ្មែរ ឡាវ និងមីយ៉ាន់ម៉ា ដែលឆ្លងដែនចូលទឹកដី ខេត្តច័ន្ទបុរីខុសច្បាប់ នឹងត្រូវបញ្ជូនទៅកាន់ប្រទេសរៀងៗខ្លួនវិញភ្លាមៗ តែបើប្រជាជននៃប្រទេសផ្សេងទៀត នឹងត្រូវផ្តន្ទាទោស តាមច្បាប់អន្តោប្រវេសន៍ របស់ថៃ មានការឃុំខ្លួន និងបង់ពិន័យជាដើម ។

ក្នុងឱកាសជាអធិបតី នៃកិច្ចប្រជុំពង្រឹងមិត្តភាព សាមគ្គីភាពនេះ លោកឧត្តមសេនីយ៍ឯក ស ថេត បានមានប្រសាសន៍ថា ជំនួបនេះពិតជាមានប្រយោជន៍ខ្លាំងណាស់ រវាងខេត្តទាំងពីរ ដោយភាគីទាំងអស់ នឹងអាចជួយគ្នា ក្នុងការទប់ស្កាត់បទល្មើសតាមព្រំដែន ដូចជាបទល្មើសគ្រឿងញៀន ជួញដូរមនុស្សជាដើម ។ ជាមួយគ្នានេះ លោកក៏ជំរុញ ដល់ភាគីទាំងពីរ នៅពេលមានកិច្ចប្រជុំលើកក្រោយ ត្រូវមានរៀបចំគណៈកម្មការបច្ចេកទេសមុន ដើម្បីឲ្យបានរៀបចំ នូវមាតិការកិច្ចប្រជុំ ឲ្យបានច្រើនចំណុច ក្នុងន័យពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយគ្នាឲ្យកាន់តែជិតស្និទ្ធថែមទៀត ។ សូមបញ្ជាក់ថា ក្រោយជំនួបនេះ ភាគីកម្ពុជា និងថៃ ក៏មានចុះកិច្ចព្រមព្រៀង ពង្រឹងកិច្ចសហប្រតិបត្តិការ ទ្វេភាគីផងដែរ ៕

## ពលករខ្មែរម្នាក់ ធ្លាក់ពីលើអគារខ្ពស់ ជុងដែក បណ្តាលឲ្យស្លាប់ភ្លាមៗនៅនឹងកន្លែងកើតហេតុ

http://www.arey-news.com/ (ថ្ងៃទី 21 February 2018 ម៉ោង 2:40 pm)

ថៃ ៖ កាលពីពេលថ្មីៗនេះ វេទ្នាត់ណាស់លោកអើយ តើនៅមានពលករខ្មែរយើងប៉ុន្មាននាក់ទៀតដែលរងគ្រោះថ្នាក់ដ៏វេទ្នាត់បែបនេះទៀត ថ្មីៗមានសេចក្តីរាយការណ៍មួយមកពីប្រទេសថៃមកថា មានពលករខ្មែរមិនស្គាល់អត្តសញ្ញាណម្នាក់ បានធ្លាក់ពីលើអគារកំពង់សាងសង់មួយនៅក្នុងប្រទេសថៃ បណ្តាលឲ្យជុងដែកធ្លាយពីម្ខាងទៅម្ខាងមើលទៅគួរឲ្យសង្វេករកអ្វីប្រៀបមិនបាន ។ ប្រភពពីបណ្តាញសង្គមហ្វេសប៊ុកមិនបានបញ្ជាក់ថា តើគ្រោះអកុសលនេះបានកើតឡើងនៅពេលណា ថ្ងៃណា និងនៅកន្លែងណានោះទេ ចំណែកស្ថានភាពរបស់ពលករនោះ មកដល់ពេលនេះ ក៏មិនដឹងយ៉ាងនៅឡើយដែរ ។ កន្លងមកមានពលករខ្មែរមួយចំនួនដែលធ្វើនៅថៃជាកម្មករសំណង់បានរងគ្រោះថ្នាក់ជាបន្តបន្ទាប់ ពិសេសករណីធ្លាក់ពីលើអគារកំពុងសាងសង់ បណ្តាលឲ្យស្លាប់ចោលប្រពន្ធកូនសាច់ញាតិ ក៏ដូចជាជួបគ្រោះថ្នាក់ចរាចរណ៍ស្លាប់ផងដែរ ៕

## រន្ធត់ណាស់.! បាក់រណ្ដៅជីសង្កត់កម្មករសំណង់ភូមាស្លាប់ 01នាក់របួស 02នាក់

http://www.prakpheaktra.com/ February 21, 2018

នៅថ្ងៃពុធ ទី21 ខែកុម្ភៈ ឆ្នាំ2018 មានហេតុការណ៍ឧបទ្ទវហេតុគ្រោះថ្នាក់បាក់រណ្ដៅជីសង្កត់កម្មករធ្វើការសំណង់នៅខេត្តភូកេត ប្រទេសថៃបណ្ដាលឱ្យមានកម្មករម្នាក់ស្លាប់នៅ និងកន្លែងកើតហេតុ និងកម្មករចំនួន02នាក់ទៀតរងរបួសធ្ងន់។ ករណីហេតុការណ៍គ្រោះថ្នាក់ខាងលើនេះបានកើតឡើងនៅក្នុងបរិវេណការដ្ឋានសំណង់មួយកន្លែងស្ថិតនៅស្រុកមឿង ខេត្តភូកេត ប្រទេសថៃ យោងតាមប្រភពព័ត៌មានពីកន្លែងកើតហេតុបានឲ្យដឹងថា រណ្ដៅជីជំរៅជាងបីម៉ែត្របានបាក់ស្រុតចុះ ហើយសង្កត់កម្មករដែលកំពុងធ្វើការនៅខាងក្រោមនោះតែម្ដង។

កម្មករដែលរងគ្រោះនៅហេតុការណ៍គ្រោះរួមមាន 1.ឈ្មោះ Nea Sor Din អាយុ 22ឆ្នាំ សញ្ជាតិ ភូមា រងរបួសធ្ងន់ 2.ឈ្មោះ Niw Ta Av អាយុ 37ឆ្នាំ សញ្ជាតិ ភូមា (ស្លាប់) 3.ឈ្មោះមិនទាន់ស្គាល់អត្តសញ្ញាណនៅឡើយ។ ក្រោយពេលកើតហេតុកម្លាំងសមត្ថកិច្ចថៃបានចុះអន្តរាគមន៍ជួយសង្គ្រោះជនរងគ្រោះ រួចបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្ត ចំណែកឯមូលហេតុបង្កអោយកើតហេតុគ្រោះថ្នាក់នេះសមត្ថកិច្ចថៃកំពុងធ្វើការស្រាវជ្រាវដើម្បីចាត់វិធានការចំពោះក្រុមវិស្វករដែលចេញផ្លង់គ្រោងសាងសង់នេះ។

## រងការបំពាន ឬអត់ការងារធ្វើ ជម្រើសដ៏អាក្រក់របស់ពលករហ្វីលីពីន

http://km.rfi.fr/asia/ ដោយ អៀង សុខមុិញ ចុះផ្សាយនៅថ្ងៃ 22/02/2018

ក្រោយហេតុការណ៍ឃាតកម្មលើស្ត្រីអ្នកបម្រើតាមផ្ទះជាតិហ្វីលីពីន នៅកូវ៉ែតមក មានស្ត្រីហ្វីលីពីនជាច្រើនរយនាក់ផ្សេងទៀត បានសម្រេចចិត្តត្រលប់មកផ្ទះវិញ ជាមួយនឹងការរៀបរាប់ដ៏ជូរចត់។ ខ្លះត្រូវរងទុក្ខវេទនាដោយការធ្វើបាប លើរាងកាយ បង្អត់អាហារ ... ពីសំណាក់ថៅកែជាម្ចាស់ផ្ទះ។ ខ្លះត្រូវបង្ខំចិត្តរត់ចេញទៅរស់នៅដោយខុសច្បាប់ ... ស្ដាប់ទៅគួរឱ្យអាសូរ ! ប៉ុន្តែស្ត្រីហ្វីលីពីនទាំងនោះភាគច្រើន គ្មានជម្រើសអ្វីក្រៅប៉ងត្រលប់ទៅផ្សងសំណាងនៅបរទេសទៀតទេ។ ហេតុការណ៍មរណៈរបស់នាង ហ្សូអាណា ដេម៉ាហ្វេលី Joanna Demafelis ពលករហ្វីលីពីនដែលបានស្លាប់ និងដែលគេបានរកឃើញសាកសពនៅក្នុងទូរទឹកកក កាលពីដើមខែកុម្ភៈ នៅក្នុងផ្ទះថៅកែកូវ៉ែតម្នាក់បានឆ្លុះបញ្ចាំង និងបំផុសឱ្យឃើញអំពីលក្ខខណ្ឌជីវិត រងគ្រោះរបស់កម្មករបម្រើការតាមផ្ទះ នៅបរទេស។

ប្រធានាធិបតីហ្វីលីពីន លោក ឌុយទែរតេ បានចេញមុខការពារប្រជាពលរដ្ឋ និងបានចោទក្រុមថៅកែកូវ៉ែតថាតែងតែរំលោភបំពានផ្លូវភេទស្ត្រីអ្នកបម្រើហ្វីលីពីន បង្ខំឱ្យធ្វើការ ដល់ទៅ ២១ម៉ោង ក្នុងមួយថ្ងៃ និងឱ្យញុំាតែអាហារសំណល់។ ជាមួយនឹងការចោទសួរថាតើពេលណាក្រុមថៅកែបញ្ឈប់សកម្មភាពអមនុស្សធម៌លើពលករហ្វីលីពីន លោកឌុយទែរតេ បានចេញក្រិត្យហាមទាំងស្រុង មិនឱ្យពលរដ្ឋហ្វីលីពីនចុះកិច្ចសន្យាថ្មីទៅធ្វើការបម្រើតាមផ្ទះនៅរាជាណាចក្រកូវ៉ែតនេះទៀតទេ ហើយកំពុងស្វែងរកមធ្យោបាយពង្រឹងការការពារកម្មការិនី ដែលនៅលើទឹកដីនោះស្រាប់។ រដ្ឋាភិបាលហ្វីលីពីនបានចាត់វិធានការធ្វើមាតុភូមិនិវត្ត ដោយឥតគិតថ្លៃ នូវរាល់ពលករដែលចង់ត្រលប់មកមាតុប្រទេសវិញ។ ១៧០០នាក់ បានមកដល់ហ្វីលីពីនកាលពីថ្ងៃចុងសប្ដាហ៍កន្លងទៅ ក្នុងនោះអ្នកជាពលករធ្វើការខុសច្បាប់ ដែលរដ្ឋាភិបាលកូវ៉ែតសុខចិត្តលាងទោសឱ្យតែត្រលប់ទៅផ្ទះ ឱ្យបានមុនថ្ងៃទី ២២កុម្ភៈ២០១៨។

ដូចបូសធ្លាយ ពលករ ធ្វើការនៅកូវ៉ែត ប្រមាណ ២៥២.០០០នាក់ ភាគច្រើនជាអ្នកបម្រើតាមផ្ទះ បានផ្ដល់សក្ខីកម្ម ចុះផ្សាយយ៉ាងផុសផុលក្នុងទំព័រសារព័ត៌មាន រៀបរាប់អំពីបទពិសោធន៍ជីវិតដ៏ជូរចត់ ៖ រងការបំពារបំពានផ្លូវភេទ កេងកម្លាំងឥតអាសូរ វាយដំពីថៅកែផ្ទាល់ ពីក្រុមគ្រួសារ។

ម៉ារីសា (អាយុ៤០ឆ្នាំ) មីហ្សែល (អាយុ៣៤ឆ្នាំ) ឡូរ៉ែនហ្សា (អាយុ៣៧ឆ្នាំ) ព្រមទាំងពលករបម្រើការតាមផ្ទះជាច្រើនទៀតដែលទើបបានមកដល់ផ្ទះវិញជាសាក្សី។ ពួកគេសុទ្ធតែត្រូវបានថៅកែវាយដំធ្វើបាប បង្អត់អាហារ ខ្លះទ្រាំបាន ខ្លះទ្រាំមិនបានក៏រត់គេចទៅធ្វើការនៅកន្លែងផ្សេង ដែលមានលក្ខខណ្ឌជីវិតប្រសើរជាង តែជាការងារខុស

ច្បាប់ ហើយត្រូវប្រឈមនឹងប៉ូលិស រស់លាក់ពួនក្នុងភាពភ័យភិតរហូត ... ប៉ុន្តែទោះជាយ៉ាងដូច្នេះក្តី ក៏ពួកគេត្រៀមខ្លួនជាស្រេចនឹងត្រលប់ទៅកូវ៉ែត ឬទៅប្រទេសផ្សេងបើមាន ដើម្បីផ្សងសំណាងទៀតដដែល។ ហេតុអ្វី ? ចម្លើយមានតែមួយ ! ពលករទាំងនេះ ខ្លះត្រលប់មកស្រុកវិញគ្មានលុយក្នុងហោប៉ៅទេ ព្រោះប្រាក់ខែដែលបានត្រូវបញ្ជូនមកកូននិងគ្រួសាររាល់ខែអស់ទៅហើយ ហើយនៅហ្វីលីពីនជាស្រុកកំណើត ជាជំរកដ៏កក់ក្តៅមួយនេះ គ្មានទេទស្សនវិស័យការងារស្ថិតស្ថេរ។ គ្មានការងារធ្វើ តើធ្វើដូចម្តេចអាចរស់បាន ?!

មិនខុសអ្វីពីពាក្យចាស់បុរាណខ្មែរ ចុះទឹកក្រពើ ឡើងលើខ្លា តើត្រូវទៅផ្លូវណា ? រវាងមានសុខគេងអត់បាយ និងរងទុក្ខបានប្រាក់ខ្លះ តើត្រូវជ្រើសយកមួយណា ? មិនទេ ! គ្មាននរណាត្រូវការទេជម្រើសបែបនេះទេ ប៉ុន្តែសម្រាប់ស្ត្រីហ្វីលីពីន សេចក្តីត្រូវការរបស់គ្រួសារ នៅក្នុងប្រទេស មានទម្ងន់ធ្ងន់ជាងលក្ខខណ្ឌជីវិតរបស់ពួកគេផ្ទាល់ម្នាក់ឯងខ្លាំងណាស់ បើទោះបីជាពេលខ្លះជីវិតនោះមានជួបភាពព្រៃផ្សៃ រត់លូនលាក់ខ្លួនពីប៉ូលិសក៏ដោយ។ម្យ៉ាងវិញទៀត សម្រាប់ហ្វីលីពីន អ្នកដែលបានទៅធ្វើការនៅបរទេសត្រូវបានចាត់ទុកជាវីរបុរស ជាអ្នកដែលបានចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ។ ព័ត៌មានទាក់ទងនឹងលក្ខខណ្ឌជីវិតរងទុក្ខ រងការធ្វើបាបរបស់ពលករ គឺជាប្រធានបទនយោបាយដ៏រសើបមួយ តែមិនបានបំបាក់ទឹកចិត្តហ្វីលីពីនឱ្យចាកចេញទៅរកការធ្វើនៅបរទេសឡើយ។

ជាសរុបមានជនជាតិហ្វីលីពីនប្រមាណជា ១០លាននាក់ ចេញទៅធ្វើការនៅបរទេស ក្នុងវិស័យផ្សេងៗ ក្នុងនោះមួយភាគធំជាស្ត្រីបម្រើតាមផ្ទះ។ បើតាមតួលេខរបស់ធនាគារកណ្តាលហ្វីលីពីន ប្រាក់ចំណូលរបស់គេ គឺជាប្រភពចំណូលសេដ្ឋកិច្ចដ៏ចំបងនៅមូលដ្ឋាន ដោយបានប្រមូលថវិកាប្រមាណ ជាង ២៨ពាន់លានដុល្លារ សម្រាប់ឆ្នាំ ២០១៧៕

## ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨

## អាវុធហត្ថរាជធានីភ្នំពេញ បង្ក្រាបករណីជួញដូរមនុស្សបោកជនរងគ្រោះថានៅរៀបការនៅចិន, ស្តាប់ការរៀបរាប់របស់នារីរងគ្រោះពិតជាគួរឲ្យអាសូរណាស់ ! នាងត្រូវលក់ឲ្យបុរសចិន ពីមួយទៅមួយដើម្បីបំរើតណ្ហា

http://www.freshnewsasia.com/ 2018-02-22

**(ភ្នំពេញ)៖** នៅពេលដែលយើងនិយាយដល់រឿងរៀបអាពាហ៍ពិពាហ៍ វាគឺជារឿងដែលសប្បាយរីករាយនៅក្នុងជីវិតរបស់យើងម្នាក់ៗ ព្រោះវាជាទំនៀមទម្លាប់ប្រពៃណីដែលមានតាំងពីបុរាណមកផង និងជាសក្ខីភាពបញ្ជាក់ពីភាពជោគជ័យនៃក្តីស្រឡាញ់ផង។ លើសពីនេះទៅទៀត មានប្រជាជនមួយចំនួន រឹតតែមានការពេញចិត្តខ្លាំង ពេលដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស។ ព្រមជាមួយគ្នាផងដែរ ដើម្បីឲ្យចំណងអាពាហ៍ពិពាហ៍របស់ពលរដ្ឋ មានភាពរឹងមាំ និងមានសុវត្ថិភាព រាជរដ្ឋាភិបាលបាន ធ្វើការកំណត់ ឲ្យអាពាហ៍ពិពាហ៍ទាំងអស់ ចាំបាច់ត្រូវតែបំពេញទៅតាមនិតិវិធី និងលក្ខខណ្ឌរួមមួយចំនួន ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរ រីឯការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស រឹតតែត្រូវបំពេញតាមលក្ខខណ្ឌកំណត់ ដែលមានចែង ក្នុងច្បាប់យ៉ាងហ្មត់ចត់បំផុត។ ហើយការរៀបអាពាហ៍ពិពាហ៍ ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម គឺត្រូវហាមឃាត់ដាច់ខាត។

ថ្មីៗនេះអាវុធហត្ថរាជធានីភ្នំពេញ បានស្រាវជ្រាវបង្ក្រាបករណីជួញដូរមនុស្ស១ករណី ដែលក្រុមមេខ្យល់ ដើរបោកជនរងគ្រោះថានឹងឲ្យទៅរៀបការនៅប្រទេសចិន។ ក្នុងនោះអាវុធហត្ថរាជធានីភ្នំពេញ បានសង្គ្រោះនារីរងគ្រោះ ០២នាក់ ដោយម្នាក់ជាអនិតិជន បានរំដោះមកពីប្រទេសចិន និងម្នាក់ទៀតបានទប់ស្កាត់ទាន់ពេលវេលា រួចផុតពីការជួញដូរ ព្រមទាំងឃាត់ខ្លួនជនសង្ស័យជាមេខ្យល់បាន០២នាក់ផងដែរ។ ករណីជួញដូរមនុស្សនេះកើតឡើងតាំងពី

អំឡុង ខែមេសា ឆ្នាំ២០១៧ ដែលដំបូងឡើយប្អូនស្រីម្នាក់ ឈ្មោះ ប.ផ អាយុ១៦ឆ្នាំ ត្រូវបានស្រ្តីម្នាក់ជាជនជាតិខ្មែរ លួងលោម ឲ្យរៀបការជាមួយប្តីចិនដោយគេជាអ្នករត់ការឲ្យ។ ក្រោយពេលព្រមព្រៀង ប្អូនស្រីក៏ត្រូវស្រ្តីមេខ្យល់ម្នាក់នោះនាំមកភ្នំពេញ ជួបជាមួយស្រ្តីមេខ្យល់ម្នាក់ទៀត ដើម្បីនាំទៅធ្វើប៉ាស្ព័រ បន្ទាប់មកនាំទៅទីក្រុងសៃហ្គន ប្រទេសវៀតណាម ជួបជាមួយមេខ្យល់វៀតណាម ទើបបន្តជិះយន្តហោះទៅកាន់ទីក្រុងហាណូយ ហើយជិះតាក់ស៊ី ទៅកាន់ព្រំដែនវៀតណាម ជាប់ខេត្តកងចូវ ប្រទេសចិន រួចទើបដើរកាត់ព្រៃភ្នំ លួចឆ្លងដែនចូលទៅប្រទេសចិន។

ប្អូនស្រីបានរៀបរាប់ថា តាមផ្លូវនៅក្នុងព្រៃលើភ្នំពេលដើរឆ្លងដែនពីប្រទេសវៀតណាម ទៅប្រទេសចិន ប្អូនស្រីត្រូវបានបានមេខ្យល់វៀតណាម ចាប់រំលោភរួចទៅហើយ ទើបប្រគល់ទៅឲ្យមេខ្យល់ជនជាតិចិនបន្ត។ ពេលទៅដល់ទឹកដីចិន ប្អូនស្រីត្រូវបានក្រុមមេខ្យល់ឃុំទុកមួយសប្តាហ៍ ទើបហៅបុរសចិន០៦នាក់ មកមើលប្អូនស្រី ពេលនោះក៏មានបុរសម្នាក់ពេញចិត្ត ព្រមទិញប្អូនស្រីក្នុងតម្លៃ១២ម៉ឺនយន់ សម្រាប់រយៈពេល០១ខែ ពេលនោះក្នុង១ថ្ងៃ ប្អូនស្រីត្រូវគេបង្ខំរួមភេទ២ទៅ៣ដង។ ក្រោយមកពីបុរសចិនទី១ ប្រគល់ប្អូនស្រីឲ្យទៅមេខ្យល់វិញ។ បានមួយរយៈមេខ្យល់នោះក៏លក់ប្អូនស្រីទៅឲ្យបុរសចិនទី២ ក្នុងតម្លៃ១៣ម៉ឺនយន់ សម្រាប់រយៈពេល១ខែកន្លះ ហើយបុរសទី២នោះ ក៏ទុកប្អូនស្រីសម្រាប់បម្រើផ្លូវភេទ ២ទៅ៣ដងក្នុងមួយថ្ងៃដូចគ្នា។ ក្រោយពេលបញ្ចប់ពីការបម្រើកាមគុណបុរសទី២ មួយរយៈក្រោយមក មេខ្យល់ក៏បានលក់ប្អូនស្រីទៅបុរសចិនទី៣ ក្នុងតម្លៃ ៦ម៉ឺនយន់ ហើយបុរសទី៣នោះ ក៏បានយកប្អូនស្រីទៅរស់នៅជាមួយ ក្នុងតំបន់ព្រៃភ្នំដាច់ស្រយ៉ាលពីទីក្រុង ដោយរស់នៅក្នុងនាមជាអ្នកបម្រើផ្លូវភេទផង និងជាអ្នកបម្រើដាច់ថ្លៃក្នុងផ្ទះផង ក្នុងនោះប្អូនស្រីត្រូវគេបង្ខំឲ្យរួមភេទគ្រប់ពេល ទៅតាមចិត្តដែលគេចង់ និងត្រូវនៅបម្រើយាយចាស់ម្នាក់ក្នុងផ្ទះ ព្រមទាំងធ្វើការងារផ្ទះសព្វមុខទាំងអស់ ដោយមិនឲ្យចេញទៅណាឡើយ។

ក្រោយពេលរស់នៅជាមួយបុរសចិនទី៣ អស់រយៈពេលប្រហែល២ខែកន្លះ នៅថ្ងៃមួយប្អូនស្រីបានរកឱកាសលួចយកទូរស័ព្ទទំនាក់ទំនងមកកាន់គ្រួសារនៅឯប្រទេសខ្មែរ។ ក្រោយពីគ្រួសារប្អូនស្រី ប.ផ បានទទួលដំណឹងពីប្អូនស្រីភ្លាម ក៏បានពិភាក្សាគ្នាឲ្យជីដូនឡើងមកភ្នំពេញ ចូលជួបឧត្តមសេនីយ៍ឯក រ័ត្ន ស្រ៊ាង មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាមេបញ្ជាការកងរាជអាវុធហត្ថ រាជធានីភ្នំពេញ ដើម្បីដាក់ពាក្យបណ្តឹងឲ្យជួយដល់ប្អូនស្រី។ បន្ទាប់ពីបានទទួលពាក្យបណ្តឹង និងមានការណែនាំយ៉ាងម៉ឺងម៉ាត់ពី នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថ លើផ្ទៃប្រទេស ត្រូវជួយសង្រ្គោះរំដោះប្អូនស្រីរងគ្រោះ មកវិញឲ្យខាងតែបានឧត្តមសេនីយ៍ឯក រ័ត្ន ស្រ៊ាង បានដាក់បញ្ជាដល់កម្លាំងជំនាញនៃការិយាល័យ បទល្មើសជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ ធ្វើការស្រាវជ្រាវយ៉ាងស្ថិតស្ថាល ជាមួយក្រុមគ្រួសារជនរងគ្រោះ រហូតឈានដល់ធ្វើការឃាត់ខ្លួនមេខ្យល់ខ្មែរម្នាក់ឈ្មោះស៊ុ ចំរើន ហៅលីលី ហៅលីហ្សា នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ហើយបានទប់ស្កាត់ស្រ្តីរងគ្រោះម្នាក់ផ្សេងទៀត ឈ្មោះ ស.ល រួចផុតពីការជួញដូរ ខណៈដែលនារីរងគ្រោះម្នាក់នេះ ត្រូវបានមេខ្យល់ ស៊ុ ចំរើន បម្រុងនាំទៅលក់នៅប្រទេសចិនជាបន្ត ។

រហូតដល់អំឡុងខែកុម្ភៈឆ្នាំ២០១៨ អាវុធហត្ថរាជធានីភ្នំពេញ ទាក់ទងនារីរងគ្រោះឈ្មោះ ប.ផ នៅប្រទេសចិន បានតាមរយៈទូរស័ព្ទ ដោយនារីរងគ្រោះ លួចទំនាក់ទំនងមកដោយផ្ទាល់ នៅពេលនោះលោកវរសេនីយ៍ត្រី សេន កូម៉ុន នាយការិយាល័យបទល្មើស ជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានណែនាំប្អូនស្រីឲ្យលួចរត់ទៅកាន់ទិសណា ដែលឮសន្ធឹករថយន្ត រកផ្លូវទៅជួបជាមួយប៉ូលីសចិន ដើម្បីឲ្យប៉ូលីសជួយនាំទៅកាន់ស្ថានទូតខ្មែរប្រចាំនៅ ទីក្រុងប៉េកាំង ។ បន្ទាប់មកអាវុធហត្ថរាជធានី ភ្នំពេញបានសហការណ៍ជាមួយនគរបាលជាតិក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី គណកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រសួងការបរទេស និង អង្គការសម្ព័ន្ធចាប់ដៃ ដើម្បីរៀបចំសំណុំបែបបទ និងសំបុត្រយន្តហោះនាំយកប្អូនស្រីរងគ្រោះ ពីទីក្រុងប៉េងកាំង មកកាន់កម្ពុជាវិញ ក្នុងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨។ នៅទីបំផុតអាវុធហត្ថរាជធានីភ្នំពេញ ក៏បានជួយប្អូនស្រីរួចផុតពីអំពើជួញដូរ និងទាសករ

ផ្លូវភេទ ព្រមទាំងបានជូនប្អូនស្រី ទៅដល់ស្រុកកំណើត បង្កើតបានជាក្តីរំភើបលាយឡំដោយទឹកភ្នែកពេញក្នុងរង្វង់គ្រួសារដ៏កម្សត់។ ក្រោយពីប្អូនស្រីរងគ្រោះបានរួចទុក្ខភ័យ ជួបជុំគ្រួសារវិញ អាវុធហត្ថរាជធានីភ្នំពេញ ក៏បន្តនិតិវិធីដោយសហការណ៍ជាមួយ អាវុធហត្ថលើផ្ទៃប្រទេស និងអាវុធហត្ថខេត្តកំពង់ចាម ធ្វើការស្រាវជ្រាវឃាត់ខ្លួនស្ត្រីមេខ្យល់ម្នាក់ទៀតឈ្មោះ ឃឹម សុខខេង នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៨ បន្ទាប់ពីមេខ្យល់ម្នាក់នេះបានគេចខ្លួនអស់ជាច្រើនខែ និងបានបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៨។

ជាលទ្ធផលនៃការបង្រ្កាបអំពើជួញដូរមនុស្សនេះ អាវុធហត្ថរាជធានីភ្នំពេញ បានរំដោះនារីរងគ្រោះជាអនិតិជនម្នាក់ពីប្រទេស ចិនមកកាន់កម្ពុជា ទប់ស្កាត់នារីម្នាក់ផ្សេងទៀតរួចផុតពីការជួញដូរ បញ្ជូនទៅស្រុកកំណើតជួបជុំគ្រួសារវិញ និងឃាត់ខ្លួន ជនសង្ស័យជាមេខ្យល់បាន០២នាក់ បញ្ជូនទៅតុលាការ ព្រមទាំងកំណត់បានមុខសញ្ញាស្ត្រីខ្មែរម្នាក់បានប្តីចិន គឺជាមេក្លោងធំក្នុងការជួញដូរមនុស្សយ៉ាងសកម្ម កំពុងគេចខ្លួនទៅប្រទេសចិន។ តាមរយៈរឿងសោកសង្វេគដែលបានកើតឡើងជាក់ស្តែងនេះ គឺជាបទពិសោធន៍បង្ហាញថា អាពាហ៍ពិពាហ៍ក្រៅច្បាប់ ជាមួយជនបរទេស គឺជាការ ប្រថុយប្រថានដ៏គ្រោះថ្នាក់បំផុត ដែលយើងទាំងអស់គ្នា គួរជៀសវាងជាច់ខាត។ ក្នុងករណីមានការលួងលោម ពីបុគ្គលណាម្នាក់ដែលគ្មានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន គឺជាអំពើបោកបញ្ឆោត ដែលអាច ឈានទៅដល់ការជួញដូរមនុស្សយ៉ាងពិតប្រាកដ ។ ដូច្នេះបើមានករណីលួងលោមទាំងនេះកើតឡើង សូមប្រញ៉ាប់រាយការណ៍ទៅកាន់អាជ្ញាធរឬសមត្ថកិច្ចដែលនៅជិតលោកអ្នកកុំបីខាន៕

## ស្ត្រីម្នាក់ត្រូវបាន ជួយសង្គ្រោះឲ្យរួចផុតពី អំពើជួញដូរផ្លូវភេទ

https://www.dap-news.com/kh/ ព្រហស្បតិ៍, ២២ កុម្ភៈ ២០១៨ 20:58 ដោយ: ដើមអម្ពិល ID:030

ភ្នំពេញ៖ លោកវរសេនីយ៍ត្រី សេន កូម៉ុន នាយការិយាល័យបទល្មើស ជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានសហការជាមួយ នគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រសួងការបរទេស និងអង្គការសម្ព័ន្ធចាប់ដៃ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨នេះ បានអន្តរាគមន៍ជួយសង្គ្រោះស្ត្រីអនិតិជនខ្មែរម្នាក់ឲ្យរួចផុតពីអំពើជួញដូរ និងទាសករផ្លូវភេទ។

កម្លាំងអាវុធហត្ថបានឲ្យដឹងថា ជនសង្ស័យជាមេខ្យល់២នាក់ត្រូវបានបញ្ជូនទៅតុលាការ ព្រមទាំងកំណត់បានមុខសញ្ញាស្ត្រីខ្មែរម្នាក់ បានប្តីចិន គឺជាមេក្លោងធំ ក្នុងការជួញដូរមនុស្សយ៉ាងសកម្ម កំពុងគេចខ្លួនទៅប្រទេសចិន។ ក្រោយពីជនរងគ្រោះ បានរួចទុក្ខភ័យ ជួបជុំគ្រួសារវិញ កម្លាំងអាវុធហត្ថរាជធានីភ្នំពេញ ជាមួយអាវុធហត្ថលើផ្ទៃប្រទេស និងអាវុធហត្ថខេត្តកំពង់ចាមធ្វើការស្រាវជ្រាវឃាត់ខ្លួនស្ត្រីមេខ្យល់ម្នាក់ទៀតឈ្មោះ ឃឹម សុខខេង នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៨ បន្ទាប់ពីមេខ្យល់ម្នាក់នេះបានគេចខ្លួនអស់ជាច្រើនខែ និងបានបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៨៕

## បុរសម្នាក់ត្រូវបានចាប់ខ្លួនភ្លាមៗ ក្រោយមានបណ្តឹងថា នាំមនុស្សចូលធ្វើការក្នុងដីថៃខុសច្បាប់

http://www.postkhmer.com/ យុត សុភចរិយា | Publication date 25 February 2018

បន្ទាយមានជ័យៈ បុរសម្នាក់ ត្រូវបានកម្លាំងការិយាលយ៍ប្រឆាំងការជួញដូរមនុស្ស ចាប់ឃាត់ខ្លួនភ្លាមៗនៅចំណុចរង្វង់មូលច្រកទ្វារអន្តរជាតិប៉ោយប៉ែត បន្ទាប់ពីទទួលបានបណ្តឹងពីជនរងគ្រោះពីរនាក់ ប្តឹងចោទប្រកាន់ថាបាននាំពួកគេឆ្លងដែនចូលទៅរកការងារធ្វើក្នុងទឹកដីថៃដោយខុសច្បាប់។

លោក ឡាយ គឹមលន់ ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្សនិយាយថា ជនសង្ស័យដែលសមត្ថកិច្ចចាប់ឃាត់ខ្លួនក្នុងករណីខាងលើនេះ ឈ្មោះអៀត អុន អាយុ៤៣ឆ្នាំ ជាបុគ្គលិកផ្នែកលក់សំបុត្រឡានពីខ្មែរទៅប្រទេសថៃ និងមានទីលំនៅភូមិប៉ោយប៉ែត សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត។ លោកបានបន្តថា ជនសង្ស័យត្រូវបានចាប់ខ្លួន តាមបណ្តឹងរបស់ជនរងគ្រោះចំនួនពីរនាក់ ដែលបានរត់គេចខ្លួនរួចពីប្រទេសថៃ ក្រោយពីពួកគេត្រូវបានជន

សង្ស័យ បោកប្រាស់យកប្រាក់ពីពួកគេក្នុងម្នាក់ៗ២៥០បាតជាថ្នូរនឹងការនាំទៅរកការងារធ្វើនៅក្នុងទឹកដីថៃ ដោយជនសង្ស័យបាននាំពួកគេ ដើរឆ្លងកាត់តាមអូរព្រំដែន ត្រង់ចំណុច កាស៊ីណូប៉ោយប៉ែត រួចហើយឲ្យពួកគេស្នាក់នៅជាបណ្ដោះអាសន្ននៅក្នុងបន្ទប់ផ្ទះជួលមួយ ក្បែរផ្សាររ៉ុងក្លឿប្រទេសថៃ ហើយជនសង្ស័យបានគេចខ្លួនដោយមិនបានរកការងារឲ្យពួកគេធ្វើឡើយ។ លោក គីមលន់ បានបញ្ជាក់ថា៖«នៅពេលនេះ ជនសង្ស័យកំពុងស្ថិតក្រោមការសួរចម្លើយ និង គ្រោងបញ្ជូនទៅកាន់តុលាការខេត្តបន្ទាយមានជ័យនៅព្រឹកថ្ងៃចន្ទនេះ»៕

## ទាហាន ឈុតខ្មៅ ថៃចាប់ ខ្មែរម្នាក់ ក្នុងចំណោម៧នាក់ដែល ឆ្លងដែនចូលកាប់ឈើ ក្រញូង

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 23 February, 2018

ពោធិ៍សាត់ ៖ ប្រជាពលរដ្ឋខ្មែរម្នាក់ ត្រូវបានទាហានឈុតខ្មៅថៃចាប់ឃាត់ខ្លួន ឯ៦នាក់ទៀត រត់គេចខ្លួនរួច ខណៈដែលពួកគេលួចឆ្លងដែនសង្ស័យថា ចូលកាប់ឈើក្រញ៉ូងខុសច្បាប់ ក្នុង ទឹកដីថៃ។ ប្រភពពីកម្លាំងសមត្ថកិច្ច នៃវរៈការពារព្រំដែនគោក ៨២៥ ទទួលទិសថ្មដា បានប្រាប់ឲ្យដឹង ថា ជនសង្ស័យដែលទាហានឈុតខ្មៅថៃ កងរយ ៥៣៦ ចាប់ខ្លួននោះមានឈ្មោះ ស៊ឹម រ៉េន ភេទប្រុស អាយុ៦៣ឆ្នាំ រស់នៅភូមិបឹងប្រើយ៍ ស្រុកបាកាន ខេត្តពោធិ៍សាត់។ វត្ថុតាងដែលដកហូតបានរួមមានឈើក្រញូង៥ដុំ និងម៉ាស៊ីនត្រង់ស៊ីន័រអារឈើ ១គ្រឿង។ ប្រភពបានបន្តថា មានបុរស ៦នាក់ទៀត ដែលចូលរួមលួចឆ្លងដែន ចូលកាប់ឈើ ក្រញូង នៅក្នុងទឹកដីថៃ ហើយត្រូវបានរត់ចែកជើងគ្នា ។ យ៉ាងនេះក្តី ខាងភាគីថៃ មិនទាន់បានបញ្ជាក់ ពីអត្តសញ្ញាណ របស់ពលរដ្ឋទាំង ៦នាក់នោះនៅឡើយទេ។ ក្រោយពេលកើតហេតុ ខាងភាគី ថៃ បានបញ្ជូនជនសង្ស័យទៅកាន់ស្នងការដ្ឋាននគរបាលខេត្តត្រាត ដើម្បីសួរនាំ ហើយបាន ជូនដំណឹងមកឲ្យកម្លាំងសមត្ថកិច្ចកម្ពុជាផងដែរ។ ប្រភពបានបន្ថែមទៀតថា នៅព្រឹកស្អែកនេះ ខាងភាគីកម្ពុជា នឹងណាត់គ្នាជាមួយទំនាក់ទំនង ដែលកាន់ច្រកព្រំដែន៥៦ ឃុំថ្មដា ស្រុកវាលវែង ដើម្បីចុះទៅសួរនាំ ស្រាវជ្រាវ និងស្វែងរកបក្សពួក និងមេខ្យល់ ដែលផ្សំគំនិតចូលរួមលួចឆ្លងដែន ចូលកាប់ឈើក្រញ៉ូងខុសច្បាប់ នៅ លើទឹកដីថៃ ឲ្យបានលម្អិត។

ហេតុការណ៍នេះ បានកើតឡើងកាលពីវេលាម៉ោង ១ និង៣០នាទីរំលងអាធ្រាត ឈានចូល ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ នៅលើទឹកដីថៃ ទល់មុខប៉ុស្តិ៍ភ្នំគុតឫស្សី ស្ថិតក្នុងភូមិសុផានហ៊ីម ឃុំឡែមកាត់ ស្រុកមឿង ខេត្តត្រាត ប្រទេស៕

## ពលរដ្ឋខ្មែរ២នាក់ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួនពាក់ព័ន្ធករណីលក់ឆ្នោតខុសច្បាប់

http://www.ppd-news.net/ 26-February-2018 /

ខេត្តបាត់ដំបង ៖ ពលរដ្ឋខ្មែរ២នាក់ត្រូវបានសមត្ថកិច្ចថៃឃាត់ពាក់ព័ន្ធករណីទីតាំងលក់លក់ឆ្នោត ដែលសមត្ថកិច្ចថៃអះអាងថា ជាល្បែងស៊ីសងខុសច្បាប់ ខណៈដែលឃាត់នេះធ្វើឡើងកាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៨។ ទីតាំងដែលមេឆ្នោតទាំងពីនាក់នេះបើកគឺស្ថិតនៅចំណុចផ្សារស៊ីកិន ស្រុកខ្លងហាត ខេត្តស្រះកែវ ប្រទេសថៃ ដែលប្រឈមនឹងច្រកតំបន់គីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូនខេត្តបាត់ដំបង ត្រូវបានសមត្ថកិច្ចថៃចាប់ឃាត់ខ្លួន ដោយចោទប្រកាន់ថា នេះជាល្បែងស៊ីសងខុសច្បាប់ដែលប្រទេសថៃហាមឃាត់។ បើតាមសមត្ថកិច្ចបានឲ្យដឹងថា តាមភាគគីថៃបានឲ្យដឹងថា អ្នកទាំងពីរមានទីលំនៅភូមិបឹងប្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ បច្ចុប្បន្ន ជនសង្ស័យទាំងពីរត្រូវបានអាជ្ញាធថៃបញ្ជូនបន្តដើម្បីចាត់ការតាមច្បាប់ប្រទេសថៃ៕

## ពលករចំនួន 23នាក់បានរងរបួស និង01នាក់ទៀតស្លាប់នៅនឹងកន្លែងកើតហេតុ

http://www.prakpheaktra.com/ February 24, 2018

កាលពីវេលាម៉ោង08:24នាទីយប់ ថ្ងៃសុក្រទី23 ខែកុម្ភៈ ឆ្នាំ2018 មានករណីគ្រោះថ្នាក់ចរាចរដ៏រន្ធត់មួយបានកើតឡើងរវាងរថយន្តដឹកពលករបុកនឹង(សិបឡូ)នៅត្រង់ចំណុចផ្លូវបំបែក (ក្លាងវាង) ស្ថិតនៅឃុំណងតាខង ស្រុក

ប៉ោងណាមរ៉ែន ខេត្តចាន់បុរី ប្រទេសថៃ ។ យោងតាមប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថា ករណីគ្រោះថ្នាក់ចរាចរខាងលើអោយមានពលករខ្មែរ និងអ្នកបើកបរថយន្តរងរបួសចំនួន 23នាក់ និងស្លាប់ 01នាក់នៅកន្លែងកើតហេតុ។ ក្រោយពេលកើតហេតុជនរងគ្រោះទាំងអសត្រូវបានភ្នាក់ងារសង្គ្រោះស្រុកប៉ោងណាមរ៉ែនខេត្តចាន់បុរី បញ្ជូនយកទៅសង្គ្រោះនៅឯមន្ទីប្រាក់បុកក្លៅចាន់បុរី។ ក្នុងករណីគ្រោះថ្នាក់ចរាចរខាងលើនេះក្រុមការងារស្ថានកុងស៊ុលកម្ពុជាប្រចាំប្រទេសថៃ កំពុងធ្វើការចុះអន្តរាគមន៍សាកសួរសុខទុក្ខពលករខ្មែរដែលសម្រាកព្យាបាលនៅមន្ទីរប្រាក់បុកក្លៅ និងមន្ទីពេទ្យប៉ោងណាមរ៉ែនភ្លាមៗផងដែរ។

**ចន្លែមសូន្យOne StopService ចំនួនពីរកន្លែងទៀតនៅខេត្តឈុនបុរី និង ខេត្តបាធុមថានី**

http://www.prakpheaktra.com/ February 22, 2018

យោងតាមការផ្តល់បទសម្ភាសន៍របស់អគ្គរដ្ឋលេខាធិការអេចិន្រ្តៃយ៍ នៃការងារថៃបានបានអោយដឹងថា ខេត្តឈុនបុរី និងខេត្តបាធុមថានីត្រៀមនិងបន្ថែមទីតាំងសូន្យ OneStopService ចំនួនពីរកន្លែងបន្ថែមទៀតដើម្បីឲ្យមានដំណើរលឿនរហ័សជាងមុន បន្ទាប់ពីខេត្តទាំងពីរនេះមានពលករបរទេសធ្វើការស្នាក់នៅច្រើនជាងខេត្តផ្សេងៗទៀត ។ បច្ចុប្បន្នសូន្យOneStopServiceនៅក្នុងខេត្តឈុនបុរីគឺនៅត្រង់មុំសាលាប្រាក់គមឡែមចប្បាំង ហើយននៅក្នុងខេត្តបាធុមថានីនៅក្នុងហាងទទំនើបសៀរាំងសិត។

**ទីតាំងត្រួតសញ្ជាតិធ្វើប៉ាស្ព័រជូនពលករខ្មែរ ជាច្រើនកន្លែងទៀតនិងបើកដំណើរការ នៅពេលឆាប់ៗខាងមុខនេះ**

http://www.prakpheaktra.com/ February 23, 2018

បន្ទាប់ពីរដ្ឋមន្ត្រីក្រសួងការងារថៃ បានធ្វើដំណើរទៅជួបពិភាក្សាជាមួយឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា កាលពីថ្មីៗកន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជានិងថៃបានសម្រេចបន្ថែមការិយាល័យត្រួតសញ្ជាតិធ្វើប៉ាស្ព័រជូនបងប្អូនពលករខ្មែរដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ចំនួនជាច្រើនកន្លែងទៀត ព្រមទាំងមានភ្នាក់ងារចល័តចុះត្រួតសញ្ជាតិធ្វើប៉ាស្ព័រជូនបងប្អូនពលករកម្ពុជានៅក្នុងតំបន់ដែលមានបងប្អូនរស់នៅច្រើន ដូចជាខេត្តនុនថាកបុរី,ឈុនបុរី, បាធុមថានី, សាមុតប្រាកានជាដើម ដើម្បីជួយសម្រួលភាពស្របច្បាប់ជូនពលករកម្ពុជាទាំងអស់ដែលមិនបានត្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅក្នុងប្រទេសថៃ។ ដូច្នេះហើយសូមបងប្អូនពលករកម្ពុជាទាំងអស់ត្រូវទៅបន្តធ្វើប័ត្រស៊ីជម្ពូ ដែលរាជរដ្ឋាភិបាលថៃប្រកាសអោយបានត្រឹមត្រូវទាំងអស់គ្នា ដើម្បីបន្តសុពលភាពស្នាក់នៅបន្តមុខទៀត បន្ទាប់ពីនោះទៀតបងប្អូននិងបានចូលទៅបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័រ នៅតាមការិយាល័យនីមួយដែលត្រៀមនឹងបើកដំណើរបន្ថែមទៀតពេលឆាប់ៗខាងមុខនេះ។

**ចាត់ហាខានខេត្តសុរិន្ទ, ចុះឃាត់ខ្លួនពលករខ្មែរធ្វើការខុសលក្ខខ័ណ្ឌច្បាប់ចំនួន 03នាក់**

http://www.prakpheaktra.com/ February 23, 2018

កាលពីថ្មីៗកន្លងទៅនេះកម្លាំងអាជ្ញាធរថៃ(ក.អ.ណ.)ខេត្តសុរិន្ទ ប្រទេសថៃ បានបើកកិច្ចសហការជាមួយអាជ្ញាធរក្រសួងការងារខេត្តសុរិន្ទ ចុះធ្វើត្រួតពិនិត្យផ្សាររាត្រី(ណែប៉ាសា) ស្ថិតនៅទីតាំងក្នុងស្រុកមឿង ខេត្តសុរិន្ទ ដើម្បីត្រួតពិនិត្យឯកសារធ្វើការរបស់ពលករបរទេសដែលកំពុងធ្វើការនៅក្នុងខេត្តសុរិន្ទ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងជួលពលករខុសច្បាប់អោយធ្វើការដោយគ្មានច្បាប់អនុញ្ញាត ។ យោងតាមប្រភពព័ត៌មានរបស់ថៃបានអោយដឹងថា ក្នុងការចុះត្រួតផ្សាររាត្រីខាងលើនេះកម្លាំងអាជ្ញាធរថៃ បានរកឃើញពលករខ្មែរធ្វើការលក់ដូរអោយថៅកែថៃមួយចំនួន ហើយមានមួយចំនួនទៀតធ្វើការខុសលក្ខខ័ណ្ឌពីច្បាប់ការងារនិងគ្មានច្បាប់អនុញ្ញាតធ្វើការនៅក្នុងប្រទេសថៃ ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួនយកទៅធ្វើការសាកសួរនៅអធិការដ្ឋានតម្រួតខេត្តសុរិន្ទដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## មិនទីតាំងធ្វើប៉ាស្ព័រនៅខេត្តសង់ក្លា

http://www.prakpheaktra.com/ February 24, 2018

ចាប់ពីថ្ងៃពុធទី28 ខែកុម្ភៈ ឆ្នាំឆ្នាំ2018 ខាងមុខនេះ មណ្ឌលផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាក្នុងខេត្តសង់ក្លា និងបិទដំណើរផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាហើយ ។ ក៏ប៉ុន្តែនិងមានក្រុមការងារចល័តចុះផ្តល់ភាពស្របច្បាប់(ធ្វើប៉ាស្ព័រ)ជូនបងប្អូនពលករកម្ពុជានៅខេត្តសង់ក្លានេះបន្ត ចាប់តាំងពីថ្ងៃច័ន្ទទី05 ខែមិនា ឆ្នាំ2018 តទៅ ដូច្នេះសូមបងប្អូនពលករខ្មែរទាំងអស់មេត្តាជ្រាបជាដំណឹង។

## ដំណឹងល្អ, សូន្យOSS ក្រុងថេប បើកអោយពលករទៅធ្វើដោយខ្លួនឯងបានហើយ.!

http://www.prakpheaktra.com/ February 25, 2018

យោងតាមប្រភពពីទំព័រហ្វេសប៊ុក สุขินพึ่งประเสริฐ បានរាយការណ៍អោយដឹងថា ចំពោះបងប្អូនពលករខ្មែរ,ឡាវ, ភូមា,ដែលចេះស្តាប់ភាសាថៃបានច្បាស់លាស់បងប្អូនអាចនាំយកឯកសាររបស់ថៅកែទៅធ្វើប័ត្រស៊ីជម្ពូ និងវីសារពីរឆ្នាំនៅទីតាំងសូន្យវ៉ាន់ស្តប់សឺរីត(អាយធីខ្មែរ)បានដោយដោយខ្លួនឯងដោយមិនចាំបាច់មានលិខិតម៉បអំណាចឡើយ។ ចំពោះឯកសារត្រូវនាំទៅធ្វើរួមមាន៖

1.អត្តសញ្ញាណប័ណ្ណរបស់ថៅកែ(ប័ត្រប្រាក់ឆាឈុន)

2.សៀវភៅគ្រួសារ(តៀនបាន)

3.លិខិតត្រួតសុខភាពចេញពីមន្ទីរពេទ្យ

4.ប័ត្រស៊ីជម្ពូឬលិខិតលុងបៀន

5.ប៉ាស្ព័រត្រួតសញ្ជាតិ

បញ្ជាក់:ក្នុងករណីថៅកែមានលំនៅដ្ឋានតាមខេត្ត ត្រូវសុំលិខិតស្នាមជួលពីផ្ទះជួលនិងលិខិតស្នាម បញ្ជាក់ពីផ្ទះដើមដែលអោយជួលផងដែរ ទើបអាចអោយពលករនាំយកទៅធ្វើបាន។

## អាជ្ញាធរថៃត្រៀមប្ដឹងថៅកែរោងចក្រទឹកកកមួយករណីបង្ខំកម្មករខ្មែរឲ្យធ្វើការលើសម៉ោង

https://www.rfa.org/ ដោយ អាស៊ីសេរី 2018-02-22

អាជ្ញាធរ និងអង្គការ នៅប្រទេសថៃកំពុងប្រមូលព័ត៌មាន ដើម្បីប្ដឹងថៅកែរោងចក្រទឹកកកថៃមួយកន្លែង អំពីការបង្ខំកម្មករខ្មែរឲ្យធ្វើការលើសម៉ោង និងបង្ខាំងកម្មករមិនឲ្យដើរហើរ។ កម្មករទាំងនេះ ឋិតនៅក្រោមអាជ្ញាធរថៃនៅឡើយ។ កម្មករខ្មែរនៅប្រទេសថៃចំនួន ១៣នាក់ និងកម្មករឡាវ ៦នាក់ ដែលត្រូវបានប៉ូលិស និងអង្គការការពារសិទ្ធិការងារ រំដោះចេញពីរោងចក្រទឹកកកបាងស៊ីមឿង ខេត្តនន់ថៈប៊ុរី នៅថ្ងៃទី១៦ កុម្ភៈ កំពុងឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស (Social Development and Human Security)។ កម្មករទាំងនេះបានអះអាងប្រាប់ក្រុមអ្នកសង្គ្រោះថា ថៅកែបានបង្ខំកម្មករឲ្យធ្វើការពី ១២ ទៅ ១៣ម៉ោងក្នុងមួយថ្ងៃ ហើយមួយខែសម្រាកបានមួយថ្ងៃដោយគ្មានប្រាក់ឈ្នួល។ ប៉ុន្តែកម្មករទាំងនេះមិនឲ្យចេញក្រៅបានទេ។ ការរំដោះកម្មករទាំងនេះធ្វើឡើងបន្ទាប់ពីមានកម្មករម្នាក់លួចចេញរួច ហើយទៅរាយការណ៍ដល់ប៉ូលិស។

កម្មករឲ្យដឹងថា ថៅកែរោងចក្រនេះ បានជ្រើសរើសកម្មករខ្មែរម្នាក់ឲ្យត្រួតត្រា និងប្រើដាវគំរាមកំហែងកម្មករដទៃទៀតឲ្យខំធ្វើការ។ កម្មករដែលជាអ្នកត្រួតត្រាកម្មករនោះសារភាពថា ខ្លួនពិតជាត្រួតត្រាលើកម្មករទាំងនោះមែន ប៉ុន្តែដាវនោះទុកការពារខ្លួន៖ «ខ្ញុំកាន់បែបនេះ ហើយអើតមើលតាមវន្ទទ្វារ ថាតើពួកគេដេកហើយឬនៅ? គេកំពុងធ្វើអី? គេលេងបៀឬធ្វើអី? ខ្ញុំដើរមើលពីរជុំអី?»។ ក្នុងពេលអាជ្ញាធរ និងអង្គការសង្គ្រោះចុះជួយរំដោះកម្មករទាំងនេះ អ្នកយកព័ត៌មានអាស៊ីសេរីផ្នែកភាសាឡាវ ដែលបានចុះយកព័ត៌មាន បានឃើញ កម្មករត្រូវគេដាក់ក្នុងអាគាររោងចក្រ

ដោយចាក់សោទ្វារដែករឹងមាំ និងមានកាមេរ៉ាសុវត្ថិភាពដាក់ត្រួតពិនិត្យនៅច្រកទ្វារចេញចូលផង។ មានឆ្កែវសមួយ ដើម ដែលកម្មករអះអាងថា គេប្រើទុកគំរាមពួកគាត់។

តាមការសម្ភាសនៅមជ្ឈមណ្ឌលប្រតិបត្តិការទប់ស្កាត់ការជួញដូរពលកម្មមនុស្ស នៃនាយកដ្ឋានការពារពលកម្ម និងសង្គមកិច្ច (Prevention of Human Trafficking on Labour Operation Center, Department of Labour Protection and Welfare) កម្មករទាំងនេះប្រាប់ថា ពួកគាត់ចូលទៅធ្វើការនៅប្រទេសថៃ តាមរយៈមេខ្យល់ ដោយមិនមានលិខិតស្នាមអ្វីទាំងអស់។ ពួកគេបានបង់ប្រាក់ម្នាក់ ២.៥០០បាត ទៅមេខ្យល់ដែលនាំទៅធ្វើការនៅទីនោះ។ ថៅកែផ្តល់ប្រាក់ឈ្នួលឲ្យកម្មករទាំងនេះពី ២០០ ទៅ ៣០០បាតក្នុងមួយថ្ងៃ។ ប៉ុន្តែថៅកែបានកាត់ប្រាក់ឈ្នួលរបស់ពួកគេ ដោយប្រាប់ថា យកទៅធ្វើលិខិតឆ្លងដែន និងប័ណ្ណធ្វើការងារ។ ទោះជាយ៉ាងនេះក្តី ពួកគាត់មិនដែលបានទទួលប័ណ្ណធ្វើការនេះទេ។

អាស៊ីសេរី មិនអាចទាក់ទងមន្ត្រីនាំពាក្យក្រសួងការបរទេសលោក ជុំ សន្ទរី ដើម្បីបញ្ជាក់ពីចំណាត់ការលើករណីនេះបានទេ នៅថ្ងៃទី២១ កុម្ភៈ ដោយសារលោកជាប់ប្រជុំ។

របាយការណ៍ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្ហាញថា មានកម្មករខ្មែរប្រមាណ ១លាន ២សែននាក់ ធ្វើការនៅប្រទេសថៃ។ កម្មករខ្លះកំពុងធ្វើការខុសច្បាប់ ក្នុងវិស័យផ្សេងៗ ដែលប្រឈមនឹងហានិភ័យដូចករណីកម្មកររោងចក្រទឹកកកនេះដែរ៕

## ហ្វីលីពីននិងកូវ៉ែតកំពុងស្វែងរកការស្រុះស្រួលគ្នាលើការធានាសុវត្ថិភាពពលករ

http://km.rfi.fr/asia/ ដោយ អៀង សុខមិញ 25/02/2018

ប្រតិភូជាអ្នកទទួលខុសត្រូវហ្វីលីពីនមួយក្រុមបានធ្វើដំណើរទៅកាន់ប្រទេសកូវ៉ែត ដើម្បីវាយតម្លៃអំពីផលប៉ះពាល់នៃបម្រាមថ្មីរបស់ប្រធានាធិបតី ទៅលើទីផ្សារពលករហ្វីលីពីន នៅកូវ៉ែត។ ប្រធានាធិបតីបានចេញក្រិត្យហាមមិនឱ្យពលរដ្ឋហ្វីលីពីនចេញទៅធ្វើការនៅកូវ៉ែតទេ ក្រោយការរកឃើញសាកសពពលករហ្វីលីពីនម្នាក់ក្នុងទូរកក កាលពីដើមខែ។

បម្រាមរបស់ប្រធានាធិបតី បានប៉ះពាល់យ៉ាងខ្លាំងដល់ពលរដ្ឋហ្វីលីពីននៅកូវ៉ែត។ នេះបើតាមការរៀបរាប់របស់ភ្នាក់ងារជ្រើសរើសពលករហ្វីលីពីន ទៅកាន់ប្រតិភូហ្វីលីពីន ដែលដឹកនាំដោយអនុរដ្ឋមន្ត្រីក្រសួងការងារ នៅក្នុងពេលជួបប្រជុំនៅស្ថានទូតហ្វីលីពីននៅកូវ៉ែត។ ជាឧទាហរណ៍ ភ្នាក់ងារមួយបានជ្រើសរើសគិលានុបដ្ឋាកហ្វីលីពីនជាង ១រយនាក់ មកធ្វើការមានតួនាទីច្បាស់លាស់នៅក្នុងមន្ទីរពេទ្យរបស់កូវ៉ែត តែឥលូវត្រូវខកខានអស់។ ភ្នាក់ងារខ្លះទៀតដែលធ្វើការក្នុងវិស័យជ្រើសរើសពលករដែរ ចង់ដាក់សម្ពាធលើរដ្ឋាភិបាលដើម្បីឱ្យប្រធានាធិបតីលើកបម្រាមនោះចេញវិញ ព្រោះយល់ថាកូវ៉ែតបានផ្តល់ឱកាសច្រើនដល់ពលករហ្វីលីពីន។ ប៉ុន្តែចម្លើយគឺទេ ! លោកអនុរដ្ឋមន្ត្រីបានប្រកាសថា បម្រាមមិនអាចលើកចេញបានឡើយ ដរាបណាក្រុងម៉ានីល មិនទាន់ទទួលបាននូវការធានាសន្តិសុខពីខាងរដ្ឋាភិបាលកូវ៉ែតចំពោះពលករហ្វីលីពីន។ រដ្ឋាភិបាលហ្វីលីពីនមិនអាចឈរស្ងៀមធ្វើមិនដឹងមិនឮបានឡើយ ! ពេលនេះអាជ្ញាធរហ្វីលីពីនកំពុងតែចរចាសមភាគីកូវ៉ែតហើយ ដូច្នេះបើលក្ខខណ្ឌសុវត្ថិភាពមិនប្តូរប្រែទេ បម្រាមនៅតែមានសុពលភាពដដែល។ នេះជាការបញ្ជាក់អះអាងរបស់លោករដ្ឋមន្ត្រី។

សូមបញ្ជាក់ថាទន្ទឹមនឹងប្រតិភូ ចុះទៅស្ទាបស្ទង់ស្ថានភាពការងារ លក្ខខណ្ឌសន្តិសុខ និងសុវត្ថិភាពរបស់ពលករហ្វីលីពីន ដែលកំពុងបន្តការងារនៅកូវ៉ែត តំណាងរដ្ឋាភិបាលមួយក្រុមទៀតនៃក្រសួងការងារ ក៏នឹងត្រូវមកដល់កូវ៉ែតដែរ ដើម្បីចរចាលើសន្ធិសញ្ញាទ្វេភាគីស្តីពីពលករតាមផ្ទះ។ កម្មវត្ថុចំបងនៃការចរចាគឺហ្វីលីពីនស្នើសុំជាសំខាន់ឱ្យពលករហ្វីលីពីនទាំងអស់អាចមានសិទ្ធិមានទូរស័ព្ទដៃ និងកាន់លិខិតឆ្លងដែនដោយខ្លួន មិនមែនឱ្យម្ចាស់ផ្ទះ(ថៅកែ)

របែអូសទុកដូចមុនទៀតទេ។ ជាសរុបមានពលរដ្ឋហ្វីលីពីនប្រមាណជាង២៥ម៉ឺននាក់រស់នៅកូវ៉ែត ភាគច្រើនជាអ្នកបម្រើការនៅតាមផ្ទះ។ ហេតុការណ៍មរណៈរបស់អ្នកបម្រើតាមផ្ទះម្នាក់ បានជំរុញឱ្យលោក ឌុយទែរតេ ចេញក្រិត្យហាមឃាត់មិនពលករហ្វីលីពីននៅធ្វើការកូវ៉ែតទៀតទេ។ ដោយឡែក ប្ដីប្រពន្ធជាតិកូវ៉ែតជាម្ចាស់ផ្ទះ ដែលជាប់សង្ស័យថាបានធ្វើទារុណកម្ម និងសម្លាប់ពលករអ្នកបម្រើហ្វីលីពីន ក្នុងទូទឹកកកនោះ ត្រូវប៉ូលិសចាប់ខ្លួនបានហើយ នៅក្រុងដាម៉ាសប្រទេសស៊ីរី ក្រោយពីមានដីកាតាមចាប់របស់ប៉ូលិសអាំងទែរប៉ូល៕

## ឥណ្ឌូនេស៊ី ខកខានមិនបាន ជួយការពារអ្នកបម្រើតាមផ្ទះ

http://www.prakpheaktra.com/ AFP | Publication date 26 February 2018 | 09:40 ICT

**ក្រុងគូឡាឡាំពួ:** ក្រុមអ្នករិះគន់ និយាយថា ដោយត្រូវបានគេជួញដូរទៅម៉ាឡេស៊ី ហើយត្រូវបានគេបង្ខំឲ្យដេកនៅខាងក្រៅជាមួយឆ្កែមួយក្បាល មុននឹងស្លាប់ ដោយសាររបួសធ្ងន់ធ្ងរ ជាករណីរំលោភបំពានថ្មីបំផុតទាក់ទិននឹងអ្នកបម្រើតាមផ្ទះឥណ្ឌូនេស៊ីម្នាក់ ដែលបង្ហាញពីការខកខាន មិនបានការពារក្រុមអ្នកជួយក្នុងស្រុក ថ្វីបើការសន្យារបស់រដ្ឋាភិបាលមានជាច្រើនលើកក្ដី។

អ្នកស្រី Adelina Sau បានស្លាប់កាលពីដើមខែនៅមន្ទីរពេទ្យ មួយថ្ងៃ ក្រោយពីត្រូវបានជួយសង្គ្រោះពីផ្ទះនិយោជករបស់គាត់នៅក្នុងរដ្ឋប៉េណាងនៃប្រទេសម៉ាឡេស៊ីដោយមានស្នាមរបួសនៅលើខ្លួនយ៉ាងធ្ងន់ធ្ងរនោះ។ និយោជកវ័យ ៦០ ឆ្នាំរបស់អ្នកស្រី ត្រូវបានចោទប្រកាន់ពីបទសម្លាប់អ្នកស្រីកាលពីសប្ដាហ៍មុន និងនៅឥណ្ឌូនេស៊ីមនុស្ស ២ នាក់ ត្រូវបានចាប់ខ្លួនដោយចោទពីបទការជួញដូរមនុស្ស។ ពលរដ្ឋឥណ្ឌូនេស៊ីប្រហែល ២,៥ លាននាក់ធ្វើការនៅម៉ាឡេស៊ីភាគច្រើនខុសច្បាប់នៅក្នុងវិស័យជាច្រើន មានចាប់ពីកសិកម្មដល់សំណង់ក្នុងនោះ មានស្ត្រីអ្នកបម្រើការតាមផ្ទះប្រហែល ៤០ ម៉ឺននាក់។

ការចោទប្រកាន់ជាច្រើនពាក់ព័ន្ធការរំលោភបំពានជារឿងសាមញ្ញទៅហើយ។ ការចោទប្រកាន់ទាំងនោះ មានចាប់ពីការធ្វើការងារលើសម៉ោង រហូតដល់ការវាយធ្វើបាប និងការរំលោភផ្លូវភេទ ដែលនាំឲ្យមានជម្លោះការទូតរវាងបណ្ដាប្រទេសជិតខាងនៅអាស៊ីអាគ្នេយ៍នេះ។ ការស្លាប់របស់អ្នកស្រី Sau បានបង្កឲ្យមានកំហឹងទូទាំងឥណ្ឌូនេស៊ី៕

## អារ៉ាប៊ីសាអូឌីត ចាប់ខ្លួនពលករខុសច្បាប់ បាន៦៧០០០០នាក់ ក្នុងរយៈពេល៤ខែចុងក្រោយ

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ២៦ កុម្ភៈ ២០១៨ 14:28 ប្រែសម្រួល: ស៊ុនលី ID:014

Riyadh:ទីភ្នាក់ងារចិនស៊ិនហួ ចេញផ្សាយនៅថ្ងៃចន្ទ ទី២៦ ខែកុម្ភៈនេះ បានឲ្យដឹងថា អារ៉ាប៊ីសាអ៊ូឌីត បានបើកប្រតិបត្តិការ ចាប់ខ្លួនពលករបរទេសចំនួន ៦៧១២៧២នាក់ ក្នុងរយៈពេលត្រឹមតែ៤ខែកន្លងមកនេះ គឺជាផ្នែកមួយ នៃបង្ក្រាបយ៉ាងធ្ងន់ធ្ងរ ទៅលើក្រុមពលករខុសច្បាប់។ ក្នុងចំណោមអ្នក ដែលត្រូវបានឃាត់ខ្លួន មានប្រមាណជា៤៦៩៨៣៦នាក់ ត្រូវបានចោទប្រកាន់ ពីបទរំលោភបំពាន ទៅលើច្បាប់លំនៅឋាន ចំនួនប្រមាណជា១៤២០១៦នាក់រំលោភទៅលើច្បាប់បញ្ហាការងារ និង៥៩៥២០នាក់ រំលោភទៅលើ ច្បាប់ប្រព័ន្ធសន្តិសុខតាមព្រំដែន។ អាជ្ញាធរអារ៉ាប៊ីសាអូឌីត បាននិយាយថា ក្នុងចំណោមអ្នកដែលរំលោភបំពាន ទៅលើច្បាប់របស់ប្រទេសខ្លួន មានប្រមាណជា៦៥ភាគរយ មកពីយេម៉ែន៣២ភាគរយ មកពីប្រទេសអេត្យូពី និង៣ភាគរយ មកពីប្រទេសដទៃ។ ប៉ូលីសក៏បានចាប់ខ្លួនបុគ្គល ចំនួន៥២៩នាក់ផងដែរ ពីបទប៉ុនប៉ងចាកចេញ ពីប្រទេសរបស់ខ្លួនដោយខុសច្បាប់ តាមរយៈការមិនបញ្ជាក់ ពីសញ្ជាតិរបស់ពួកគេ៕

# ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨

## សាកសពពលរដ្ឋខ្មែរ៣នាក់ បញ្ជូនពីថៃមកខ្មែរក្នុងថ្ងៃតែមួយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៨ម៉ោង ១៧:១៧មុ៉ត សារុន

ខេត្តបន្ទាយមានជ័យ ៖ សពពលរដ្ឋខ្មែរ៣នាក់ត្រូវបានភាគីថៃបញ្ជូនឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅរសៀលថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ បន្ទាប់ពីស្លាប់លើទឹកដីថៃដោយគ្រោះថ្នាក់ចរាចរ និងករណីដេកស្លាប់សង្ស័យខ្យល់គរ និងមហារីកគ្រាប់ឈាម ។ ករណីស្លាប់ដោយគ្រោះថ្នាក់ចរាចរបានកើតឡើងកាលពីយប់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ នៅស្រុកវ៉ាត់ថាណាណាក់ខន ខេត្តស្រះកែវ រថយន្តបុកបន្តកន្ទុយគ្នា៣គ្រឿង ។ ជនរងគ្រោះឈ្មោះ ម៉ុង សំណាង ភេទស្រី អាយុ៥៩ឆ្នាំ មានទីលំនៅភូមិតាសីឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង ។ តាមសាច់ញាតិសពនិយាយថា ជនរងគ្រោះមុនកើតហេតុ បានចូលទៅព្យាបាលជំងឺនៅខេត្តស្រះកែវ លុះជាសះស្បើយក៏នៅសម្រាកលេងជាមួយកូនដែលស្នាក់នៅលក់ដូរក្នុងខេត្តកើតហេតុ ។ សាច់ញាតិបន្តថា នៅថ្ងៃកើតហេតុ ដោយជនរងគ្រោះធ្វើដំណើររួមជាមួយកូនស្រី និងចៅព្រមទាំងស្ត្រីជាថៅកែថៃរបស់កូនគាត់បើករថយន្តដឹកទំនិញមកឲ្យគេនៅព្រំដែន (ផ្សាររុងក្លឿ) មិនទាន់ដល់គោលដៅផងក៏ជួបឧប្បត្តិហេតុខាងលើ ដោយរថយន្តគេបុករថយន្តជនរងគ្រោះជិះពីក្រោយបន្តកន្ទុយគ្នា៣គ្រឿង បណ្តាលឲ្យជនរងគ្រោះ និងស្ត្រីជាថៅកែថៃស្លាប់សរុប២នាក់ ខណៈកូនស្រី និងចៅស្រី របស់ជនរងគ្រោះ (ខ្មែរ) រងរបួសធ្ងន់កំពុងព្យាបាលក្នុងមន្ទីរពេទ្យ នៃខេត្តកើតហេតុនៅឡើយ ។

ដោយឡែកសព២ផ្សេងទៀត ម្នាក់ជាពលករធ្វើការសំណង់នៅខេត្តប្រាជីនបូរី ប្រទេសថៃ ដេកស្លាប់សង្ស័យខ្យល់គរកាលពីម៉ោង០៤ព្រឹក ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំនេះ ។ ជនរងគ្រោះឈ្មោះ មឿន នី ភេទប្រុស អាយុ៣៧ឆ្នាំ មានទីលំនៅភូមិខាន់ស ឃុំគោល ស្រុកអង្គរជុំ ខេត្តសៀមរាប និងម្នាក់ទៀតជាអ្នកក្រុងប៉ោយប៉ែតចូលទៅមើលជំងឺនៅមន្ទីរពេទ្យក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ បានស្លាប់ដោយជំងឺមហារីកគ្រាប់ឈាមកាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ។ ជនរងគ្រោះឈ្មោះ ម៉េង ចាន់នី ភេទប្រុស អាយុ៦០ឆ្នាំ ។ សពពលរដ្ឋខ្មែរទាំង៣ សព២នាក់ត្រូវសាច់ញាតិជួលរថយន្តដឹកបន្តទៅស្រុកកំណើត និងសពម្នាក់ទៀតជាអ្នកក្រុងប៉ោយប៉ែត ត្រូវបានភាគីថៃ ជួយបញ្ជូនដល់លំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី ៕

## នៅសល់២៥ថ្ងៃទៀតប៉ុណ្ណោះ ក្រុមការងារចម្រុះហត្ថពលកម្ម នឹងចុះត្រួតពិនិត្យតាមបណ្តាសហគ្រាស គ្រឹះស្ថាននានា ដែលកំពុងប្រើប្រាស់កម្លាំងពលករបរទេស

http://www.freshnewsasia.com/ 2018-02-26

**(ភ្នំពេញ)៖** នៅសល់២៥ថ្ងៃទៀតប៉ុណ្ណោះ ក្រុមការងារចម្រុះហត្ថពលកម្មរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងចុះត្រួតពិនិត្យតាមបណ្តាសហគ្រាស គ្រឹះស្ថាននានា ដែលកំពុងប្រើប្រាស់កម្លាំងពលករបរទេស។ នេះបើតាមសេចក្តីជូនដំណឹង ដែលអង្គភាពសារព័ត៌មាន Fresh News ទទួលបាននៅថ្ងៃទី២៦ ខែកុម្ភៈនេះ។

សេចក្តីជូនដំណឹងបានអំពាវនាវថា «**សូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ការដ្ឋានសំណង់ កាស៊ីណូ ក្លឹបកំសាន្តនានា អាជីវកម្មរណប អាជីវកម្មតាមប្រព័ន្ធ Online អាជីវកម្មពេលរាត្រី អាជីវកម្មលើផ្ទៃទឹក ឬអាជីវកម្ម ផ្សេងៗទៀត និងជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងប្រើប្រាស់ពលករបរទេស និងជនបរទេសដែលខកខាន មិនទាន់បានបំពេញកាតព្វកិច្ចធ្វើបណ្ណ-សៀវភៅការងារជនបរទេសឆ្នាំ២០១៧កន្លងមក ត្រូវប្រញាប់បំពេញបែបបទបង់អាករបណ្ណ-សៀវភៅការងារ ក្នុងរយៈពេល៣០ថ្ងៃ (ចាប់ពីថ្ងៃទី២២ ខែកុម្ភៈ)**»។

សូមរម្លឹកថា ក្រសួងមហាផ្ទៃ ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០១៨ បានចេញប្រកាសរួមគ្នាថានឹងដាក់ទោសម្ចាស់ ឬនាយកសហគ្រាសណា ដែលទទួលយកពលករបរទេស ឲ្យធ្វើការដោយគ្មានបណ្ណ និងសៀវភៅការងារ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអន្តោប្រវេសន៍

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
អគ្គនាយកដ្ឋានការងារ

លេខ: ១៥៥៥.[illegible]

ថ្ងៃ[illegible] ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០១៨

**សេចក្តីជូនដំណឹង**

**ស្តីពី**

**កាតព្វកិច្ចធ្វើប័ណ្ណ-សៀវភៅការងារជនបរទេស របស់ម្ចាស់សហគ្រាស គ្រឹះស្ថាន**
**កាស៊ីណូ និងជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយ**
**ក្នុងព្រះរាជាណាចក្រកម្ពុជា**

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងប្រើប្រាស់ពលករបរទេស និងជនបរទេសមានកាតព្វកិច្ចអនុវត្តច្បាប់ស្តីពីអន្តោប្រវេសន៍ ច្បាប់ស្តីពីការងារ លិខិតលេខ ១២៣ សជណ.អក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ និងប្រកាសអន្តរក្រសួងលេខ ៧១៩ ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា កន្លងមកម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាមួយចំនួននៅពុំទាន់អនុវត្តកាតព្វកិច្ច និងបន្តគេចវេះប្រើប្រាស់ពលករបរទេសដោយពុំបានបំពេញកាតព្វកិច្ចក្នុងការធ្វើប័ណ្ណ-សៀវភៅការងារជនបរទេសឱ្យបានគ្រប់ៗគ្នា គិតមកដល់ចុងឆ្នាំ២០១៧។

អាស្រ័យហេតុនេះសូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ការដ្ឋានសំណង់ កាស៊ីណូ ក្លឹបកំសាន្តនានា អាជីវកម្មរណប អាជីវកម្មតាមប្រព័ន្ធOnline អាជីវកម្មពេលរាត្រី អាជីវកម្មលើផ្ទៃទឹក ឬអាជីវកម្មផ្សេងៗទៀត និងជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងប្រើប្រាស់ពលករបរទេស និងជនបរទេសដែលខកខានមិនទាន់បានបំពេញកាតព្វកិច្ចធ្វើប័ណ្ណ-សៀវភៅការងារជនបរទេសឆ្នាំ២០១៧កន្លងមក ត្រូវប្រញាប់បំពេញបែបបទបង់អាករប័ណ្ណ-សៀវភៅការងារ ក្នុងរយៈពេល៣០ថ្ងៃចាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងនេះតទៅ។


ក្រុមការងារចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសនឹងចុះត្រួតពិនិត្យតាមបណ្ដាសហគ្រាស គ្រឹះស្ថាន ការដ្ឋាន សំណង់ កាស៊ីណូ ក្លឹបកំសាន្តនានា អាជីវកម្មរណប អាជីវកម្មតាមប្រព័ន្ធ Online អាជីវកម្មពេលរាត្រី អាជីវកម្មលើផ្ទៃទឹក ឬអាជីវកម្មផ្សេងៗទៀត និងជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅតែបន្តគេចវេះលួចលាក់ប្រើប្រាស់ពលករបរទេសខុសច្បាប់ និងជនបរទេសដែលខកខានមិនបានអនុវត្តតាមខ្លឹមសារខាងលើនេះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានការងារ នឹងធ្វើការដាក់ពិន័យ និងផ្ដន្ទាទោសតាមទោសប្បញ្ញត្តិជំពូកទី១៦នៃច្បាប់ស្ដីពីការងារ និងផ្ដន្ទាទោសតាមទោសប្បញ្ញត្តិនៃច្បាប់ស្ដីពីអន្តោប្រវេសន៍។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានការងារ សង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី ជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានប្រើប្រាស់ពលករបរទេស និងជនបរទេសដែលប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងនេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

អគ្គនាយក

សេង_សក្ដា

## ក្រសួងការងារថៃ បន្ថែមសូន្យធ្វើប័ត្រស៊ីជម្ពូ ចំនួនពីរកន្លែងទៀតនៅក្នុងទីក្រុងបាងកក

http://www.prakpheaktra.com/ February 27, 2018

កាលពីថ្ងៃច័ន្ទទី26 ខែកុម្ភៈ ឆ្នាំ2018 ម្សិលមិញនេះក្រសួងការងារថៃចេញលិខិតប្រកាសបន្ថែមទីតាំងសូន្យ OneStopService ចំនួនពីរកន្លែងបន្ថែមទៀតដើម្បីជួយសម្រួលដល់បងប្អូនពលករខ្មែរ,ឡាវ,ភូមា ដែលត្រូវទៅ(ត) ប័ត្រស៊ីជម្ពូ និងវីសារពីរឆ្នាំ និងក្នុងសូន្យនីមួយៗ នៅក្នុងទីក្រុងបាងកក។ ចំពោះទីតាំងសូន្យ OneStopService ទាំងបួនកន្លែងនៅក្នុងទីក្រុងបាងកកប្រទេសថៃនោះរួមមាន៖

1.ស្ថិតក្នុងហាងទំនើបតាំងហួរសេង(តំបន់ធន់បុរី)

2.ស្ថិតនៅក្នុងហាងទំនើបបីកស៊ីផេតការសេម(តំបន់បាងខែរ)

3.ស្ថិតនៅក្នុងក្រសួងការងារថៃ (តំបន់ឌិនដែង)

4.ស្ថិតនៅក្នុងហាងទំនើបអាយជីខ្វែរ(តំបន់ឡាក់ស៊ី )

ដូច្នេះសូមបងប្អូនពលករខ្មែរទាំងអស់ប្រញាប់រួសរាន់ទៅធ្វើ(ត)ប័ត្រស៊ីជម្ពូ, ប្ដូរថៅកែ, ធ្វើវីសារនៅតាមសូន្យនីមួយៗអោយបានមុនពេលកំណត់។

## សេចក្ដីជូនដំណឹងស្ដីពីការផ្អាកដំណើរការការិយាល័យបញ្ជាក់អត្តសញ្ញាណ នៅខេត្តសុងក្លា

https://www.facebook.com/ Royal Embassy of Cambodia in Bangkok ថ្ងៃទី ២៧ កុម្ភៈ ឆ្នាំ២០១៨

សេចក្ដីជូនដំណឹងស្ដីពីការផ្អាកដំណើរការការិយាល័យបញ្ជាក់អត្តសញ្ញាណ នៅខេត្តសុងក្លា នឹងផ្អាកដំណើរការ ចាប់ពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ នេះតទៅ ហើយក្រុមការងារចល័តអន្តរក្រសួងនឹងប្ដូរទីតាំងសម្រាប់ការ

បញ្ជាក់អត្តសញ្ញាណ និងប្រមូលទិន្នន័យ មកខេត្តប៉ាធុមថានី ដែលមានអាស័យដ្ឋាន នៅផ្សារ ZeerRangsit ជាន់ទី៤, លេខ៩៩ ភូមិ៨ ផ្លូវផាហ៊ុនយ៉ូធិន ឃុំគូគត ស្រុកឡាំលូកកា ខេត្តប៉ាធុមថានី ។

សម្រាប់ការិយាល័យ បញ្ជាក់អត្តសញ្ញាណ និងប្រមូលទិន្នន័យ នៅខេត្តប៉ាធុមថានី នឹងចាប់ ផ្តើមដំណើរការ ចាប់ពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ នេះតទៅ។ ករណីបងប្អូនពលករមានចង្ងល់ពាក់ពន្ធ័ នឹងបញ្ហានេះ សូមបងប្អូនពលករទាក់ទងមកលេខទូរសព្ទ័ ០៨២ ៤២ ២០ ០១១, ០៨២ ៤២ ២០ ០៧៧ និង ០៨២ ៤២ ២០ ០៤៤ ។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**
លេខ:......០៥០............គ.ផ.ថ

## សេចក្តីជូនដំណឹង

យោងតាមលទ្ធផលនៃកិច្ចប្រជុំទ្វេភាគីរវាងក្រសួងការងារថៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ថ្ងៃទី ១៣ និង១៤ ខែ កុម្ភៈ ឆ្នាំ២០១៨ នៅភ្នំពេញឡើងមក គណៈកម្មការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឱ្យបានជ្រាបថា **ការិយាល័យបញ្ជាក់អត្តសញ្ញាណ និងប្រមូលទិន្នន័យ នៅខេត្តសុងក្លា នឹងផ្អាកដំណើរការ ចាប់ពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ នេះតទៅ ហើយក្រុមការងារចល័តអន្តរក្រសួងនឹងប្តូរទីតាំងសម្រាប់ការបញ្ជាក់អត្តសញ្ញាណ និងប្រមូលទិន្នន័យ មកខេត្តប៉ាធុមថានី ដែលមានអាស័យដ្ឋាន នៅផ្សារ ZeerRangsit ជាន់ទី៤, លេខ៩៩ ភូមិ៨ ផ្លូវផាហ៊ុនយ៉ូធិន ឃុំគូគត ស្រុកឡាំលូកកា ខេត្តប៉ាធុមថានី ។**

សម្រាប់ការិយាល័យ បញ្ជាក់អត្តសញ្ញាណ និងប្រមូលទិន្នន័យ **នៅខេត្តប៉ាធុមថានី នឹងចាប់ផ្តើមដំណើរការចាប់ពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ នេះតទៅ។**

ករណីបងប្អូនពលករមានចង្ងល់ពាក់ពន្ធ័ នឹងបញ្ហានេះ សូមបងប្អូនពលករទាក់ទងមកលេខទូរសព្ទ័ ០៨២ ៤២ ២០ ០១១, ០៨២ ៤២ ២០ ០៧៧ និង ០៨២ ៤២ ២០ ០៤៤ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

បាងកក ថ្ងៃសុក្រ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨
**ជ.ប្រធានគណៈកម្មការ**
**អនុប្រធាន**

**ឈុំ ទិសារ៉ាណា**

# សេចក្ដីជូនដំណឹងឈប់សម្រាកក្នុងពិធីបុណ្យមាឃបូជា ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨

https://www.facebook.com/ Royal Embassy of Cambodia in Bangkok ថ្ងៃទី ២៧ កុម្ភៈ ឆ្នាំ២០១៨

គណៈកម្មការផ្ដល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឱ្យបានជ្រាបថា ក្រុមការងារបើកផ្ដល់លិខិតឆ្លងដែន(PP)/លិខិតធ្វើដំណើរ(TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំស្ថានទូតកម្ពុជានៅទីក្រុងបាងកក និងក្រុមការងារអន្តរក្រសួងចល័តនៅទីក្រុងបាងកក និងខេត្តរ៉ាក់យ៉ង នឹងឈប់សម្រាកចំនួន ០១ថ្ងៃ នៅក្នុងពិធីបុណ្យមាឃបូជា គឺនៅថ្ងៃទី១៥ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ។ ករណីបងប្អូនពលករមានចង្ងល់ពាក់ពន្ធ័ នឹងបញ្ហានេះ សូមបងប្អូនពលករទាក់ទងមកលេខទូរសព្ទ័ ០៨២ ៤២ ២០ ០១១, ០៨២ ៤២ ២០ ០៧៧ និង ០៨២ ៤២ ២០ ០៤៤ ។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**
លេខៈ ០៥៧ គ.ផ.ថ

**សេចក្ដីជូនដំណឹង**

គណៈកម្មការផ្ដល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឱ្យបានជ្រាបថា ក្រុមការងារបើកផ្ដល់លិខិតឆ្លងដែន(PP)/លិខិតធ្វើដំណើរ(TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំស្ថានទូតកម្ពុជានៅទីក្រុងបាងកក និងក្រុមការងារអន្តរក្រសួងចល័តនៅទីក្រុងបាងកក និងខេត្តរ៉ាក់យ៉ង នឹងឈប់សម្រាកចំនួន ០១ថ្ងៃ **នៅក្នុងពិធីបុណ្យមាឃបូជា គឺនៅថ្ងៃទី១៥ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ។**

ករណីបងប្អូនពលករមានចង្ងល់ពាក់ពន្ធ័ នឹងបញ្ហានេះ សូមបងប្អូនពលករទាក់ទងមកលេខទូរសព្ទ័ ០៨២ ៤២ ២០ ០១១, ០៨២ ៤២ ២០ ០៧៧ និង ០៨២ ៤២ ២០ ០៤៤ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

បាងកក ថ្ងៃ[illegible] ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ត្រូវនឹងថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០១៨
ជ.ប្រធានគណៈកម្មការ
**អនុប្រធាន**

**ឈុំ ទិសារ៉ាណា**

## ជនជាតិរុស្ស៊ី មួយក្រុម មកធ្វើជាគ្រូបង្រៀន រួមភេទនៅថៃ ត្រូវសមត្ថកិច្ចបង្ក្រាប

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ២៦ កុម្ភៈ ២០១៨ 22:10 ដោយ: ណៃ តុលា ID:030

បរទេស៖ ក្រុមជនជាតិរុស្ស៊ី ដែលចូលរួមនៅក្នុងការ ហ្វឹកហ្វឺន ដែលគេហៅថាវគ្គហ្វឹកហ្វឺន របៀបរួមភេទនោះ ត្រូវបានចាប់ខ្លួនដោយ អាជ្ញាធរនៅក្នុងទីក្រុង រមណីយដ្ឋានដ៏ល្បីល្បាញមួយរបស់ថៃ។ យោងតាមសារព័ត៌មាន Sputnik ចេញនៅយប់ថ្ងៃទី២៦ ខែកុម្ភៈ បានឲ្យដឹងថា បណ្តាញទូរទស្សន៍ជាតិថៃបានផ្សាយវីដេអូ មួយដែលបង្ហាញពីមន្ត្រីប៉ូលីសបាន ធ្វើបង្ក្រាបនៅក្នុងការជួបជុំគ្នា មួយដែលរៀបចំដោយ អ្នកគ្រូបង្រៀនផ្លូវភេទ តាមជំនាញខ្លួនឯង ចំនួន ១០នាក់ ក្នុងសណ្ឋាគារ Ibis នៅផាតាយ៉ា។ ជនជាតិរុស្ស៊ីទាំងនោះ ត្រូវបានគេចោទប្រកាន់ពីបទចូលប្រទេស និងស្នាក់នៅទីនោះដោយខុសច្បាប់ បន្ទាប់ពីការផុតកំណត់ទិដ្ឋាការ ក៏ដូចជាធ្វើការនៅក្នុងប្រទេសថៃដោយគ្មានការអនុញ្ញាតត្រឹមត្រូវ។ បន្ទាប់ពីបានសម្ភាសអ្នកចូលរួមក្នុងព្រឹត្តិការណ៍នោះ ប៉ូលិសបានដឹងថា អ្នកហ្វឹកហាត់ ឬសិស្សរុស្ស៊ីចំនួន ៤៣នាក់បានបង់ប្រាក់ ២០.០០០បាត (ប្រហែល ៦៣៨ដុល្លារ) សម្រាប់វគ្គបណ្តុះបណ្តាលរយៈពេលប្រាំថ្ងៃ។ អ្នកដែលត្រូវបានឃាត់ខ្លួន "គ្រូបង្ហាត់ផ្លូវភេទទាំងនោះ" ពេលនេះកំពុងប្រឈមនឹងការកាត់ក្តី និងការនិរទេសចេញវិញពីប្រទេសថៃ។ នេះបើតាមអ្នកការទូតរុស្ស៊ី បានប្រាប់សារព័ត៌មាន Sputnik ៕

# ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨

## រាជរដ្ឋាភិបាលកម្ពុជា បានអំពាវនាវដល់ម្ចាស់រោងចក្រសហគ្រាសផ្តល់ព័ត៌មានពីពលករបរទេស

http://cambodiapolice.com/ ម៉ោង 6:53 pm 27 កុម្ភះ 2018 37

**ភ្នំពេញ ៖** រាជរដ្ឋាភិបាល បានអំពាវនាវដល់ម្ចាស់រោងចក្រ សហគ្រាស សហការជាមួយអាជ្ញាធរផ្តល់ព័ត៌មានពីពលករបរទេស ដែលបម្រើការងារនៅក្នុងប្រទេសកម្ពុជា ដើម្បីជាប្រយោជន៍គ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចំណូលថវិកាជាតិ។

ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅបន្តរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៅរសៀលថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨នេះ នាទីស្តីការក្រសួង សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានប្រសាសន៍ថា រាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យមានជនបរទេសធ្វើការនៅកម្ពុជា ដោយមិនស្របច្បាប់ទៀតនោះឡើយ ហើយបើនៅតែបន្តទៀត នឹងនាំឱ្យបាត់បង់ដល់ចំណូលថវិកាជាតិ និងបាត់បង់ឱកាសការងាររបស់ប្រជាពលរដ្ឋកម្ពុជា ។ សម្តេចក្រឡាហោម បានបញ្ជាក់ថា ក្នុងចំណោមជនបរទេសអន្តោប្រវេសន៍ ដែលមកស្នាក់នៅ និងធ្វើការនៅកម្ពុជាជាង១៦មុឺននាក់ គឺមានតែប្រមាណ៥មុឺន៧ពាន់នាក់ប៉ុណ្ណោះ ដែលមានប័ណ្ណការងារស្របច្បាប់ពីរាជរដ្ឋាភិបាលកម្ពុជា ។ សម្តេចក្រឡាហោម បានបន្តថា ក្នុង១ឆ្នាំៗ កម្ពុជាបាត់ចំណូលជាង២០លានដុល្លារ ពីការគេចវេសបង់ពន្ធរបស់ពលករបរទេស ដែលមកធ្វើការងារនៅក្នុងប្រទេសកម្ពុជា ។ សម្តេចបន្តទៀតថា ជនបរទេសអន្តោប្រវេសន៍ និងពលករបរទេស ដែលមកស្នាក់នៅ និងបម្រើការនៅក្នុងប្រទេសកម្ពុជា ត្រូវតែអនុវត្តទៅតាមគោលការណ៍ច្បាប់ដែលបានកំណត់ បើពុំដូច្នោះទេ នឹងត្រូវពិន័យជាប្រាក់ទ្វេគុណ ឬបណ្តេញចេញពីប្រទេសកម្ពុជាតែម្តង ។

ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឱ្យដឹងថា អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបង្កើនសមត្ថភាពគ្រប់គ្រង និងដោះស្រាយបញ្ហាប្រឈមនានា ដែលជាបញ្ហាគន្លឹះសំខាន់ៗមួយចំនួន ដើម្បីឈានទៅគ្រប់គ្រងជនបរទេសខុសច្បាប់ក្នុងប្រទេសកម្ពុជា ក្នុងនោះបន្តត្រួតពិនិត្យ និងស្វែងរកអ្នកកាន់ឯកសាររដ្ឋបាលមិនប្រក្រតី ព្រមទាំងត្រួតពិនិត្យហត្ថពលករបរទេស ដើម្បីឱ្យអនុវត្តច្បាប់របស់កម្ពុជា ដោយបានទៅធ្វើប័ណ្ណការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ចំពោះការងារគ្រប់គ្រងច្រកទ្វារបច្ចុប្បន្នអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានសហការជាមួយក្រុមហ៊ុនឯកជន ដើម្បីបង្កើន និងតម្លើងប្រព័ន្ធគ្រប់គ្រង

ព្រំដែន ដែលហៅថា Cambodia Border Management System និងបំពាក់នៅគ្រប់ច្រកទ្វារអន្តរជាតិទាំង ២៤ប៉ុស្តិ៍ ដែលប្រព័ន្ធនេះមានមុខងារដូចនឹងប្រព័ន្ធ PISCES ហើយប្រព័ន្ធនេះជាប្រព័ន្ធទិន្នន័យថ្នាក់ជាតិ ដែលអាចរក្សាបាន ព័ត៌មានសម្ងាត់ រក្សាបាននូវសន្តិសុខ និងផលប្រយោជន៍ជាតិ ។

យោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា ជនបរទេសអន្តោប្រវេសន៍សរុប ចំនួន៤៦.៧៧៦គ្រួសារ ស្មើនឹងមនុស្សចំនួន១៧៦.៨១២នាក់ ក្នុងនោះស្រីមានចំនួន ៧៩.៧២៨នាក់ ក្នុងនោះជនបរទេសបែបអន្តោប្រវេសន៍កាន់កាប់ប្រើប្រាស់ឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ចំនួន២០.២១៨គ្រួសារ ស្មើនឹង មនុស្ស៧៣.៣៩៧នាក់ ស្រី៣៥.៨៨៨នាក់ មាន០៥សញ្ជាតិ លើ៧ប្រភេទឯកសាររួមមាន ៖ សៀវភៅស្នាក់នៅចំនួន ១៨.៥៨០ក្បាល សៀវភៅគ្រួសារ ចំនួន២.១៧៧ក្បាល សំបុត្រកំណើត ចំនួន១១.៣៣៦ច្បាប់ សំបុត្រ អាពាហ៍ពិពាហ៍ ចំនួន២៤១ច្បាប់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួន៦.៧២២ប័ណ្ណ លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ចំនួន៦៣២ក្បាល និងប័ណ្ណសម្គាល់កម្មសិទ្ធិអចលនវត្ថុចំនួន៤១ប័ណ្ណ ។

របាយការណ៍ដដែលបានបង្ហាញថា នៅឆ្នាំ២០១៧ ជនបរទេសប្រព្រឹត្តបទល្មើសក្នុងប្រទេសកម្ពុជា ចំនួន ៣៧៦លើក មានមនុស្ស ១៧៧១នាក់ មាន៣៧ សញ្ជាតិ ។ ក្នុងនោះ ក៏មានជនបរទេសរងគ្រោះ ចំនួន ២០៥នាក់ ដោយស្លាប់ ១១៩នាក់ និងរបួស ៨៦នាក់ មាន៣០សញ្ជាតិ ។ របាយការណ៍ ដែលបានផ្សព្វផ្សាយក្នុងកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០១៧ ក៏បានបង្ហាញថា ជនបរទេស ដែលបានប្រព្រឹត្តបទល្មើស កំពុងជាប់ឃុំក្នុងពន្ធនាគារ នៅទូទាំងប្រទេសកម្ពុជា គិតត្រឹមខែធ្នូ ឆ្នាំ២០១៧ មានចំនួនសរុប ១១៣០នាក់ ( ស្ត្រី ២៦៥ នាក់ ) មានចំនួន៤៦ សញ្ជាតិ ក្នុងនោះជាប្រភេទជនដែលត្រូវចោទ ចំនួន២០៤នាក់ (ស្រី ៤៣នាក់) ជនជាប់ចោទ មានចំនួន ១០៨នាក់ (ស្រី ៣០នាក់) ពិរុទ្ធជនមានចំនួន៣៩១នាក់(ស្រី១៣៤នាក់) និងទណ្ឌិតមានចំនួន ១៦២នាក់ (ស្រី ៥៨នាក់) ៕

## សម្តេចក្រឡាហោម ស ខេង អំពាវនាវឲ្យនិយោជកទាំងអស់ កុំទទួលយកបុគ្គលិកជាជនជាតិបរទេស ដែលគ្មានប័ណ្ណការងារចូលធ្វើការ

http://www.freshnewsasia.com/ 2018-02-27

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨នេះ បានអំពាវនាវនិយោជក (ថៅកែរោងចក្រ) ទាំងអស់ កុំទទួលយកបុគ្គលិកជាជនជាតិបរទេស ដែលគ្មានប័ណ្ណការងារឲ្យចូលបម្រើការ ហើយប្រសិនក្រសួងរកឃើញថា មានបុគ្គលជាជនជាតិបរទេសនោះ និយោជកនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

ក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងទិសដៅបន្ត របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា ការទទួលបុគ្គលិកជនបរទេស ដែលគ្មានប័ណ្ណការងារឲ្យចូលធ្វើការនេះ នឹងធ្វើឲ្យរដ្ឋបាត់បង់ប្រាក់ចំណូល ប្រមាណ២០លានដុល្លារក្នុងមួយឆ្នាំ, លំបាកក្នុងការគ្រប់គ្រងសន្តិសុខ និងប៉ះពាល់ដល់ការងាររបស់ជនជាតិខ្មែរ។ សម្តេច ស ខេង បានថ្លែងយ៉ាងដូច្នេះថា «**តាមច្បាប់អ្នកដែលយកជនបរទេសឲ្យចូលធ្វើការ ត្រូវតែស្របតាមច្បាប់ បានន័យថា ត្រូវតែមានប័ណ្ណការងារ អត់ប័ណ្ណការងារធ្វើមិចកើត ហើយប្រសិនបើថ្ងៃក្រោយយើងរកឃើញថា កន្លែងណាបញ្ហានិយោជកទទួលខុសត្រូវតែម្តង ផាកពិន័យតាមណុងតែម្តង [...] យើងអំពាវនាវទៅនិយោជកឲ្យគាត់សហការ ពេលទទួលបុគ្គលិក កម្មករបរទេស គឺត្រូវតែមានការជាប់ជាមួយ ហើយជាពិសេសប័ណ្ណការងារ**»។

ដើម្បីអនុវត្តការងារនេះ ឲ្យកាន់តែមានប្រសិទ្ធភាព សម្តេចក្រឡាហោម ស ខេង បានជំរុញឲ្យអង្គភាពពាក់ព័ន្ធរបស់ក្រសួងមហាផ្ទៃ សហការជាមួយក្រសួងការងារ ចុះផ្សព្វផ្សាយ អប់រំណែនាំ ដល់និយោជកទាំងអស់អំពីបញ្ហានេះ

ប៉ុន្តែការចុះអប់រំណែនាំនេះ ត្រូវតែធ្វើឡើងស្របតាមលក្ខខណ្ឌច្បាប់ និងក្រមសីលធម៌។ សម្តេចក្រឡាហោម បានគូស បញ្ជាក់ថា ក្នុងករណីចាំបាច់ដែលនិយោជកមិនព្រមអនុវត្ត និងសង្ស័យថាកន្លែងណាមានកម្មករធ្វើការអត់ច្បាប់ ឬ បង្កើនល្បែងស៊ីសង ត្រូវតែបញ្ជូនក្រុមប្រតិបត្តិការទៅតែម្តងដើម្បីបង្ក្រាបបទល្មើសនេះ។

របាយការណ៍របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបង្ហាញថា ក្រុមការងារចម្រុះអធិការកិច្ចហត្ថពលកម្ម បរទេស ដែលមានក្រសួងការងារ និងក្រសួងមហាផ្ទៃ បានចុះត្រួតពិនិត្យសហគ្រាស គ្រឹះស្ថាននានាចំនួន ៣,៩៦៩ គោលដៅ មានពលករបរទេស សរុបចំនួន៣២,៥១២នាក់ មាន៩៣សញ្ជាតិ ក្នុងនោះបានផាកពិន័យជនបរទេស ប្រកបមុខរបរ និងបម្រើការងារគ្មានប័ណ្ណការងារ ចំនួន១,៣៨៩នាក់៕

## អាជ្ញាធរថៃបញ្ជូនសពពលករខ្មែរពីរនាក់មកស្រុកកំណើតវិញតាមច្រកដូង

http://www.rasmeinews.com/ February 27, 2018, 8:23 PM

(បាត់ដំបង)៖សមត្ថកិច្ចច្រកទ្វារអន្តរជាតិដូងស្ថិតក្នុងស្រុកកំរៀងខេត្តបាត់ដំបងកាលពីរសៀលថ្ងៃទី២៧ខែ កុម្ភៈឆ្នាំ២០១៨បានទទួលសពពលករខ្មែរពីរនាក់ដែលចូលទៅធ្វើការដោយខុសច្បាប់ពីអាជ្ញាធរថៃដឹកយកមកប្រគល់ ជូនអាជ្ញាធរខ្មែរវិញសម្រាប់ប្រគល់សាច់ញាតិយកទៅធ្វើបុណ្យនៅឯស្រុកកំណើត។

លោកមុយ សាលិតមេប៉េអឹមមូលដ្ឋានស្រុកកំរៀងបានឱ្យដឹងថាសពពលករខ្មែរទាំងពីរនាក់មានឈ្មោះប្រាក់ ប៊ុនធឿនភេទប្រុសអាយុ៣១ឆ្នាំស្លាប់នៅថ្ងៃទី២៥ខែកុម្ភៈឆ្នាំ២០១៨នៅមន្ទីរពេទ្យបាងណា ខេត្តឈុនបូរីប្រទេសថៃ។ មូលហេតុស្លាប់ជំងឺខ្លាញ់រុំបេះដូងនៅភូមិស្វាយជ្រុំឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបងនិងឈ្មោះសាត កែលឿង ភេទប្រុសអាយុ៣២ឆ្នាំ។ មូលហេតុស្លាប់ដោយចង ក សម្លាប់ខ្លួនឯងនៅខេត្ត រ:យ៉ងប្រទេសថៃ នៅភូមិស្វាយឃុំ ព្រាល ស្រុកកញ្ជាច ខេត្តព្រៃវែង។ សពទាំងពីរនាក់នេះអាជ្ញាធរខ្មែរបានប្រគល់ជូនក្រុមគ្រួសារដឹកយកធ្វើបុណ្យតាម ប្រពៃណីខ្មែរនៅឯស្រុកកំណើត៕ទS/ដោយៈគ្រញូង

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរ៦នាក់មកកម្ពុជាវិញតាមច្រកអន្តរជាតិជាំ

http://www.rasmeinews.com/ February 27, 2018, 8:49 PM

(ឧត្តរមានជ័យ)៖អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន៦នាក់មកកម្ពុជាវិញតាមច្រកអន្តរជាតិជាំ កាលពី វេលាម៉ោង១១ព្រឹកថ្ងៃទី២៧ខែកុម្ភៈឆ្នាំ២០១៨ ដែលថៃចាប់ខ្លួនពីបទកាប់ឈើក្រញូងក្នុងដីថៃ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦កន្លងទៅ។ការដែល ចូលកាប់ឈើឆ្លងព្រំដែនតាមចំណុចភូមិអូរស្វាយ ស្រុកត្រពាំងប្រាសាទ ហើយបាន ជាប់គុកនៅខេត្តស៊ីសៈកេតប្រទេសថៃ អស់ជាច្រើនខែ។

សមត្ថកិច្ចបានឱ្យដឹងថាពលរដ្ឋខ្មែរនោះរួមមាន១-ឈ្មោះ ភន ភារុន ភេទប្រុស អាយុ១៧ ឆ្នាំ រស់នៅភូមិព្រៃ ទទឹង ឃុំជ្រៃរៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។២-ឈ្មោះ វន រិន ភេទប្រុស អាយុ ១៤ ឆ្នាំ រស់នៅ ភូមិអូរស្វាយ ឃុំអូរ ស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។៣-ឈ្មោះ ហៅ សល់ ភេទប្រុស អាយុ១៤ ឆ្នាំ រស់នៅភូមិថ្នល់ ឃុំ ទទួលភ្លើស ស្រុក- ខេត្តកំពង់ធំ ។ ៤-ឈ្មោះ សៀង ទី ភេទប្រុស អាយុ៣៣ ឆ្នាំ រស់នៅភូមិស្រះរំដេង ឃុំផ្ទះរុង ស្រុក ភ្នំក្រវាញ់ ខេត្តពោធិសាត់។៥-ឈ្មោះ ហ៊ាង ភាព ភេទប្រុស អាយុ៣៣ ឆ្នាំ ភូមិព្រៃក្រទួត ឃុំតាលក ស្រុកបាកាន ខេត្ត ពោធិសាត់ ។៦-ឈ្មោះ សេង គិន ប្រុស៣០ ឆ្នាំ រស់នៅភូមិស្ទឹង ឃុំលលៃ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ៕ទS/ ដោយ៖សហការី

## ស្ត្រីខ្មែរនឹងទៅបម្រើតាមផ្ទះម៉ាឡេស៊ីខែមិថុនា ប៉ុន្តែអ្នកជំនាញនៅបារម្ភ

https://thmeythmey.com/ 27, Feb 2018 , 7:59 pm

វ៉ាស៊ីនតោន ៖ នៅខែមិថុនាខាងមុខនេះ ប្រទេសកម្ពុជានឹងបញ្ជូនពលការិនីទៅធ្វើការជាស្ត្រីបម្រើតាមផ្ទះនៅ ប្រទេសម៉ាឡេស៊ីឡើងវិញ បន្ទាប់ពីបានបិទអស់រយៈពេល៦ឆ្នាំ ប៉ុន្តែអ្នកជំនាញខាងសិទ្ធិពលករសម្តែងការព្រួយបារម្ភ ដោយសារតែរដ្ឋាភិបាលកម្ពុជានៅមិនទាន់ដាក់យន្តការត្រឹមត្រូវដើម្បីការពារពលការិនីទាំងនោះនៅឡើយទេ។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីនៃអង្គការការពារសិទ្ធិពលករសង់ត្រាល់បានបញ្ជាក់បន្ថែមថា លោកនៅតែមិនទាន់ឃើញថា រដ្ឋាភិបាលខ្មែរបានចាត់វិធានការអ្វីជាធំកំភួនដើម្បីធានាសុវត្ថិភាពស្ត្រីដែលត្រូវទៅបម្រើនៅតាមគេហដ្ឋាននៅឡើយ។ លោក ហូយ៉ា បានបន្ថែមក្នុងកម្មវិធីពិភាក្សានោះថា៖ «យើងក្រឡេកមើលពីយន្តការនៃការការពារវិញយើងនៅឃើញថា មានការខ្វះចន្លោះខ្សោយមែនទែន ហើយនេះគឺជាអ្វីដែលកើតឡើងហើយជាការព្រួយបារម្ភដែលហើយក៏មិនមានប្រព័ន្ធណាមួយដែលអាចធានាបាននូវសុវត្ថិភាពពួកគាត់បានដែរ»។ វិធានការបង្ការដែលលោក ហូយ៉ា ស្នើឡើង គឺត្រូវមានគណៈកម្មការដែលចុះតាមដានការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងប្រទេសទាំងពីរ រក្សាទិន្នន័យជាក់លាក់ពីចំនួនស្ត្រីបម្រើតាមផ្ទះនិងកន្លែងដែលពួកគេធ្វើការ និងបង្កើតប្រព័ន្ធផ្តល់សញ្ញាណាមួយដែលពលការិនីអាចផ្តល់មកសមត្ថកិច្ចនៅពេលមានការរំលោភបំពាន។ លោកបានបន្ថែមថា៖ «ស្ត្រីដែលធ្វើការតាមផ្ទះគឺគាត់នៅពេលដែលមានបញ្ហាគាត់អត់ដឹងថាទៅរកអ្នកណាទេ»។ អង្គការសង់ត្រាល់ធ្លាប់ជួបករណីកន្លងមកដែលមានការលក់ស្ត្រីបម្រើតាមផ្ទះបន្តពីទីភ្នាក់ងារពលករមួយទៅមួយទៀត ដោយពលការិនីមិនដឹងខ្លួន ហើយធ្វើការសងប្រាក់ជំពាក់មិនរួច។

សារព័ត៌មាននៅក្នុងប្រទេសម៉ាឡេស៊ីបានរាយការណ៍ថា ផ្អែកតាមអនុស្សរណៈរវាងកម្ពុជានិងម៉ាឡេស៊ីដែលបានចុះហត្ថលេខាកាលពីឆ្នាំ២០១៥ គឺស្ត្រីដែលមកធ្វើការបម្រើតាមផ្ទះនឹងទទួលបានការធានារ៉ាប់រង ត្រូវមានទូរស័ព្ទដៃដើម្បីប្រើប្រាស់ និងត្រូវមានគណនីធនាគារផ្ទាល់ខ្លួន។ ម៉ាឡេស៊ីរំពឹងថានឹងទទួលយកស្ត្រីបម្រើតាមផ្ទះពីកម្ពុជាចំនួន៥០.០០០នាក់ក្នុងមួយឆ្នាំៗ។ នេះបើតាមសេចក្តីរាយការណ៍របស់ Malaysia Mail Online។ បច្ចុប្បន្ននេះមានស្ត្រីកម្ពុជាចំនួន៨.០០០នាក់កំពុងធ្វើការនៅប្រទេសម៉ាឡេស៊ី។ ការងារដែលពលករខ្មែរទៅធ្វើគឺជាប្រភេទការងារដែលគ្មានជំនាញ ដូច្នេះពួកគេទទួលបានប្រាក់ខែតិចតួចបើប្រៀបធៀបនឹងពលករដែលមកពីប្រទេសដទៃ។

លោកស្រី មូរ សុខហួរ បានលើកឧទាហរណ៍ថា ពលករមកពីប្រទេសហ្វីលីពីនមួយចំនួនគឺទៅធ្វើការងារដែលមានជំនាញខាងសុខាភិបាលដូចជាទៅមើលថែមនុស្សចាស់ជរាជាដើម។ លោកស្រីបន្ថែមទៀតថា នៅបណ្តាប្រទេសអារ៉ាប់ស្ត្រីខ្មែរប្រឈមមុខនឹងការរើសអើងដោយសារតែសាសនាខុសគ្នានិងគ្មានជំនាញដែលត្រូវចាត់ក្នុងប្រភេទទទួលបានប្រាក់ខែទាបជាងគេបំផុត។ លោកស្រីបន្ថែមថា៖ «យើងចាប់ផ្តើមពីការអប់រំរបស់យើង។ យើងយកមនុស្សចេញទៅស្ទើរតែគ្មានការអប់រំផងដូច្នេះយើងយកពលករដែលអត់មានការអប់រំខ្វះបច្ចេកទេសយកទៅលក់ក្នុងតម្លៃដ៏ថោកបំផុត»។ ប្រទេសកម្ពុជាបានដាក់បម្រាមមិនឱ្យនាំស្ត្រីបម្រើតាមផ្ទះទៅម៉ាឡេស៊ីកាលពីខែតុលាឆ្នាំ២០១១បន្ទាប់ពីមានរបាយការណ៍ពីការវាយធ្វើបាបរាងកាយនិងរំលោភច្បាប់ដោយថៅកែម៉ាឡេស៊ី៕

## តុលាការខេត្តសៀមរាបចោទប្រកាន់បុរសជនជាតិអង់គ្លេសពីររូបពីបទប្រព្រឹត្តអំពើអាសអាភាស

https://www.rfa.org/khmer/ ដោយ ហេង សកល 2018-02-27

តុលាការខេត្តសៀមរាបបានសម្រេចចោទប្រកាន់បុរសជនជាតិអង់គ្លេសពីររូប ម្នាក់អាយុ៦៣ និងម្នាក់ទៀតអាយុ៦៩ឆ្នាំ ពីបទប្រព្រឹត្តអំពើអាសលើកុមារាអាយុចន្លោះពី១៣ ទៅ១៥ឆ្នាំ។ សេចក្តីថ្លែងការណ៍របស់អង្គការអេបផល (APLE) បានឱ្យដឹងកាលពីថ្ងៃទី២៧ ខែកុម្ភៈ នេះថា សមត្ថកិច្ចបានចាប់ខ្លួនបុរសទាំងពីររូបនេះ ក្រោយពីសហគមន៍បានរាយការណ៍ថា មានករណីប្រព្រឹត្តអំពើអនាចារ ទៅកុមារាមួយចំនួននៅក្នុងភូមិមួយ ឋិតក្នុងខេត្តសៀមរាប។

ជនសង្ស័យម្នាក់បានសារភាពថា លោកពិតជាបានប្រព្រឹត្តអំពើអាស ព្រមទាំងបានឱ្យប្រាក់មួយចំនួនដល់កុមាររងគ្រោះទាំងនោះផងដែរ។ ជនសង្ស័យម្នាក់ទៀតធ្លាប់ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនកាលពី២០ឆ្នាំមុនពីបទប្រព្រឹត្តអំពើពេស្យាចារទៅលើកុមារាអាយុក្រោម១៥ឆ្នាំ។ លោកបានផ្តល់ប្រាក់ឱ្យកុមារចន្លោះពី២០០បាត ទៅ៣០០បាត ស្មើនឹងប្រមាណ ៦ដុល្លារ ទៅ១០ដុល្លារអាមេរិកសម្រាប់ការរួមភេទម្តងៗ។

អង្គការអែបផល (APLE) និងអង្គការសង្គមស៊ីវិលផ្សេងទៀត កំពុងយកចិត្តទុកដាក់ថែរក្សាកុមាររងគ្រោះទាំងនោះ ដើម្បីស្តារនីតិសម្បទាឡើងវិញ។ បច្ចុប្បន្នជនសង្ស័យទាំងពីររូបកំពុងឃុំខ្លួនក្នុងពន្ធនាគារខេត្តសៀមរាប និងរង់ចាំការកាត់ទោសនៅពេលខាងមុខនេះ ក្រោយតុលាការបានចោទប្រកាន់កាលពីថ្ងៃទី២៧ ខែកុម្ភៈ៕

## អាជ្ញាធរថៃចុះត្រួត(សយ)សុខុមវីត23 ឃាត់ខ្លួនបានពលករខុសច្បាប់និងជនជាតិបរទេស ចំនួន 75នាក់

http://www.prakpheaktra.com/ February 28, 2018

អាជ្ញាធរថៃបើកយុទ្ធនាការចុះត្រួតតំបន់ទេសចរណ៍កណ្តាលក្រុងបាងកក ឃាត់ខ្លួនបានជនបរទេសនិងពលករខុសច្បាប់ចំនួន 75នាក់ កាលពីវេលាម៉ោង01:28នាទីយប់ រំលងអាធ្រាត្រឈានចូលថ្ងៃពុធទី28 ខែកុម្ភៈ ឆ្នាំ2018 កម្លាំងអាជ្ញាធរនិងសមត្ថកិច្ចពិសេសថៃ បានបើកយុទ្ធនាការចុះត្រួតពិនិត្យតំបន់ទេសចរណ៍នៅចំណុច(Soi)សុខុមវីត23 អាសូកមុនទ្រី ចំកណ្តាលក្រុងបាងកកចំនួន110 កន្លែង ក្នុងព្រឹត្តិបត្រការណ៍នេះកម្លាំងអាជ្ញាធរថៃធ្វើការឃាត់ខ្លួន បានជនជាតិបរទេសស្នាក់នៅខុសច្បាប់មាន,អូកានដា,ឥណ្ឌា,ស៊ូដង,និងខ្មែរ សរុបចំនួន 75នាក់ ។

## ព័ត៌មានរសើប ! ក្រុមស្ត្រីនៅក្នុង ប្រទេសស៊ីរី ត្រូវបានក្រុមអ្នកនាំជំនួយ ធ្វើការជួញដូរផ្លូវភេទ

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៨ កុម្ភៈ ២០១៨ 08:34 ប្រែសម្រួល: ម៉ៅ បុប្ផាមករា ID:012

BBC៖ ទូរទស្សន៍ BBC បានផ្សព្វផ្សាយនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ថា តាមការសិក្សារបស់ BBC បានរកឃើញថា ក្រុមស្ត្រីនៅក្នុងប្រទេសស៊ីរី ត្រូវបានគេលក់ ឲ្យបម្រើផ្លូវភេទ ដោយក្រុម បុរសៗដែលជាអ្នក នាំជំនួយ ជួសមុខឲ្យ UN និងក្រុមមនុស្សធម៌អន្តរជាតិទាំងឡាយ ។ ក្រុមបុគ្គលិកនាំជំនួយបាននិយាយថា ក្រុមបុរសៗ នឹងធ្វើពាណិជ្ជកម្មលើស្បៀងអាហារ និង ជំនួសមកវិញជាការ បម្រើផ្លូវភេទ ។ ទោះបីជាមានការព្រមានអំពីរឿង អាស្រូវផ្លូវភេទ៣ឆ្នាំកន្លងមកនេះ របាយការណ៍ថ្មីមួយ បានបង្ហាញថានៅតែមាន សកម្មភាពនេះកើតឡើងដដែល នៅក្នុងប្រទេសស្ថិតនៅ ភាគខាងត្បូងមួយនេះ ។ ក្រុមទីភ្នាក់ងារអង្គការសហប្រជាជាតិ និងបណ្តាអ្នកមនុស្សធម៌បាននិយាយថា ពួកគេ បានទទួលលទ្ធផលសូន្យ នៃការជួញដូរ ហើយមិនទទួលស្គាល់រាល់ករណី នៃការកើតឡើងរឿងអាស្រូវ ដោយក្រុមអង្គការ ដៃគូនៅក្នុង តំបន់ឡើយ ៕

---